D24969
(DC-Cam)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ រៀល សន អាយុ៦៩ឆ្នាំ

## នៅ ភូមិព្រៃតាឡី ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ

## នៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០០១

ឃីមៈ ចុះមិនមែននៅសាលារៀនហ៎ នៅមន្ទីរពេទ្យ ។

សនៈ តាព្រហ្មហ្នឹងបើនិយាយពីលើកសម្បត្តិ គណបក្សប្រជាជនគឺតាព្រហ្មហ្នឹងខ្លាំងជាងអាណា អាណាអាណីទាំងអស់ ទៅយកខៀវ សំផន ទៅយកអីម៉ោហ្នឹងតាព្រហ្មហ្នឹងអ្នកយកម៉ោ ហ្នឹងតាព្រហ្មអ្នកយម៉ោហា៎ ។

ឃីមៈ ចា៎!

ជិតខាងៈ តាព្រហ្មដែលយើងចង់ជួបហ្នឹងហ៎ ។

សនៈ ហ្នឹងហើយចាស់ហើយ ។

ឃីមៈ ចាស់ហើយ ។

សនៈ ខ្ញុំបានជួបជាមួយគាត់៣ ៤, ៥ឆ្នាំហើយ ។

ឃីមៈ តាព្រហ្មហ្នឹង ហើយហ្នឹងអ៊ុម ណា? អ៊ុំមើលទៅ ស្គាល់ទេ? យ៉ា យ៉ាហ្នឹង?

សនៈ មិត្តយ៉ានៅហ្នឹងដែរ ។

ឃីមៈ នៅតាកែវដែរ ។

សនៈ អាហ្នឹងអនុខ្ញុំ ហើយហ្នឹង ។

ឃីមៈ អញ្ចឹងហ៎?

សនៈ ហ្នឹងហើយ ។

ឃីមៈ ចុះគាត់ធ្វើអីគេបងយ៉ាហ្នឹង?

សនៈ នារីពេទ្យ ។

ឃីមៈ ប្រធានអីគេ?

សនៈ ប្រធានពេទ្យ ពេទ្យស្រីៗ ខ្ញុំប្រុស ប៉ុន្តែខ្ញុំក្តាប់រួម ។

ឃីមៈ ចាស! ហើយគាត់ខាងស្រីៗ?

សនៈ បាទ!

ឃីមៈ អញ្ចឹងចុះគាត់បេះអីបងយ៉ា បេះអីខ្លះ?

សនៈ ចេះពេទ្យដែរ ។

ឃីមៈ គាត់រៀននៅឯណាទៅ?

សនៈ អន្កាល់ហ្នឹង ពីមុនខ្ញុំដូចអត់បានក្តាប់បានទេប៉ុន្តែដល់ក្រោយទៅគេយកមកឲ្យនៅជាមួយខ្ញុំ ។

ឃីមៈ អ៎!

សនៈ គាមខ្មែរហ៎ា ។

ឃីមៈ ចាស!

សនៈ ខ្ទួយគាព្រហ្មហ្នឹង ។

ឃីមៈ អ៎! បងយ៉ាខ្ទួយគាព្រហ្មហ៎?

សនៈ បាទ!

ឃីមៈ អញ្ចឹងសុទ្ធតែខ្មែរគាត់អញ្ចឹង ។

សនៈ ហី! ជឿនហ្នឹងប្រពន្ធគាសោមហ្នឹង ។

ឃីមៈ ហ្នឹងហើយឥលូវនៅរស់ហ៎ ប្រពន្ធគាសោម?

សនៈ ណាដាក់ប្រពន្ធជឿនម៉េច?

ឃីមៈ ខ្ញុំច្រលំ ។

សនៈ ប្រពន្ធគាសោម ។

ឃីមៈ អញ្ចឹងទេហ៎! ប្រពន្ធគាសោម ។

សនៈ ដាក់ជឿនផង សោមផង ។

ឃីមៈ អ៎! ជាតិ?

ជិតខាងៈ អត់មានដូរអីទេ ។

ឃីមៈ ចុះថានៅរស់អីហ៎?

សនៈ ពួថានៅប៉ៃលិន អីនៅណាទេ ។

ឃីមៈ អ៎! អញ្ចឹងទេហ៎ អត់អីទេ អត់ជួបអត់អីទេ?

សនៈ ជាតិហ្នឹងក៏ជាគណស្រុកដែរ ។

ឃីមៈ ចា៎!

សនៈ គណស្រុក១០៥ ។

ឃីមៈ ចាស! ចុះយាយបឿនហ៎ាអុំ យាយបឿន?

សនៈ យាយបឿននៅអន្លង់វែង អន្កាល់ក្រោយពីខ្លួយឯងម៉ោ ។

ឃីមៈ អញ្ចឹង?

សនៈ ម៉ោផ្ទះ ម៉ោហើយឲ្យអាណាហៅខ្ញុំឲ្យទៅជួប ខ្ញុំអត់ទៅ ។

ឃីមៈ ចុះម៉េចក៏មិនទៅលេងគាត់ផង?

សនៈ ខ្ញុំចង់ជួបដែរហ្នឹង ចង់ដឹងថាក្រែងលោគាត់មាននៅធ្វើសកម្មភាពអីហ៎ ។

ឃីមៈ ចា៎!

សនៈ ដល់ម៉ោប្រញាប់ឲ្យគេមកហៅ ហើយខ្ញុំដូចអត់សូវចង់តូវផងអាអ្នកមកហៅហ្នឹងបបួល ទៅជួបជាមួយតាម៉ុក ។

ឃីមៈ អ៎!

សនៈ នៅភ្នំពេញដែរ ។

ឃីមៈ គេមិនឲ្យទេអុំហ្អើយ!

សនៈ ឲ្យតើខ្លួយ ។

ឃីមៈ ចឹងឲ្យជួបដែរតើហ្អី?

សនៈ ឲ្យតើ ។

ឃីមៈ ចុះអ៊ំមិនព្រមទៅសាកមើលអ៊ំ?

សនៈ ខ្ញុំវាដូចជា ។

ជិតខាងៈ ស្ទាក់ស្ទើរ ។

សនៈ មិនហ៎! មិនស្ទាក់ស្ទើរទេ បើជួបដូចជាមិនសូវល្អ តាម៉ុកហ្នឹង ។

ឃីមៈ ខ្លាចគេថាអីៗហ៎?

សនៈ មិនអីទេ ។

ឃីមៈ ខ្ញុំថាអត់អីទេអុំ ជិនាន់ឥលូវ?

សនៈ អត់អីទេ! អស់ហ្នឹងទៅសុំតែលុយតាម៉ុកតើ

ឃីមៈ ចា៎!

សនៈ អាខ្លះគាត់ឲ្យ ១០០ ១៥០ អីអញ្ចឹងទៅ ។

ឃីមៈ អ៎!

សនៈ ខ្លះឲ្យ ២០រអីអញ្ចឹងម៉ោ ។

ឃីមៈ ឥលូវហ្នឹង?

សនៈ បាទ!

ឃីមៈ ក្រែងគាត់ជាប់គុក? ម៉េចក៏សុំបាន?

សនៈ ដឹងអីរឿងជាប់គុក មិនជាប់គុកខ្ញុំមិនដឹងទេ ប៉ុន្តែអញ្ចឹង ។

ឃីមៈ ចាំ! អ៊ំ!

សនៈ ដល់ហើយដល់ពេលហៅទៅជួបយាយបឿន យាយបឿនថាចង់ជួបម៉ាក្រែត ខ្ញុំថាហ៎ អត់ទេ ។

ឃីមៈ អ៊ំ! អញ្ចឹងយាយបឿនហ្នឹងគណស្រុកដែរ?

សនៈ គណស្រុក ។

ឃីមៈ គាត់ឡើងឆ្នាំណា?

សនៈ ឆ្នាំចុងក្រោយផុតពេល តាសានមិនទាន់ម៉ោ ។

ឃីមៈ ចាំ!

សនៈ ឡើងមួយរយៈរហូតដល់តាសានម៉ោ ។

ឃីមៈ ៧៧ ៧៨ហ្នឹងហេ៎?

សនៈ ហើយទៅតែម្តង ។

ឃីមៈ តាសានគាត់ទៅណាវិញ ក្រែងគាត់នៅគណស្រុករហូតដល់៧៩ហេ៎ តាសាន?

សនៈ ពេល ពេលយាយបឿនឡើងតាសានអត់ទាន់មកទេ នៅស្រុកកោះអណ្តែត ។

ឃីមៈ អ៊ំ! យាយបឿនកាលមុនជាគណឃុំជាងទង?

សនៈ គណឃុំជាងទង ។

ឃីមៈ អញ្ចឹងមិនមែនយាយបឿននៅខាងសមាគមនារីហេ៎?

សនៈ អត់ទេសមាគមនារី ដូចជា កូនគាត់ ហ្អី ប្អូនគាត់ ។

ឃីមៈ អ៊ំ! អ៊ុំខ្ញុំចង់សួរអ៊ុំថាអញ្ចេះ ខ្ញុំកាលមុនប្រវត្តិគណតំបន់មានអ្នកណាខ្លះអ៊ុំ នៅយើង គណតំបន់១៣ ណាគេខ្លះ?

សនៈ គណតំបន់១៣ហ្នឹង ។

ឃីមៈ កាលឆ្នាំ៧០ ដល់៧៥ អ្នកណាគេអ៊ុំ?

សនៈ មានតែប៉ុណ្ណឹងអ្នកនឹង តាសោម ។

ឃីមៈ តាសោមមុនគេហេ៎?

សនៈ តាមុត ។

ឃីមៈ តាមុតក្រែងគាត់នៅកងពលកំពង់សោមឯណោះហ្អី?

សនៈ អត់ចុងក្រោយទេហ្នឹង!

ឃីមៈ អញ្ចឹងហេ៎?

សនៈ បាទ! ដល់ដកពីគណៈតំបន់ទៅហា៎ ។

ឃីមៈ ចាស! អ៎ ហើយតាសោមគេឲ្យធ្វើអីខ្លះទៅ?

សនៈ អនុតាមុតហ្នឹង ។

ឃីមៈ អញ្ចឹងអនុតាមុត?

សនៈ ហ្នឹងហើយ ហើយនារីនៅកន្លែងតំបន់ហ្នឹងអក្តាល់នុង មាននារីម្នាក់ហា៎ ។

ឃីមៈ ចា៎!

សនៈ ហើយប្រុសដែលប្រធានហ្នឹង តាមុត ហើយអនុប្រធានហ្នឹងតាសោម ហើយនារីម្នាក់ ហ្នឹងមេឃុំប្រពន្ធតាមុតហ្នឹង កាលហ្នឹងនៅក្រមុំហា៎ ។

ឃីមៈ ចា៎!

សនៈ ដល់ក្រោយមកទៀតខ្ញុំអត់ដឹងទេ ។

ជិតខាងៈ ក្រោយមកអត់ទំនាក់ទំនងជាមួយគេផង ។

សនៈ ក្រោយមកខ្ញុំអត់ដឹងមាននារីៗច្រើន ។

ឃីមៈ អុំស្គាល់ប្រវត្តិតាសោមហ្នឹងម៉េចទេ គាត់នៅភូមិណាខ្ញុំគ្រាន់តែសរសេរតិចៗដាក់ក្នុងថា គណស្រុក?

សនៈ ខ្ញុំអត់ដឹង ខ្ញុំកំពុងតែនិយាយពីម្សិលមិញរឿងតាសោមហ្នឹង ។

ឃីមៈ អញ្ចឹងហេ៎?

សនៈ ខ្ញុំដឹងថាស្រុកគាត់នៅណា ។

ឃីមៈ ចា៎!

សនៈ និយាយពីរឿងគាត់ថា បើគេ..........នៅពេទ្យពីដើមហៅពេទ្យដើមអំពិលហ្នឹង ខ្ញុំខស្បា យកអីវ៉ាន់ទៅលេងគាត់ គាត់ដើរបានតែ៩ ជំហានទេ ។

ឃីមៈ អ៎!

សនៈ អាហ្នឹងចុងក្រោយហា៎ ។

ឃីមៈ ចាស! ចុះថាគេចាប់គាត់នោះ?

សនៈ	អត់ណាចាប់ហ៎ ដល់..មិនបាច់ចាប់ទេ តាសោម ចុះខ្ញុំដឹងអត់ចាប់ទេ ដល់ពេលចេញពីភ្នំពេញចេញអាខ្មែរមុនគេផុតរថភ្លើងហ៎ មិនដឹងយកដាក់ណា ។

ឃីមៈ	ចា៎!

សនៈ	ដាក់សាប់ តែដាក់សាប់ហើយ ដើរហួសតែ៩ ដប៉ាានសាប់ហើយ ។

ឃីមៈ	អ៎!

សនៈ	អាខ្មែរមុនដំបូងយើងមិនដឹងទេ ខ្មែរមុនដំបូងដិះសុទ្ធតែរដ្ឋមន្ត្រីហើយពីដំបូងហ្នឹង ។

ឃីមៈ	ត្រូវហើយគេជិះមកពី៧៩ ហ៎អ៊ឺ?

សនៈ	បាទ! បើត្រូវហួសដល់ប្រទេសថៃក៏សាប់ ។

ឃីមៈ	ចា៎!

សនៈ	ត្រូវតែសាប់ ។

ឃីមៈ	ចាស! ចុះគាត់តាំងពីឆ្នាំ៧០ ម៉ោហ្នឹតាសោមហ្នឹង?

សនៈ	ឆ្នាំ៧០ សម័យនួវ... ។

ឃីមៈ	កាចហ៎?

សនៈ	កាចណាស់ ។

ឃីមៈ	អ៎! ស្មានតែគាត់ស្លូត បាបហ៎អុំ ឃើញហ៎អុំជឿដែរហ្នឹង បើមានជំនឹក្នុងខ្លួនហ្នឹងអុំឯងហ្នឹង! ចុះតាជឿនចុះបន្ទាប់ពីតាសោម?

សនៈ	តាជឿន ឆ្នុកហ្នឹង?

ឃីមៈ	ដឹងជឿនមួយណា ថា?

សនៈ	អ៎! ជឿនហ៎ ។

ឃីមៈ	ថានៅតំបន់ដែរ ពូសួរគេនិយាយហ៎?

សនៈ	បាទ! យុវជន ។

ឃីមៈ	អញ្ចឹងហ៎?

សនៈ	ឥឡូវនៅក៏ស្លាប់ទេ បងអាជន មិនដឹងថាស្លាប់អីនៅទេទៀត បើអាជនដឹងតែនៅ?

ឃីមៈ	អញ្ចឹងគាត់ប្រធានតំបន់ហ្នឹងដែរអ៊ឺ?

សនៈ	ហ្នឹងហើយយុវជន ។

ឃីមៈ	អញ្ចឹង! ខាងយុវជន ប្រធានខាងយុវជន?

សនៈ	យុវជន ដល់ក្រោយមកខ្ញុំអត់ដឹងហ៎ ។

ឃីមៈ ចាស! ហើយចុះតាមុតហ្នឹង? តាមុត?

សនៈ តាមុតនៅគណតំបន់ហ្នឹងរហូត ដកយកទៅកាន់កងពលហ្នឹងហ្នងទៅ ។

ឃីមៈ អញ្ចឹងគាត់នៅគណតំបន់តាកែវមុន បានទៅកងពលក្រោយ ហ្អីក៏?

សនៈ ទៅកងពលក្រោយ ។

ឃីមៈ អ៊ំ! ហើយទៅជំនួសណាគេ ពេលដកតាមុតចេញ?

សនៈ ដកតាមុតចេញហ្នឹងមានណាគេខ្លះទេច្រើនណាស់ ខ្ញុំស្គាល់ នូវស្គាល់តែតាគិតមួយ ។

ឃីមៈ ចាំ!

សនៈ គណតំបន់១៣ ហ្នឹងហាំ?

ឃីមៈ ចាំ!

សនៈ ព្រាប គិត ។

ឃីមៈ ចាស! ហើយចុះតាជឿនអ៊ុំអត់ស្គាល់ហេំ? ប្រវត្តិគាត់ម៉េចទៅ?

សនៈ ផ្ទះនៅត្រពាំងធំហាំ ។

ឃីមៈ អញ្ចឹង! ចុះរាល់ថ្ងៃគាត់រស់ឬក៏ស្លាប់?

សនៈ តាជឿនហ្នឹងក្មេងទេណាស់ ។

ឃីមៈ ចាំ!

សនៈ អត់ចាស់ទេ!

ឃីមៈ ចាំ!

សនៈ គាត់ហ្នឹងមានឪប្អូម រៀនបានខ្លះសឹកុង១ឆ្នាំបានផ្ទុះអាវុធ ។

ឃីមៈ អ៊ំ!

សនៈ ប្អូនគាត់ទើបតែជាប់ឪប្អូមក្រោយហ្នឹង អាហ្នឹងនៅទេ អាជន ។

ឃីមៈ ចាំស! ធ្វើអីគេជនហ្នឹង ប្អូនតាជឿន?

សនៈ ឥឡូវនៅ.......ធ្វើអីទេ នៅតែភ្នំពេញហ្នឹង ធ្វើអីៗនៅតែម្តុំហ៊ុនសែនគេហ្នឹង ។

ឃីមៈ ចុះកាចហ្អីស្លូតាជឿនហ្នឹង?

សនៈ ស្លូត ។

ឃីមៈ អត់អីទេហេំ?

សនៈ បាទ!

ឃីមៈ គ្រប់គ្រងប្រជាជនអី?

សនៈ	ជឿនហ្នឹងគាត់មានសីលធម៌ល្អណាស់មនុស្ស ត្រពាំងធំហ្នឹង ។

ឃីមៈ	ចា៎!

សនៈ	ខ្ទួយតាម៉ុក តាអីហ្នឹង ។

ឃីមៈ	អញ្ចឹងបងប្អូនតាម៉ុកដែរ?

សនៈ	បងប្អូន ។

ឃីមៈ	ចុះខ្ញុំសួរយាយវុធ ថាធ្វើពេទ្យហ៎ា ។

សនៈ	បាទ!

ឃីមៈ	គាត់ថាតាសោមហ្នឹង ក៏គេចាប់ហើយតាជឿនហ្នឹងក៏គេចាប់យកទៅសំលាប់ដែរ ។

សនៈ	ខ្ញុំមិនដឹងទេរឿង រឿងតាសោមមីអូនឯងជឿអុំទៅ ។

ឃីមៈ	ចាស!

សនៈ	អុំហ្នឹងហើយដែលយកអីវ៉ាន់ទៅជូនគាត់ ពីរនាក់អាជនហ្នឹង អាជនហ្នឹងវាប្រធានមន្ទីរស្រុក ។

ឃីមៈ	ចាស!

សនៈ	ដល់អញ្ចឹងជូនកាលថ្ងៃណា ខែក្រោយៗណឹង ត្រូវដុតក្រឡាន ដុតកន្ទាំអីយកទៅលេងគាត់ ។ អត់មាអាណាចាប់យកធ្វើស្អីទេ មិនបាច់ចាប់ទេ ។

ឃីមៈ	ចុះ ជន ណឹងប្រធានអី?

សនៈ	ប្រធានមន្ទីរស្រុក ។

ឃីមៈ	មិនមែនគណៈស្រុកទេ?

សនៈ	មិនមែនទេ ប្រធានមន្ទីរស្រុក ។

ខីមៈ	ដល់ពេលវត់គ្មានអ្នកណាដឹងថាម៉េៗចទេ ឮថាដឹកយកទៅដាក់ចោលអីណឹង ខ្ញុំឮពីគណៈស្រុក ។

សនៈ	ស្តាយណាស់ ស្តាយយកមនុស្សដាក់ចោល ធាត់ជាងនេះទៀត ហី គាត់កាលអត់ទាន់ឈឺស្គមជាងមីប្អូន ។

ឃីមៈ	ហី ជន ណឹងគាត់កាចឬស្លូត?

សនៈ	អូ ! ស្លូតណាស់ នៅរហូតដល់ឥឡូវ ប៉ុនគេអ្នកមានខ្ញុំអត់បានទៅជួប សុទ្ធតែអ្នកមានហើយឥឡូវនៅភ្នំពេញ ។ គេមកយូរហើយ ទំនាក់ទំនងតាំងពីខ្មែរក្រហម ។

ឃីមៈ	ចុះឥឡូវគាត់ធ្វើអីគេជនណឹង?

សនៈ អត់ដឹងធ្វើអី ប៉ុនមកជាមួយ ប្អូនថ្លៃតម៉ាកដែរណឹង ជន្ទងគេណឹង ។

ឃីមៈ គេឥឡូវធំជាងយើងទៀត គេធំៗដដែលអ៊ី ។

សនៈ ធំណាស់ ។

ឃីមៈ ហ៊ី ចុះតាម៉ុត កូនប្រុសតាម៉ុកណឹង កាច ឬស្លូត?

សនៈ តាម៉ុត មិនជាកាច មិនជាស្លូតទេល្មម គាត់ដូចបេះគិត ។ មនុស្សអ្នកបួស នេះផ្ទះគាត់នៅស្រែក្នុងនេះ នៅឃុំស្រែចែង ។

ឃីមៈ ហ៊ី ប្រពន្ធគាត់ខុំណឹង?

សនៈ មនុស្សឆ្កួតណឹង ឆ្កួតតើ ឆ្កួតមែនទែន ឡប់ហ្នឹងធ្វើគណៈស្រុកឡប់ដែរ ។ ធ្វើគណៈស្រុកឆ្កួតមែនទែនហ្នឹង ។ នេះចិះឡានមកពីនេះ ហួសអន្លង់សោមប្រហែលម៉ាគីឡូមកមានផ្ទះមួយ ផ្ទះថ្មមួយបញ្ចោតថ្មពីមុខតិចពីត្បូងផ្លូវណឹង ទៅវិញមើល មើល នៅដេកណឹងដេក ឆ្កួតណឹង ហ៊ី អាដើមស្វាយទាំងអស់ណឹងធ្វើកំពែងឲ្យខ្ញុំទៅស្រោចទឹក ឲ្យតែខ្ញុំម្នាក់ទេ ។

ឃីមៈ ហេតុអីគេដទៃ?

សនៈ មិនដឹង ។

ឃីមៈ ហ៊ី ដឹកនាំគេម៉េចទៅអ៊ីឆ្កួតចឹង?

សនៈ ដល់ហើយទៅគេឲ្យនៅតែម៉ាកន្លែងទេ ។

ឃីមៈ គាត់ឡើងគណៈស្រុកឆ្នាំណាខុំណឹង?

សនៈ ឡើង យាយខុំណឹងគណៈស្រុកយូរណាស់តាំងពីឆ្នាំចិតប៉ុន្មានយាយ ។ យាយខុំដូចតាំងពីយូរហើយ ក្រោយតាញ៉ៅ មុនតាញ៉ៅ ។ អូ កាលជាមួយតាញ៉ៅណឹង យាយខុំប្រធាន តាញ៉ៅអនុ ។

ឃីមៈ ហ៊ី យាយបឿនទើបឡើងក្រោយទេ?

សនៈ យាយបឿនក្រោយទេ ។

ឃីមៈ យាយបឿនជាបងប្អូនតាព្រំដែរ?

សនៈ ក្មួយ ។

ឃីមៈ គាត់កាចស្លូតយាយបឿនណឹង?

សនៈ យាយបឿន គាត់មិនសូវកាចប៉ុន្មានទេ ប៉ុនគាត់ដាច់ខាតបដិវត្តន៍ គេហៅថាពួកណឹងសុទ្ធតែពួកវណ្ណៈគេ ដាក់ខ្លួនគេជាវណ្ណៈកម្មករផ្តាច់ការលើវណ្ណៈខ្ពស់ជាងគេហើយ ។

ឃីមៈ អ៊ីកាលណឹងវណ្ណៈណាធំជាងគេ កាលសម័យខ្មែរក្រហម?

សនៈ វណ្ណៈកសិករ ។

ឃីមៈ វណ្ណៈកសិករធំជាងគេ?

សនៈ អាស វណ្ណៈកម្មករធំជាងគេកាលណឹង ។

ឃីមៈ អូ កម្មករ កសិករណឹង?

សនៈ កសិករក៏ដោយប៉ុន្មែកកសិករណឹងចេះអប់ខ្លួនចេះកសាងខ្លួនឲ្យទៅជាកម្មករនោះ គឺអត់មានអីទេ មានតែស្បែងមួយទៅទេ អាណឹងហើយហៅកម្មករ ។ អាណឹងហៅ កម្មករហើយដាច់ខាតបក្សជនសុទ្ធតែអាណឹងហើយ កាលជំនាន់នោះ ។ ប៉ុនដល់ក្រោយៗមកឲ្យតែអ្នកធ្វើបានល្អគេឲ្យឡើងទៅជាបក្សសីលធម៌ល្អ ។

ឃីមៈ ចុះយាយបឿនណឹងតាមងមុនរំដោះ ៧៥ ទៀត កាន់កាប់គណៈស្រុកប្រធាន?

សនៈ មុន ។

ឃីមៈ ក្រែងគាត់នៅឃុំ?

សនៈ ឃុំដល់ហើយ គាត់នៅនេះក៏ខ្ញីដែរ ហើយទៅ ទៅនៅស្រុកនោះ ស្រុកតានីនេះ ខេត្តកំពត ស្រុកអង្គរជ័យ ។

ឃីមៈ ចឹង គាត់ផ្លាស់ទៅណោះវិញ?

សនៈ បាទ ធ្វើប្រធាននោះវិញ ។

ឃីមៈ ចុះគាត់នៅនេះដល់ឆ្នាំណា?

សនៈ ឆ្នាំដល់ចាប់តាតាវ ឆ្នាំណាកាលឯងនៅព្យាបាលតាគិតណឹង បានតាគិតឡើងធ្វើ គណៈស្រុក ។

ឃីមៈ ចឹង តាគិតចិតប៉ុន្មាន?

ឌីមៈ ៧៥

សនៈ ហឺ តាគិតគាត់ធ្វើគណៈស្រុកបានតែមាឆ្នាំទេ ។

ឃីមៈ កាលមុនអ្នកនិយាយចឹងដែរ ថាធ្វើបានមាឆ្នាំផ្លាស់ទៅ ។

សនៈ ផ្លាស់ទៅធ្វើគណៈតំបន់១៣ ហើយដកពី១៣ទៅ២៥ ។

ឃីមៈ ធ្វើនៅ១៣បានប៉ុន្មានខែ?

សនៈ នៅ១៣ បានមាឆ្នាំ ប៉ុនអត់មានធ្វើការអី ឈឺខ្ញុំព្យាបាល ។

ឃីមៈ គាត់ស្លូតបូកាច?

សនៈ ស្អួតណាស់ ហី ប្អូនឯងស្តាប់សំដីតាគិត បើជឿតាមសំដីតាគិតអត់មានបានរត់រញ៉ៀរញ៉ៃយួនចូលពេញដីចិនទេ ។ គាត់ចេះតែថា តាសនហើយគេបើចែកវណ្ណៈចែកប្រភេទ អីចឹង មុខជារកប្រែនៅមិនបាន ។ រកព្រៃនៅមិនបាន មានគណៈស្រុកមួយទៀត ប៉ុនខ្ទឹមៗគណៈស្រុកច្រើនណាស់ ។

ឃីមៈ តាចាយដែរ ថាអត់ចេះអក្សរ?

សនៈ អត់ចេះអក្សរទេ ណឹងហើយ ។

ឃីមៈ ឥឡូវគាត់ទៅណាហើយតាចាយណឹង?

សនៈ ស្លាប់បាត់ហើយទៅនៅអង្គវែង ជាមួយតាម៉ុក ។

ឃីមៈ គាត់ឈឺ ឬគេសម្លាប់?

សនៈ ឈឺទាំងប្តីទាំងប្រពន្ធស្លាប់អស់ហើយ ។

ឃីមៈ អ៊ំចេស សុំទោស ខ្ញុំចង់សួរអ៊ំគណៈស្រុក កាលមុនបំផុត កាលឆ្នាំ៧០ដល់៧៥តាញ៉ៀវ

សនៈ បាទ!

ឃីមៈ ចុះបន្ទាប់ពីតាញ៉ៀវអ្នកណា យាយបឿន?

សនៈ មិនទេ មិនយាយបឿនទេ យាយខុំ ។

ឃីមៈ យាយខុំពីឆ្នាំណាដល់ឆ្នាំណា?

សនៈ មិនបានគិតទេ គ្រាន់ដឹងបន្ទាប់ ក្រោយយាយខុំមកតាជឹម តាជឹមហើយតាចាយ ។

ឃីមៈ ចុះតាភី អ៊ំនិយាយថាតាភី?

សនៈ ប្រធានមន្ទីរស្រុក មុនអាដន ។

ឃីមៈ អូ ហើយបានដនណឹង?

សនៈ បាទ ភី ណឹងប្រធានមន្ទីរស្រុកតាំងពីឆ្នាំ៧០បាក់ជើងម្ខាង កាចចោលម្រាយហើយអានោះ ។

ឃីមៈ នៅរស់ទេ ចឹងថាគេសម្លាប់ជាមួយតាខែមបាត់ហើយភីណឹង ។

សនៈ ខ្ញុំអត់ដឹងទេ ។

ឃីមៈ គេថាចង់បាញ់ ។

សនៈ ប្រហែលហើយ គេបាញ់ក៏បាញ់ចុះអាណឹងកាចណាស់ ។

ឃីមៈ ចឹងគាត់មិនមែនគណៈស្រុកទេ គ្រាន់តែប្រធានមន្ទីរទេភីណឹង?

សនៈ ប្រធានមន្ទីរ ។

ឃីមៈ ខែមយោធាអ៊ុំ?

សនៈ មិនមែនទេ មិនមែនតាខែមណឹង ។ តាខែមណឹង ទៅដល់ស៊ឹងឃាចណឹងហៅប្រជុំ ក្រោយតាម៉ុកហៅប្រជុំហើយ តាខែមហៅប្រជុំ ហើយសួរខ្ញុំថាមានដឹកគ្រែមួយមកពីតាកែវអត់ មានគ្រែមួយនៅតាកែវណឹង គាត់ថា គាត់ដាក់មាសនៅពេញ ជើងគ្រែណឹង ។ ខ្ញុំថាអាណាទៅដឹកគ្រែមក ដឹកបាយស៊ីមិនបានផង ។

ឃីមៈ កាលណឹងអ៊ុំរត់ដល់ណា៧៩ណឹង?

សនៈ រត់ដល់ស៊ឹងឃ្លាចណឹង ដល់ណឹងតាម៉ុកតាកុំមកវិញ ហ្អែងនៅណឹងហើយ ។

ឃីមៈ ភ្នំ?

សនៈ អត់ទេភូមិ ភូមិក្រសាល ។

ឃីមៈ ស្រុកអី?

សនៈ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ អត់ដឹងមិនដឹងស្រុកប៉ុន្មានទេ គេដាក់ឈ្មោះប៉ុនភ្លេច បាត់ហើយ ។

ឃីមៈ មិនដល់ភ្នំក្រវ៉ាញកាលណឹង?

សនៈ អត់ទេ ។

ឃីមៈ អ៊ុំទៅម្នាក់ឯង ចុះស្រីៗពេទ្យណឹង?

សនៈ ទៅទាំងអស់ មិនទាំងអស់ទេ ទៅ៨-១០នោះ យាយអីណឹងកូនខ្ញុំអីណឹងទៅទាំងអស់គ្នាបរទេះ ។

ឃីមៈ ចុះនារីពេទ្យធ្វើការជាមួយអ៊ុំទៅដែរ?

សនៈ ទៅដែរ ទៅប៉ុន្មាននាក់យាយ ។

ឃីមៈ ចុះយើងអត់ទៅបានទេ កាលរត់ណឹង?

សនៈ មានទាស់អី ប៉ុនខ្ញុំចង់បានទៅ ប៉ុនកាលណឹង ដូចអត់ទាន់ជះស្រះថា យួនវាវៃលុកដល់ណាដល់ណីទេ ។

ខីមៈ តានេះគាត់ងប់នឹងបដិវត្តន៍ ដាច់ខាត មានតែខ្ញុំទេ..... ។

សនៈ ដាច់ខាត ។ ទៅដល់នោះធ្វើថ្នាំទៀត ហីធ្វើថ្នាំដល់នោះ ពេទ្យចង់ធ្វើហ្នឹងអត់ខ្វះមេថ្នាំ ។

ឃីមៈ នៅនេះក្រ?

សនៈ នៅនេះក្រណាស់ទៅទិញបានតិចៗ បេខូអីបានពីរបីដប ។

ឃីមៈ ចុះក្រែងចិនឲ្យថ្នាំមកដែរអ៊ុំ?

សនៈ ចិនឲ្យ ប៉ុនគេធ្វើតែនោះ ប៉ុនខ្ញុំណេះអត់ ។

ឃីមៈ ចុះអត់យករបស់ចិនមកទេ ចិនជំនួយមក?

ទីមៈ ប្អូនឯងជំនួយមកណឹង យកទៅណាដល់គេវៃព្រឹមមកណឹងវារត់យកតែអាយុមិន តែរួចផង ។

ឃីមៈ អ៊ំតាញៀវស្លាប់ហើយតើ?

សនៈ តាញៀវស្លាប់ហើយ ។

ឃីមៈ គាត់ស្លាប់រឿងអីតាញៀវណឹង?

សនៈ ស្លាប់នៅសមរភូមិជុំវិញតាកែវណឹង នៅព្រៃលើ ។

ឃីមៈ ឆ្នាំណា?

សនៈ ឆ្នាំ៧៣-៧៤ណឹង ឆ្នាំណឹង ឆ្នាំគាត់គិតនៅធ្វើគណៈស្រុក ។

ឃីមៈ គាត់ឡើងវៃ?

សនៈ វៃបែកបន្ទាយ គេចូល ។

ឃីមៈ ចុះតាជឹមគេនៅរស់ទេ?

សនៈ តាជឹមនៅរស់ ។

ឃីមៈ យាយខ្ញុំណឹងរៀនដល់ណាខ្លះទៅ ដែលថាឆ្លួត?

សនៈ យាយខ្ញុំមិនដឹង ខ្ញុំអត់ដឹង ដូចគ្មានបានរៀនទេ ពួកណឹង ។

ឃីមៈ ចុះថាកូនតាម៉ុកសុទ្ធតែឆ្លួតម៉េចចឹង?

សនៈ ឆ្លួតចឹងទាំងអស់ ។

ឃីមៈ ចុះកូនតាម៉ុកមានប៉ុន្មាននាក់?

សនៈ កូនតាម៉ុកមានខ្ញុំ មីគ្រូ ។

ឃីមៈ គ្រូធ្វើអីគេ?

សនៈ មីគ្រូណឹងមាត់ឆែបអត់ឆ្លួត មានតែមួយ ណឹងក៏អត់រៀនដែរ ។

ឃីមៈ ម៉េចបានធ្វើពេទ្យ?

សនៈ តាម៉ុកយកទៅផ្ញើជាមួយប្រជាជននៅឃុំអូរសារាយ យើងស្រុកត្រាំកក់យើងនេះដែរ នៅភូមិតាអាំនេះ ភ្ញើតាំងពីតូច ចឹងគ្មានបានរៀនបានសូត្រអីទេ ។

ឃីមៈ ចុះម៉េចសម័យណឹងបានធ្វើពេទ្យ?

សនៈ ចេះតែនៅៗយកផ្ញើជាមួយគេ ។

ឃីម: កាលណឹងនៅពេទ្យណា?

សន: កាលណឹងនៅពេទ្យតំបន់ ។

ឃីម: ថាពេទ្យភាគ?

សន: ពេទ្យភាគនៅតាកែវ ។

ឃីម: គាត់ប្រធាន ឬអ្នកណាប្រធាន?

សន: ប្អូនតែដល់យកទៅមានកូនតាម៉ុកយកទៅចឹងទោះបី កាលណឹងកូនតាម៉ុកធ្វើប្រធាន ។

ឃីម: ឈ្មោះហូរណឹងមែនទេ?

សន: ណឹងហើយ ។

ឃីម: ប្ដីឈ្មោះរ៉េនណឹងឌ?

សន: អារ៉ែនណឹងហើយ ។

ឃីម: ប្ដីបងហូរណឹង?

សន: ណឹងហើយ ។

ឃីម: ប្រធានពេទ្យភាគណឹង?

សន: ណឹងហើយ ។

ឃីម: ចុះបងគ្រូណឹងថាធ្វើធំដែរ?

សន: ធ្វើធំដែរ ប៉ុនគ្រាន់តែនៅណឹងទេ ។

ឃីម: ប៉ុនថ្នាំអី ខ្ញុំឃើញក្នុងឯកសារ ថ្នាំអី គាត់អ្នកទាក់ទង គាត់ទៅយកនៅភ្នំពេញ ។ ចង់បានន័យថាគាត់គួរសដែរ ។

សន: មិនទេ អាណឹងមិនបាច់មានមុខអីទេ គ្រាន់តែគេទុកចិត្តមិនក្បត់ ។

ឃីម: ហឺ ចុះកូនតាម៉ុកប៉ុន្មាននាក់?

សន: កូនតាម៉ុកមាន ខ្ញុំ ហូរ គ្រូ ហ៊ាញ ណឹង ។

ឃីម: ហ៊ាញណឹងធ្វើអី?

សន: ប្ដីសុទ្ធតែកងពលទាំងអស់ ប៉ុនសុទ្ធតែឆ្គួត ។

វគនា: ៤ ណឹងឆ្គួតទាំង៤ហ្នឹង?

សន: អត់ទេ អត់អាគ្រូមួយមាត់ឆែប ។ ប៉ុនមាត់ណឹងធ្វើស្អាតហើយ ។

ឃីម: ចាំ តែថានៅនិយាយនៅក្រដួរ ៗដដែល ។

សនៈ កាលនៅនេះធ្វើចឹងហើយ មីមួយចាក់ចង្កេះចឹងវាស៊េច ទៅរយៈមកវិញ ។ វាទើបជាតិចៗ ។

វគនាៈ ចុះអ៊ំឆ្លួតណឹង ឆ្កួតពីកំណើត?

សនៈ ឆ្កួតកំណើតសុទ្ធតែឆ្កួតពីកំណើតទាំងអស់ អាហ៊ាញណឹងឆ្កួតមែនទែន ឆ្កួតឡឹកឡក់និយាយពីស្អាត ហី ប្តីអាបូរាណ ។

ឃីមៈ ហី ធ្វើអីគេហ៊ាញណឹង?

សនៈ គ្មានធ្វើស្អីទេក្មួយ បើតាមមើលនៅពេទ្យនៅអីណឹងគ្មានធ្វើស្អីទេ គ្រាន់តែនៅជាមួយគេចឹងហ្នឹង ។ មិនបាច់ចេះសួ ចុះបើវាលេលីគេមិនដឹង ។

ឃីមៈ ចុះបងហ៊ាញណឹង គាត់ធ្វើពេទ្យ គាត់អត់មានឋានៈអីទេ?

សនៈ អត់ទេ អត់មានទេ ។

ឃីមៈ បងហូរ គាត់រៀនបានជ្រៅរជះដែរបងហូរ?

សនៈ មិនជាជ្រៅជ្រះប៉ុន្មានទេ ប៉ុនគ្រាន់តែចេះដឹង ។

ឃីមៈ គាត់ប្រពន្ធគណៈកងពល៦០៣ ។

សនៈ សុទ្ធតែប្រពន្ធកងពល ខ្ញុំមិនដឹងកងពលលេខប៉ុន្មាន ខ្ញុំអត់ដឹងទេ ។

ឃីមៈ ចាំ ហីចុះរាល់ថ្ងៃនៅរស់ទេ?

សនៈ អាហូរនៅ ។

ឃីមៈ គាត់នៅណា?

សនៈ នៅកាលនេះ នេះនារីម្នាក់មកនិយាយថា កាលតាម៉ុកនៅអន្លង់វែង សួរថាចុះតាម៉េចដែរ តាសុខសប្បាយទេ តាអត់អីទេ សុខសប្បាយទេនៅជាមួយកូនម៉េម៉ាយ ៤នាក់ ។

ឃីមៈ ហាំ ម៉េម៉ាយទាំង៤?

សនៈ បាទ!

ឃីមៈ ចុះអាគ្រូណឹងម៉េម៉ាយដែរ?

សនៈ ម៉េម៉ាយទាំងអស់ងាប់អស់ហើយ ។

ឃីមៈ ប្រុសៗងាប់ទាំងអស់?

សនៈ ប្រុសៗងាប់ទាំងអស់?

ឃីមៈ ងាប់អស់ហើយ?

សនៈ បាទ ផាប់ទាំងអស់ ដល់ចុងក្រោយអាក្រក់ សីលធម៌អាក្រក់ហ្នឹងពួកអស់ណឹង វាអាង អំណាច ។

ឃីមៈ ហឺ គាត់ស្លាប់រឿងអីប្តីៗ ?

សនៈ អត់ដឹង ខ្លះបាញ់ខ្លួនឯង អាខ្លះគេបាញ់ ដល់ហើយបេះថាចាញ់ ។

ឃីមៈ ចុះបងហូរវាល់ថ្ងៃធ្វើអី?

សនៈ មិនដឹង ខ្ញុំអត់ដឹង ។

ឃីមៈ ឥឡូវដឹងថា គាត់ធ្វើការរកស៊ីធ្វើពេទ្យដែលឬអត់?

សនៈ ដូចគ្នាទេ នៅទោះបីនៅអន្លង់វែងអីក៏អត់ ។

ឃីមៈ ពូសួរថាលក់ដូរ លក់ខ្ទឹមលក់អី លក់ប៊ីចេងអី ។

សនៈ រឿងយាយបឿនណឹងក៏ខ្ញុំអត់ដឹងដែរ ។

ឃីមៈ ចុះយាយចែមគាត់ធ្វើអីគេយាយចែម?

សនៈ យាយចែមណឹងគណៈតំបន់ដែរ ។

ឃីមៈ គាត់ប្រធាន?

សនៈ មិនប្រធានទេ ប៉ុនប្រធាននារីតំបន់១៣ម្នាក់ដែរ ដល់ក្រោយមកខ្ញុំមិនដឹងទៅណាទៀត ។

ឃីមៈ ចុះយាយប៉?

សនៈ យាយបូក៏គណៈតំបន់ ។

ឃីមៈ ចឹង សុទ្ធតែគណៈតំបន់ស្រីៗ ?

សនៈ ចុះគណៈតំបន់មាននារីម្នាក់ ត្រូវតែមាននារីម្នាក់ ។

ឃីមៈ ផ្នែកខាងនារី ។

សនៈ ដូចយើងឥឡូវនេះចឹង ។

ឃីមៈ ចាំមើលតាញ៉ៅក៏ស្លាប់ នៅតាញឹម?

សនៈ នៅតាជឹម ។

ឃីមៈ ចុះតាចាយអុំ?

សនៈ តាចាយស្លាប់ ។

ឃីមៈ ចុះតាគិត?

សនៈ តាគិតស្លាប់ ។

ឃីមៈ ចុះតាភី?

សនៈ តាក៏ខ្ញុំអត់ដឹងទេ ។

ឃីមៈ ចុះតាសាន?

សនៈ តាសាននៅ តាសានក្រោយពីក្ងួយឯងទៅមក ។

ឃីមៈ ចឹង?

សនៈ ប៉ុនគាត់អត់មកផ្ទះខ្ញុំទេ ។

ឃីមៈ ចុះគាត់ធ្វើអីគេរាល់ថ្ងៃ?

សនៈ គាត់អត់ធ្វើអីទេ ។

អូនៈ គាត់នៅណាឹងទេរាល់ថ្ងៃ?

សនៈ អត់ទេ នៅប៉ៃលិន ប៉ុនអត់យកប្រពន្ធដែលប្អូនតាម៉ុក យាយគៀនណឹង ។

ឃីមៈ អូ យាយគៀន ឋីបានអត់យក?

សនៈ យាយគៀន គាត់អត់យក ។

ឃីមៈ យាយ គៀន អត់យកមិនមែនតាសានអត់យកទេ?

សនៈ បាទ!

ឃីមៈ ឋី បានអត់យក?

សនៈ តាសានមិនដឹងម៉េច ។ តាសានណឹងគាត់ឡេឡឺទៅ កាលនេះគាត់ធ្វើគ្រូបង្រៀនអីណឹង ពេលចូលមកតាសែនឲ្យម៉ូតូអាធំមួយ ។ ដល់ក្រោយមកទៀតមិនដឹងម៉េច ។ ដល់មកនេះអត់បានជួបខ្ញុំ ។

ឃីមៈ ចុះយាយបូររាល់ថ្ងៃនៅណាយាយបូរ?

សនៈ យាយបូរក៏ស្លាប់ ។

ឃីមៈ ស្លាប់រឿងអី?

សនៈ អត់ដឹងមិនដឹងស្លាប់រឿងអី ។

ឃីមៈ យាយថែមថានៅរស់?

សនៈ បាទ!

ឃីមៈ កាលមុនតាមកធ្វើបុណ្យជាមួយយាយបឿនមកឃុំជាងទងនេះ ។

សនៈ ខ្ញុំមិនចង់ជួបខ្លាចពួកអស់ណឹងទេ ចឹងបានខ្ញុំប្រយ័ត្នណឹង ខ្លាចពួកអស់ណឹងវានៅចូលដៃចូល ដើងជាមួយពួកភាវរកម្មជាមួយអីព្រោះវាមិនទៀតទេ ពួកអស់ណឹង ចឹងយើងអត់ចូលធ្វើទេពេលមកជួបណឹង ។ ប៉ុនវានាំមានអាសង្ស័យ ។ ខ្ញុំមានមិត្តភក្តិម្នាក់នៅ

អាមេរិក មកកាលពីខែ៧ខែ៨ ហៅខ្ញុំទៅជួប ។ ដល់ខ្ញុំទៅជួប ដល់ចង់មកផ្ទះខ្ញុំ ខ្ញុំអត់ឲ្យមក ខ្ញុំខ្លាច ។ ហី ខ្ញុំខ្លាចត្រូវរបស់ខ្ញុំមែន ខ្លាចមានការអី ។

ឃីមៈ ឈ្មោះណឹងមែន?

សនៈ អត់ទេ ប៉ុនខ្ញុំខ្លាច ព្រោះគេទៅបាត់ហើយយើងមិនដឹងចិត្ត ។ បើដឹងថាគេធ្វើហ្នឹងអាណឹង មិនខ្លាចទេ មុនធ្វើប្រាប់រដ្ឋអំណាចគេហ្នឹង ។ ឥឡូវខ្ញុំទៅជួបអានេះៗម៉េចៗ មកវិញខ្ញុំប្រាប់ ។

ឃីមៈ អ៊ំកាលនៅស្រុកត្រាំកក់ណឹងខ្មែរក្រហមរំដោះឆ្នាំណា មិនទាន់រំដោះ៧៥ទេ មុន៧៥ណឹង ។

សនៈ តាំងពីឆ្នាំ៧០ ។

ឃីមៈ រំដោះបានទាំងស្រុងកាន់កាប់ទាំងស្រុងនៅម៉ាស្រុកត្រាំកក់ណឹង មិនមែនម៉ាដុំៗ?

សនៈ ខ្ញុំមិនបានគិត ប៉ុនបេស ក្នុយពិចារណា ពេលផ្ទុះអាវុធប្រាវហើយភ្លាម គឺអត់បើតាមខ្ញុំចូលជ្រៅជាមួយខ្មែរក្រហម គឺអត់មាន គឺខ្មែរក្រហមហ្នឹងកាន់អំណាចស្រុកត្រាំកក់ ។

ឃីមៈ ចុះនៅអន្លុងសោមអ៊ំ?

សនៈ អើ លើកលែងតែក្នុងតួអន្លុងសោមចេញ ។ ចុះក្នុយពិចារណាមើលបេស គ្រាន់តែព្រឹបគ្រាន់តែផ្ទុះអាវុធព្រឹបចឹង ស្រាប់តែមានគណៈឃុំគណៈអីដើរធ្វើការពេញដីទៅឃុំលាយទៅឃុំណាទាំងអស់គ្នាអាលឹង ។

ឃីមៈ ឆ្នាំ៧០ណឹង?

សនៈ បាទ ទៅព្រឹកថ្ងៃល្ងាចមកប្រជុំៗដើរ ។

ឃីមៈ ខាងខ្មែរក្រហមទាំងអស់ប្រធានប្រធានអីណឹង?

សនៈ ទាំងអស់ហ្នឹង មិនមែនមេឃុំចាស់ អ្នកធ្វើថ្មី ឯមេឃុំចាស់រួចអស់បាត់នៅស្ងៀមបេសរត់ទៅក្នុងអស់ ។

អូនៈ បានន័យថា វារៀបយូរហើយ?

សនៈ រៀបយូរហើយ ដូចក្នុយឯង ខ្ញុំនិយាយថាតាព្រំអីណឹង តាព្រំពីមុនគាកត់ជានិរសា ។ យកពួកអស់ណឹងចេញមក យាយបឿន ក្រោយមកយាយថែម យាយអីចូលរួម យាយបូអីណឹងធ្វើតាមណឹង វាអត់មានបែកការណ៍អីរហូត ។ គេទុកចិត្ត ។ ចឹងពួកណឹង យាយអីមួយទៀត ប្អូនយាយបឿន ។ មួយទៀត គាត់នៅស្រុក១០៥ណឹងដែរ ។ ខ្ញុំ

ចង់និយាយពីប្ដីគាត់ ។ ប្ដីរបស់គាត់ជានិរសានៅកន្លែង ខៀវ សំផន ណឹង ដោយៗ មកគាត់យកធ្វើប្ដី ។ ឡេឡឺៗខ្ទិច ។

យឹមៈ ចឹងគាត់នៅរស់ទេ?

សនៈ នៅ ។

យឹមៈ នៅណា?

សនៈ នៅណឹងទាំងអស់ នៅអន្លង់វែងទាំងអស់ ។

យឹមៈ ហឹ គេអត់មកនៅស្រុកទេ ចុះហេតុអីបានគេអត់មកនៅ?

សនៈ ក្មួយឯងទៅនោះបានដឹង អំបុងទៅនៅស្រុកណឹងដែរតើ ។ និយាយពីដីយកប៉ុន្មានបាន ប៉ុណ្ណឹង និយាយពីដីល្អណាស់ស្មៅកំពស់ដំបូលផ្ទះយើង ។

យឹមៈ ថាធ្វើស្រូវល្អ?

សនៈ ធ្វើអីក៏ល្អដែរ ។

យឹមៈ ថាខៀវសំផននៅដាំពោតណឹង?

សនៈ បាទ ខ្ញុំទៅណឹង ។

យឹមៈ ចឹងធ្លាប់ទៅអន្លង់វែងដែរ?

សនៈ ទៅ ។

យឹមៈ ឆ្នាំណាអ៊ំ?

សនៈ ឆ្នាំ៩១ ។

យឹមៈ ហឹម៉េចទិដ្ឋភាពនៅណឹង?

សនៈ កាលណឹងបើកុំតែខ្ញុំទៅអន្លង់វែងណឹង យើងនៅនេះពិបាកធ្វើខ្មែរក្រហមដែរណឹង ។ ខ្មែរក្រហមមានសម្ភារច្រើនណាស់ ច្រើនមែនទែនហ្នឹងមានគ្រប់មុខ ដូចខ្ញុំកាលមុនបាន និយាយប្រាប់ថា មានត្រពាំងមួយបណ្ដោយវាប្រហែលជា៥០០ម៉ែត្រ ហើទទឹងណឹងក៏ ប្រហាក់ប្រហែលគ្នា គេហៅព្រះត្រពាំងអ្នកស្រុកណឹង ចុះនៅកណ្ដាលព្រៃ ។ ហឹត្រពាំង ណឹងត្រឹមចឹង ឃើញដើមឈើនៅក្នុងត្រពាំងប៉ិនៗឡាន ។ មិនមែនដាំទេ វាដុះក្រោយពី លើត្រពាំងណឹងហើយ ។ ចឹងសម្ភារៈខ្មែរក្រហមតំបន់១ តំបន់២ តំបន់៣ តំបន់៤ គេណឹងនៅជុំវិញណឹង ដាក់កណ្ដាលវាលណឹង គរកំពស់ៗណាណីម៉ាតំបន់ៗ ។ បើគ្រាប់ វិញ ខ្ញុំទៅនៅណឹងម៉ាអាទិត្យ ទៅជួយចែកគ្រាប់ចែកអី កាលណឹងមានខាងសើរការ

មានខាងសីហនុខាងអីណឹង នៅមិនទាន់ចូលគ្នាណឹង មកបើកតែពីរខ្មែរក្រហមណឹង ។ បើកអង្ករក៏បើកពីខ្មែរក្រហម បើកគ្រាប់បើកកាភ្លើងពីខ្មែរក្រហមទាំងអស់ ។

ឃីមៈ ចុះអ៊ំទៅធ្វើអីកាលណឹង គេឲ្យទៅធ្វើអី?

សនៈ បេសកម្មកាលណឹងខ្ញុំធ្វើប៉ូលីស ។

ឃីមៈ ចុះគេដឹងទេថាអ៊ំខាងនេះ?

សនៈ អត់ ។

ឃីមៈ ចុះអ៊ំទៅដល់និយាយធ្វើម៉េចបានគេទុកចិត្ត?

សនៈ អត់ទេ សុទ្ធតែមិត្តភក្តិកងពល ។

ឃីមៈ ដើម្បីថាឲ្យគេមកបង្រួបបង្រួមចូលណឹងកាលណឹង?

សនៈ បាទ!

ឃីមៈ ចុះអ៊ំទៅនិយាយម៉េចខ្លះកាលណឹង?

សនៈ និយាយត្រឹមតែអ្នកកងពលលេខម៉ានទេ ភ្លេចហើយ ឥឡូវនៅធ្វើការជាមួយ ហ៊ុន សែន វាមក ។

**SideB**

សនៈ អាណឹងកងពលធំ មិនមែនកងពលតូចទេ ។ ឥឡូវមកអស់សុទ្ធតែទីប្រឹក្សា ហ៊ុន សែន ។ ប៉ុនកាលមុន អាណាមិនបានមុន អាណឹងមិនបានកៀកទេ ។ ខ្ញុំទៅខ្លាចបែកការណ៍ទៅយូរដែរណឹងព្រោះពួកព្រៃ ។

ឃីមៈ ចុះអ៊ំថា នៅអន្លង់វែងអត់ទាន់រំដោះ ចុះឆ្នាំណាគេរំដោះអន្លង់វែងបាន?

សនៈ ដល់ឆ្នាំ៧៥ហ្នឹង ។

ឃីមៈ មិនមែន៧៣ទេ?

សនៈ ទេ មិនមែន៧៣ទេ ។

ឃីមៈ ចុះថាបង្កើតសហករណ៍អ៊ំ បង្កើតឆ្នាំណា សហករណ៍អ៊ំថាគេដាំមិនទាន់ហូបរួមទេ?

សនៈ តាំងពីឆ្នាំ៧៥មកហ្នឹង ។

ឃីមៈ ចុះកាលមុន៧៥?

សនៈ វាចេសក្ដួយវាមានម៉ាដុំៗ បើខ្ញុំនេះតាំងពីឆ្នាំ៧៥ហ្នឹង ។ គ្រាន់តែឆ្នាំ៧៥ណឹងគេមានរៀបចំជា គេហៅធ្វើសមាគននោះ អាណឹងក៏ដូចជាសហករណ៍ដែរ ។ ឧទាហរណ៍ខ្ញុំធ្វើស្រែបានចឹង ខ្ញុំដឹកម៉ាគោយកទៅដាក់រួម ។ ដល់ពេលខ្ញុំអស់គេដឹកយកមកឲ្យហូប ។

ឃីមៈ ចុះក្រុមប្រវ៉ាស់ដៃកាលណឹង មានតាមពីណា?

សនៈ ក្រុមប្រវ៉ាស់ដៃមានតែម៉ាឆ្នាំទេ មុនឆ្នាំ៧៥ ។ ដល់ក្រោយមកអត់ទេ ។

ឃីមៈ គេធ្វើម៉េចក្រុមប្រវ៉ាស់ដៃណឹង?

សនៈ ប្រវ៉ាស់ដៃណឹងប្រវ៉ាស់តែគ្នាឯងណឹងធម្មតា ។

ឃីមៈ គ្នាប៉ុន្មាននាក់ទៅ?

សនៈ មិនទៀតទេ ដូចថាយាយផ្ទះនេះគាត់ស្ទូងខ្ញុំទៅជួយគាត់ទៅ គេក៏ទៅជួយទាំងអស់គ្នា ។ ដល់ស្អែកខ្ញុំស្ទូងមកទាំងអស់គ្នា ដូចយើងធ្វើរាល់ថ្ងៃនេះចឹង ។

ឃីមៈ ដល់ពេលផលបានពីណាគេ?

សនៈ ផលបានរបស់យើង ។

ឃីមៈ របស់យើង របស់អ្នកណារបស់អ្នកណឹង?

សនៈ បាទ!

ឃីមៈ តែយើងមានឲ្យទៅអង្គការខ្លះទេ?

សនៈ កាលណឹងអត់ ។

ឃីមៈ ចុះអ្នកណាប្រាប់ឲ្យធ្វើ ឬយើងធ្វើខ្លួនយើងក្រុមប្រវ៉ាស់ដៃ?

សនៈ អត់ទេ សុទ្ធតែភូមិគេណែនាំឲ្យធ្វើប្រវ៉ាស់ដៃ ។

ឃីមៈ ចុះក្រុមសាមគ្គី?

សនៈ អាណឹងហើយក្រុមសាមគ្គី ។

ឃីមៈ ចឹង តែមួយទេ?

សនៈ បាទ!

ឃីមៈ អូ ខ្ញុំស្មានតែផ្សេងគ្នាក្រុមសាគ្គីណឹង ។ ចុះ ថានៅឃុំគូស បង្កើតសហករណ៍មុនគេនៅឆ្នាំ៧៣មែនទេ?

សនៈ គេបង្កើតមែន ប៉ុនខ្ញុំអត់មានបាន ។

ឃីមៈ នៅឃុំគុសណឹង?

សនៈ បាទ ប៉ុនដូចបរាជ័យអាម៉េចទេ ។

ឃីមៈ បរាជ័យម៉េច?

សនៈ ធ្វើសហករណ៍ ធ្វើបាយរួមចឹង ដល់ហើយធ្វើអត់បានរំសាយវិញ ។

ឃីមៈ ឆ្នាំ៧៣ណឹង មិនទាន់រំដោះបានកាលណឹង?

សនៈ បាទ អានេះបេស រឿងប្រជុំទៅសន្និបាតអីគេណែនាំថាឲ្យយើងធ្វើ យើងឈានទៅសហករណ៍ អ្នកណាធ្វើបានមុនអីចឹង ។ ហី កាលណឹងគណៈឈ្មោះស៊ី ឬឈ្មោះអីទេ គាត់ធ្វើបានមុនគេ ដល់ក្រោយមកគាត់បរាជ័យ ដល់ក្រោយមកបានធ្វើទាំងអស់គ្នា ។ សូម្បីតែនៅឃុំម៉ុំនេះក៏ធ្វើដែរបានរំសាយវិញ ។

ឃីមៈ ឆ្នាំ៧៣ណឹងធ្វើម៉ាំសារវិញ?

សនៈ បាទ រំសាយវិញ ។

ឃីមៈ ចឹ ម៉េចបានបរាជ័យ?

សនៈ អត់មានអីហូប ។

ឃីមៈ ម៉េចចឹង?

សនៈ ចុះប្រមូលអត់ទាន់បានគ្រប់ស្រូវនៅតាមផ្ទះ ចឹងប្រមូលអត់បានអស់ ។

ឃីមៈ ចឹងគេចង់ប្រមូលដាក់រួម?

សនៈ បាទ កាលណឹងគេទំនាស់ខ្លាំងណាស់កាលណឹងទំនាស់គ្នាខ្លាំងណាស់ ។

ឃីមៈ ទំនាស់ម៉េច?

សនៈ ចុះកាលណឹងសតិអារម្មណ៍ ទំនាស់ផ្នែកសតិអារម្មណ៍ចុះខ្ញុំវ៉ាន់ណឹង ដូចថាផ្ទះមានសម្ភារៈពេញផ្ទះស្រាប់តែប្រមូលទៅដាក់រួបទាំងអស់ ពិរចាណាមើល ស្រូវពេញក្រង់ផ្ទះនេះអត់មានស្រូវផ្ទះនោះអត់មានស្រូវ ។

ឃីមៈ គេបានហូបដែរ?

សនៈ បានហូបដែរ អាណឹងសតិអារម្មណ៍ ។ មិនយកទៅហូបបានតែម៉ាំរយៈ៤-៥ថ្ងៃអស់អាលីង ។

ឃីមៈ ដល់ចឹងរំសាយ?

សនៈ រំសាយ ខ្ញុំអត់ដែលបានគិតផងអាណឹងមិនដឹងគេរំសាយបានប៉ុន្មានអីម៉ាន ។ ខ្ញុំបេសបានខ្ញុំមិនសូវបានគិតណឹង ។ ការងារនៅផ្ទះនៅតាមភូមិណឹង គិតតែការងារទៅឆ្ងាយៗ ។ ការងារប្រជាជនបេះប្រើខ្ញុំ ខ្ញុំគេស្រួលប្រើខ្ញុំដូចគោចឹង ។

ឃីមៈ ចឹងបានន័យថា ស្រែចំការអឹំអត់ដឹងគេធ្វើម៉េចៗ

សនៈ អត់សូវដឹងគេធ្វើម៉េចៗទេ ប៉ុនគ្រាន់តែដឹងទំនាស់ចិន អត់ដែលបាននៅភ្ជួររួម ភ្ជួរអី ភ្ជួររួមបានកាលធ្វើនៅតាមក្រុមប្រវ៉ាស់ដៃតាមក្រុមណឹង ដែលនៅបានភ្ជួរដល់ក្រោយ អត់ទេ ។

ឃីមៈ ចុះឆ្នាំណាដែលអ៊ំថាធ្វើទៅដឹកម៉ាតៅយកទៅភាគទានគេ?

សនៈ អាណឹងចេស តាំងពីយូរមុនឆ្នាំ៧០ទៀតគេធ្វើស្វាត់ ជាសមាជិកគេហៅសមាជិកសហគមធ្វើចិន ។ ប្អូននេះដាក់ម៉ាតៅ ប្អូននោះដាក់ម៉ាតៅទាំងអស់គ្នា ថាបានស្រូវ២០០រយថាំងចិន ដល់ខែណឹងខែអត់ណឹង ។ គេដើរពិនិត្យសមាជិកគេអ្នកណាអត់បាយ ។ អត់មកប៉ុន្មានខែ បើថាអត់៣ខែ ៣ខែណឹងអស់ស្រូវប៉ុន្មានគេឲ្យទៅវិញ ។

ឃីមៈ ហី ចុះកងទ័បបានអី?

សនៈ កងទ័ពកាលណឹងគេទិញ ។ កងទ័ពអីទិញ យួនអីណឹងមកទិញស្រូវនៅផ្ទះខ្ញុំ ខ្ញុំរកកាប់យួន ។ ក្រោមផ្ទះណឹង ។ ខ្ញុំនោះវាជួរចត់ណាស់ ។ ទិញនៅផ្ទះខ្ញុំណឹងអង្ករគេប្រមូលមកលក់ឲ្យយួនលក់នៅណឹង ពេលយួនវាអត់លុយទិញខ្ញុំលក់ឲ្យទ័ពខ្មែរ យួនរករឿងខ្ញុំមិនខ្ញុំរកកាប់ ។ ទាញកាំបិតដកពីណឹងរកកាប់ ។

ឃីមៈ ចុះរកកាប់ចឹងវាថាម៉េច?

សនៈ វាបោះកាំភ្លើងវាចោល ។

ឃីមៈ វាចង់ឲ្យយើងលក់ឲ្យវា?

សនៈ វាអត់លុយ ។ខ្ញុំដល់មកពីរត់វិញ ចង់ឈ្លោះជាមួយយួនទៀត ។ ឈ្លោះជាមួយយួនចេះបៃដន្យអី ក្រោយជួបពួកណឹង ។ គេយកខ្ញុំទៅឲ្យធ្វើផ្លូវឲ្យអាយួន ខ្ញុំជាកម្មាភិបាលអាពតចេះតែ ទៅ ។ ដល់ហើយខ្ញុំ ដូចថាឲ្យភូមិខ្ញុំណឹង១០០ម៉ែត្រ ដល់ហើយមកផ្ទះ ។ ធ្វើហើយវា អត់ឲ្យមក ។ អត់ឲ្យមកខ្ញុំរកកាប់ ផ្អើលឆោរឡោទាំងអស់គ្នា ។ វាក៏ឲ្យមកទាំងអស់គ្នា ប៉ុន្មានឃុំណឹង៣-៤ឃុំ ។

ឃីមៈ ជី បានវាអត់ឲ្យមក?

សនៈ ទុកឲ្យធ្វើទៀត វាកម្លាំងទៅដល់ហើយវាអត់ចង់ឲ្យកម្លាំងមកវិញទេ វ៉ាស់កម្លាំងទៅក្រោយវាពិបាកក្ដាប់មិនបាន ។ ម្សិលមិញ និយាយគ្នានៅវត្ត និយាយរឿងណឹង ។

D24969
(DC-Cam)
ចុះលេខថ្ងៃ 17-8-06

# មជ្ឈមណ្ឌលឯកសារកម្ពុជា
## បទសម្ភាសន៍ជាមួយរៀល សន នៅភូមិព្រៃតាលី ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ នៅថ្ងៃទី ២២ ឧសភា ២០០១

*ដោយ អែម សុខឃីម ប៊ុន និង ឡុងអូន*

ឃីមៈ នៅមជ្ឈមណ្ឌលឯកសារហើយមជ្ឈមណ្ឌលឯកសារមាននាទីចងក្រងរឿងខ្មែរក្រហ មនឹង ដែរយើងចាត់ទុកដូចជាប្រវត្តិសាស្ត្រអញ្ចឹងអ៊ំយើងចងក្រងម៉ាគន្លាក់ៗ ។ ខ្ញុំនឹង សរសេរ ខាងពេទ្យដោយពួសួរថាអ៊ំណឹងធ្លាប់ធ្វើពេទ្យសម័យខ្មែរក្រហមអញ្ចឹងខ្ញុំមកចង់ឲ្យ អ៊ំនិយាយ ប្រាប់ពីបច្ចេកទេសពេទ្យ របៀបគេប្រើថ្នាំម៉េចអីម៉េចណឹង តើរបនាសម្ព័ន្ធគេ យ៉ាងម៉េច ខ្លះ ។ អ៊ំ ចាំប៉ុណ្ណានិយាយប៉ុណ្ណឹង អត់ចាំក៏គ្មានបញ្ហាអីដែរអ៊ំ

សនៈ អត់ទេ ដូចគ្នាកាលអ្នកមកមុននិយាយអញ្ចឹងដែរ

ឃីមៈ អញ្ចឹង នេះសៀវភៅទស្សនាវដ្ដីនេះម៉ាខែចេញម្ដង គេពត៌មានផ្សេងៗ ។អ៊ំមានចាំឈ្មោះ ទេអ្នកណា ប្រហែលមកពីអង្គការជាមួយខ្ញុំ អ្នកណាគេមកសួរអ៊ំណឹង

សនៈ ខ្ញុំកត់យកទុកទាំងអស់ទៀត ប៉ុនសៀវភៅណឹងមិនដឹងនៅណា ភ្លេចបាត់ហើយ

ឃីមៈ កាលមកណឹងស្រី ឬប្រុស

សនៈ ប្រុស

ឃីមៈ ស្រុកកំណើតនៅតាកែវដែរ

សនៈ ស្រុកកំណើតនៅតាកែវ ឬក៏នៅកំពង់ត្រាចទេ ខ្ញុំភ្លេចបី បួនឆ្នាំហើយ ហីនេគាត់ធ្វើ សាស្ត្រាចារ្យនៅ សកលវិទ្យាល័យភ្នំពេញ

ឃីមៈ គ្រូជួន ដឹង?

សនៈ អូ ប្រហែលហើយ

ឃីមៈ គ្រូជួនហើយ កាលណឹងគាត់សរសេរខាងភូមិភាគនិរតី

សនៈ ណឹងហើយ

ឃីម៖ កាលណឹង ឆ្នាំ៩៥ គាត់ធាត់មុខរាងធំ

សន៖ បាទ

ឃីម៖ ប៉ុន្តែគាត់សរសេរអត់ទាន់ចប់ណា ឥឡូវពួកខ្ញុំតទៅវិញ តែគាត់សរសេររបៀបគ្រប់គ្រង ផ្សេង តែខ្ញុំខាងពេទ្យ ។ ហើយខ្ញុំចង់សួរអ៊ីខ្លះៗពីបញ្ហាពេទ្យណឹងគេប្រើម៉េច អ៊ីរៀបរាប់ តាំងពីចូលដំបូង តើបដិវត្តន៍គេបែកឆ្នាំណាៗ

សន៖ បាទ

ឃីម៖ មុនណឹងអ៊ំធ្វើអីគេ?

សន៖ ខ្ញុំនៅភូមិដល់ហើយនៅក្រោយទៅធ្វើជាងនៅស្រុក ១០៥ណឹង ដល់ធ្វើជាងស្រុកបានប្រ ហែលជាពីរឆ្នាំ ជាងម៉ាឆ្នាំ ចូលពីរឆ្នាំ ។ តាម៉ុកគាត់ឲ្យទៅធ្វើស្ពាននៅទំបន់ឧបត្របែកនេះ ហើយកំពុងតែធ្វើស្ពានណឹងស្រាប់តែប្រធានមន្ទីរ ស្រុក១០៥គេណឹង គេហៅខ្ញុំឲ្យទៅ កន្លែងមន្ទីរស្រុកណឹង ។ ខ្ញុំភ័យដែរកាលណឹង ព្រោះនៅអគ្គភាពជាងខ្ញុំ គេយកទៅដាក់គុក សំលាប់ចោលអស់ពីរបីនាក់ មានយកប្រុទ្ធ ឥឡូវម្នាក់យកប្រុទ្ធណឹង នៅធ្វើសាស្ត្រាចារ្យ បង្រៀនលោកសង្ឃនៅពុទ្ធកៈវិទ្យាល័យភ្នំពេញ ណឹងប្រុទ្ធឈ្មោះដួចគ្នាគាត់នៅធ្វើជាងជាមួ យខ្ញុំដែរ ។ ប្រាប់គេ ដូចថាមានខ្ញុំមានអីអញ្ចឹង ថាក្រែងប្រុទ្ធ ។ក្រោយមកពេលដែល ប្រធានស្រុកណឹងហៅខ្ញុំទៅកន្លែងមន្ទីរស្រុកទៅដល់ខ្ញុំឃើញមន្ទីរពេទ្យប្រហែលបីខ្នាន ។ មានថ្នាំពេទ្យគ្រប់មុខ ទាំងសារ៉ាង ទាំងស្តេតូ អាអាប់បារីតុស្តុងអីច្រើនណាស់ ។ ច្រើនមេនទែន ។ ដល់ហើយគាត់ប្រាប់ខ្ញុំថា គាត់មេជាងខ្ញុំ ឥឡូវមិនដឹងនៅណាទេនៅបាក់ ជើងម្ខាង ។គាត់មិនមែនប្រធាន ប្រធានមន្ទីរស្រុក ហើយគណៈស្រុកណឹងមាន ដោយឡែកទៀតឈ្មោះដឹម ។ បងដឹមនៅ ឥឡូវនៅអន្លង់វែង ។ ដល់គាត់ប្រាប់ថាបង ឯងចេះមើលអក្សរថ្នាំ ពេទ្យអីទេ បងឯងមើលហើយដាក់មុំៗ ហើយរើសសារ៉ាង អាប់បារីតុងស្តុង រើសស្តេតូណឹងដាក់ឲ្យត្រូវកំប្លេវា ដាក់មុំៗ ។ ខ្ញុំរើសដាក់ហើយ ។ហីថ្នាំ ដែលមានការចាំបាច់ប្រើរាល់ថ្ងៃដូចជាអាស្ពីរីន គែនីដង់អី តេត្រាស៊ីគ្លីនដាក់ម៉ាដុំ ៗ ។ អញ្ចឹងខ្ញុំដាក់មានថ្នាំអំពូលអីច្រើនណាស់ ។ ដល់ហើយស្រាប់គាត់សួរខ្ញុំថា នែអាថ្នាំ សំរាប់ ប្រើចាំបាច់រាល់ថ្ងៃអាណាខ្លះ ឲ្យដាក់មាឡាំងដាក់កេសៗហើយដឹកយមកវត្តចំបា៉ ។ ឲ្យខ្ញុំដឹក

យកមក ។កន្លែងណឹងមុនដំបូងពេទ្យស្រុក ។ ដល់គាត់ថាឲ្យយកមក គាត់ឲ្យយកសាវ៉ាង មកប្អូន ដប់ម្ភៃ មានអាតូចមានអាធម មានកំប្លេហ្វុងសំរាប់មាំពេទ្យ ។ ខ្ញុំអត់ដឹងគេឲ្យខ្ញុំធ្វើពេទ្យទេ ដល់មលដល់ណឹង គេឲ្យនៅណឹង អត់មានមនុស្សនៅណឹងផង ឲ្យចាំសម្ភារនៅណឹង ។ ខ្ញុំថាអានេះធ្វើម៉េចចេស ខ្ញុំអត់ដឹងទេ គេអត់មានប្រាប់ម៉េចទេ ។ អូ អានោះលាក់ការណាស់ច្បាស់ណាស់ ។ដល់ខ្ញុំនៅចាំណឹងបានបីថ្ងៃ ហូបបាយជាមួយសាលាឃុំគេណឹងស្រាប់ឃើញតាម៉ុកដឹកថ្នាំមកឡានអាកាត់ៗចិនណឹងពីរឡាន ។ ហើយថ្នាំពេទ្យទៀត យកមកដាក់ណឹង ខ្ញុំថាយី ខ្ញុំវរហើយ ។ ដល់ស្រាប់តែបី បួន ប្រាំថ្ងៃក្រោយមកសរសេរសំបុត្រមួយឲ្យខ្ញុំប្រាប់ថា ឲ្យខ្ញុំនេះចាំទទួលយុវជន៨នាក់ ។ ក្រោយណឹងមកខ្ញុំឃើញយុវជន៨នាក់មកដល់មែនទៅដល់សួរថាហ្អែងគេឲ្យមកណឹងមកធ្វើអី ថាអត់ដឹង គេឲ្យមកនៅជាមួយ អ៊ឹងឯណឹងហ្នឹងខ្ញុំឆ្ងល់អត់មានទឹកឃើញរឿងពេទ្យអីអាលីង ។ស្រាប់តែក្រោយទៀតឲ្យយុវជន៨នាក់ទៀត ។ហីប្រគល់ឲ្យតាៗពីនាក់ទៀត ។ តាៗណឹងម្នាក់ជាបក្សជន មិត្តពោតឡូវនៅក្បាលអូជាប្រធានឃុំ ។ ព្រោះគាត់ជាបក្សជន ខ្ញុំអត់ជាបក្សជនទេ ហេតុអីក៏ប្រគល់គាត់ណឹងមកឲ្យខ្ញុំហើយគាត់ណឹងជាបក្សជនល្អណាស់ ហើយប្រគល់មិត្តដូមកទៀត ។ដូណឹងចេះធ្វើពេទ្យ ។ខ្ញុំដឹងថាអូ ប្រហែលគេយកមិត្តដូណឹងមកឲ្យធ្វើពេទ្យព្រោះខ្ញុំមិនដែលធ្វើពេទ្យ ។ ដែលរៀនពេទ្យតិចតួចកាលពីដើមរៀនពីមិត្តភក្តិនៅជាពេទ្យនៅពេទ្យឃុំច្រើនកាលណោះ ។ យាមអីចេះដឹងអីប្រើថ្នាំអីតិចតួចណឹង ។ ដល់ថ្ងៃក្រោយមកណឹងបញ្ជូនអ្នកជំងឺទៅ នេះបញ្ជូនអាលន់យើងនេះនិងយាយប៉ាចបងប្អូនខ្ញុំ ខ្ញុំថា អូ អានេះគេដាក់ពេទ្យតើ ។ ដល់ក្រោយមកឲ្យទៅរៀន ។ណឹងក៏ខ្ញុំអត់ដឹងថាពេទ្យដែរ គ្រាន់តែសង្ស័យថាគេដាក់ពេទ្យហើយបានគេដាក់អ្នកជំងឺ ហើយអ្នកជំងឺនេះត្រូវជាបងប្អូនឯងទៀត ។ អាលន់ឈឺ ទៅដល់ខ្ញុំអត់ចេះមើលគេក៏អត់ចេះមើលបញ្ជូនទៅពេទ្យតំបន់នៅត្រពាំងអានាបឲ្យទៅមិត្តសី ។ លីសែងយកទៅនៅត្រពាំងអានាបណឹងទៅ វាគ្រុនចាញ់ ។ហីកាលណឹងខ្ញុំមិនដឹងថាគ្រុញចាញ់ ឬគ្រុនម៉េចទេ ដឹងតែឈឺ ។ ដល់ហើយចេះតែទទួលអ្នកជំងឺ គេបញ្ជូនអ្នកជំងឺ គេអត់មានប្រាប់ថាធ្វើពេទ្យអាលីងអត់ទាន់ បានអ្នកជំងឺប្រហែល២០នាក់ បានដឹងថាយើង ប្រហែលជាពេទ្យហើយ ប៉ុនមិនដឹងជាពេទ្យស្អីទេ ។ អត់ឃើញពេទ្យ ហីសុទ្ធតែអត់ចេះពេទ្យទាំងអស់គ្នា ។ប៉ុនអត់ចេះពេទ្យណឹង ពេលយកទៅបញ្ជូនទៅៗដល់ពេទ្យតំបន់ ។ ដល់ណឹងរក

ប្រជាជននៅជិតណឹង១ សែនទៅពេទ្យតំបន់យើងគ្រាន់តែធ្វើសំបុត្រខេទ្រុសនាមមួយថាទៅពីចំប៉ា ៗអញ្ចឹងគេចេះតែទទួល ដល់បានប្រហែលមាំខែជាងឃើញសំបុត្រគណៈស្រុកមួយសរសេរឲ្យខ្ញុំម្នាក់ឯងទៅរៀនពេទ្យមធ្យម កាលណឹងឆ្នាំ ១៩៧៦ ៧៧ ទៅរៀនបីខែ ពេទ្យបឋមដល់ ៗ ទៅរៀនណឹងចេស ខ្ញុំនៅនេះដដែល ទៅរៀនណឹងខ្ញុំជិះកង់ ទៅរៀនរាល់ថ្ងៃ ប៉ុនមកកន្លែងនេះ ៗ ទៅរៀននៅត្រពាំងអានាប ៗ ប៉ុនសីណឹងគាត់ពេទ្យប្រហែលជាអាំងពែកមាំញ៉ ក៏មិនដឹងអីក៏មិនដឹង ៗ គាត់ត្រូវគ្នាជាមួយខ្ញុំណាស់ ព្រោះកំរិតវិជ្ជាណឹងប្រហាក់ប្រហែលគ្នា ៗ គាត់នៅរស់ គាត់ខស្សាហ៍មកផ្ទះខ្ញុំណាស់ ឥឡូវគាត់នៅភ្នំពេញ

ឃីមៈ សីណឹងនៅរស់ទេ គាត់នៅម៉ុណា

សនៈ អត់ដឹងផ្ទះនៅភ្នំពេញដឹងផ្ទះនៅត្រាំខ្នា នៅខាងលិចផ្លូវ ខាងលិចដើមអំពិលកៀក យើទៅពីនេះទៅនៅខាងស្ដាដៃ នៅផ្សារហ្វង ទៅដល់ណឹងសួរគេទៅ ដល់អាដើមអំពិលក្អួយឯងទៅពីនេះទៅ អត់មានដើមអំពិលនៅចិញ្ចើមថ្នល់ទេ ក្នុងផ្សារណឹង ត្រង់ភ្លឺនៅត្រពាំងលិចណឹងមានដើមអំពិលមួយសួរថាពេទ្យសីនៅណាគេប្រាប់ ៗ ត្រាំខ្នា នៅស្រុកបាទី ខេត្តតាកែវ ៗ ប្រហែលគាត់អត់នៅណឹងទេ ព្រោះគាត់ទុក្ខសិចគាត់ ព្រោះប្រពន្ធគាត់គេយកទៅដាក់គុកគេវៃចោល ៗ គេយកទៅដាក់នៅសន្ទុងអី ទៅវៃថ្ម ទៅស្លាប់មិនដឹងស្លាប់ណា

ឃីមៈ ចុះសីណឹងគាត់អត់អី?

សនៈ សី ណឹង កាលនឹងគាត់ទៅរៀន មេឌីសាំងនៅភ្នំពេញ ៗគាត់ទៅរៀនបាត់គេចាប់ប្រពន្ធ ៗហើដល់ខ្ញុំនៅណឹងបានពីរខែជាងជិតបីខែ គេឲ្យមកនៅត្រពាំងគល់បានគេប្រាប់ថាពេទ្យស្រុក១០៥នៅស្រុកត្រាំកក់ណឹង មិនមែនខ្ញុំគ្រប់គ្រងពេទ្យទេ មាននារីម្នាក់ទៀតគេជាបក្សជន ៗ កាលណឹងខ្ញុំអត់ទាន់ចូលបក្សជនទេ គ្រប់គ្រង ៗ នារីណឹងនៅស្រុកកោះអណ្ដែតឈ្មោះនារីម៉េត នៅរស់ទេ មិនដឹងនៅឃុំអី ៗ នៅណឹងគេឲ្យទៅរៀនពេទ្យមធ្យម ទៅរៀនបានបីខែ ៗ រៀនជាមួយបងសីណឹងទៀត ពេលបងសីត្រលប់មកពីរៀននោះមកវិញ ៗ

ឃីមៈ អ៊ំអត់ដែលទៅរៀននៅភ្នំពេញទេ?

សនៈ អត់ទេ ៗរៀនពេទ្យមធ្យមណឹងហើយចប់មកនៅវិញបានមាំឆ្នាំ

ឃីមៈ រៀនពេទ្យនៅឆ្នាំណា?

សនៈ នៅឆ្នាំ ១៩៧៧ ៧៨ ណឹងក្រោយគ្នាតិច រៀនជាប់គ្នា ៗអាណឹងមកនៅនេះជាប់ហើយ ចង់ដឹងពីរឿងសកម្មភាពធ្វើថ្នាំអីណឹង

ឃីមៈ ចាំ

សនៈ ធ្វើថ្នាំចេសទេ ធ្វើថ្នាំកាលណឹងតាម៉ុកគាត់មានលុយ គាត់ឲ្យខ្ញុំទៅទិញមេថ្នាំ ពីស្រុកយួនមានមេកង់ហ្វូ មេកាល់ស្យូម មេជូ កាលណឹងនៅស្រុកយើងនេះអត់មាន គ្រប់មុខ គាត់ឲ្យថ្ងៃខ្លួនឯងមាំចំនួនណា

ឃីមៈ ចុះម៉េចគេទិញអញ្ចឹងកាលសម័យអាពតគេអត់ចាយលុយ?

សនៈ ពីដំបូង ឆ្នាំ៧៦ ៧៧នៅមានចាយលុយលន់ ណុល ដល់ពេល លន់ ណុល រត់ណឹងបានគេលែងចាយ ខ្ញុំទៅចាយលុយនៅ

ឃីមៈ ឆ្នាំ៧៥គេបែក ១៧មេសាគេបែក

សនៈ បាទៗ លន់ ណុលរត់ ខ្ញុំទៅជាប់នៅបាក់ដៃណឹង លុយពីរបាវក្រដាស ៥០០អាខៀវៗណឹង ចាក់ចោលក្នុង គេឈប់ចាយ ទៅដល់យួនដឹងឯងអត់ដឹងមុនៗ យួនក្មេងជាងអាអូននេះតិចឈ្មោះអាគីក អាគីកថា អូ ពូសនអត់ដឹងលន់ ណុលរត់ ខ្ញុំអត់ដឹង កាលទៅណឹងណាត់គ្នាហើយ ថ្នាំមាំកាណូត

ឃីមៈ អញ្ចឹងមុនបែកតិច

សនៈ មុនបែក នល់ ណុលតិចណឹង ដល់ត្រលប់មកវិញក៏បានថ្នាំពេទ្យមក

ឃីមៈ ចុះធ្វើម៉េចបានថ្នាំពេទ្យមក

សនៈ ខ្ញុំបោកយួន កាលណោះសមណាស់ ខ្ញុំដឹងថាយួនវាចង់បានអាផ្លែអូញមូញនោះៗ អាផ្លែណឹងគេយកធ្វើប៊ីយែ អាចឹងខ្ញុំជិះចុះកាណូតពីអន្លុងកន្ទែងពីពាណិជ្ជកម្មតំបន់គេណឹង ឃើញផ្លែអូញម៉ូញគេច្រើនណាស់ ឃើញផ្លែតែពីរដើម ក៏ប្រាប់អញ្ចឹងៗខ្ញុំថាអញ ទៅវិញហើយ អញចាក់លុយណឹងចោលហើយ ហ្អែងមិនបាច់ដុតទេ អញទៅដឹកផ្លែណឹងមកអញទៅត្រីនអន្លុងរទេអញមកវិញហើយៗ ពូហ្អែងទៅដឹកអីគេ អញទៅដឹកផ្លែអូញមូញព្រោះផ្លែអូញមូញនៅណឹងពីរទូកៗ វាថាបើផ្លែអូញមូញនៅណឹងពីរទូក មិនបាច់ទេ ពូឯង

យកថ្នាំពេទ្យណឹងមកហ្នឹង មិនមែនតែថ្នាំពេទ្យទេ មានរកណាតលីឡុងខ្មែរអង្រឹង សម្ភារអី តាមគេកំម៉ង់ ។ មន្ទីរតំបន់អ្នកកំម៉ង់ កាលនៅចាយលុយទៅយកពីតាម៉ុក ដល់ក្រោយ មកខ្ញុំទៅបោកយួនបានមាំនេះណឹងមក មកប្រាប់តាម៉ុក តាម៉ុកថាហ្នឹងប្រយ័ត្ន ជាមួយ យួន ហ្នឹងទៅធ្វើអីផ្ដេសផ្ដាសអញ្ចឹង ។ ខ្ញុំថាពូឯងទៅយកអីទៅសងវាទៅអាគីក

ឃីមៈ ចុះមានយកអីទៅឲ្យគេ?

សនៈ មានផ្លែអូញមូញណា ផ្លែអូញមូញផ្លែពីរដើមណឹងប្រហែលដប់

ឃីមៈ អញ្ចឹងទេ ថាពីរទូក កុហកយួន

សនៈ កុហកវា

ឃីមៈ អូ ខ្ញុំស្មានតែនិយាយមែនទែន

សនៈ អាណឹងខ្ញុំនិយាយពីសកម្មភាពទៅទិញថ្នាំមេថ្នាំជាពិសេសចង់បានមេថ្នាំ ។ កាលណឹង កាល់ ស្បូមទិញម្ដង ៣០គីឡូ ឲ្យលុយវា វាថាប៉ុន្មានឲ្យវាប៉ុណ្ណឹង ហីពេលទៅអត់លុយ ជួនកាល ទៅយកជ្រូក៣០ ៤០ក្បាលនៅស្រុក៥៥ ស្រុកព្រៃកប្បាស បួនតាម៉ុក ធ្វើគណៈ ស្រុក ឈ្មោះចុង ។ គ្រាន់តែទៅប្រាប់ថា តាឲ្យយកជ្រូកមាំនក្បាលអញ្ចឹង គោ គាត់ឲ្យ ហើយដេញទៅ ដេញទៅដល់ប្រគល់ឲ្យយួន ហើយយកឥវ៉ាន់មិនដែលគិតថាអានេះថ្លៃ ប៉ុន្មានៗ

ឃីមៈ អូ យួនចំណេញណាស់ យើងស្រុកសង្គ្រាម

សនៈ អូ មិនបាច់ទេ ធ្វើម៉េចឲ្យតែបាន អាណឹងនិយាយពថ្នាំ ។ ថ្នាំមាំចំនួនទិញមកហ្នឹង ទិញថ្នាំ អំពូល តែអាណាចាំបាច់ដូចជាថ្នាំណាដែលយើងអត់មានមេ ដូចជាអីត្រូប៉កឌីហ្សូន ដូច ជា អ៊ូអាប៉ាកអ៊ីន អាថ្នាំសង្គ្រោះ ទិញគេមកហ្នឹងសំរាប់ទ័ព

ឃីមៈ ចុះមានចិនជំនួយមកដែរ?

សនៈ ចិនដល់ក្រោយមក ដល់ក្រោយមកដឹកមកតាំងឡាន១ហ្នឹង ថ្នាំចិននេះខ្ញុំមកនៅត្រពាំងគល់ ណឹង ថ្នាំចិនពេញឃ្លាំងហ្នឹង ។ ។កាលណឹងបែកលន់ ណុល ដឹកមកយកមកច្រើន ដូច ថាបីឡាន កាត់ចិនមក ហៅពេទ្យឃុំមកចែកបានមាំឡាំងម្នាក់ ជាង១០ឃុំ ១២ឃុំកាល ណឹង មាំស្រុក ។ ឥឡូវមានតែដប់ឃុំទេ ។ ១២ ឃុំណឹងមកចែកបានពីឡាំង បីឡាំងម្នាក់

យកទៅដល់ឃុំទៀត បានតិចណាស់ ប៉ុននៅខ្ញុំច្រើនមែនទែន ។ នៅខ្ញុំនេះសំបូរតែស្រា សំបូរមែនទែន ស្រា បិត ស្រាអេស្កាដេនៅភ្នំពេញ ដឹកយកមកឲ្យ ជួនកាលដឹកមក បីពាន់លីត្រអីវ៉ាន់ ។ស្រាហិនស៊ី ស្រាគ្រប់ម៉ាកច្រើន។ ប៉ុនខ្ញុំអត់ចេហហូបស្រាទេ កាល ណឹងចេកសំរាប់អ្នកកូនងែត ម៉ាចំនួនណាដែលគ្នាយ៉ាប់ពេកស្រាណឹង ។ ចែកតាមលទ្ធភា ពជាពិសេសចែកឲ្យឃុំ យកមកដូចថាច្រើនណាស់បីពាន់លីត្រ ដល់ចេក១២ឃុំបានតិចម្នាក់ ខ្ញុំបិទតែខ្លួនឯងទេ ម៉ាថ្ងៃបិទបានបីធុន ។

ឃីមៈ ពេលអ៊ំទៅយកថ្នាំមកម៉េចទៀតអ៊ំ?

សនៈ យកមកធ្វើយើងលាយ យើងបិទមានរូបមន្តគេ យើងបិទទឹកសំរាប់លាយណឹង បិទខ្លួនឯង មានឆ្នាំងមានអី

ឃីមៈ បិទប្រភេទថ្នាំអីខ្លះ?

សនៈ បិទតែទឹកលាយទេ

ឃីមៈ ទឹកយើងធម្មតាណឹង

សនៈ បាទ យើងបិទទឹកណឹង ខ្ញុំបិទមិនដូចគេទេ នៅពេទ្យគេ គេបិទត្រឹមតែអាអូឌីស៊ីស៊ីលេណឹង ខ្ញុំឌីស៊ីស៊ីលេ ហើយបានយកលាយនៅកន្លែងខ្ញុំ

ឃីមៈ ឌីស៊ីស៊ីលេ មានន័យម៉េច?

សនៈ អាអូឌីស៊ីស៊ីលេគេបិទតែម្តងទេ ដល់ឌីពីរយកអាណឹងទៅបិទម្តងទៀត អញ្ចឹងថ្នាំខ្ញុំមានគុណ ភាព នៅកំពង់សោមអីមកយកថ្នាំពីខ្ញុំ

ឃីមៈ សំរាប់ជំងឺអី?

សនៈ មិនដឹងជំងឺអីទេ ឲ្យតែគេត្រូវការ ប៉ុនមិនមានច្រើនមុខទេ មានកាល់ស្យូម មានបេឌូ មានបេអង មានកងហ្វូ មានអ៊ីដែលខ្ញុំទិញមេពីគេបានមក សារ៉ូមផ្អែម សារ៉ូមប្រៃខ្ញុំធ្វើខ្លួន ឯង ។

ឃីមៈ សារ៉ូមផ្អែមធ្វើម៉េច?

សនៈ សារ៉ូមផ្អែមទិញមេគេមក ។សារ៉ូមប្រៃខ្ញុំធ្វើខ្លួនធ្វើពីអំបិលស្ងោរអំបិលពីរបីដង អំបិលដូចអំបិលអានាម័យគេឥឡូវយកមក ។ ប៉ុន្តែខ្ញុំធ្វើពីរបីដង ធ្វើក្នុងបន្ទប់ស្អាតណាស់ ។

ឃីមៈ មានប្រដាប់បិទ តើយកមកពីណា?

សនៈ មាន ខ្ញុំធ្វើខ្លួនឯងខ្លះ

ឃីមៈ ធ្វើបិទស្រាអញ្ចឹង?

សនៈ ដូចអញ្ចឹង ប៉ុន្តែខ្ញុំធ្វើស្អាតមែនទែនកន្លែងណឹង ខ្ញុំធ្វើស្អាត

ឃីមៈ ចុះអីមានចាំរបៀបធ្វើទេ ធ្វើលក់អីបានទេ?

សនៈ កាលមកមុនដំបូងធ្វើ ខ្ញុំហូតអំពូល ប៉ុនអាអំពូល Local ណឹង មិនមែនអំពូលផ្ទាស់ស៊ិចដូចគេណា

ឃីមៈ បានមកពីណាអំពូល Local ណឹង

សនៈ ធ្វើខ្លួនឯងស្លអំបែងដបហើយផ្លុំរួចកាត់មានអាប្រដាប់ដាំងមាសសំរាប់កាត់ អាស្នប់សំរាប់រំលាយ ណឹងយកមកកាត់ ។

ឃីមៈ យើងយកអំបែងស្លរំលាយអី?

សនៈ រំលាយ កាលណារលាយយកមកផ្លុំ យើងមានដែកមួយប្រហោង ទុយោ ដល់កាលណាយើងមើលថាល្មមហើយដែក យើងក្លុំវា យកអាដែកប្រហោងណឹង ដល់ក្លុំទៅវាប៉ោងហើយទាញមក វាវែង ធ្វើក្នុងបន្ទប់ជិតធ្វើបានវែង។ បើចង់បានខ្លី យើងយកអំបោះមកកាត់ ។ ស្អាតប៉ុនស្រួច។ អាផ្លាសស៊ិចគេធ្វើជាមួយជីឡាច់ ខ្ញុំអត់ចេះធ្វើ ។

ឃីមៈ អីអ្នកធ្វើថ្នាំអត់មានដឹងថា អាណឹងយកមកសំរាប់ព្យាបាលអីទេ?

សនៈ សារ៉ូមប្រៃយកទៅព្យាបាលអ្នកកើតរាគរូសច្រើន អ្នកលើសឈាម

ឃីមៈ ចុះសារ៉ូមផ្អែម បេអូ បេអង យកមេមកពីវៀតណាមមក

សនៈ យកមកដាក់អំពូល

ឃីមៈ ចុះគេស្លម៉េចអីអាបេខូអីណឹង?

សនៈ	អត់ទេ យកមេមកដាក់លាយជាមួយទឹកបិទ ឌីស៊ីស៊ីលេណឹង ។ បើបិទតែម្តងទុកបានគេបួនដប់ថ្ងៃវាអាចកករ ។បើបិទពីរដងទុកបានបីខែ អត់អី ។

ឃីមៈ	អូ អញ្ចឹងថ្នាំគេកំណត់ថ្នាំគេ?

សនៈ	បាទៗ ដល់មាំឆ្នាំទៅជួបជុំគ្នាម្តងនៅពេទ្យតំបន់ និយាយគ្នាពីរឿងធ្វើថ្នាំពិសោធន៍ ។ ប៉ុន្តែខ្ញុំដឹង ខ្ញុំវាយតម្លៃថា អូមិនកើតទេ រឿងរបបប៉ុល ពតណឹងធ្វើថ្នាំមិនកើតទេ ព្រោះសន្សំសំចៃណាស់តាមខ្ញុំរៀនសូត្រខាងអាបាម៉ាស៊ីណឹងវាត្រូវការលុយច្រើនណាស់ ទាល់តែទិញសម្ភារឲ្យបានធ្វើកើត ។ ដូចខ្ញុំចង់ធ្វើអំពូលថ្លាសលស៊ុចណឹងដីខ្សាច់មានស្អីៗច្រើនណាស់ ហើយដីខ្សាច់ស្រុកយើងនេះអត់ធ្វើបានទេ ទាល់តែយកមកពីមាត់សមុទ្រអាម៉ាត់ ។ ចង់ធ្វើអីទៀតច្រើនដែរ ដល់ខ្ញុំនិយាយទៅគេថាមិនកើតទេ គ្មានស្អីធ្វើទេ យើងលើកប្រាប់គេ ។ ពេលលើកឡើងគេវាយតម្លៃសតិអារម្មណ៍ ខ្ញុំគេវៃតម្លៃជាងគេគឺខ្ញុំថាសតិអារម្មណ៍អនុធនសតិអារម្មណ៍ បញ្ញាវ័ន្តអញ្ចឹង មិនមែនកម្មករ ។កម្មករគេច្នៃប្រឌិត គេធ្វើខ្ទួនគេអីខ្ទួនគេ ។ ប្អូនឯងគិតមើលបើចង់ធ្វើឲ្យវាវិទ្យាសាស្ត្រ ទៅច្នៃម៉េចកើតយើងចំណាស់ណោះហើយ ។ បើចង់ធ្វើអីមួយទាល់តែយើងប្រមូលគ្នាមិនពឹងគេម៉េចទៅ ។ ទាល់តែរៀនដល់ណាដល់ណី ។ គេវៃតម្លៃអីក៏វៃទៅ

ប៉ុនៈ	ពេលដែលអ៊ំយកមេថ្នាំមកពីវៀតណាម អ៊ំយមកមកផលិតនោកន្លែងអី?

សនៈ	នៅមន្ទីរពេទ្យ

ប៉ុនៈ	មន្ទីរពេទ្យណឹងនៅឃុំអី?

សនៈ	នេះនៅក្នុងសាលាឃុំត្រពាំងធំខាងជើងណឹង អាសាលាឃុំណឹង កន្លែងធ្វើថ្នាំ ស្អាតរបស់ខ្ញុំណាស់ ខ្ញុំដាក់ម៉ាស៊ីនត្រជាក់ទៀត ។ ខ្ញុំមកពីរត់វិញម៉ាស៊ីនត្រជាក់ណឹងនៅ ម៉ាស៊ីនភ្លើង ក៏នៅដែរ

ប៉ុនៈ	សាលាឃុំណឹងនៅក្នុងភូមិអី?

សនៈ	នៅភូមិអង្គត្រាវ

ប៉ុនៈ	ឆ្នាំណាដែលអ៊ំផលិតថ្នាំ?

សនៈ តាំងពី ៧៨ រហូត ដល់រហូតរត់ទៅលាយថ្នាំនៅភ្នំក្រវាញទៀត ទៅបិទស្រា បិទអីឲ្យតាម៉ុកណឹងឆ្នាំ៧៩ណឹង ។ យាយណឹងស្ដីឲ្យខ្ញុំយាយណឹងវៃធូងអស់ណឹងចោល ៗកុំយាយវៃចោល

ឃឹមៈ ម៉េចអ៊ំត្រឡប់មកស្រុកវិញ?

សនៈ យី អស់អីហើយ ពេទ្យធ្វើថ្នាំណឹងនៅ ៤ ៥ ៧នាក់ ហីអង្គនៅសល់អង្ករបីបាវបបួលគេមក គេអត់មកគ្រប់គ្នា ខ្ញុំចោលរទេះចោលគោមក ៗទៅដល់ស៊ឹងខៀវណឹងតាម៉ុកថា ហ្អែងកុំទៅនៅធ្វើថ្នាំចាក់ឲ្យយុវជន ៗយុវជន៤០០នាក់យកចេញពីភ្នំពេញខ្ញុំធ្វើថ្នាំឲ្យទាំងអស់នៅក្នុងព្រៃណឹង ។ ខ្ញុំលាយថ្នាំ ទៅមើលឡានមកពីភ្នំពេញទៅខ្វះអីមេថ្នាំមេថ្នាំអាពេញឡានហ្នឹង

ប៉ុនៈ ក្រោពីពូធ្វើថ្នាំហើយ ពូមានព្យាបាលអ្នកជំងឺ?

សនៈ មកព្យាបាលអ្នកជំងឺនៅមន្ទីរពេទ្យណឹងត្រពាំងគល់ណឹង មន្ទីរពេទ្យស្រុក១០៥ នៅឆ្នាំ៧៧ ៧៨ ណឹងរហូតទល់បែក បររទេះចេញពីពេទ្យណឹងហ្នឹង

ប៉ុនៈ ប្រភេទជំងឺច្រើនជាជំងឺអី?

សនៈ ច្រើនតែរាគរុសច្រើនជាងគេ ខ្វះជីវជាតិ ។ ខ្ញុំលើកឡើងនៅកន្លែងសន្និបាតថាខ្វះជីវជាតិគេថាខ្ញុំវៃប្រហារអង្គការ វៃប្រហារសហករណ៍គេ ៗខ្ញុំថាមិនដឹងវៃប្រហារម៉េចទេលោកម្ចាស់ថ្ងៃហើយ ។ ខ្ញុំថាអញ្ចឹងមែន អ្នកណាមិនថាហីទៅ ហីខ្ញុំពេទ្យចាស់ជាងគេមានតែប៉ុន្មាន នាក់ ។ ហីឲ្យអ្នកជំងឺគ្មានអ្នកណាជាងខ្ញុំ ខ្ញុំឲ្យសាច់ជ្រូក ឲ្យសាច់គោ កាប់គោមួយស្ងួបានពីបីថ្ងៃ សព្រលិតអីនាយអាយណឹង កន្លែងពេទ្យស្រុក១០៥ណឹងមានហូបលើសគេជាងពេទ្យនានា ។ ប៉ុនកន្លែងខេត្តផ្សេងខ្ញុំមិនដឹង ។ ពក់ចឹកអីណឹងគេបញ្ជូនមកឲ្យខ្ញុំដូចថាពេទ្យតំបន់ពេញអស់ ។

ប៉ុនៈ ទាហានមកពីខាងណា?

សនៈ ទាហានប៉ុល ពតណឹង ទាហានទ័ពតំបន់អីដែយមកមកពីណាពីណីអីណឹង កាលណឹងឲ្យតែអ្នកណាគេខ្លាំងជាងគេឬកន្លែងណាខ្លាំង គេយកមកវៃនៅណឹង ។ អញ្ចឹងយើងមិនសន្និដ្ឋានថាទ័ពមកពីណាពីណីទេ ។

ប៉ុនៈ អ៊ំថា ធ្លាប់ធ្វើពេទ្យនៅត្រពាំងគល់ តើមន្ទីរពេទ្យឃុំណា

សនៈ យកវត្តណើងធ្វើពេទ្យហ្នឹង វត្តត្រពាំងគល់មានលក្ខណ៍ វិហារថ្មីវាគេធ្វើហើយ កាលដែលខ្ញុំនៅណើងអត់មានវិហារទេ មានតែសរសរទេ

ប៉ុនៈ តើអ្នកជំងឺនៅសំរាកណើងរយៈពេលយូរឬក៏ បានមកសំរាកព្យាបាលម៉ាភ្លែត

សនៈ អត់ទេ នៅសំរាកទាល់តែជា អាខ្លះដូចថាពេទ្យឃុំយកមកផ្ញើពេទ្យក៏ស្លាប់នៅណើង ខ្លះអាចយកទៅពេទ្យតំបន់ណើងវារស់បញ្ជូនទៅពេទ្យតំបន់នៅត្រពាំងអានាប ។ ដល់ក្រោយមកគេយកមកដាក់នៅសាលាដើមចំបក់នេះខាងក្រោម

ប៉ុនៈ មានស្លាប់ទេនៅក្នុងមន្ទីរណើង?

សនៈ ស្លាប់ មុនដំបូងស្លាប់រង្វើល១ ដល់យូរទៅស្លាប់ច្រើនណាស់សុទ្ធតែជំងឺរាគ ជំងឺខ្វះជីវជាតិ

ប៉ុនៈ ចុះបានមេថ្នាំមកតាំងពីវៀតណាមព្យាបាលអត់ជា?

សនៈ អត់ទេ គ្មានមេថ្នាំណាជួយជំងឺខ្វះជីវជាតិទេ ។ មានបងប្អូននៅភ្នំពេញយកមកដល់នេះគ្រីប ខ្ញុំអត់បញ្ហា ខ្ញុំនិយាយពីធ្វើបដិវត្តន៍ហូបបាយរឹងកាលណើងក្នុងប៉ុន្មានឆ្នាំ ធ្វើជាគេណើងហូបបាយរឹងបានប្រហែល១ខែចុះ ខ្ញុំហូបបបរជាមួយសំលព្រលិត ខ្ញុំធ្លាប់នៅនេះមានអ៊ីប៉ុនអ្នកមកពីភ្នំពេញ ជួយម៉េចក៏ជួយមិនបានដែរ ។ យើងធ្វើម៉េចបើគេសួរមូលហេតុស្លាប់ច្រើនមកពីប្រធានពេទ្យមិនសូវគិតគូ ខ្ញុំថាគិតគូ ប៉ុនខ្វះជីវជាតិតើឲ្យពេទ្យទៅធ្វើម៉េច ។ និយាយរួមខ្វះជីវជាតិ ស្លាប់ជំងឺរាគ ដល់ចុងក្រោយបំផុតស្លាប់ម៉ាថ្ងៃ៩នាក់ ហើយប្រុសមិនសូវទេ

ឃីមៈ ស្លាប់ម៉ាថ្ងៃ៩នាក់ នៅឆ្នាំណា?

សនៈ ឆ្នាំ ៧៨ ចូល៧៩ ណើង ដល់៧៩ណើងបន្តិចហើយ តាមពេទ្យឃុំសែងមកដល់ស្លាប់ឲ្យវាសែងទៅវិញវាមិនសែងទេ ទុកឲ្យខ្ញុំកប់ណើង លោកម្ចាស់ថ្ងៃហើយ

ឃីមៈ ចុះកាលដំបូង អ៊ំចូលបដិវត្តន៍ឆ្នាំណា?

សនៈ ឆ្នាំ៧៥

ឃីមៈ ចុះមុនណើងគេឲ្យអ៊ំធ្វើអី?

សនៈ អត់ទេ កាលមុនជាកម្លាំងសំងាត់

ឃីមៈ ចុះកាលនៅឆ្នាំ៧២ ៧៣ អ៊ំធ្វើអី?

សនៈ ធ្វើស្រែណឹង

ឃីមៈ អ្នកណាគេអ្នកកាន់កាប់ ឈ្មោះអីប្រធានតំបន់កាលឆ្នាំ៧២ ៧៣ ៧៤ មុនរំដោះ៧៥?

សនៈ កាលណឹងមានតែតា១ប៉ុន្មាននាក់ណឹង មិនទាន់ដឹងមុខដឹងមាត់ជាស្អីទេ មានតែតាម៉ុក

ឃីមៈ កាលណឹងតាម៉ុកម៉ាភូមិភាគឬម៉ាតំបន់?

សនៈ កាលណឹងម៉ាភូមិភាគ

ឃីមៈ ចុះតាមតំបន់មួយៗអ្នកណា?

សនៈ តាមតំបន់បងសោមស្លាប់ នៅតាម៉ុត តាម៉ុតណឹងនៅភ្នំពេញរាល់ថ្ងៃ ផ្ទះសុទ្ធគេនៅនេះ នៅជីតៗនេះទាំងអស់

ឃីមៈ អូ ផ្ទះសុទ្ធតែនៅតាកែវ ។ ចុះហេតុអីនៅភូមិភាគនិរតីណឹងសុទ្ធតែអ្នកបដិវត្តន៍ច្រើនម៉េស

សនៈ ក្មួយ និយាយពីដើមទី ក្រោយពីខ្ញុំការហើយ ខ្ញុំឈប់រៀន ប្រលងឌីប្លូមធ្លាក់ឈប់ម៉ាឆ្នាំ នៅឆ្នាំ ១៩៥៩ ខ្ញុំឈប់នៅភ្នំពេលម៉ាឆ្នាំ ហើយខ្ញុំមកការជាមួយយាយ ។ ការហើយខែណឹង ខ្ញុំមិនចេះក្បួរអី ខ្ញុំក៏ទៅធ្វើកាំបិតនៅផ្ទះចាមផ្សារអន្ទរកា ខ្ញុំក៏ឃើញខៀវ សំផន នៅណឹង ។ ខៀវសំផនណឹង ខ្ញុំជាអ្នកទូលនំទៅការគាត់ ធ្វើនំបារាំងទៅការឲ្យគាត់

ឃីមៈ ចុះប្រពន្ធគាត់នៅណា?

សនៈ ប្រពន្ធគាត់ជាលេខាដាក់ទឹឡូគាត់

ឃីមៈ អូ ថាខៀវសំផនអត់ប្រពន្ធ?

សនៈ ចាំតែអត់តើ ខ្ញុំពីរនាក់ប្រពន្ធតាម៉ុក យាយខឹម

ឃីមៈ ឈ្មោះអីប្រពន្ធខៀវសំផន?

សនៈ អត់ស្គាល់ឈ្មោះ ភ្លេច

ឃីមៈ អូលេខាគាត់ហ្នឹង តើស្អាតទេ អ៊ំ?

សនៈ គួរសមដែរ ។ ក្មួយដឹងម៉េចទេ ខ្ញុំនិយាយដើមខ្សៀវសំផនតិចចុះ កូនគាត់មកឆ្លតទាំងអស់ កនឆ្លត ឥឡូវណឹងក៏មាននៅដែរ ប៉ុនមិនដឹងនៅណា នៅប៉ៃលិនខ្ញុំអត់ដឹង

ឃីមៈ ម៉េចចឹងបានឆ្លត

សនៈ ក្មួយឯងសួរមើល កូនខ្សៀចសំផនឆ្លត

ឃីមៈ ហេតុអីបានកូនឆ្លត?

សនៈ ដឹងអី ខ្ញុំអត់ដឹងដែរ

ឃីមៈ ខ្ញុំទៅសម្ភាសន៍យាយវុធ គាតប្រាប់ថា ខ្សៀវសំផន ដាច់ពងពាក់កណ្ដាល

សនៈ ក្មួយឯងកុំជឿ នេះខ្ញុំនិងខ្សៀវសំផន ខ្ញុំដឹងច្រើនថ្ងៃដែលពីសង្គមចាស់ សង្គមសីហនុយូរ ហើយ ថ្ងៃដែលគេវៃខ្សៀវសំផនសំរាគណឹង

ឃីមៈ ឆ្នាំណាកាលណឹងវៃសំរាគណឹង?

សនៈ ខ្ញុំអតដឹងទេ ខ្ញុំនៅក្មេង ខ្ញុំនៅយូរបានស្រាក់សំរាប់ផ្ទះ សារិនឆាក សារិនឆាក ក៏គាត់មក នេះដែរ កាលចេញតស៊ូ ហើយប្រពន្ធគាត់និងខ្ញុំនេះគឺថា វៃក្បាលគាជិតសិទ្ធ

ឃីមៈ ចុះគេវៃខ្សៀវសំផនម៉េចខ្លះ?

សនៈ ថ្ងៃដែលគេវៃណឹង វៃសំរាគខោអាវខ្ទេចខ្ទីរអស់អាលីង

ឃីមៈ កាលណឹងរឿងអី?

សនៈ កាលណឹងគេស្អប់ក្រហម មិនដឹងអ្នកណាអ្នកវៃ ខ្ញុំនៅក្មេងតូចវៃសំរាគ ពងក្ដដើរទៅឆ្កុយ អញ្ចឹងចេះតែដើរទៅ ដើរទៅអ្នកសីក្លូរត់យកក្រមាមកឲ្យ គាត់ក្រវ៉ាតចោល ខ្ញុំឃើញនៅ តាមផ្លូវ

ឃីមៈ អញ្ចឹងគេវៃហើយ គាត់ដើរឲ្យគេមើលហ្នឹង

សនៈ បើសំរាគហើយ មិនដឹងអាម៉េចបើខ្ញុំនៅក្មេងក៏អត់ចាប់អារម្មណ៍ ហើយខ្ញុំមកបួសមក ហើយកាត់មកណោះ ។ ដល់ក្រោយមកខ្ញុំដឹងថាខ្សៀវសំផន មនុស្សអន់

ឃីមៈ អន់ម៉េច អ៊ំ កាត់សុទ្ធតែមកពីស្រុកបារាំងសរសេរសៀវភៅ

សនៈ ខ្ញុំដឹង ខ្ញុំវែកមៃ្មខៀវសំផន អន់កាលនេះ កាលណឹងខ្ញុំធំហើយ ទៅប្រឆាំងគ្នាជាមួយរបបសីហនុ ដែលសាច់គោឡើងថ្លៃ អាចឹងគេមិនឲ្យគាត់ធ្វើរដ្ឋមន្ត្រីពាណិជ្ជកម្ម ធ្វើបានបីខែគាត់រត់ចុះខ្លួនឯងធ្វើមិនកើត ។ អញ្ចឹងបានខ្ញុំថាគាត់អន់

អូនៈ ប្រហែលជាគាត់មានមូលហេតុបានគាត់ចុះចេញពី?

សនៈ ប្អូន មិនងាយធ្វើបានទេ មនុស្ស គ្រប់គ្រងមនុស្ស ។ ខ្ញុំធ្លាប់គ្រប់គ្រងមនុស្ស កាលពីមុនគេថាឲ្យធ្វើប្រធានក្រុមកើត ធ្វើមេភូមិកើត មេឃុំក៏កើត ធ្វើមេស្រុកក៏កើត ធ្វើចៅហ្វាយខេត្តក៏កើតដែរ ។ខ្ញុំនៅភូមិនេះតាំងពីដើមមកខ្ញុំគ្រប់គ្រង ខ្ញុំអត់ធ្វើមេភូមិទេ ប៉ុនប្រជាជនគេស្តាប់ខ្ញុំ គេមិនខ្លាចទេ គេស្តាប់ហ្នឹងគេគោរព បានខ្ញុំទៅគ្រប់គ្រងនៅបុស្តិ៍នៅឃុំត្រពាំងយោងទៅពីរឆ្នាំទំរាំគ្រប់គ្រងបាន មិនធម្មតាមនុស្ស

ឃីមៈ ម៉េចបាន អ៊ីយល់ថាខៀវសំផនអន់?

សនៈ អន់មកពីគាត់ធ្វើមិនកើត?

ឃីមៈ ក្រែងគាត់មានមូលហេតុស្អប់របបសីហនុអីទេ អ៊ី?

សនៈ បើស្អប់ធ្វើកាច់ឲ្យប្រាវទៅ អាណាគេមិនស្អប់ តែគេគ្មានលទ្ធភាព ណឹងហើយរបបមួយៗមិនមែនពេញចិត្តទាំងអស់គ្នាទេ ក្នុយឯងជឿទេខុត្តមគតិផ្សេងគ្នា អញ្ចឹងអត់ទេ ។ បើអញ្ចឹងធ្វើកាច់ឲ្យភឹង ឲ្យគេឃើញមើល គេគាំទ្រ ។ ខ្ញុំមិនចង់និយាយទេ ខំគាំទ្រសឹងអី

ឃីមៈ ដល់ពេលក្រោយពីវៃតើខៀវសំផនទៅណា?

សនៈ ដើរទៅខ្ញុំមិនដឹងទៅណា ខ្ញុំមកនេះមក

ឃីមៈ ហេតុអីបានជួបគាត់នៅនេះឆ្នាំណា គេការឲ្យ?

សនៈ ជួបគាត់មកដកាំបិត ដល់ក្រោយមកខ្ញុំមិនបានឃើញប៉ុនបងប្អូនខ្ញុំនៅនេះ គាត់ជិះដីរទៅគេ រកចាប់ ។អូ ប្រវត្តិតស៊ូនៅនេះបានខ្លាំង ខ្លាំងណាស់ ខ្ញុំណឹងហើយអ្នកទទួលបងប្អូនមកពីភ្នំពេញនៅត្រង់នេះ ពួកអ្នកបដិវត្តន៍ មកដុះពោះធំស្អុយៗបណ្តើរកូន ហ៊ីៗ សឹងតែស្រែកយំស្តាយមនុស្ស កូនរកមុំឲ្យស្អាតៗមក ហើយទៅបាត់ៗ ។ ខ្ញុំហើយអ្នកទទួលណឹងអានេះវាអញ្ចេស ខ្ញុំចង់និយាយថា វាមិនសម មិនគួរធ្វើបាន កុំធ្វើល្អដាង អាធ្វើហើយ

ឲ្យគេវេទនាគ្រប់គ្នា ។ដឹងទេ បញ្ហាវិត្តមួយចំនួនធ្វើឲ្យយើងស្លាប់ដោយសារគេ ធ្វើដបីដបា មិនដឹងអី ។

ឃីមៈ ចុះ អ៊ំមើល ខៀវសំផន សុទ្ធតែមកពីស្រុកបារាំង ហឺហ៊ូយន់ ហ៊ូនឹម ប៉ុល ពតអី សុទ្ធតែមកពីស្រុកបារាំងទាំងអស់ ស្រាប់តែអញ្ចឹង ម្នាក់ៗឆ្ងល់គ្រប់គ្នាមិនដឹងជារឿងស្អី ស្រាប់តែធ្វើអញ្ចឹង?

សនៈ ខ្ញុំនិយាយរឿងមួយ ថាខ្ញុំអួតខ្លួនខ្ញុំតិចចុះ ខ្ញុំនៅវត្តលោក មុនដំបូងលោកប្រើខ្ញុំ ទៅទិញកាសែតប្រជាជន នៅកន្លែងស្នាក់ការកាសែតខាងលិចវត្តលង្កា ។ ខ្ញុំទៅទិញមិនដំបូងតែម៉ាច្បាប់ទេ ដល់យូរៗទៅឡើងបីច្បាប់ យូរទៀតឡើង១៣ច្បាប់ កាសែតប្រជាជន។ ដល់ខ្ញុំអាយុបាន១៨ បង ណុបបូផាន់ គាត់ចាស់ជាងប្អូននេះតិចប្រធានកាសែតគាត់ហៅថា ជាអ្នកកសាងកម្លាំង គាត់សួរខ្ញុំ គាត់ណែនាំខ្ញុំឲ្យមើលឃើញពីមាគ៌ារបស់សង្គមកនិយម ខ្ញុំតាមគាត់ តាមរហូតដល់ឆ្នាំខ្ញុំប្រលងឌូប្លូមហើយ កាលណឹងខ្ញុំជិះស៊ីក្លូទៅផ្ទះដឹកអង្ករម៉ាបាវ គ្រាន់តែជិះសីក្លូមកដល់ត្រង់កាច់ជ្រុងវត្តលង្កាណឹង អានេះផ្លូវប៉ាស្ទ័រ អានេះផ្លូវសីហនុកាច់ជ្រុងណឹង អាណាបាញ់មាំងដួលប្រួស នឹងមុខខ្ញុំណឹងនៅលើស៊ីក្លូ គាត់កំពុងដើរ ខ្ញុំកំពុងជិះសីក្លូ ។ ខ្ញុំពីរនាក់ពួកម៉ាកខ្ញុំប៉ុក ឈឺនឥឡូវនៅស្រុកបារាំង អានោះចុះរត់ដេញហ្មងទៅដល់ផ្ទះខាងកើត ម៉ម សុន ថាបាញ់អាចុយម៉ាយនេះសិន ដេញអញអីហ្អែង

ឃីមៈ ថីបានបាញ់?

សនៈ កាលណឹងរឿងនយោបាយ ហឺខ្ញុំរហូត តាំងពីណឹងមកខ្ញុំលែងរវីរវល់

ឃីមៈ ដឹងមុខអ្នកបាញ់ណឹងទេ ហឺយើងអត់កាំភ្លើងហ៊ានដេញគេ?

សនៈ មិនដឹងម៉េច ខ្ញុំអត់ដេញផង។ ខ្ញុំទៅតាមគាត់លើកដាក់សីក្លូ ពួកសីក្លូជួយលើកដាក់រហូតដល់ផ្លូវនរោត្តម កាលណឹងអត់មាន វិមានឯករាជ្យ ទៅដល់ផ្លូវបត់ គាត់ប្រាប់ថា អាសនហ្អែងទៅវត្តវិញទៅ ។

ឃីមៈ ចុះគាត់អីទេ អត់ស្លាប់ទេ?

សនៈ ស្លាប់ តែមិនដឹងស្លាប់នៅណា កែងដឹងហើយ ។ អញ្ចឹងបានខ្ញុំថា ពួកអស់ណឹងធ្វើឲ្យតែគេពិបាកវេទនា ងាប់មនុស្ស ហើយប្រជាជនដែលស្លាប់ដោយសារពួកអស់ណឹងច្រើនណាស់

កាលណឹងយើងឃើញគោលនយោបាយមាគ៌ាមកក្នុងសៀវភៅណឹង ក្មួយឯងដឹងទេ សុទ្ធតែរមូល មាគ៌ាសង្គមនិយម ។ គោលនយោបាយគេល្អណាស់ ប៉ុន្តែបុគ្គលិកអនុវត្តន៍ ។

ឃីមៈ ពេល អ៊ីចូលបដិវត្តន៍ណឹងតាម៉ុកអ្នកនាំចូលហ្នឹង?

សនៈ មិនទេ គ្នាគាត់ តាគិត មិនដឹងស្អីគិតទេ ព្រាប គិត គណៈតំបន់២៥ ផ្ទះគាត់នៅតាខ្មៅ ពេលយួនចូលមក ខ្ញុំដូចពួកម៉ាកអញ្ចឹង តែគាត់ក្មេងជាងខ្ញុំតិច ដេកអោបតែគ្នា ។ គាត់ថា ឥឡូវយួនមកហើយ រត់ទៅណាមកណា ផ្ញើប្រពន្ធជាមួយខ្ញុំមក គាត់ស្លាប់ហើយ

ឃីមៈ កាលណឹងឆ្នាំណាកាលតាគិតនាំទៅ?

សនៈ ខ្ញុំចូលបដិវត្តន៍ ៧៥

ឃីមៈ ចុះអ៊ីបានទទួលតួនាទីអីដែរ

សនៈ អត់ទេ គ្រាន់តែជាកំលាំងស្នូលនៅតាមភូមិឃុំ

ឃីមៈ មានន័យម៉េចកំលាំងស្នូលណឹង?

សនៈ កសាងកម្លាំង មិនមែនចូលទាំងអស់គ្នាទេ ដល់តែយើងដើរខ្សឹបខ្សៀវទៅចលនាចេះមួយៗ ព្រោះ ដូចថាផ្ទះនេះនៅគាំទ្រ លន់ ណុល យើងកសាងកម្លាំង

ឃីមៈ កាលណឹងយុវជន យុវនារីចូលទាំងកង១ គេឃោសនាម៉េចខ្លះបានចូលខ្លាំង?

សនៈ អូ ចូលទាំងកង១ មិនទេ អញ្ចឹងហ្នឹង គឺខ្ញុំរៀនយុវជន យុវនារីច្រើនណាស់ គ្រប់ភូមិនៅជិតៗនេះទាំងអស់ ។ ខ្ញុំថាបើចង់សប្បាយអីម៉ាយប់អីណឹងហៅមកលេងសិល្បៈម៉ាយប់ហីទៅធ្វើទ័ពទាំងអស់

ឃីមៈ ចុះហេតុអីបានគេចង់ម៉េស?

សនៈ គេចង់ធ្វើហ្នឹង គេចង់តស៊ូ កាលណឹងគេហៅថាកំទេចសក្តិភូមិនាយទុន ។ អាណឹងយើងនិយាយខ្លី

ឃីមៈ អូ តើគេបញ្ចុះបញ្ចូល ឬពួកគេយល់ខ្លួនឯង

សនៈ មិនទេគេបញ្ចុះបញ្ចូលហ្នឹង កាលនឹងកម្មាភិបាលដើរបញ្ចុះបញ្ចូលតាមភូមិឃុំ ហៅថាកសាងកម្លាំង ។ ដូចថាត្រូវការយុវជនម៉ាឃុំណឹង១០នាក់ គ្រាន់តែយើងរើសនេះមួយនោះមួយ

ណើងវាទីង មកចង់៩០នាក់ ទាំងយុវនារី ទាំងយុវជន គឺអត់បាន ហើបមាត់មិនបានហ្នង ទោះបីដឹងថាទៅស្លាប់ហើយ ក៏នៅតែទៅ

ឃឹមៈ សូមសរសើរ គេធ្វើបដិវត្តន៍ល្អ ?

សនៈ គោលនយោបាយដំបូងវា

ឃឹមៈ គេនិយាយអីខ្លះបានគេ..គោលនយោបាយអីខ្លះ?

សនៈ គោលនយោបាយរបស់មាក៏សគ្គមកនិយមក្នុយឯងទៅមើលអាក្នុងនៅអាលឺរូយ៉ាល់កន្លែង វត្តភ្នំ មានបណ្ណាល័យមួយណើង កាលណើងខ្ញុំទៅមើលណើងដែរ

ឃឹមៈ អូ បណ្ណាល័យជាតិ ។ ចុះគេនិយាយអីខ្លះបញ្ចុះបញ្ចូលយុវជន យុវនារីណើង?

សនៈ គេនិយាយពីការជិះជាន់ របស់មនុស្ស និយាយឲ្យខ្ញី។ មុនដំបូងគេលើកឡើងពីវណ្ណៈជិះ ជាន់ប្រជាជន ដូចថាយករបប យកពន្ធស្រែ យកពន្ធគោ យកពន្ធផ្ទះ យកពន្ធដើមត្នោត យកពន្ធភ្លៃ ពីដើមយកអញ្ចឹង ។ ផ្លែយក មិនយកម៉េចផ្លែខ្ញុំឈឺខ្ញុំយកទៅពេទ្យ ។ បើអញ្ចឹង មិនអស់ឆ្នាំពេទ្យគេ ។ ដល់ក្រោយមកណើងគេជិះជាន់គ១គ្នារហូតដល់ជិះជាន់គ្នា គាត់លើ ណើង ក៏ទ គ្នាទៅ ណើងយើងនិយាយឲ្យខ្ញី ។

ឃឹមៈ កាលណើងយុវជន យុវនរី អាយុប្រហែលប៉ុន្មាននាក់ចូលណើង ចូលបដិវត្តន៍ធ្វើទាហាន ធ្វើពេទ្យអីណើង?

សនៈ អាយុ តាំងពី១២ ១៣ ក្មេង១ អត់មានសល់ទេ ភូមិមួយទៅស្អាតបេស កូនខ្ញុំអាមួយ នេះ ។កូនខ្ញុំក្មេងប៉ិនអត់នៅជាមួយខ្ញុំផង ទៅនៅណាខេត្តកំពង់ស្ពឺណាណោះ កូនខ្ញុំសុទ្ធតែ ប្រុសអត់មាននៅខ្លួនអីមួយ ដល់ពេលមកពីរត់វិញ មកមូលតិលអត់មានឆាប់អីមួយ ។ អាកូនបងគេ មកដល់អាយុ ១៧ ហើយ អត់មានចេះ ក អីម៉ាតួ ។ ខ្ញុំយកទៅឲ្យរៀននៅ អនុវិទ្យាល័យតាកែវណើង ហើយអត់ចេះអីម៉ាតួ រៀនដល់ជាប់បាក់ឌុប ហើយទៅប្រលង មេឌីសាំងចេញមកឥឡូវអត់ធ្វើអី នៅរកស៊ីផ្សា ។ កូនខ្ញុំ5បុស៥ ជាប់បាក់ឌុបទាំងប្រាំ ។ មានកូនស្រីមួយនៅជាមួយតាម៉ុក ដល់គេយកមក ។

ឃឹមៈ កាលតាម៉ុកនាំ អីចូលពេទ្យណើងកាលណើងឆ្នាំ៧៥ឬ៧៦ដែរ ?

សនៈ កាលណើង ៧៧ ៧៨ហើយ ។ កាលមុនណើងខ្ញុំធ្វើជាងអីសិន

ឃីមៈ ចូលទៅដល់ភ្នំមានបុគ្គលិកប៉ុន្មាននាក់?

សនៈ ៦០ ប្លាយកគាប់រួម

ឃីមៈ សុទ្ធតែស្រី ឬប្រុស?

សនៈ សុទ្ធតែប្រុសទាំងអស់ជាង

ឃីមៈ និយាយពីពេទ្យ?

សនៈ អូ ពេទ្យ ៩៦នាក់ ពេទ្យស្រុក ឥឡូវនោក្នុងភូមិព្រៃខ្វាវ នៅវត្ត

ឃីមៈ នៅក្នុងពេទ្យ អឹ ណឹងចែកជាផ្នែកអីខ្លះ ពេទ្យ អឹកាន់កាប់?

សនៈ មានពេទ្យផ្នែកបុរស ជាមួយខ្ញុំមានយុវជន១២ នាក់ ១៣នាក់ទាំងខ្ញុំ ក្រៅពីណឹងនារី ទាំងអស់ផ្នែកឆ្មប និងព្យាបាលជំងឺទូទៅមានតែពីរណឹង

ឃីមៈ ចុះយុវជនធ្វើអី?

សនៈ ព្យាបាលជំងឺ ពូៗ

ឃីមៈ ចុះយុវជណ១២នាក់ណឹងមានចំណេះវិជ្ជាច្រើនទេ?

សនៈ ចេះខ្ញុំឲ្យទៅរៀននៅភ្នំពេញ ចេះគ្រាន់

ឃីមៈ ចុះចំណេះទូទៅថ្នាក់ទីប៉ុន្មាន ដែលបានធ្វើពេទ្យណឹង?

សនៈ អត់ទេ ចេះតែមើលអក្សរអីនាយអាយ

ឃីមៈ ចុះហេតុអីបានរើសយកអ្នកអត់ចេះ?

សនៈ គ្មានហ្នឹង អត់មានហ្នឹង កាលណឹងយុវជនអាចេះៗទៅកងទ័ពអស់ហើយ ក្មួយខ្ញុំកូនថៃផ្ទះនេះខាងលិចនេះ វាប្រលងឌីប្លូមពីសង្គមចាស់ជាប់ហើយណឹង ទៅធ្វើប្រធានវរសេនាធំទៅជាមួយតាម៉ុកហើកូននេះទៅធ្វើប្រធានយុវជនស្រុកត្រាំកក់ហើយទៅនៅចំការកៅស៊ូទៅធ្វើលេខាស្រុកហើអាមួយប្អូនអាណឹងក៏ប្រធានវរសេនាធំដែរ នៅសៀមរាប

ឃីមៈ មិញថាគណៈស្រុកឈ្មោះអី?

សនៈ តាគិត មុនតាជឹម ដល់ក្រោយមកតាគិត ចេញពីតាគិតណឹងទៅ តាសាន ប្អូនថ្លៃតាម៉ុក

ឃីមៈ គណៈស្រុកត្រាំកក់ណឹង?

សនៈ បាទ

ឃីមៈ ចុះអ្នកអត់សូវចេះអក្សរធ្វើពេទ្យអញ្ចឹងម៉េចដែរ អ៊ំ?

សនៈ អត់ទេ គ្រាន់ឲ្យវាចាក់ថ្នាំនាយអាយយើងអ្នកព្យាបាល

ឃីមៈ ចុះនារីពេទ្យ?

សនៈ នារីក៏អញ្ចឹងដូចគ្នាដែរ អ្នកជំងឺគឺព្រលឹមឡើងខ្ញុំដើរមើលទាំងអស់ ត្រូវចាក់ថ្នាំអី?

ឃីមៈ ចុះនារីប្រហែលប៉ុន្មាននាក់?

សនៈ ៩៦នាក់ពេទ្យទាំងអស់ហើយ ប្រុស១៣នាក់

ឃីមៈ ចុះរបៀបគ្រប់គ្រង អ៊ំធ្វើម៉េច?

សនៈ ព្រឹកឡើងមានកម្មវិធីបោសជ្រះ យើងចែកជាក្រុម ក្រុមណាត្រូវបោសជ្រះ ក្រុមណាត្រូវលាងសារ៉ាំង ក្រុមណាត្រូវព្យាបាល ក្រុមណាត្រូវដើររកបន្លែរកម្ហូប

ឃីមៈ សុទ្ធតែពេទ្យណឹងចែកគ្នាធ្វើបុក៏ មានដាច់ដោយឡែក?

សនៈ ចែកគ្នាក្រុមគ្នា ហើយដូរគ្នា មានយកអ្នកដាំបាយម្នាក់ដែរក្មួយតាម៉ុក ឈ្មោះពុត្ត ឥឡូវវានៅ លក់ផ្សារ ។គាត់ដាំបាយជាអចិន្ត្រៃយ៍

ឃីមៈ អញ្ចឹង អ៊ំខ្លួនឯងមិនហត់ហើត បើគេអត់ចេះផងគ្រាន់តែចេះចាក់ថ្នាំ អ៊ំអ្នកដើរមើល?

សនៈ ហត់ដែរណឹង បើថ្ងៃមិនសូវពិបាកទេ ពេលយប់បានពិបាកមែនទែន ហើយគ្រប់គ្រងនារីពិបាកជាងយុវជនទៀត

ឃីមៈ ហេតុអី?

សនៈ យុវជណនិយាយតែម៉ាម៉ាត់ស្តាប់បាន ម៉ាឆ្នាំ នារីនិយាយកន្លះខែវាអត់ស្តាប់

ឃីមៈ ហេតុអី ចេះតែពីបាកម៉េចនារីណឹង?

សនៈ ក្មួយឯងអត់ដឹង ដល់យាយនេះចេះតែស្តីឲ្យខ្ញុំ ។ នារីនៅជាមួយខ្ញុំ ខ្ញុំគិតគូទាំងអស់ តាំងពី រកគូស្រេក ខ្ញុំការឲ្យ ពេលការណឹងខ្ញុំមានជ្រូកមានធ្មើន ហើយរស់នៅធម្មតាណឹងមានខោ ពីបីកំប្លេមានអាវទ្រនាប់មានខោទ្រនាប់ គេវៃតំលៃខ្ញុំ គេលើក ប្រធានពេទ្យតំបន់ប្អូនតាម៉ុក ឈ្មោះគឿន ប្រាប់ខ្ញុំថាពូឯងដូចគិតគូរឿងនារីមាំម៉េស ខ្ញុំថាសួរយុវជនមើល

ទៅ នៅជាមួយគ្នាខ្ញុំគិតវាអត់ ថាខ្ញុំគិតតែនារីម៉េចកូនគេមកនៅជាមួយឯង គ្រាន់តែអាវ ទ្រនាប់ពីរម្នាក់ ខោខ្លីពីរៗ ខ្ញុំគិតមែន យាយណឹងស្តីឲ្យខ្ញុំព្រោះខ្ញុំទៅកំម៉ង់ថា ឥឡូវ កាត់អាវទ្រនាប់ឲ្យខ្ញុំ ខោខ្លីប៉ុន្មានរយ ឲ្យនារី

ឃីមៈ ចុះ អីថាពិបាកគ្រប់គ្រងម៉េចនារី និយាយអត់ស្តាប់?

សនៈ សីលធម៌ ផ្តេសផ្តាសណាស់

ឃីមៈ ផ្តេសផ្តាសម៉េច?

សនៈ វាចេះតែឆានៅប្រុសៗ ឆានៅស្រីៗគ្នា ឯងក៏ឆានៅដែរ ៗអញ្ចឹងខ្ញុំថាពិបាកគ្រប់គ្រង

ឃីមៈ បុគ្គលិកពេទ្យណឹង?

សនៈ ខ្ញុំមិនមែននិយាយពីអ្នកជំងឺទេ វាខូច អាខ្លះវាចង់បានប្តី ចេះចុះ

ឃីមៈ ចុះអង្គការមានវិធនការម៉េច?

សនៈ មាន វិធានការណ៍បណ្តើរៗ យើងពិបាកដែរណឹង កាលណឹងមុននឹងរៀបការគេមើលវណ្ណៈ ភាពប្រហាក់ប្រហែលគ្នាបានគេការ

ឃីមៈ ចុះគេមានដាក់ទារុណកម្មអីទេ ខុសពីរឿងសីលធម៌?

សនៈ មានដែរ ពេទ្យខ្ញុំដកចេញ មានយកទៅដាក់គុកក្រាំងតាចាន់មួយក្មេងឈ្មោះ នៅរស់ រាល់ថ្ងៃនៅភូមិទួលរកា

ឃីមៈ ចុះមានដឹងថាគេធ្វើទារុណកម្មគាត់ម៉េចទេ គ្រាន់ខុសសីលធម៌អញ្ចឹង?

សនៈ អត់ដឹង តែគេយកទៅដាំបាយអីនៅគុក

ឃីមៈ ចុះបុរសដែលខុសសីលធម៌ណឹង?

សនៈ នៅក្នុងអង្គភាពដាង តែកាលណឹងវាយកគ្នាធ្វើប្តីប្រពន្ធទាល់តែបានក្រោយមក

ឃីមៈ ចុះនារីភាគច្រើនខុសីលធម៌ហ្នង?

សនៈ មិនខូចទេ ប៉ុនវាពិបាកគ្រប់គ្រង ដូចយុវជននៅជាមួយខ្ញុំ អញ្ចឹងមានបន្ទប់មួយដេកជាមួយ ខ្ញុំគ្នាមានគ្រែមួយសំរាប់ខ្ញុំ និងគ្នា១២នាក់ណឹងមានគ្រែតែ៤ ៥ ៦ទេ ៗអញ្ចឹងបើអា៦

ដេក អា៦យាមយប់ៗ ស្រីៗអស់ណឹងចេះតែមកលួចមកយប់ៗ ប្រុសៗអត់ហ៊ានទៅទេ ស្រីៗមក ស្រីខ្លាំង ខ្ញុំខ្លាច

យឹមៈ មិនដែលទេ មានតែស្រីគេរៀនប្រុសទៅរកស្រី?

សនៈ ខ្ញុំចង់តែនិយាយឲ្យច្រើនទៀតទេ ដូចកាលខ្ញុំទៅរៀននៅភ្នំពេញពីដើម ខ្ញុំមានពួកម៉ាកមួយ ក្មេងឈ្មោះវាទៀត វាមានបងស្រីមួយ ស្រាប់វាបបួលខ្ញុំទៅលេង ខ្ញុំថាអូស្រីគ្រអញ្ចឹងទេ

យឹមៈ ក្រែងគេរាប់អានធម្មតា

សនៈ មិនទេ

យឹមៈ លើកលែងតែ អឹមួយទេ ក្រៅពីណឹងអត់មានទេ អឹ មានតែប្រុសមកមុនៗ មានតែ អឹមួយទេដែលសុភាពបុរស

សនៈ ខ្ញុំថា មិនជឿ គ្រប់គ្រងស្រីៗពិបាកជាងប្រុស ក្មួយឯងជឿខ្ញុំទៅ បើគេឲ្យគ្រប់គ្រង មានប្រុសនិងស្រី បើគ្រប់គ្រងប្រុសៗអត់ចេះពិបាកទេខ្ញុំប្រាប់

យឹមៈ ចា៎ ចុះប្រុសៗគេអត់មានពោះធំណា

សនៈ មិនទេ វាពិបាកហ្នឹង វាពូកែអេចអូញជាក់គ្នា ខ្សឹមខ្សៀវបេះបួយ និយាយរួមបេះបួយ ហ្នឹង

យឹមៈ ស្រីៗតែអញ្ចឹងឯងៗ ចុះគេដាក់វិន័យអីខ្លះនៅក្នុងពេទ្យមួយៗណឹង ឲ្យធ្វើម៉េចខ្លះ?

សនៈ អាណឹងវិន័យពីថ្នាក់លើគេដាក់ បើប្រសិនណាមានខុសត្រង់ផ្នែកអស់ណឹង បើមានតួនាទីអី ត្រូវដកចេញ ដូចធ្លាប់ព្យាបាលគេលេងឲ្យព្យាបាលហើយ អាណឹងទោសស្រាលៗ បើធ្ងន់ ដល់ខិលខូចនឹងគ្នា យកទៅដាក់គុកមែនទែន

យឹមៈ បើថ្នាក់លើដាក់អញ្ចឹង យើងជួយលាក់ទៅ អឹ?

សនៈ លាក់មិនបានទេ យើងជាអ្នកធ្វើរបាយការណ៍ លាក់អត់បានទេក្មួយ យើងដឹងក្រោយប្រ ជាជនទេ អញ្ចឹងប្រជាជនគេរាយការណ៍មុន រឿងដល់យើងពេលប្រជុំម្ដងៗគេលើកឡើង

យឹមៈ ចុះវិន័យពេលព្យាបាលគេឲ្យធ្វើម៉េចខ្លះ ដាក់វិន័យលើបុគ្គលិកពេទ្យណឹងម៉េចខ្លះចំពោះ អ្នក ជំងឺ?

សនៈ ចំពោះអ្នកជំងឺធម្មតា អាណឹងវិន័យធ្វើធម្មតាដូចពេទ្យ គេឲ្យស្លៀកខោអាវស ប៉ុនកាលនោះ អត់មាន មានតែមួយកំប្លេម្នាក់សំរាប់ធ្វើថ្នាំ ដូចជាមានវល់អី ។ វិន័យពេទ្យធម្មតាខ្ញុំដឹងវិន័យពេទ្យយើងយកចិត្តទុកដាក់ជាមួយប្រជាជន ប៉ុនទោះបីយ៉ាងណាក៏ដោយចុះ នារីក៏នៅតែខុសឆ្គងពាក្យសំដីជាមួយអ្នកជំងឺដែល១ យើងដោះស្រាយ

ឃីមៈ ហេតុអី?

សនៈ ជួនកាលគាត់ទាមទា គាត់ឈឺខ្លាំងពេទ្យ ទាមទាឲ្យត្រូវបញ្ជូន តែពេទ្យមិនព្រមបញ្ជូនឈ្លោះគ្នា ជេរគ្នា ស្រី១ច្រើនអញ្ចឹង ប្រុស១មិនហ៊ានសោះ រហូតដល់ក្រោយមក៧៩មក ។

ប៊ុនៈ ខ្ញុំចង់សួរពីពេទ្យឆ្មបណឹង តើស្រី១នារីដែលធ្វើពេទ្យឆ្មបណឹងធាប់ឆ្លងកាត់ពេទ្យទៅរៀននៅសាលា រៀននៅខ្វែងណា?

សនៈ រៀន មុនដំបូងខ្ញុំទៅរៀន ឆ្មបក៏រៀនដែរ មកវិញខ្ញុំបង្រៀនគេ នៅក្នុងពេទ្យស្រុកហៅពេទ្យឃុំបង្រៀនទាំងអស់គ្នា ។ ម៉ាឃុំមានបីនាក់សំរាប់ធ្វើឆ្មប

ឃីម៖ អុំដឹងពីរចនាសម្ព័ន្ធច្រើន ឧបមាថានៅពេទ្យក្នុងពេទ្យស្រុកណឹង គេចែកប៉ុន្មានពេទ្យនៅតាមឃុំ គ្រប់ឃុំ?

សនៈ មានគ្រប់ឃុំ ភូមិអត់ទេ

ឃីមៈ ចុះម៉ាឃុំមានពេទ្យប្រហែលប៉ុន្មាននាក់?

សនៈ មាន១២ ១៥ នាក់ ក្នុងម៉ាឃុំ ។ យើងរើសយកមាក់ពីរនាក់អីតាមឃុំឲ្យទៅរៀន នៅភ្នំពេញ ។ រៀនពេទ្យគ្រូនចាញ់ គឺរៀននៅពេទ្យកាល់ម៉ែត្រ

ឃីមៈ អូ បញ្ជូនទៅតាមឃុំណឹង ។ អុំទៅមុនគេ ទៅឆ្នាំណា៧៦ណឹង អុំទៅរៀនពេទ្យណាកាលណឹង?

សនៈ ខ្ញុំរៀននៅនេះ អត់ទៅភ្នំពេញផង

ឃីមៈ ចុះម៉េចខពេទ្យឃុំទៅ ហើយ អុំអត់ទៅអញ្ចឹង?

សនៈ កាលមុនដំបូងគេឲ្យរៀននេះ ដល់ក្រោយទៅគេហៅទៅរៀននៅពេទ្យកាល់មែត្រ

ឃីមៈ ចុះ អុំធ្លាប់ទៅដែរ?

សនៈ អត់ទេ គ្រាន់តែជូនកម្លាំងទៅ ដូចជូនអ្នកជំងឺអីទៅពេទ្យរុស្ស៊ី

ឃីមៈ ចុះ អ៊ំមានដឹងថាអ្នកណាគេរដ្ឋមន្ត្រីខាងក្រសួងសុខាភិបាលមកទូទាំងប្រទេស

សនៈ តា ជួន ជឿន

ឃីមៈ ចុះម៉េចដឹងថាគាត់ខាងណឹង?

សនៈ មិនដឹងម៉េច បើតាជួន ជឿនណឹងតាំងពីសង្គមកចាស់មក ខ្ញុំនៅក្មេងធ្លាប់នាំអ្នកជំងឺទៅឲ្យគាត់វះកាត់ឲ្យ

អូនៈ អ៊ំសុំទៅ អ៊ំអាយុប៉ុន្មានហើយ?

សនៈ អាយុ ៦៥

ឃីមៈ ចុះ អ៊ំធ្លាប់ជួបតាជួន ជឿនដែរ?

សនៈ ធ្លាប់

ឃីមៈ កាលណឹងគាត់អាយុប្រហែលប៉ុន្មានតាជួន ជឿន

សនៈ ប្រហែលអាអូនឯង

ឃីមៈ ក្មេងទេ?

សនៈ កាលខ្ញុំនៅក្មេងដែរ គាត់បងច្រើនៗ កាលណឹងខ្ញុំនៅស្រែននោង អញ្ចឹងមានអ្នក ឈឺត្រូវការវះកាត់អី ខ្ញុំពីដើមគេអត់ដឹង ហើយខ្ញុំទៅរៀនកំពេញតាំងពីតូចហើយដឹងជាងគេ គេឲ្យនាំទៅ

ឃីមៈ កាលណឹងនៅលន់ ណុលឡើង?

សនៈ តាំងពីសីហនុនោះ

ឃីមៈ ពេល អ៊ំធ្វើពេទ្យនៅស្រុកនេះហើយតើផ្លាស់ទៅពេទ្យណាទៀតទេ?

សនៈ អត់ទេ នៅណឹងរហូតដល់ថ្ងៃបែកណឹងហ្នង ថ្ងៃបែកបររទេះចេញ យាយណឹងរញ៉េរញ៉ៃទៅជាមួយគ្នា កាលណឹងកូនខ្ញុំអានេះនៅតូច ប៊ុនអត់នៅជាមួយខ្ញុំទេ ទៅមើលគោអីណា

ឃីមៈ ចុះរបៀបគ្រប់គ្រង អ៊ំធ្វើម៉េចខ្លះនៅក្នុងពេទ្យណឹង?

សនៈ មិនធ្វើម៉េច គ្រាន់តែទទួលផែនការ ប្រជុំម៉ាអាទិត្យណឹង ប្រជុំម្ដងប្រជុំជីវភាពណឹង ។ ដូចផែនការបច្ចេកទេស អប់រំខាងផ្នែកនយោបាយមុនដំបូង ផ្នែកយោធា ហីផ្នែកបច្ចេកទេសព្យាបាល តាមមុខជំនាញ ឆ្នបយើងនិយាយតាមឆ្នប ឯជំងឺទូទៅតាមជំងឺទូទៅ ។

យឹមៈ អញ្ចឹងសុទ្ធតែ អ៊ំអ្នកបង្រៀនទាំងអស់ពេលមកណឹង?

សនៈ បាទ មិនបង្រៀនរាល់ថ្ងៃទេ បីខែបានបង្រៀនម្ដង ប៉ុនប្រជុំជីវភាពប្រជុំរាល់អាទិត្យ

យឹមៈ ប្រជុំជីវភាពដើម្បីអី?

សនៈ ដើម្បីរិះគន់ផង ដើម្បីទិតៀន ដើម្បីជួយកែលំអចំណុចខ្វះខាត ផ្នែកបច្ចេកតេសអីណឹង ។ ជៀសវៀងកុំឲ្យឈ្លោះគ្នាជាមួយអ្នកជំងឺ

យឹមៈ នយោបាយ អ៊ំអ្នកបង្រៀនដែរ?

សនៈ បាទ

យឹមៈ កាលណឹងបង្រៀនពីអីនយោបាយ?

សនៈ បង្រៀនតាពីរឿង ពីរទេ ពីរឿងសក្ដិភូមិមូលធន និងវណ្ណៈកសិករ ព្រោះយើងជាកសិករ បើនិយាយពីកម្មករពួកណឹងមិនដឹងទេ ។

យឹមៈ ចុះ អ៊ំពន្យល់គេម៉េចខ្លះ?

សនៈ ឲ្យគេធ្វើរបៀបរបប ដូចជារស់នៅរបៀបសង្គមនិយម ធ្វើអីមួយក៏គិតរបបសមូហភាពដែរ

យឹមៈ ចុះក្នុងពេទ្យណឹងអនុវត្តន៍បានទេ នារីៗបុគ្គលិកពេទ្យណឹង?

សនៈ បានម៉ាចំនួន

យឹមៈ ចុហពេលអត់បានណឹងយើងមានវិធនាការណ៍ម៉េច?

សនៈ យើងអប់រំបណ្ដើរៗ

យឹមៈ ចុះផ្នែកជំងឺមួយៗអ្នកណាជាប្រធាន?

សនៈ ខាងឆ្វេងទន្ទេមាននារីម្នាក់ទៀត ។ ក្រោមខ្ញុំមាននារីម្នាក់ក្ដាប់នារីណឹងរួមទៀតឈ្មោះហៀង តែស្លាប់បាត់ហើយ ដោយត្រូវគ្រាប់ ក្រោយមកហើយនៅអន្លង់វែង

យឹមៈ ក្រៅពីនារីណឹងមានអ្នកណាទៀតទេ?

សនៈ អត់ទេ មានតែពីរនាក់

ឃីមៈ ចុះគាត់ចេះបច្ចេកទេសពេទ្យទេ?

សនៈ ចេះ ប៉ុនគាត់មិនចេះដូចខ្ញុំទេព្រោះគរិតវិជ្ជាវាក្រោម

ឃីមៈ ចុះផ្នែកជំងឺទូទៅអ្នកណាគេ?

សនៈ ខ្ញុំ មានតែខ្ញុំហ្នឹង

ឃីមៈ ចុះក្នុងមាថ្ងៃតើមានអ្នកជំងឺចូលប្រហែលប៉ុន្មាន?

សនៈ ដល់ចុងក្រោយបំផុតមកមាថ្ងៃ បួន ១០ នាក់ៗ បើសិនណាគ្រាន់តែនិយាយហើយក្នួយស្តាប់ណឹងប្រហែលជាមិនចង់ជឿទេ ខ្ញុំគ្រាន់តែឃើញអ្នកជំងឺ មិនដឹងមើលម៉េច មកដល់វាហួសសមត្ថភាពឧទាហរណ៍ថា ក្នួយឯងបររទេះគោណឹងស្រាប់តែគេថា ឲ្យដឹកដើមត្នោតមួយធមមាប៉ុនមេឃណឹងដឹកវាមិនរួចទេ ៗយើងមើលឃើញទៅណាណីនោះ អាណឹងគេហៅសតិអារម្មណ៍ ៗ យើងមើលឃើញថាបើសិនណាកន្លែងស្រុកណាបានមើលបាន

ឃីមៈ ចុះយើងគិតបញ្ជូនទៅខេត្តទៀត?

សនៈ បញ្ជូនទៅ ក្នួយឯងជឿខ្ញុំចុះ ក្រែងថាខ្ញុំមើលមិនជិតដល់ម៉េចមិនដឹង បើថាគាជួន ជឿនខ្ញុំមិនដឹង ហើយបងសីណឹងដែលគាត់ធ្វើពេទ្យចាស់ណឹង ក៏មិនជាងខ្ញុំដែរ ហើយពេទ្យណាណីណឹងសុទ្ធតែអន់ជាងខ្ញុំ ខ្ញុំមើលទៅឃើញអញ្ចឹង ៗគ្រាន់តែក្នួយឯងមកអង្គុយណឹង ៩នាក់ៗ ខ្ញុំចោលអ្នកជំងឺមួយរៀបរត់ចេញ នៅសល់អ្នកជំងឺម្នាក់ខ្ញុំបបួលគ្នាសែងយកមកដាក់ថ្នល់ព្រោះយួនមកដល់ហួសអន្លង់សោមនេះ ៗ ខ្ញុំឲ្យយួនយក ៗ ដល់ខ្ញុំមកវិញ សួរគេគ្រប់គ្នា ថាអត់ដឹង ៗ អ្នកជំងឺយកមកពីឃុំរំចង់នៅក្រុងតាកែវណឹងគាត់សស្អាត មិនដឹងប្រពន្ធរដ្ឋមន្ត្រីណាអីណាទេ យើងមិនដឹងមើលម៉េចបើសាច់កន្ទុលៗ ហើយគាត់ចេះតែឈឺដើរអត់រួច ហត់ ៗ គាត់និយាយបាន ខ្ញុំបររទេះចេញហើយខ្ញុំសែងដាក់ចំកណ្តាលថ្នល់ មិនមែនដាក់ឲ្យឡានកិនទេ ដាក់ឲ្យគេយក

ឃីមៈ ចុះប្រជាជន១៧មេសាមានចូលកន្លែង អ៊ំប្តូទាំងពួក

សនៈ ចូលគ្នាលាយឡំទាំងអស់ អត់មានថាមូលដ្ឋាន ២៧អីទេ គឺចូលលាយគ្នាទាំងអស់ៗ មើលទាំងអស់ យកចិត្តទុកដូចគ្នា ៗ ខ្ញុំនេះខុសគេណាស់រហូតដល់សង្គមកនេះអញ្ចឹង

យឹមៈ វមិញថាអ្នកឈឺ តាំង១៧មេសា ទាំងមូលដ្ឋានខុះជីវជាត់

សនៈ ខុះជីវជាតិក្ហួយ

យឹមៈ ចុះយើងគិតរាយការណ៍ទៅលើ?

សនៈ រាយការណ៍ចង់ងាប់ហើយ គេថាយើងសតិអារម្មណ៍ វៃប្រហារសហករណ៍គេ ។ ខ្ញុំថាបើអញ្ចឹងមែន ។ហឺពួកអស់ណឹងកុំអីវាធ្វើបាបយើងដែរប៉ុនកាលណាវាយកទៅលើក ឡើងនៅលើ លើគេដឹងជាង គេដឹងថាពិតជាជំងឺខុះជីវជាតិ ព្រោះវាអត់អី បើអាអស់ ណឹងវាលេងតែមាន់ស្ងោររាល់តែថ្ងៃនៅលើ ហើយគ្នានេះមានស្អី ។ ខ្ញុំស្ងួតែ ព្រលិត តែត្រកួនណឹងចង់ងាប់ហើយ

យឹមៈ ចុះឲ្យអ្នកជំងឺហូបអីគេ?

សនៈ ខ្ញុំណឹងគ្រាន់បើជាងគេ ខ្ញុំដាំបាយឲ្យហូបអ្នកជំងឺ ខ្ញុំទៅដីកស្រូវខ្ទនឯងរហូតកំពង់យោល ទោះតាម៉ុកគាត់ថាម៉េច ក៏ខ្ញុំដីកដែរ គោខ្ញុំសុំគេ គ្រាន់តែឲ្យហូបសន្សំសំចៃដែរ សុំគោឃុំណាមួយហូបបានបីបួនថ្ងៃ ហើយជិតដល់ថ្ងៃទៅសុំជ្រូកគេមួយទៀត ខ្ញុំសុំគ្រប់ឃុំទាំងអស់គេបើកសិទ្ធឲ្យខ្ញុំ

យឹមៈ ហើយមាំថ្ងៃឲ្យហូបប៉ុន្មានដង អ្នកជំងឺ?

សនៈ ពីរដង

យឹមៈ ចុះព្រឹកអត់បានទេ?

សនៈ ព្រឹកអត់បានទេ តែមិនថ្ងៃពេកទេម៉ោង៩អីហូបហើយ បាយណឹង ប៉ុនបាយណឹងមិន បានរឹងទេ ។

យឹមៈ ចុះបុគ្គលិកពេទ្យហូបអីគេ?

សនៈ បុគ្គលិកពេទ្យក៏ហូបអញ្ចឹង ។ខ្ញុំចង់និយាយថានារីពិបាកគ្រប់គ្រងក្ហួយ ខ្ញុំអត់ដែលឲ្យពួក ដាំបាយ បើពួកណឹងដាំបាយឲ្យខ្ញុំហូបខ្ញុំអត់ហូបទេ ខ្ញុំហូបតែបបរទេ អាចឹងគឺពួកណឹងវាលួចដាំបាយស៊ី ហើយម្ហូបយើងស្ងួមកអស់ណឹង វាលួចធ្វើស៊ីដែរ ។ ចុះធ្វើឲ្យខ្ញុំ ខ្ញុំអត់ហូបអញ្ចឹងទាល់តែវាលួច ។ អូ អត់បានទេ នៅមិនបានដប់ថ្ងៃទេ បើសិនណាយើងអនុវត្តន៍ផែនការស៊ីបាយជាមួយពេទ្យណឹង ខ្ញុំអត់ទេ តែវៃជួងម៉ឹងទៅមុនគេហើយ បបរហូបបីចាន

បើសំលព្រលិតហូបកន្ទះចាន ។ ហូបបបរហើយបានហូបសំលកន្ទះចានដើរមកកន្ទែង វិញ មកហូបទឹកនៅកន្ទែង ។

ឃីមៈ ចុងនារីពេទ្យណឹងហូបដូចយើងដែរ ចុះថាលួចដាំបាយ?

សនៈ ដូចយើងដែរ ប៉ុនលួចដាំបាយយប់អីពេលយាម

ឃីមៈ ចុះ អីថាម៉េច?

សនៈ ហៅមកអប់រំណែនាំ គេសារភាពបានម៉ារយៈអីណឹងក្រោយវាទៅទៀតហើយ ។ ហីក្ដួយឯងដឹងម៉េចទេគ្នាឃ្លានវាចង់ហូប ។ ខ្ញុំមិនសូវយកចិត្តទុកដាក់អាគេខុសឆ្គងទេ ខ្ញុំ អនុគ្រោះបេះតែលាក់ទៅ ។អូ ឈ្មោះមីហានណឹងដែលថាទៅគុកក្រាំងតាចាន់វាទៅ ធ្វើផ្ដេសផ្ដាសឲ្យគេមើលឃើញក្រៅ

ឃីមៈ អូ ឈ្មោះហាន នៅភូមិអីឃុំអី?

សនៈ ឥឡូវនៅភូមិទួលរកា ឃុំដាងទង បើចង់ដឹងពីគុកក្រាំងតាចាន់ វាពេទ្យណឹងទៅគ្រាន់តែឲ្យដាំបាយមានឲ្យធ្វើអី រកអ្នកដែលទទួលធ្វើទារុណកម្ម ។ ទៅផ្សារត្រាំកក់ទៅសួរអនុប្រធាននគរបាល ។ មនុស្សឥឡូវគេប្រាប់គេលែងលាក់ហើយ

ឃីមៈ ចុះកន្ទែង អីណឹងគ្រឿងបរិក្ខាពេទ្យណឹងគេយកមកពីណាវិញ?

សនៈ បើតាមខ្ញុំមើលដឹកពីភ្នំពេញមក

ឃីមៈ តាម អីមើសម្ភាររបស់ណឹងផលិតនៅណា?

សនៈ របស់របរដែលប្រើការតាំងពីដើមមករហូតគឺច្របូកច្របល់មានរបស់បារាំង មានរបស់អាល្លឺម៉ង់ មានរបស់យួន របស់ថៃអីណឹង ប៉ុនដល់ចុងក្រោយគឺរបស់ចិនសុទ្ធហ្នឹង ។ គ្រាន់តែធុងបាញថ្នាំ ជិត១០០ហ៊ីសារ៉ាំងថ្នាំពេទ្យសុទ្ធតែមកពីចិនទាំងអស់ ។ អ្នកជំងឺថាខ្វះអីថ្នាំដឹកទាំងឡានមក ប៉ុនដល់ហៅ១២ឃុំមកចែក បានតិចម្នាក់ អាថ្នាំមុខខ្លះមានចែកគ្នាបានតែពីប្រអប់ ឬក៏ពីអំពូលម្នាក់ក៏មានដែរ ។

ឃីមៈ ហីម៉ាស្រុកត្រាំកក់ណឹងមានពេទ្យប៉ុន្មាន?

សនៈ មានតែពេទ្យស្រុកណើងពេទ្យតាមឃុំ ប៉ុន្តែពេទ្យតំបន់នៅក្នុងណើងដែរ ពេទ្យតំបន់នៅសាលាដើមចំបក់នេះ ហីនិងនៅត្រពាំងអានាបណើង ។

ឃីមៈ ចុះពេទ្យភាគនៅតាកែវ?

សនៈ នៅតាកែវ

ឃីមៈ ចុះអ្នកណាគេប្រធានពេទ្យតំបន់?

សនៈ មី គឿន ប្អូនតាម៉ុក

ឃីមៈ ចុះពេទ្យសី ប្រធានពេទ្យណា ?

សនៈ ពីមុនដល់ពេល គេចាប់គាត់យកទៅឲ្យនៅមន្ទីរតំបន់នៅតាកែវ ដល់ហើយឈប់ធ្វើពេទ្យ ។ ដល់ហើយគឿនណើងធ្វើប្រធានរហូតដល់រត់ ដល់យកអ្នកជំងឺទៅឲ្យព្យាបាលក្នុងព្រៃ

ឃីមៈ ពេទ្យតំបន់នៅឃុំឈ្មោះអី?

សនៈ ឃុំត្រាំកក់ ស្រុកត្រាំកក់ ហីនៅសាលាដើមចំបក់នេះ ឃុំពពេល

ឃីមៈ ចុះថ្នាំពេទ្យដេលផលិតនៅកន្លែង អីមានប៉ុន្មាន?

សនៈ ខ្ញុំចេះ ការណែនាំពីថ្នាក់លើ គេហៅទៅរៀនចេះធ្វើវីតាមីនសេ ប៉ុនខ្ញុំធ្វើតាមគេម៉ាចំនួនតូចទេ ខ្ញុំទៅទិញមេវីតាមីនសេ ពីយួនមកដែរ

ឃីមៈ ឆ្នាំ៧៥ណើង

សនៈ បាទ

ឃីមៈ ចុះទិញម៉េចបានបើថា អឹចាក់លុយចោលនោះ

សនៈ មាស យកមាសទៅ មាសតាម៉ុកគាត់ឲ្យ មាសតំបន់គេឲ្យ យកទៅ ៤ ៥គីឡូទៅដូយួន ។ ក្មួយបងប្អូននៅក្នុងភូមិនេះគ្រាន់តែដឹងថាខ្ញុំទៅស្រុកយួន អាខ្លះធ្វើម៉ាដលឹងទៅទិញ អាខ្លះពីរបីដី បាននាឡិកាពីរបីម៉ាដំបរ

ឃីមៈ ចុះ ពាក់គេអត់ដកទេ?

សនៈ មានអីសុទ្ធតែកម្មាភិបាលទាំងអស់

ឃីមៈ ឆ្នាំណា អឹ យកមាសទៅដូរណើង?

សនៈ ឆ្នាំ៧៥ ៧៦ណឹង

យីមៈ ចុះមានដឹងពីរបៀបគេធ្វើមេថ្នាំណឹងម៉េចទេ?

សនៈ អត់ដឹង ដឹងតែចេះ ឧទាហរណ៍ថាចង់ធ្វើថ្នាំអីដែលគេធ្វើឯករាជ្យម្ចាស់ការ ចង់ធ្វើកង់ហូ ថ្នាំសំរាប់ថ្នាំជំនួយដង្កើម គេយកដើមប្រេងខ្យល់មកធ្វើ និងស្លឹមប្រេងខ្យល់ យកមកបិទ ពីរបីសារមានប្រសិទ្ធិភាពដែរ ។ គេយកមកលាងទឹកឲ្យស្អាតយកទៅដាក់ចំហុយ និងយកដំរ វាឡើងមក ។អណឹងគ្មានអ្នកណាប្រឌិតទេគឺវិទ្យាសាស្រ្តធ្វើអញ្ចឹងហ្មង ។ វាជួយបាន ម៉ា ចំនួនតូចខ្ញុំដឹង ។ ក្រៅពីណឹងទៀតចេះតែសាកល្បងអីច្រើនដែរ

យីមៈ ចុះមានគាសគ្គមកិច្ចអីជួយទេ?

សនៈ មាន គាស្លាប់អស់ហើយ

យីមៈ គាត់ដឹងច្រើន?

សនៈ គាត់ដឹងច្រើន ប៉ុនខ្ញុំអញ្ចេះ ថ្នាំបូរាណនិងខ្ញុំណឹង ខ្ញុំអត់ចូលចិត្ត ខ្ញុំថាមិនដេះដូចជាយកមក ព្យាបាលមុខណាទៅ ដូចជាដដែល១ ដូចអត់បានការអី ។ អញ្ចឹងខ្ញុំអត់សូវយកចិត្តទុកដាក់ ទេ ប៉ុនគាណឹងគាត់ យកចិត្តទុកដាក់ណាស់ កាលណឹងមានឡានមួយ គាត់ទៅណា គាត់យក ទៅគិរីវង្សរកថ្នាំ ។ បើខ្ញុំចាក់ថ្នាំទៅវាមិនបាត់ហៅគាត់មកពិភាក្សា គាត់ថាថ្នាំ នេះអញ្ចេហអញ្ចេះមានបាត់ដែរ ។ ពេលខ្ញុំព្យាបាលណឹង មានគាសគ្គមកិច្ចផង ហឹមាននារី ពីរនាក់ផង ។

យីមៈ ឈ្មោះអីគាសគ្គមកិច្ចដែលស្លាប់ណឹង?

សនៈ គាពូន ស្លាប់ខ្ញុំស្តាយណាស់ខ្ញុំ ហៅគាត់អត់មកពេលដែលរត់ទៅ ដល់ពេលយួរទៅ រកអីស៊ីជិតឆាប់មកដល់ផ្ទះ គ្រាន់តែរដ្ឋអំណាចសួរនាយអាយគាត់រត់ទៅព្រៃវិញ ឆាប់ ។ គាត់ឆាប់នឹងអត់បាយ ។

យីមៈ ចុះគាណឹងគាត់ចេះស្វាទេ?

សនៈ អត់ទេ គ្រាន់រកអ្នករកថ្នាំហើយធ្វើអាថ្នាំបុកណឹង ធ្វើឲ្យ ដូចថាដាំឲ្យក្ដួយឯងហូបអញ្ចឹងទៅ

យីមៈ ចុះក្នុងពេទ្យណឹងមានថ្នាំបូរាណផង ថ្នាំសម័យផង?

សនៈ មាន

ឃីមៈ ចុះថ្នាំអាចម៍ទន្សាយដូចគេនិយាយណឹង?

សនៈ អាណឹងគាត់អ្នកធ្វើថ្នាំណឹងគ្រាន់បើដែរ ឧទាហរណ៍ថា ត្រូវការគាត់ធ្វើថ្នាំអីម៉ាមុខណា យកឫសឈើឫសព្រៃមកធ្វើសាកសិទ្ធិដែរ ជំងឺអីនាយអាយតិចតួច តែជំងឺធមធុំមិនដេះ ទេ

ឃីមៈ អ៊ំ មេថ្នាំណឹងដឹងតែជាហ្មង យកហ្មងធ្វើខ្លួនយើងដែលលាយជាមួយទឹកបិទណឹង

សនៈ ជាតាមធម្មតា

ឃីមៈ ពូកែដែរ របស់វៀតណាម

សនៈ ពូកែដែរ នៅក្នុងបាវណឹងមិនរបស់វាទេ របស់អាមេរិកកាំងអីណឹង

ឃីមៈ អញ្ចឹងមិនមែនរបស់វាទេ

សនៈ មិនមែនតែមវាទេ ខ្ញុំឃើញពេលយកមក ព្រោះខ្ញុំទិញទាំងបាវៗ

ឃីមៈ អូ ទិញពីវៀតណាមមកមែន ប៉ុនមិនមេនវៀតណាមធ្វើទេ?

សនៈ មិនមែនទេ របស់អាមេរិកកាំង អ្នកណាអ្នកណីអិច្រើនណាស់ ព្រោះពេលយកមកគេមានផ្លាកវាឃើញដាក់ក្រុមហ៊ុនអាមេរិកាំង មកស្តុកនៅណឹង

ឃីមៈ ចុះកាលណឹងក្រែងអាពតអត់ត្រូវជាមួយវៀតណាម ម៉េចគេឲ្យយើងទៅទិញ

សនៈ ខ្ញុំទៅយួនទាស់គ្នា មួយយួនអាមេរិកកាំង និងយួនយៀកកុង នៅណឹងនៅពេញព្រំប្រទល់ ខ្ញុំទៅសុំច្បាប់អាយៀកកុងទៅ នោគាំងពីអន្តរទៅ ទៅរហូតដល់បាក់ដៃហ្មង

ឃីមៈ កាលណឹងឆ្នាំណា?

សនៈ ឆ្នាំ៧៥ ៧៦ ណឹង នៅពេញណឹង ។កាលមុនអាយួនយៀកកុងណឹងនៅពេញភ្នំនេះ ឆាំ ៧៥

ឃីមៈ ចុះ៧៥ មិនទាន់ទៅ

សនៈ ទៅ

ឃីមៈ ចុះអ៊ំទៅទំនាក់ទំនងធ្វើម៉េច?

សនៈ សុំវាទៅ សុំវាទៅទិញ

យឹមៈ ឲ្យមាសហ្វូន អត់មានថ្វីនដី មាំដបប៉ុន្មានដីទេ អ៊ំ?

សនៈ អត់មានគិតអញ្ចឹងទេ គិតតែមកថាមានលុយប៉ុណ្ណោះ រាប់មើលទៅហើយគិតទៅ ហើយឲ្យមក ។ ដូចជ្រូកអញ្ចឹងដេញជ្រូកទៅ ប្រាប់ថាជ្រូកមាន៤០ក្បាល ថាត្រូវការក្រណាត់លីឡុងយកខ្សែអង្រឹង យកថ្នាំពេទ្យ តាមអីតាមគេកំម៉ុង គឺថាវាចំណេញលើយើង ។ ប៉ុនដល់៧៩ វាមកជាប់គុកនៅ ខ្ញុំធ្វើប៉ូលីស ។ ចាប់មិនដឹងមូលហេតុអីដល់មកខ្ញុំឃើញ

យឹមៈ ចុះ អ៊ំចេះនិយាយវៀតណាមដែរ

សនៈ អត់

យឹមៈ ចុះម៉េចទាក់ទងគ្នាកើត?

សនៈ អានោះកាលណឹងដុះវានៅសាយហ្គ៉ វាឃួន ប៉ុនឃួននៅស្រុកខ្មែរ

យឹមៈ អ៊ំកាលយកមាសពីវគីឡូទៅ តើគេឲ្យប៉ុន្មាន?

សនៈ ច្រើនដែរ បានមកមាំទូកធំ មកដល់នេះដាក់ពីរឡានធំៗ

យឹមៈ តើជាទេ ពេលយកថាំមកព្យាបាល បៈជាខ្វះអត់ខ្វះ?

សនៈ មិនទៀតទេក្អួយជំងឺកាលណឹងយើងមិនដឹង បើគ្មានអីឆ្មុះមើលឲ្យដឹងថាខូចត្រង់នេះ ខូចត្រង់នោះ ប៉ុនយើងគ្រាន់ដឹងច្បាស់ថា បើកាលណាវាក ហើម ស្លេកអី យើងដឹងថាខ្វះជីវជាតិហើយ ។ យើងឲ្យបាយហូបឲ្យច្រើន ហើយមានថ្នាំរួម មិនមេនដាំថ្នាំបាត់ទេទាល់តែហូបដែរ បើអត់ហូបនៅតែអត់បាត់អញ្ចឹង ។

យឹមៈ ចុះ អ៊ំមានដឹងថាកាលគេរើសយកនារីចូលធ្វើពេទ្យណឹង គេមានរើសលក្ខណៈសម្បត្តិម៉េច

សនៈ មាន រើសយកកូនអ្នកអត់មានពាក់ព័ន្ធអី ដូចថាក្រុមគ្រួសារខ្ញុំអីអត់មាន ។ អ្នកណាដែលគេបំរុងចាប់ដាក់គុកនៅស្រុកអីណឹង មានបងប្អូននៅក្នុងអីអត់មានទេ ។

យឹមៈ មើលទៅស្រីៗពេលដែលចូលណឹងតើមានសារៈសំខាន់ទេចូលធ្វើពេទ្យធ្វើបដិវត្តន៍ឲ្យអង្គការ

សនៈ មាន សំខានតែរឿងព្យាបាលជំងឺណឹង

យឹមៈ ចុះដូចថាខាងកងទ័ពអី?

សនៈ ណើងក៏ដូចតែគ្នា ព្រោះព្យាបាលជំងឺប្រជាជន ទូទៅ យុវជនអីមកពេញទឹកពេញដីណើង ពេទ្យនៅជិតណាព្យាបាលណើង ។

ឃីមៈ ចុះស្រីៗណើងចង់ចូលពេទ្យអត់ទេ ឬក៏យើងទៅអូសយើងមក?

សនៈ អូចង់ម៉ាំណាស់

ឃីមៈ ម្នាក់ៗចង់ហ្នង

សនៈ ចង់

ឃីមៈ ហេតុអីបានគេចង់?

សនៈ ចុះធ្វើពេទ្យ ពេទ្យកាលនោះក៏ដូចពេទ្យសម័យនេះដេ ពេទ្យស្លៀកពាក់ស្អាតៗ ខ្មៅមែន ប៉ុនស្អាតយើងមានចុះទៅជាំជំណាំណា ។ មុនដំបូងគ្រាន់តែឲ្យព្យាមតែស្បោងក៏ចង់ព្យាយដែ

ឃីមៈ ចុះអ្នកអត់ចេះសោះ ដំបូងធ្វើម៉េចទៅ?

សនៈ មកដល់ឲ្យរៀនរាងសារ៉ាំង រៀនបោសប្រាសបន្ទប់អ្នកជំងឺគក់ខោអាវអ្នកជំងឺ

ឃីមៈ ចុះចាក់ថ្នាំអីចេះដែរពេទ្យណើង?

សនៈ ចេះ រៀនទាំងអស់ ឆ្នបចេះសឹងទាំងអស់ដល់យូរទៅ ។ ខ្ញុំហៅប្រជុំរាល់ខែ នៅកន្លែងខ្ញុំ ចេះឆ្នបទាំងអស់ ។ឯកទេសពេទ្យដេលខ្ញុំរៀនចុងក្រោយច្បាស់ ចេះជាងគេ ដូចថាយល់មានដុង យើងឆ្ងល់

ឃីមៈ ចុះយើងប្រុសណើងគេឲ្យទៅមើលគេឆ្លងទន្លេអីដែរ

សនៈ បើកាលណាអាណាពិបាកយើង ។ខ្ញុំមកដល់ស្រុកភ្លាមបង្រៀនយាយខ្ញុំឲ្យចេះធ្វើឆ្នបបាន ចិញ្ចឹម កូនរស់ គាត់ចេហធ្វើឆ្នបរហូតដល់ឥឡូវ

ឃីមៈ ចុះស្រីៗអស់ណើងមើលទៅរៀនដល់ថ្នាក់ទីប៉ុន្មាន?

សនៈ មានកិរិតវិជ្ជាតែក្មួយខ្ញុំមួយនៅផ្ទះនេះ ឥឡូវលក់មាសដូរមាសនៅផ្សារ តែមួយណើងរៀនដល់ថ្នាក់ទី៥ ឡើងទី ៤ ។ក្រៅពីណើងអត់ទេ គ្រាន់តែចេះមើលអក្ខការ

ឃីមៈ ចុះម៉េចអក្ខការគេអញ្ជើង?

សនៈ គេចង់អញ្ជើងវិញ កាលណើងមិនយកអ្នកចេះពេក ដូចថាច្រើនក្បត់

យឺម: អូ អ្នកបេះក្បត់

សនៈ អ្នកបេះ បេះគិត ដូចខ្ញុំបេហានឹងគេដែរ ម៉េចអត់អីៗ អត់ទេខ្ញុំនេះ បេះក្បួនសង្គមហើយ ខ្ញុំធ្វើអត់ឲ្យខុសទេ ដឹងគន្លាក់វា

យឺម: តាមពិតមើលឃើញសង្គមមាគ៌ាណឹងម៉េចដែរ អ៊ំ យល់ម៉េចដែរពេល អ៊ំនៅក្នុងរបបណឹង

សនៈ កាលណឹង ខ្ញុំអង្គុយចាំសើច អញ្ចឹងបានថាអាណិតអាក្មួយផ្ទះនេះ វាឆាប់ហើយ អាណឹង វាជាប់ឪប្អូនពីសង្គមចាស់ ដល់ហើយវាណឹងជាកម្មាភិបាលជំនាន់ប៉ុល ពតជាមួយខ្ញុំដែរៗ វាស្លាប់ឆ្នាំទៅក្រោយមកធ្វើប៉ូលីសដូចខ្ញុំ វាពាក់សក្តិបួន វាពាក់សក្តិបួនដែរៗ គេអួត ក្អេងក្អាងខុសពីមាគ៌ាសង្គមកនិយមៗអញ្ចឹងខ្ញុំពីរនាក់ណឹងកាលណាពួគេថា ខ្ញុំថាដល់ទៀត ហើយ រកព្រៃពួនមិនបាន ដឹងតើ ឃើញគេធ្វើខុស ហើយយើងអត់ហ៊ានថាគេ យើងនៅស្ងៀមៗ ដឹងអាក្រក់បុគ្គលិកអនុវត្តន៍ ទ្រឹស្តី និយាយពីគោលនយោបាយសង្គមកនិយម វែងណាស់ទៅមើល ល្អណាស់

យឺម: កាលណឹងគេយកមាគ៌ាអីមកបង្រៀន សង្គមនិយមប្រទេសណា?

សនៈ ពីចិន ម៉ៅសេទុងណឹងហ្នង

យឺម: ល្អ អ៊ំ ខ្ញុំមិនដែលអានផង?

សនៈ ក្មួយឯងធ្វើសាកមើល មនុស្សវាម៉េច ក្នុងទ្រឹស្តី ប៉ុនយកមកអនុវត្តន៍លោកម្ចាស់ថ្លៃហើយ

យឺម: អ៊ំមានចាំខ្លះទេ អ៊ំ?

សនៈ ខ្ញុំនិយាយតែរឿហូបម៉ាមុខទេ ក្មួយឯងមើលធ្វើសមូហភាព ដល់បានមកហូបសមូហភាព ហូបម៉ាថ្ងៃបីបួនដង ដល់ហូបតាមចំណង់ៗ ក្មួយឯងពិចារណា ហេតុអីខ្ញុំមិនចូលចិត្តជាមួយគេ នេះគ្រួសារខ្ញុំមួយដាំត្រសក់ ឪឡឹក បីស្រែដើម្បីគ្រប់គ្រងគ្រួសារខ្ញុំគ្នាបីបួននាក់ ខ្ញុំដាំខ្ទឹម ខ្ញុំដាំកញ្ចាយ ដាំដី ណឹងគ្រួសារតែមួយ ហើយដល់ពួគេថា ធ្វើសមូហភាពដល់ម៉ាកង ហើយហូបតាមចំណង់ យើងមិនឯកភាពជឿគេ បើយើងម្នាក់យើងធ្វើប៉ុណ្ណឹងហើយ ចុះទំរាំយើងទាំងអស់គ្នាធ្វើ យកទៅណាអស់ៗ ដល់ធ្វើ គិតទៅម៉ាសហករណ៍ដាំត្រសក់ ប្រហែលម៉ាម្ភៃស្រែ មនុស្សម៉ាចំហៀងឃុំធ្វើម៉ាម្ភៃស្រែៗ បើចំហៀងឃុំបើមានស្រែ៣ ភាគ ធ្វើឲ្យបាន២ភាគ៣ពីស្រែណឹងមើលអាណឹងបានច្រើនច្រើនៗ បើ២០នាក់ ៣០នាក់

មិនបានចេកម៉ាគុម្ពផង ហ៊ីស៊ីស្តីទៅ ។ អាណឹងគឺខុស ៗមាត់គឺខុស ចិនគេមិនមែនធ្វើអញ្ចឹងទេចិនបើសិនណាធ្វើដូចពួកឈឹងវាមិនធ្វើបានប៉ុណ្ណឹង ។ ឥឡូវនេះគេមិនចង់ធ្វើទេ អាសង្គមនិយមពាផ្ទៀង ។

យីម: កាលអ៊ំរៀនពេទ្យ គេរៀនបណ្តើរអនុវត្តន៍បណ្តើរ?

សន: រៀនបណ្តើរអនុវត្តន៍បណ្តើរ ៗចូលសាលាបានពីរម៉ោងចេញទៅព្យាបាល បងស៊ីគាត់គ្រាន់បើដែរ គាត់ប្រាប់អានេះជំងឺនេះវាពិបាកអញ្ចេះមួយៗ បើជំងឺគ្រុនចាញ់អី យើងងាយទេ កាលណោះមានប្រដាប់មើលមេរោគគ្រុនចាញ់ដែរ យើងមិនពិបាកទេ ប៉ុនជំងឺផ្សេងៗ ជំងឺទូទៅគាត់ប្រាប់

យីម: ពេល អ៊ំចូលណឹង តើប៉ុន្មានថ្ងៃបាន អ៊ំចេះចាក់ ចេះព្យាបាល?

សន: ចាក់ថ្នាំចេះតាំងពីអត់ទាន់ចូល

យីម: តើថ្នាំពេទ្យអីគេមានបង្រៀនសរសេរឬគ្រាន់តែប្រាប់យើង?

សន: បង្រៀនសរសេរមាំណាស់ បងស៊ីគាត់ហៅថាបញ្ញាវន្តដែរ គាត់សរសេរបារាំង បើគាត់សរសេរបារាំងគាត់សរសេរខ្មែរទៀត ។ កាលណឹងសរសេរបារាំងបានមានតែខ្ញុំ មួយនិងពេទ្យណាក់មួយនៅឃុំគូស ឥឡូវគេធ្វើគ្រូបង្រៀន

យីម: ចុះបុគ្គលិកប៉ុន្មាននាក់ដែលរៀនជាមួយ អ៊ំណឹង?

សន: ៦០នាក់ជាងម៉ាសាលា ធំ ហូបបាយ ហូបបបរអស់ម៉ាខ្ទះម្តងម៉ាពេល

យីម: មកពីណាខ្លះ?

សន: មកតាមស្រុក គេហៅគ្រប់ស្រុកទាំងអស់ មន្ទីរពេទ្យតំបន់

យីម: អ្នកដែលបានមករៀនណឹងសុទ្ធតែពួកពេទ្យតំបន់ ស្រីៗមានទេ?

សន: មាន ប្រុសច្រើនជាង

យីម: ពេលមុន អ៊ំ ដែលថាតាម៉ុកបញ្ជូនទៅណឹង តាម៉ុកអត់មាននិយាយប្រាប់ថាម៉េចទេ មុនចូលពេទ្យ?

សនៈ មិនមែនតាម៉ុកទេ ប្រធានមន្ទីរស្រុក គាត់អត់មាននិយាយថាម៉េចទេ ។ កាលណឹងបែប គេថាខ្ញុំចេះធ្វើពេទ្យអីធំដុំ ខ្ញុំធ្វើជាងណឹង ប៉ុនខ្ញុំមានសារ៉ាំងមានថ្ងៃនោះប្រធានឃុំញ៉ាំញ៉ាំង គាត់ឈឺ ថាឈឺក្តៅ កាលណឹងខ្ញុំមានថ្នាំអាណាសាំងណឹង ។

ឃឹមៈ ចុះ អ៊ំ មើលដូចដួនជឿនអីណឹងគាត់នៅដល់ឥឡូវ?

សនៈ ដួន ជឿន គាត់ដាច់ខាតហើយ ខ្ញុំដឹង ព្រោះវត់ទៅជាមួយគ្នាទៅក្នុងព្រៃជាមួយគ្នា ។

ឃឹមៈ ទៅដល់ណឹងជួប ដួន ជឿនដែរ?

សនៈ អត់ជួបទេ ប៉ុនខ្ញុំដឹងព្រោះខ្ញុំបេសកម្មកាលធ្វើប៉ូលីស គេឲ្យទៅធ្វើបេសកម្មនៅអន្លុងវែង នៅជរំ សាគធូ សាគបីអីណឹង

ឃឹមៈ ហឺ ដួន ជឿនណឹងគាត់ដាច់ខាតម៉េច អ៊ំ?

សនៈ គាត់ដាច់ខាតជាមួយប៉ុល ពត ។ មុនដំបូងត្រូវគ្នាណឹង ប៉ុនដល់ក្រោយមកបែកគ្នា

ឃឹមៈ បែកគ្នាឆ្នាំណា?

សនៈ បែកអាចុងក្រោយបំផុតឥឡូវណឹង ៩៨ ៩៩ ណឹង មកបែកគ្នាត្រឹមណឹង បែកគ្នាមកពីកំលាំងតាសែនបុកណឹង ។ ដួន ជឿន មកជាមួយតាម៉ុកមក ហើយប៉ុល ពតដាច់ខាត ។ខ្ញុំដឹងដោយសារនរីមាក់និយាយប្រាប់ទេថា ពេលដែលមេប៉ុល ពតរត់ ទៅពួនគេសែងទៅដាក់នៅភ្នំមួយ មិនដឹងណាទេ ខ្ញុំភ្លេចហើយហាវាមកនិយាយណឹង ហឺអន្តរក្សទាំងអស់គ្នាណឹងស្លៀកក្រមា ទៅណឹងសែងដាក់ប៉ុកអត់មានអន្តរមៅគ្រប់ទេ អញ្ចឹងគេរកអត់ឃើញទេ ។ ត្រូវធ្វើម៉េចបើអត់អន្តរស៊ី ពួកអស់ណឹងមិនចេញមក រកអន្តរ ស៊ីអញ្ចឹងគេទៅរកឃើញដោយសារអាណឹង ។ តាម៉ុករកឃើញ តាម៉ុករកសំលាប់ចោល

ឃឹមៈ រកសំលាប់ប៉ុល ពតណឹង

សនៈ ថី បានអត់សំលាប់ គាត់រកអត់ឃើញ គេធ្វើបានមុន ។មិនដឹងម៉េចទេ អាណឹងខ្ញុំអត់សួរ ដឹងទេអាណឹង ដឹងតាមគេនិយាយប្រាប់ ។

ឃឹមៈ គាត់សាហាវ ប៉ុល ពតមើលទៅ

សនៈ សាហាវ ដាច់ ខាត ។ អញ្ចឹងថាបញ្ញាវ័ន្តមួយចំនួនធ្វើឲ្យប្រជាជនស្លាប់ដោយសារខ្លួននិយាយមិនច្បាស់ និយាយបន្ទេមបន្ទំ ។ ខ្ញុំនិយាយរឿងមួយពេលយួនវ៉ៃវាំងមកដល់វត្តភ្នំខ្ទែង ឆ្នាំ៧៩ តាម៉ុកណឹងសរសេរសំបុត្រឲ្យមកខ្ញុំ ឲ្យខ្ញុំកប់ខ្មោចយុទ្ធជនម៉ាឡានសេអ៊ីមសេ ហើយខ្ញុំរៀបរទេះហើយ រៀបរត់ ពីរនាក់តាពូន តាសង្គមកិច្ច ពេទ្យស្រីឲ្យទៅមុនអស់អាលីង ។ អាអ្នកបើកឡានរត់បាត់ ហើយឡាននៅណឹងខ្ញុំពីរនាក់គាត់បេះបោះ ហើយគ្រាប់ ភីង ។អាណឹងនិយាយពីអំណាច ។ មុនណឹងតិច ខ្ញុំទៅសួរតាគិត ហើយប្រាប់យាយឲ្យធ្វើអង្ករដំណើបខខ្ញុំម៉ាតៅជង គាត់ធ្វើនៅសហករណ៍ ហើយខ្ញុំដុតក្រឡាន ខ្ញុំដើងដុតក្រឡានល្អលេខមួយ ។ដុតហើយខ្ញុំដាក់ទៅក្នុងឡាននៅមន្ទីរស្រុក យកទៅឲ្យគាត់ ។អាណឹង ខ្ញុំនិយាយពីមុន ដែលយួនមកដល់តិច ។ខ្ញុំជួបគាត់ តែខ្ញុំទៅដល់គឺកាត់រត់មកអោបខ្ញុំខ្ញុំតាគិត គណៈតំបន់២៥ណឹង ព្រោះមិត្តភក្តិជិតស្និត ។ពេលខ្ញុំទៅលើកនេះ ខ្ញុំមើលទៅក្រោមផ្ទះ ខ្ញុំឃើញ យីតាគិតឃើញឡានអញចូលមកហើយម៉េចអត់មករត់មក អញ្ចឹងបេះតែនឹកក្នុងចិត្ត តែខ្ញុំមើលទៅឃើញមនុស្សនៅអង្គុយនៅវិឡាជិតផ្សារតាខ្មៅ ឃើញមាឌធំបុិនស ស្គុសខ្ញុំថាអ្នកណា ព្រោះខ្ញុំអត់ស្គាល់ប៉ុលពត ។

ឃីមៈ អូ ៧៩ ណឹង

សនៈ បាទ អាណឹងយួនចូលដល់អ្នកលឿងហើយ ។ដល់ខ្ញុំឈប់ឡានយកឥវ៉ាន់ចេញ បានគាត់ដើរមកសួរថាសនមកជាមួយអ្នកណា ខ្ញុំថាខ្ញុំមកជាមួយយាយគៀន ប្អូនតាម៉ុកប្រធានពេទ្យ ។ ហើយយាយបឿនមួយទៀត អនុស្រុក១០៥ ណឹង មកថ្ងៃមុន មករកខ្ញុំខ្ញុំចង់ជួបដែរណឹង ។

ឃីមៈ អូ ពុស្សូរថាមកធ្វើបុណ្យ

សនៈ ដល់គាត់មក គាត់សួរខ្ញុំ ខ្ញុំបេះឆ្ងល់ សួរថាតាសនឯងមកធ្វើអី ខ្ញុំថាយួនៗមកដល់ជិតហើយរត់ទៅពួនណាអីណា គាត់ថា អញ្ចឹងឈប់សិន ។ខ្ញុំសួរថាអ្នកណា គាត់ថាប៉ុល ពត ។មកដល់មុខអាពត សួរផ្ទាញ់ផ្ទាលខ្ញុំ សួរថាតាសន អាណាអ្នកដុតក្រឡានណឹង បុិនគាត់ដឹងថាខ្ញុំដុតហើយ តែគាត់សួរមុខតាពត សួរពើ ។ហើយតាពតណឹងសួរថា ចុះគាត់នៅណា ។តាគិតថា គាត់ពេទ្យស្រុក១០៥ គេផក់ក្បាល ហើយគេសួរយកអង្ករពីណាអីពីណា

ហើយខ្ញុំមិនទាន់ឆ្លើយតាគិតថាយកអង្ករពីយាយជីក គាត់ដាក់ឆាំរប្រពន្ធខ្ញុំនឹងថាយាយជីក ។ ខ្ញុំថាបាទ អញ្ចឹងតាសនឯងបិតឲ្យខ្ញុំប្អូន ឲ្យស្អាត ។ ក្រឡានខ្ញុំមិនមែនដុតទេឆ្អើរ ហើយមានក្រែមួយប៉ុល ពតអង្គុយស៊ីអស់៤ ហើយបេកអំបូងម៉ាស្និត ហើយឲ្យខ្ញុំបិត ៧ ៨ទៀតយកទៅសមរភូមិឲ្យនិរសាយកទៅឈ្មោះអាន្ទួនមួយទៅពីនេះដែរ យកទៅឲ្យសិនសេន ។អាណឹងខ្ញុំចង់និយាយពីអំណាចមុិញ ។ សនឯងបំរុងទៅណា គាត់អត់និយាយម៉ាម៉ាត់ទេ និយាយពីទឹកភ្នែកយំប្រហែលម៉ាផ្ទិល តាគិតណឹង ។ តាសនឯងនិយាយពីដើម ប៉ុន្មានត្រូវទាំងអស់ អត់ខុស ។ ខ្ញុំប្រាប់អារឿងបែកវណ្ណៈណឹង ថាបែកវណ្ណណឹងធ្វើឲ្យមនុស្សវៃគ្នាងាប់ទេ ហ្អែងណឹងដើងវៃ ចុះយើងខ្លាចអីដឹងថាមិត្តភក្តិ ពេលយប់ដេកអោបគ្នា យំ លែងនិយាយគ្រាន់ប្រាប់ថាពេលទៅវិញ យកប្រពន្ធអញទៅផង ។ប្រពន្ធគាត់នៅនឹងដែរ ហើយឲ្យយកមាសនៅក្រោមគ្រែគាត់ ប្អូនចានដែកធំៗ ថាយកឥវ៉ាន់អង្គការទៅផង ខ្ញុំថា តាឯងចេះតែថាហើយ អង្គការណាទៀត ខ្ញុំមិនយកទេ បើឲ្យប្រពន្ធខ្ញុំយកទៅ អាណឹងរបស់ក្តៅក្រហាយណឹង ងាប់ខ្ញុំ ប្រហែលមិនបានដល់នោះផង ។ ហើយក៏ហីទៅ ខ្ញុំក៏យកប្រពន្ធគាត់មក គាត់មកតាមក្រោយ យួនកាក់ពីប អាកាត់ៗគាត់ដឹកមាសណឹង ហីគាត់ជិះឡានស៊ីបនៅក្រោយគាត់ក៏ថយទៅក្រោយវិញទៅ ។ មាសណឹងយួនយកអស់អាលីង ប្អូនចានដែក ។ បើសិនណាខ្ញុំចង់យកវិញ តែខ្ញុំមិនដែលទេ ដូចនៅពេទ្យអ្នកជំងឺស្លាប់មានមាសរហូតដល់បីប្អូនប្រាំដំលឹងអីណឹង ក្នុងម៉ាឆ្នាំ ខ្ញុំបញ្ជូនឲ្យទៅគេវិញ មិនដែលប៉ះពាល់អីតិចទេខ្ញុំអត់ឲ្យយាយនេះដឹងទេ យាយនេះចង់បាន ។ រត់ទៅដល់ត្រពាំងអណ្តើតប្រធានពាណិជ្ជកម្មស្រុកកាន់មាសម៉ាក្រវ៉ង់ប្រហែលប្អូប១០ ដំលឹង អ៊ីៗឯងយកឥវ៉ាន់អង្គការទុកផង ខ្ញុំថាទេ យកទៅវិញ ខ្ញុំអត់ឲ្យដឹង យាយនេះទៅឆ្លូតទឹកជិតណឹង បើនៅជិតគាត់គាត់ឲ្យយក បានមកចាយ មកពីរត់វិញដែរណឹង ប៉ុនខ្ញុំវាដាច់ខាតកាលណឹងធ្វើអី អត់ឲ្យប៉ះពាល់ទេ ។

ឃឹមៈ អ៊ំតាគិតណឹងគាត់ធ្វើប្រធានតំបន់តាំងពី៧៥ ដល់៧៩?

សនៈ អត់៧៥ ទេ ។កាល៧៥ ៧៦ ៧៧ គាត់នៅលេខាស្រុកត្រាំកក់ ដល់ ៧៧ ជិត៧៨ នឹងបានគាត់ទៅនោះ

ឃីមៈ គាត់យំហ្មង

សនៈ គាត់យំ គណៈស្រុកអីណឹងសុទ្ធតែកាលីបអន់ជាង ចុះគិតគូអីអត់ឃើញ ។

ឃីមៈ ពេល អ៊ីចូលរៀនពេទ្យគេឲ្យអ៊ីធ្វើម៉េចខ្លះ ដំបូងដែលអត់ចេះអីសោះ?

សនៈ ចេះខ្លះដែរគេណែនាំរៀនទ្រឹស្តីតាមឯកសារពេទ្យត្រឹមត្រូវមានសៀវភៅពេទ្យណឹង សំរាប់មើលរៀនមុនដំបូងគេឲ្យរៀនពីដងខ្លួនមនុស្សទាំងអស់ណឹង ។ ច្បាប់ពេទ្យគេមានវិន័យត្រឹមត្រូវណាស់ ប៉ុនដោយផ្នែកពេទ្យយោធាខ្ញុំមិនដឹងទេ ពេទ្យយោធាគ្មានរៀនចូលគ្នាទេ ។ មិនដឹងគេរៀនសូត្រណាអីខ្ញុំអត់ដឹងទេ ប៉ុនមកបើកថ្នាំឃើញមកបើកថ្នាំនៅពេទ្យខ្ញុំដូចមកពីកំពង់សោមអីណឹង គេដឹងថាខ្ញុំសំបូរថ្នាំពេទ្យ

ឃីមៈ ចុះ អ៊ីគេឲ្យរៀនប៉ុន្មានម៉ោង និងអនុវត្តន៍ប៉ុន្មានថ្ងៃ?

សនៈ រៀន បីខែពេទ្យបឋម ម៉ាថ្ងៃរៀន៥ ម៉ោង ២ម៉ោងរៀនទ្រឹស្តី ហើយបានអនុវត្តន៍

ឃីមៈ ចុះកាលឆ្នាំ៧៦ណឹង នៅពេទ្យកន្លែង អ៊ីរៀនណឹងមានមនុស្សចូលច្រើនទេ អ្នកជំងឺ

សនៈ ចូលច្រើន មកតាមភូមិឃុំ ច្រើនណាស់ ច្រើនដល់ ៤០០នាក់ ដល់ពេលស្លាប់ៗម៉ាថ្ងៃ ៥នាក់ក៏មាន រហូតដល់ ១៥នាក់

ឃីមៈ សលាប់អស់ ៤០០នាក់ណឹង

សនៈ មិនអស់ទេ ជាចេញទៅវិញ ។ ជាពិសេសបងប្អូន១៧ ត្រូវតែស្លាប់ ព្រោះហើម ខ្ញុំថាខ្វះជីវជាតិ ។ជាពិសេសជំងឺខ្វះជីវជាតិ

ឃីមៈ ចុះពួកមូលដ្ឋានអត់សូវខ្វះទេ?

សនៈ គេអត់សូវខ្វះទេ គេអ្នកមូលដ្ឋានគេដឹង គេដឹងកន្ទុកកន្លែងរកស៊ីបាន រកស៊ីក្រៅបាន ដូចថាយាយខ្ញុំអញ្ចឹងគាត់ដឹងអ្នកណានៅគ្រប់គ្រងក្នុងភូមិនេះ គាត់មកឃុមឃិតបានដូងអីហូបនាយអាយ ។

ឃីមៈ ចុះពួក១៧ មេសា មកពីភំពេញ បក៏មកពីណាខ្លះ?

សនៈ មកពីភ្នំពេញ មកពីកំពង់សោម មកពីណាគ្រប់ទាំងអស់ណឹង

ឃីមៈ ពេលគេឲ្យអ៊ីចូលគេមានប្រាប់ថាមានគោលការណ៍អីបានគេឲ្យចូលពេទ្យ?

សនៈ ស្រុក១០៥ អត់ពេទ្យហ្មង

ឃីមៈ ប៉ុន្តែភាគច្រើននារី ម៉ាតាកែវខ្ញុំរាប់មើលប៉ុន្មានរយនាក់ នេះគ្រាន់ខ្ញុំដឹងត្រួសៗពេទ្យនៅភ្នំពេញទេ?

សនៈ ច្រើន ចុះគ្រាន់តែនៅកន្លែងខ្ញុំ ពេទ្យ៩៦ ដក យុវជនចេញ១២ នៅសល់ ៧០ជាង

ឃីមៈ ចុហ អ៊ីមានដឹងថាពេទ្យតំបន់មានប៉ុន្មាននាក់បុគ្គលិក?

សនៈ ពេទ្យតំបន់ច្រើនណាស់ជាង១០០នាក់ ជិត២០០នាក់ ចុះទំរាំម៉ាឃុំ ១៥នាក់ ១២ នាក់ អីទៀតច្រើនណាស់

ឃីមៈ ពេទ្យតំបន់ធំមែនទែន?

សនៈ ធំ

ឃីមៈ គេមានបច្ចេកទេសគេត្រឹមត្រូវដែរ?

សនៈ គេគ្រាន់បីដែរ ពេទ្យតំបន់បងសីណឹង គ្រាន់បើ ៗ បងសីជំហរគាត់ល្អ ដូចថាឃើញគេធ្វើខ្លាំងពេក គាត់គ្រាន់តែក្រវីក្បាល ហើថ្ងៃណាគាតបង្រៀន គាត់ជិះម៉ូតូមកមានឡារ៉ូសមេរ៉ីកាលមួយៗម្នាក់ ធ្វើថ្នាំពេទ្យព្យាបាលជំងឺ ពិភាក្សាគ្នា ពិគ្រោះគ្នាអញ្ចេហមួយៗ គាត់គ្រាន់បើ ខ្ញុំតូចតាចជាងគាត់ ប៉ុនការយល់ដឹងប្រហាក់ប្រហែលគ្នា ៗ គាត់ចូលចិត្តខ្ញុំ

ឃីមៈ ចុះបច្ចេកទេសពេទ្យគេអនុវត្តន៍ម៉េចខ្លះនៅក្នុង?

សនៈ អនុវត្តន៍ បើយើងអត់ចេះព្យាបាលទូទៅ គាត់ត្រូវអនុវត្តន៍ជាក់ស្តែងអ្នកជំងឺណឹងហ្មង ៗ ថាអ្នកជំងឺក្រែនេះឈឺអញ្ចេះមួយ ៗ ដូចតែពេទ្យយើងអញ្ចឹង

ឃីមៈ ចុះរបៀពិសោធន៍ថ្នាំ មើលជំងឺអីគេធ្វើម៉េច គេមានវិភាគមេរោគដែរ?

សនៈ អត់ទេ កាលណឹងគ្មានទេ មានតែមេរោគគ្រុនចាញ់តែម៉ាមុខទេ ក្រៅពីណឹងអត់ដឹងទេ

ឃីមៈ ចុះអត់ដឹងអញ្ចឹង យើងព្យាបាលម៉េច?

សនៈ អញ្ចឹងបានថា យើងព្យាបាលតាមទ្រឹស្តី អាណឹងត្រូវតិច ខុសច្រើន

ឃីមៈ អ៊ីការព្យាបាលភាគច្រើន តើជាច្រើនជាង ឬស្លាប់ច្រើនជាង?

សនៈ ជាច្រើនជាងហើយស្លាប់ក្នុយឯងមើលអ្នកជំងឺរាប់ពាន់នាក់នៅក្នុងពេទ្យខ្ញុំអ្នកជំងឺខ្ញុំប្រហែលជាពីរពាន់នាក់ដែលព្យាបាល តាមលេខរៀងព្យាបាល ស្លាប់ជាង៤០០នាក់ ណឹងគ្រាន់តែនៅពេទ្យស្រុក មាំស្រុកត្រាំកក់

យឹមៈ តាំងពីឆ្នាំណាដល់ឆ្នាំណា?

សនៈ តាំងពីខ្ញុំធ្វើពេទ្យរហូតដល់ចប់

យឹមៈ អ៊ំអ្នកកត់បញ្ជីបានដឹង?

សនៈ សុទ្ធតែគេធ្វើរបាយការណ៍ឲ្យមក ៤០០នាក់ជាង

យឹមៈ អញ្ចឹងបានន័យថាមិនសូវស្លាប់ដែរ រឿងឈឺអីណឹង?

សនៈ យី មិនសូវស្លាប់ម៉េចក្នុយ ស្លាប់ច្រើនណាស់កាលណឹង

យឹមៈ ស្លាប់ជាង៤០០នាក់ណឹងតែនៅពេទ្យទេ នៅតាមភូមិឃុំអីយើងអត់ដឹងទេ?

សនៈ នៅភូមិឃុំមិនសូវមានទេ

យឹមៈ ពេល អ៊ំរៀនពេទ្យ តើគេមានឲ្យហ៊ឹកហ៊ឺនម៉េចខ្លះដើម្បីឲ្យក្លាយជាគ្រូពេទ្យល្អ?

សនៈ ប្រាប់គេណែនាំ វិន័យ រៀនសូត្របច្ចេកទេស

យឹមៈ ចុះគេមានដាក់វិន័យអីធំដុំទេ នៅពេទ្យតំបន់ណឹងវិន័យគេអីខ្លះ?

សនៈ មានផ្នែកនយោបាយ និងខ្មាំង គេហៅថាខ្មាំង ខ្មាំងជ្រៀតជ្រែកតាមអ្នកជំងឺ ឬតាមគ្នាដែរ គេឲ្យពិនិត្យបច្ច័យដែរ ហីវាមានអញ្ចឹងមែន

យឹមៈ ចុះខ្មាំងណឹងម៉េចទៅ?

សនៈ អញ្ចឹងបានខ្ញុំថា ចូលចិត្តមើលឃើញអ្នកធ្វើខុសណឹង ថាខ្មាំងណឹង បុគ្គលិកអ្នកថា អញ្ចឹងកាលនឹងខុសច្រើនណាស់

យឹមៈ មើលឃើញខុសម៉េច?

សនៈ ឧទាហរណ៍ ដូចប្រពន្ធបងសី ខ្ញុំមិនវៃប្រហារគាត់ទេ គាត់ខុស គេចាប់គាត់ទៅ ដាក់គុក ខ្ញុំវៃតំលៃគាត់មាបាតុភាពរឿងគាត់លាបម្សៅពេញខ្លួនពេលយប់ឡើង ។ ខ្ញុំដឹងកាលណឹងខ្ញុំទៅរៀនពេទ្យមធ្យម ។ ហើយគាត់នៅពេទ្យ គាតធាត់ហើយស គន្ធុល តែប៉ណ្ណឹងបើតាម

ខ្ញុំមើលហើយគាត់មានសីលធម៌ជាមួយបុគ្គលិកពេទ្យៗខទាហណ៍ក្មួយឯងណឹងមកធ្វើ ពេទ្យនៅណឹងដែរ ខុសឆ្គងអី គាត់ស្តីដេរ គាត់ កាច បងប្អូរណឹង ។ ខ្ញុំមានកូនមួយនៅ ពេទ្យណឹងដែរ ធ្វើបាបកូនខ្ញុំដែរ ប៉ុនខ្ញុំមិនដែលមាត់ ។

ឃីមៈ តាមពិតគ្រាន់តែប៉ុណ្ណឹងទេគេចោទថាក្បត់ ?

សនៈ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ក្រៅពីណឹងទៀតខ្ញុំដូចអត់ដឹង ហីបើមានច្រើនជាងណឹងទៀតពួកណឹងគេ មិនមែនឲ្យវែថ្មអីទេ គេយកទៅបាញ់ចោលទាំងថ្ងៃត្រង់ណឹង ។

ឃីមៈ លាបម្សៅអីបានដែរសម័យណឹង ហើយប្រជាជនគេអត់ឲ្យប្រើម្សៅទេ?

សនៈ អត់សោះហ្មង

ឃីមៈ ឌី អ៊ំ?

សនៈ អាណឹងគេហៅសតិអារម្មណ៍ពួកសក្តិភូមិ

ឃីមៈ នៅពេទ្យពេទ្យតំបន់ណឹងមានខុសសីលធម៌អីដែរ?

សនៈ មាន បងសីគាត់អនុវត្តន៍ដូចខ្ញុំដែរ ខ្ញុំរៀនពីគាត់ដែរ ខ្ញុំមិនឆេវឆាវ មិនស្ទូវមាត់ករ ច្រើនយខ្លួនទៅពាំង ប៉ុនមានរឿងអីធំពេកគាត់អត់ហ៊ានទេ

ឃីមៈ ពេលដែល អ៊ំធ្វើពេទ្យតើគ្រូពេទ្យមានភារកិច្ចធ្វើអីខ្លះ តាំងពីប្រលឹមដល់យប់?

សនៈ ជាពិសេសរឿងព្យាបាលជមងឺ អ្នកព្យាបាលត្រូវតែព្យាបាលតាមវេន តាមក្រុម បើក្រុមណាត្រូវព្យាបាលចាប់ព្យាបាលហ្មង តាំងពីព្រលឹម រហូតដល់ពេលបាយល្ងាច ដល់យប់បើក្រុមណាធ្វើពលកម្ម ដល់ខែស្ទូងឲ្យទៅស្ទូងម៉ាក្រុមនៅស្រែជុំវិញមន្ទីរពេទ្យ ។ សន្កមនិយមអញ្ចឹង ផែនការគេដាក់ឲ្យ ។

ឃីមៈ ចុះគ្រូពេទ្យមើលទៅមានយកចិត្តទុកដាក់អ្នកជំងឺទេ?

សនៈ យកចិត្តទុកដាក់ណាស់ពួកពេទ្យតំបន់ណឹង

ឃីមៈ គេមានគិតឋានៈអីទេ?

សនៈ អត់ទេ

ឃីមៈ ចុះខុបមាថាមានគណៈស្រុក ឬអ្នកណាមកធំលើណឹងដូចជាប្រធានតំបន់អីមានដែលមកសំភាន់ពេទ្យណឹងទេ?

សនៈ ខ្ញុំមិនដឹង បើកន្លែងខ្ញុំមានតែឃុំ

ឃីមៈ ចុះនៅពេទ្យតំបន់ណឹងមានរបជាជន១៧មេសាទៅសំភាន?

សនៈ មាន

ឃីមៈ អឺបុគ្គលិកពេទ្យណឹងមានពួក ១៧ មេសាទេ?

សនៈ បុគ្គលិកពេទ្យអត់សោះហ្នឹង

ឃីមៈ ចុះថីបានគេអត់យក?

សនៈ មិនដឹងម៉េច មិនដែលចាប់អារម្មណ៍ផង រៀនបុគ្គលិកពេទ្យណឹង បើកាលណាវាខ្លះខ្ញុំទៅប្រជុំអីស្នើហ្នឹង ដល់នេះស្រាប់តែឃើញគេបញ្ជូនមនុស្សមក ទំរាំគេកសាងកម្លាំម៉េច អត់ដឹងទេ ។

ឃីមៈ ចុះ អឺអត់មានដឹងថារើសអញ្ចេះ យកអពោះអីទេ?

សនៈ អត់ទេ

ឃីមៈ ចុះពេលអ្នកជំងឺមកសំភានពេទ្យ អ្នកជំងឺណឹងមានបានទទួលផលប្រយោជន៍អីពីពេទ្យទេ

សនៈ អត់មានទេ

ឃីមៈ ចុះ អឺវិញជាពេទ្យអង្គការគេផ្តល់ការទទួលខុសត្រូវម៉េចខ្លះ តើគេយកចិត្តទុកដាក់ទេ?

សនៈ គេយកចិត្តទុកដាក់ទេ អាណឹងកាលនៅមន្ទីរស្រុក គេហៅទៅប្រជុំកសាងសតិអារម្មណ៍ ឲ្យមើលប្រជាជនឲ្យល្អ គេនិយាយល្អដែរ

ឃីមៈ ចុះអឺមានដែលទទួលការសរសើរពីអង្គការទេ?

សនៈ អត់ទេ មានតែគេស្តីរាយការណ៍ប្រាប់គេថាខែណោះ ស្លាប់អស់១២ហើយ គេស្តី គេថាមើលជំងឺមិនជា

ឃីមៈ ចុះពេលគេស្តីតើអឺថាម៉េចទៅ?

សនៈ ខ្ញុំអត់ហ៊ានមាត់

ឃីមៈ ចុះ អ៊ំអត់មានប្រាប់គេថាខ្វះជីជាតិទេ?

សនៈ អាណឹងថា ថាតាំងពីលើកមុន ថាខ្វះជីវភាព គេវៃប្រហារសហករណ៍គេ អាណឹងយើងបញ្ជក់មូលហេតុនៃការស្លាប់

ឃីមៈ ចុះរបៀបបញ្ជូនអ្នកជំងឺ គេធ្វើម៉េចខ្លះទំរាំមកដល់ពេទ្យ?

សនៈ បញ្ជូនអ្នកជំងឺមានពេទ្យផ្សេងជាអ្នកបញ្ជូនមក ពេទ្យឃុំបញ្ជូនមកពេទ្យស្រុក ពេទ្យស្រុកបញ្ជូនមកពេទ្យតំបន់

ឃីមៈ តើមានសំបុត្រអីទេ?

សនៈ មានសំបុត្រសរសេរត្រឹមត្រូវ ។ជួនកាលគ្នាអត់បានអីហូបពីព្រឹកមកធ្វើពលកម្មនៅតាមកងអីឈឺខ្យល់អីគេនាំមកពេទ្យ

ឃីមៈ ចុះបើអត់មានសំបុត្រតើគេទទួលគេ ?

សនៈ អត់ទេ យើងត្រូវតែទទួល យើងអត់មានប្រកាន់ត្រូវតែទទួលទេ គឺអត់មានប្រកាន់ខាងណាណីទេ ខ្ញុំអញ្ចឹងខុសគេ ។ ខ្ញុំដែលយកចោរមកមើលដែរកាលណោះ ។ចុះអាណាដឹងថាចោរធាតពិតខ្ញុំភ័យដែរណឹង ពេលដែលដឹងថាចោរ ។ មានមនុស្សមួយរត់ពីកងដើរឆ្កេកឆ្កាច ដើរទៅនៅនេះទៅនៅនោះ ស្រាប់វាមកវាឈឺ ដេកឈឺនៅផ្ទះ ខ្ញុំទៅឃើញ ក៏យកមកដេកពេទ្យ ។វាក៏ទៅលួចអង្ករ លួចសាច់ជ្រូកគេនៅណា ។ គេមករកឃើញនៅក្នុងពេទ្យខ្ញុំនេះសឹងដាច់ខ្យល់ងាប់ ។ ដល់ហើយខ្ញុំភ័យខ្លួនឯង ។ កាលណឹងតាគិត ឬតាជឹមទេនេះ អូ តាសាន ចុងក្រោយបំផុត តាសានប្អូនថ្លៃតាម៉ុក គេឲ្យខ្ញុំនិយាយឲ្យច្បាស់មើល ម៉េចក៏យកចោរមកដេកពេទ្យ ។ ខ្ញុំនិយាយតាមហូរហែដែលខ្ញុំយកមក តែតាសានណឹងគាត់ប្រូវីស័រ គាត់អ្នកចេះដឹង ។ ម្លោះហើយចុងបញ្ចប់ដែលខ្ញុំភ័យខ្លួនណឹង បានគាត់ប្រាប់ថាយើងពេទ្យអ្នកណាក៏មើលទៅ ចោរក៏ដោយអីក៏ដោយ ប្រាប់កន្លែងសន្និបាតទៀត ។ អូខ្ញុំដូចដើរលើអាកាសអត់ដឹងអញ្ចឹងកាលមុនភ័យ ។

ឃីមៈ នៅកន្លែង អ៊ំមានបញ្ជូនបុគ្គលិកពេទ្យទៅរៀននៅភ្នំពេញ ម៉ាវគ្គប៉ុន្មាននាក់?

សនៈ  ទៅរៀនម៉ាវត្តគ្រូនចាញ់មុនដំបូងពីរនាក់ក្មេងឈ្មោះម្នាក់ ម្នាក់ឈ្មោះហេងជាមេភូមិត្នោតធំ ឃុំអូ សារាយ ។ គ្រូនចាញ់ទៅពីវត្ត ឆ្នាំ ៧៨ ៧៩ អាហេងណឹងមកអត់ទាន់ដល់ផ្ទះផង ជួបខ្ញុំពាក់កណ្តាលផ្លូវ វារត់ពីភ្នំពេញមក ។

ឃីមៈ  ចុហហេតុអីបាន អ៊ំអត់ទៅរៀនខ្លួនឯងអញ្ចឹង?

សនៈ  គេអត់ឲ្យទៅ ហើយខ្ញុំមើលទៅដូចថា អាឯងមេលមិនបានឲ្យគេមើលម្តង

ឃីមៈ  ចុះបើយើងលើកសំណើរទៅលើគេមានយកចិត្តទុកដាក់ទេ ឧបមាថាប្រជាជនខ្វះជីវជាតិ ត្រូវធ្វើអញ្ចេះមួយៗ តើគេមានអនុវត្តន៍តាមយើងទេ?

សនៈ  អាចដែរ អាចបានម៉ាចំនួនដែរ ឧទាហរណ៍ថា កាលណោះគេឲ្យម្ហូបខ្ញុំអត់ទៀតទាត់ ដល់ពេលនោះខ្ញុំលើកថាខ្វះជីវជាតិ គេប្រាប់ ចុះទៅប្រជុំ ប្រធានពេទ្យ និងប្រធានឃុំទៅជាមួយគ្នា គេប្រាប់ប្រធានឃុំទាំងអស់ថា បើពេទ្យស្រុកទៅហូប ត្រូវឲ្យ កុំឲ្យមាន់ តែត្រូវឲ្យជ្រូក ឬឲ្យគោ ព្រោះមាន់អត់មាន ។ អញ្ចឹងតាំងពីណឹងមកគេយកចិត្តទុកដាក់ដែរ បើថាតាចាយៗដែលជាលេខាស្រុកដែរ និយាយពីរឿងរាកមួល ស្ដាប់អីណឹងគាត់ស្តីឲ្យខ្ញុំច្រើនណាស់គាត់ថាឲ្យខ្ញុំ គិតបបួលគ្នាដាំត្របែក យកត្រួយត្របែកបុកឲ្យអ្នកជំងឺ គាត់បេះអក្សរតិច ។ ហីពីចារណាមើលលេខាស្រុកនិយាយអញ្ចឹង យើងមិនអន្តុយចាំសើច ។ គេនិយាយពីរើ បាក់ទ្រម គេគ្រស៊ីក្ខីនអីណា គាត់និយាយាពីរឿងត្រួយត្របែក ។

ឃីមៈ  ចុះ អ៊ំអត់មានមាត់តតាំងអី?

សនៈ  អត់តតាំងទេ ប៉ុនចាញ់ខ្ញុំ មានម៉ាថ្ងៃនោះធ្វើសន្និបាតនៅតាកែវកន្លែងភូមិភាគ ប្រហែលខ្ទង់ឆ្នាំ៧៧ ៧៨ ណឹង គាត់ទៅធ្វើសន្និបាត តាចាយណឹង គាតជាមនុស្សក្រផុតលេខអាវណ្ណៈល្អរបស់សង្គមនិយម ដល់ធ្វើបានពីរថ្ងៃរត់មក នៅម៉ោង១យប់ និរសាគាត់ទៅដាស់ខ្ញុំថា តារាកមួលប៉ុន្មានថ្ងៃនៅតាកែវ ឥឡូវមកនេះឲ្យពូឯងទៅមើល ខ្ញុំថាម៉េចហើយតា ហី មិនកើតទេសនអើយ ខ្ញុំថាចុះតាកែវអត់មានដើមត្របែកម៉េចតា ហ៊ី សនឯងកុំនិយាយលេងខ្លាំងណាស់ ។ ខ្ញុំថាខ្លាំងម៉េចក្រែងប្រាប់ឲ្យខ្ញុំបុក ត្របែកប៉ុន្មានត្បាល់ៗរឿងរាកមួលអញ្ចឹង ។ខ្ញុំពុថាយកត្រួយត្របែកនិងចេក ខ្ញុំថាមិនដឹងពុអគ្គការ ថាអញ្ចឹងខ្ញុំថា

តាមអង្គការ ។ ចុះខ្ញុំខ្លាចអី គាត់ហៅថាមនុស្សកាលីបអន់ដល់ហើយខ្ញុំយកថ្នាំ ភាគមួល ចាក់មាំម្ជុលទេស្រាប់មាត់ហ្នឹង ។

ឃីមៈ ចុះអង្គការមានដាក់វិន័យលេ អ៊ំម៉េច ឲ្យអនុវត្តន៍អីម៉េចក្នុងពេទ្យ ទេិគេដាក់បទបញ្ញាឬ យើងអនុវត្តន៍ខ្លួនយើង ឬគេ?

សនៈ គេដាក់បទបញ្ញាតែថ្នាំពេទ្យទេ ខ្ញុំដែលខុសតែមួយទេ គឺខ្លាចមានខ្មាំងនៅក្នុងណឹង តែប៉ុណ្ណឹង

ឃីមៈ ចុះគេមើលលក្ខណៈម៉េចថាខ្មាំង?

សនៈ មានពេលមួយខ្ញុំមិនប្រាប់គេ មាន មានទាហានទៅធ្វើវិទ្ធង្សា បាចគ្រាក់ ទាហានគេប្រឆាំង ជាមួយលទ្ធិណឹង

ឃីមៈ អ៊ំអត់ប្រាប់អង្គការ

សនៈ ប្រាប់តែអត់ប្រាប់ឈ្មោះ យើងអត់ដឹងដែរ ហើយយាមកាម

ឃីមៈ អ៊ំកាល អ៊ំថាខុសសីលធម៌ណឹង ពេលគេដាក់ទារុណកម្ម តើគេមានការលើកលែងទោសទេ

សនៈ លើកលែងទោសតែមួយចំនួន ក្នុងម៉ារយៈ ពេលបីខែអីណឹង ។ ចំពោះកងចល័តដែលខ្ញុំ កាប់បានអត់មានស្លាប់ទេ តែស្លាប់ច្រើនដូចស្លាប់តាមផែនការ ដូចថាផែនការ បើផ្នែក យោធាតាំងពីពាក់អាតស៊ីដង់ឡើង ឲ្យតែមានឋានៈគេសំលាប់ចោលទាំងអស់ បើផ្នែករដ្ឋបា លត្រឹមជំទប់លេខមួយឡើង ត្រូវសំលាប់ទាំងអស់

ឃីមៈ ចុះម៉េច អ៊ំដឹងថាមានផែនការណឹង?

សនៈ ចុះបើគេប្រាប់អញ្ចឹង

ឃីមៈ អ្នកណាគេអ្នកប្រាប់ឈ្មោះអី?

សនៈ គណៈស្រុកគេប្រាប់ ពេលទោសន្និបាតប្រាប់ ហើយខ្ញុំមានពីសោធន៍ជាក់ស្តែង ខ្ញុំមានប្អូន មួយនៅរាល់ថ្ងៃ វានៅយុវជន វានៅភ្នំពេញវាពាក់អាត់ស៊ីដង់ ខ្ញុំអត់ដឹងថាវាពាក់អី ដល់ ពេលចេញមក មកផ្ទះវានៅលីវ ថ្ងៃអញ្ចឹងគេប្រជុំ គេប្រាប់ថាប្រជាជនក្នុងមកច្រើន ណាស់ អ្នកណាធ្វើទាហានថាអត់ធ្វើអីចឹង ខ្ញុំក៏អត់ដឹងថាម៉េចដែរ គ្រាន់ប្រាប់ថាឲ្យចាំមើល

ដឹងអ្នកណាពាក់សក្តិ ត្រឹមអាត់ស៊ីដង់ឡើតត្រូវបញ្ជូនឲ្យគេធ្វើការចោល គេប្រាប់អញ្ចឹង គណៈស្រុក កាលណាណឹងពួកណឹងរត់ចេញមកពីភ្នំពេញ

ឃឹមៈ អូ ឆ្នាំ៧៥

សនៈ អាចឹងខ្ញុំមានប្អូនមួយពាក់អាតស៊ីដង់ចេញពីភ្នំពេញមក ធ្វើប៉េអឹម ដល់ពេលយប់ម៉ោង ប្រហែលមួយ ម៉ោងពីរភ្លឺ ប្រធានចំការសៀងនៅច្រមុះភ្នំដីររមៀលមិត្តភក្តិអានោះសួត មកសួរខ្ញុំថា បងឯងមានប្អូនម្នាក់ឈ្មោះវៀល ខែមទេ ខ្ញុំថាមាន បងឯងដឹង យើងប្រជុំ ថ្ងៃមិញ គេថាពាក់ត្រឹមអាត់ស៊ីដង់ឡើងគេវៃចោលទាំងអស់ ខ្ញុំថាវៃ១ទៅខ្ញុំដឹង ខ្ញុំទៅពាក់ ឲ្យវា ជាមួយគ្នាឯង ហីថាឲ្យទៅសួរចៅហ្វាយស្រុកមើលហេតុអីបានគេបញ្ជូនមកណឹងវិញ វាសួរគេរហូតដល់ជិតភ្លឺមកដល់ប្រាប់ខ្ញុំ ថាគេបញ្ជូនមកឲ្យខ្ញុំផ្ញើឲ្យខ្ញុំមើល អ្នកណឹងទើសខ្ញុំ ប្អូនខ្ញុំណឹងរស់ដោយសារខ្ញុំ ។ បើកុំមានខ្ញុំងាប់បាត់ បើខ្ញុំជាមនុស្សផ្តេសផ្តាសទៀត គេវៃ ចោលបាត់ ប៉ុន្មានខ្ញុំលួឥតខ្ចោះដែរណឹងក្នុងរបបណឹង ។

ឃឹមៈ កាលសន្និបាតណឹងគេយកមនុស្សម៉េចទៅសន្និបាត?

សនៈ យកតែកម្មាភិបាល ទាំងអស់ម៉ាស្រុក គណៈស្រុកគេមកទាំងអស់គ្នាហ្នឹង តាជឹម

ឃឹមៈ តាជឹមណឹងដែលប្រាប់ថា ត្រឹមអាតស៊ីដង់ឡើងផ្នែកយោធា បើផ្នែករដ្ឋបាលត្រឹមជំទប់ទី១ ឡើង?

សនៈ បាទ

ឃឹមៈ ចុះគ្រូម៉េចបានគេយកសំលាប់ដែរ?

សនៈ អញ្ចឹងបានថាណឹង

ឃឹមៈ ចុះពេល អ៊ំជួបពួកម៉ាកដែលធ្វើជាគណៈ២៥ណឹង គាត់មាននិយាយរឿងប្រាប់ពីការ សំលាប់មនុស្សអីទេ?

សនៈ គាត់ប្រាប់ គាត់ណែនាំខ្ញុំ គេមានកូនតាម៉ុកណឹងឆ្កួត កូនស្រី មីខុំ គាត់ថា សនឯង កុំធ្វើឲ្យមីចំកួ តណឹងទឹង មីចំកួតណឹងអត់បានទេ មីចំកួតណឹងប្រើអីធ្វើណឹង

ឃឹមៈ ចុះឆ្កួតម៉េចចេះធ្វើ?

សនៈ	អញ្ចឹងបានថា

ប៉ុនៈ	កូនតាម៉ុកណឹង ឈ្មោះខ្ញុំ ដែលតាវៃព្រះអីណឹង

សនៈ	ណឹងហើយ ងាប់បាត់ហើយ ប្រពន្ធអាម៉ុត

ឃីមៈ	ទើបឆ្កួតក្រោយ

សនៈ	ឆ្កួតតាំងពី កើតមក កូនតាម៉ុកឆ្កួតទាំងអស់ មីកាឆែបណឹងក៏ឆ្កួតដែរ

ឃីមៈ	ឆ្កួតម៉េច ចុះម៉េចដឹកនាំគេកើត ឆ្កួតរបៀបឡប់ ខ្មោចចូល ឬឆ្កួត

សនៈ	អត់ទេឆ្កួតហ្នឹងអត់ដឹកនាំកើតទេ ។ខ្ញុំស្រោចទឹកដើមស្វាយធំៗ យាយខ្ញុំប្រើខ្ញុំឲ្យរែក ទឹកស្រោច ដើមស្វាយ ហើយធ្វើគ្រលុកជុំវិញ ។ខ្ញុំស្រោច

ឃីមៈ	អ៊ំតាមមើលសតីល្អឬម៉េច អ៊ំ

សនៈ	ឆ្កួត ឆ្កួតហ្នឹង វក់មែនទែន

ឃីមៈ	ឆ្កួតជីវ៉ូ

ប៉ុនៈ	គេថាខ្ញុំណឹងឆ្កួត ត្រឹមវៃក្បាលព្រះ គាស់ព្រះ?

សនៈ	មិនទេប្អូន ឆ្កួតហ្នឹង

ឃីមៈ	អញ្ចឹងកូនគាត់ឆ្កួតទាំងអស់

សនៈ	អូ អាគ្រូដូចអត់អីទេ ។ កាលណាវាត្រូវវក់វាឆ្កួត ។ ការមីចំកួតក្រោយនេះមីប្អូននេះការជាមួយអាបូរ៉ាន់ ខ្ញុំប្រាប់ថា អាបូរ៉ាន់ហ្អែងកមយកមីណឹងឆ្កួតទេណា វាថាឆ្កួតអីក៏ដោយឲ្យតែបានធ្វើកូនប្រសារតាម៉ុក ហើយការទៅ ការណឹងដឹកបីយេអស់ប្អូនដប់កេសដឹកមកពីកំពង់សោម កាលឆ្នាំ៧៦ ការនៅវត្ត ខ្ញុំធ្វើនំបារាំឲ្យគេឆឡាំង ។ ពេទ្ធនៅជាមួយខ្ញុំបើការវិញ ខ្ញុំសុទ្ធតែធ្វើនំ រកសាច់ជ្រូកអីឲ្យ

ឃីមៈ	ចុះបូរ៉ាន់ណីជីបានងាប់?

សនៈ	អាបូរ៉ាន់ ពួកយួនបាញ់

ឃីមៈ	ចុះតាំងពី អ៊ំធ្វើពេទ្យមកមានផលវិបាកអីម៉េចទេ ធ្វើប្រធានពេទ្យ?

សនៈ ខ្ញុំអត់មានផលវិបាកអី ទេ ពិបាកតែដោះស្រាយរឿងម្ហូប បន្លែ គេដូចជាមិនសូវកៀប
គៀបគអី ។

ឃីមៈ ចុះ អ៊ំមានបានរៀបការឲ្យបុគ្គលិកពេទ្យណឹងដែរ?

សនៈ ការឲ្យបានប ៣ ៤ ៥នាក់ដែរណឹង

ឃីមៈ តើគេមានដៃនការ ឬ ក៏ស្រឡាញ់គ្នា?

សនៈ គេស្រឡាញ់ បើអាប្រុសស្រឡាញ់ទៅសួរស្រុក គេឲ្យការក៏ការទៅ។ ប្អូនឯងចូលជួបជាមួយយាយវុធហើយ

ឃីមៈ ចាំជួបហើយ

សនៈ ប្តីមិត្តវុធណឹងក៏ខ្ញុំការឲ្យដែរ ប៉ុនការជាមួយមិត្តវុធណឹងខ្ញុំអត់ទៅការទេ អាជននៅទល់ដែនគេអ្នកការ មុនណឹងខ្ញុំការឲ្យនារីម្នាក់នៅពេទ្យឃុំអូសារ៉ាយ យកមកបេ្តជ្ញា អាប្តីណឹងបេ្តជ្ញាថាយកនារីណឹធ្វើប្រពន្ធ នារីណឹងបេ្តជ្ញាថាមិនយកទេ ខ្ញុំខាតអស់នំបារាំងពីរកេស និងជ្រូកមួយ ។ សួរទៅប្រហែលម៉ោងនៅចឹងដដែល ។ មីណឹងវាអត់ស្រឡាញ់ នារីណឹងគួរសមដែរ

ឃីមៈ ប្តីយាយវុធណឹងស្អាតបាតដែរ

សនៈ វាក្បាលត្រងើល។ យាយវុធណឹងកូនយួនទេ ម៉ែឪបងប្អូនវាងាប់អស់អាលឹង ប្អូន។វានិយាយពីស្អាត។ចុះកូនយួនមែនទែន

ឃីមៈ តាជួន ជឿន អ្នកជួយ ហើយខៀវ សំផនអីណឹងជួយគាត់ គាត់និយាយ

សនៈ អាណាក៏ជួយគាម៉ុកអីក៏ជួយដែរ ប៉ុនចុងក្រោយមកងាប់អស់រលីង គេយកវៃចោលដល់គេឈ្នះទៅ ។និយាយពីនារីពីរនាក់ណឹងប្អូនយាយវុធ ស្អាតមែនទែន មិនមែនដូចយាយវុធទេ មនុស្សមិនជាបើណឹង។ ម៉ែឪយួន

ឃីមៈ គាត់និយាយយំចង់ងាប់ហើយ ហើយគាត់ថាប្តីគាត់ណឹងរៀបការអត់ស្រឡាញ់ទេ តែឃើញស្មោះស្ម័គ្រក៏ស្រឡាញ់ទៅ

សនៈ បើគាត់មិនយកអាណឹង ក៏អត់មានប្ដីរហូតដល់ឥឡូវ គាត់ការពារកូនខ្ញុំណាស់ កូនខ្ញុំអាបង កាលណឹងនៅពេទ្យជាមួយគាត់ អានោះនៅតូច ប្រពន្ធតាសីធ្វើបាប បានគាត់ជួយ

ឃីមៈ គាត់និយាយយំព្រោះខំជួយតាំងពីខៀវសំផនអីណឹង តាំងពីជំនាន់សីហនុ

សនៈ ផ្ទះគាត់នៅជិតស្ទឹងសម័យតស៊ូណឹងតាម៉ុកអីណឹងទៅពឹងម៉ែឪវា ។ អាហឿនណឹងយុវជនខ្ញុំណឹង ។ ហ៊ូនឹម ហ៊ូយន់មកធ្វើសន្និបាតនៅនេះ ក្រោយមកគេសំលាប់គាត់ចោល បបួលគ្នាស្ដាយ

ឃីមៈ ម៉េចបានគេសំលាប់គាត់?

សនៈ រឿងកាលណឹង ខ្មែរក្រហមបោះលុយ គាត់ថាឲ្យចាយ ហឺប៉ុល ពតគេមិនឲ្យចាយ រឿងធំមិនមែនរឿងតូចទេ បើម្នាក់ឲ្យចាយ ម្នាក់មិនឲ្យចាយ ទូទាំងប្រទេស ហើយលុយបោះហើយខ្ញុំយកមកបន្លាញផ្ទះ ។ ថ្ងៃណឹងខ្ញុំជួប អាណុបណែបតួកុនណឹង វាពួកម៉ាកខ្ញុំអាយុដំណាលគ្នានេះផ្ទះវាក្បែសាលឃុំជាងទង ។ គេចាប់បាននៅក្អែកទុំ កាលវៃ យកមកជួបខ្ញុំខ្ញុំប្រាប់ថា អាណែមហ្អែងកុំទៅវិញណា នៅជាមួយអញបានហើយ អញជួយការពារហ្អែង ។ វាមិនព្រម វាថាអាលឹកមីគឹមណូវ៉ាអីណា ប្រពន្ធវានៅភ្នំពេញ ហើយវាធ្វើទាហានសក្តិពីរមកវៃខ្មែរក្រហម ហើយខ្មែរក្រហមចាប់បានយកមកផ្ទះខំអន្ទរវា កុំឲ្យទៅវិញ វាទៅ ដល់គេឲ្យពួក១៧មកណឹង មកបណ្ដើរប្ដីប្រពន្ធមកយំសស្រិសស្រាក់ ខ្ញុំថាអញមិនដឹងធ្វើម៉េចទេ ខ្ញុំបាននិយាយប្រាប់ហេតុផលប្រាប់វាហើយ វាមិនឈ្នះពួកភ្នំពេញណឹងមិនឈ្នះអញទេនៅណឹងចាំម៉េចៗគង់តែវាមកទេហឹមកចាំយើងយកវិញហើយហ្អែងនៅអោបដៃជើងតាៗ ។ វាថានៅមិនបានទៅហើយ ឲ្យខ្ញុំធ្វើសំបុត្រឲ្យ ។ទៅវិញ បានទៅដល់ណោះលែទមាំគ្រាំងទៀត ទៅដល់នោះវាឡើងសក្តិប៉ុន្មាន ។ មកដល់នេះគេយកទៅគេថាយកទៅលេងកុន ជួយធ្វើប្រឡាយនេះ ខ្ញុំឲ្យដូងឲ្យអី ខ្ញុំថាអញមិនដឹងទេ រើយយកដូងស៊ីអាហើយ អញតូចតាចកំប៉ិកប៉ុក ។វាថាហ្អែងជួយអញផង ។ខ្ញុំថាជួយមិនបានកាលណោះជួមិនបានទេ ព្រោះបុគ្គល បើតាមមាគ៌ានយោបាយរបស់គេគឺអត់ទេ បើថាគេគិតម៉េច បក្សពួកម៉េច ។ ក្រោយណែនាំឲ្យអាណាគេធ្វើទៀតគេមិនធ្វើទេបដិវត្តន៍ ។

ឃីមៈ ចុះគេមាននៅក្នុងពេទ្យមានគេឲ្យដើទៅណា?

សនៈ ឲ្យ ឲ្យទៅបានខ្ញុំ ចាត់តាំងទាល់តែមានសំបុត្របេសកម្មបានទៅបាន

ឃីមៈ ចុះយើងចង់ដើរដូចរាល់ថ្ងៃ?

សនៈ អត់ទេ សូមទៅផ្ទះអីមិនបានទេ

ឃីមៈ ថីបានគេអត់ឲ្យទៅ?

សនៈ គេមិនឲ្យដើរហើរសេរី គ្រប់កន្លែងទាំងអស់ៗ បើពេទ្យទៅចាក់ថ្នាំអីណាចេះតែទៅបានៗ មិនមែនថាចង់ទៅនេះអីទេ ៗ ខ្ញុំដែលទៅព្យាបាលជំងឺនៅក្រាំងតាចាន់ដើម្បីចង់ចូលក្រាំងតាចាន់មិនដឹងធ្វើម៉េចអញ្ជើងប្រធាននគរបាលត្រូវមិត្តភក្តិទៅសន្និបាតជួបគ្នាថា សរសេរសំបុត្រមួយស្នើពេទ្យទៅមើលអានាម័យអីនៅកន្លែងណឹងម្តងមើល ៗហើយមិន ដឹងម៉េចស្រាប់តែឃើញសំបុត្រគេមួយ ៗលេខាស្រុកសុំពេទ្យឲ្យទៅជួយចាក់ថ្នាំការពារ ប៉ុនធាតុពីខ្ញុំចង់ ហើយឲ្យគេធ្វើសំបុត្រៗ មានឃើញអីបើគេដាក់គុកនៅក្នុង ពេលទៅឃើញតែអាអ្នកនៅក្រៅៗណឹង ជាពិសេសខ្ញុំ ចង់ទៅមើលមីហានផង ពេទ្យខ្ញុំទៅដល់វាកំពុងដាំបាយ ស៊ីបាយអីហើយ ខ្ញុំថាមិនដឹងចាក់ថ្នាំឲ្យអាណាបើនគរបាលអត់មានឈឺ ខ្ញុំគ្រាន់តែចែកថ្នាំទៅវិញ

ឃីមៈ ចុះណឹងសាហាវទេ គេធ្វើបាបអីខ្លាំងទេ?

សនៈ ប្អូនឯងមិនដែលទៅមើល ឃើញក្បាល់ខ្មោចៗ បើតាមខ្ញុំគឺបាត់អស់ពាក់កណ្តាល

ឃីមៈ ចុះតាម៉ុកកាចទេ?

សនៈ កាច

ឃីមៈ ចុះជាមួយ អ៊ំអីអត់អីទេ?

សនៈ ប៉ុនតាម៉ុក អត់គិតអាណាណីទេ កូនខ្លួនគាត់ គាត់មិនគិតផង

ប៉ុនៈ អ៊ំថាកូនគាត់សុទ្ធតែឆ្លូត ម៉េចគេឲ្យធ្វើការធំៗម៉េស

សនៈ មិនមែនគាត់ទេ គេដាក់តានខ្មែរអញ្ជើងហ្នឹង ឧទាហរណ៍ស្រុកអីណឹង មជ្ឈឹមអីគេចាត់តាំងមិនមែនតាម៉ុកចាត់តាំងឲ្យកូនឯងធ្វើអត់ទេៗ

ប៉ុនៈ ចុះអ្នកណាគេមជ្ឈឹម?

សនៈ ប៉ុល ពតមក មិនដឹងអាណាអាណីទៀត ។ កាលណឹងគេមានរដ្ឋាភិបាលគេមួយនៅឃុំអូរសារ៉ាយ គេចាត់តាំង ។ ខ្ញុំទៅបន្តោងសារ៉ូមឲ្យមីខុំ ហើយប្រើខ្ញុំឲ្យវែកទឹកស្រោចដើមស្វាយធំ ពេលនោះតាម៉ុកមកទាន់ តាម៉ុតក៏មកដែរ ។គ្រាន់តែឃើញខ្ញុំពេទ្យដាក់សារ៉ូមថាឈឺចេះឈឺចុះ ដល់តែឃើញអាផ្ញើកំពែងស្រោចដើមស្វាយណឹង តាម៉ុកសួរអាណាផ្ញើកំពែងស្រោចដើមស្វាយណឹង ខ្ញុំឆ្លើយមុនគេ ព្រោះប្រើខ្ញុំ ថាយាយខុំ គាត់ថា ហ្អែងឆ្កួតតាមមនុស្សឆ្កួតដែរ ចេះនិយាយថាខ្ញុំឆ្កួតតាមមនុស្សឆ្កួតដែរ ប៉ុនគាត់ដឹងឆ្កួតមិនដកចេញ

ឃីមៈ ចុះបងណឹងឆ្កួតម៉េចគាត់ចេះបញ្ឈោគេ?

សនៈ បញ្ឈោតាមឆ្កួត មីកូនខ្ញុំនៅជាមួយយាយខុំណឹង

ឃីមៈ ចុះតាកូនខៀវ សំផនឆ្កួតដែរកាលនឹង?

សនៈ យាយខឹមទូលនំបារាំង ខ្ញុំដឹកនំសន្សម ដល់ស្ពានមួយនៅទំនប់ពកត្របែក មានព្រៃអាសីច្រើនណាស់ មានផ្លូវមួយចូលទៅត្រង់ក្នុងមន្ទីរខៀវសំផន ខ្ញុំតូចតាចជាងគេ ប៉ុនជិតស្និតជាមួយអស់ណឹងណាស់ ខ្ញុំចេះរកក្រឡារស់ សូម្បីតែយួនមកដល់ក្អួយឯងមើលមិនមានពេទ្យនៅជនបទមិនដឹងទៅទិញថ្នាំណា ឈឺនោះពិបាកនោះពិបាក ខ្ញុំទៅទាក់ទងយួននៅភ្នំដីរមៀល យួនយកពេទ្យយកឆ្នបមក ខ្ញុំឃើញថាមនុស្សមានសំណាង គេអត់មានប្រកាន់អីទេ ខ្ញុំមួយចូលបានពេញភ្នំទាំងអស់ អញ្ចឹងអាណាឈឺខ្ញុំទៅយកពេទ្យប្អូន ដប់នាក់ពាក់អាវ ដាវសទ្រលុកៗ ។

ឃីមៈ ចុះខៀវ សំផន ណឹងការនៅឆ្នាំណា?

សនៈ ភ្លេចហើយ ។ តាំងការហើយមិនដែលជួបទេ ។ ខៀវសភន រឹងទទឹង ដូចថាមិនបត់បែនតាមជ្រាជនខ្លះ ខ្ញុំថាមិនហៅមនុស្សចេះទេអញ្ចឹង ។

ឃីមៈ អ៊ំពុពាក់ប៉ុលពតតាំងពីឆ្នាំណា?

សនៈ ទើបពុ កាលខ្ញុំនៅរៀន ពុតែសាឡុត ស កាលនៅភ្នំពេញ ។ទើបឃើញរូប កាលយកក្រឡានទៅណឹង ខ្ញុំមិនដែលឃើញទេ ។ បើខៀវសំផនវិញឃើញមាំណាស់ ហ៊ូយន់ហ៊ូនឹម ។ ហ៊ូយន់គ្រូម៉ាត់ខ្ញុំណឹង បង្រៀនសីសំាមនៅកម្ពុជាបុត្រណឹង

ឃីមៈ ចុះ អ៊ំតាមមើលខៀវសំផន និងហ៊ូយន់អ្នកណាគ្រាន់បើជាង?

សនៈ អូ អត់បានមាំចំណិត ហ៊ូយន់ ហ៊ូនឹមអីមាំតិច ពីរនាក់ណឹងខ្ញុំធាប់ជួបផ្ទាល់ ។ គាត់ចេះណាស់ ហ៊ូយន់ ហ៊ូនឹម គាត់ទៅបង្រៀនណឹងបើអ្នកណាមិនចេះគាត់យកចិត្តទុកដាក់ អាណឹងជាងគេ ។

ឃីមៈ សម័យអាពត អីមានបាត់បងអីទេ?

សនៈ បាត់បងបងថ្លៃមួយ ដោយសារទៅធ្វើទ័ពសម័យអាពត

ឃីមៈ ចុះអីឈឺចាប់ទេ?

សនៈ កាលណឹងមិនឈឺចាប់ទេ ដោយសារថា ខ្ញុំគិតច្រើនថ្ងៃងថ្ងៃងថា បើកុំរៃវបបលន់ ណុល ឲ្យបានម្តង ដល់ក្រោយមកពិបាក ។ បើសិនណារបបណឹងមករហូតដល់ឥឡូវមិនមែនសប្បាយព្រោះក្រោយណឹងមកគង់តែប្រទូសប្រទះគ្នាដដែល ៗ នឹកឃើញអញ្ចឹង ។ ដល់មករបបប៉ុល ពត ដេលថាល្អណាស់ កុំតែគេវៃមាំព្រឹបទៀត ក៏អត់មានដីធ្វើដែរ ។

ឃីមៈ ចុះខបមាថាគេបង្កើតតុលាការអី តើ អីចង់ឲ្យមានទេ កាត់ទោសខ្មែរក្រហម ចិត្ត អី?

សនៈ ខ្ញុំមិន តើគេចង់កាត់ទោសអ្នកណាមួយ ។ ខ្ញុំថាបើកាត់ទាល់តែកាត់ទាំងអស់គ្នា យើងត្រូវគិតឲ្យខ្លាំងចំបាំងប៉ុល ពតនេះ មិនមែនប៉ុល ពតធ្វើម្នាក់ឯងទេ អាណាធ្វើខ្លះ ៗបើកាត់ទោសតាម៉ុក ប៉ុល ពត ក៏មិនកាត់ទោសអាមេរិកាំងផង កាត់ទោសចិនផង ព្រោះពួកអស់ណឹងគាំទ្រខ្លាំងណាស់ ៗចិន គាំងពីមុនមករហូត ខ្ញុំលឺគ្រាប់វែកជងដីករទេះផង សុទ្ធតែរបស់ចិន ណឹងអាណាគេកមកសំលាប់មនុស្ស?

ឃីមៈ តែអ្នកណាគេជាអ្នកសំលាប់ប្រជាជនឯង គេចង់ដឹងអញ្ចេះ ចិនមិនមេនឲ្យសំលាប់ទេប្រជាជនវា វាក៏ធ្វើសង្គមនិយមដែរអត់ដូចយើង?

សនៈ មិនទេដូច ធ្វើបដិវត្តន៍វប្បធម៌ បើមិនធ្វើអញ្ចឹងធ្វើម៉េចទៅ ម៉េចហៅបដិវត្តន៍វប្បធម៌ បើមិនសំលាប់ យកមកធ្វើស្អី រៀនតាមចិន ។ វាធ្វើបដិវត្តន៍វប្បធម៌វាផាប់អស់ប៉ុន្មាន ៣០ លាននាក់ ហីយើងអស់អាលីង ៗធ្វើអញ្ចឹង

ឃីមៈ ប៉ុនចិនគេបដិវត្តន៍វប្បធម៌គេដើម្បីជឿន លឿនឲ្យរៀនសូត្រ យើងនេហបំបិទសាលា

សនៈ អាណឹងថាចឹងចុះ ខុសគ្នា អាណឹងគេថាអញ្ចឹងធ្វើបដិវត្តន៍វប្បធម៌ទ ខ្ទេចហើយ ។ បើនិយាយពីរឿងតស៊ូគឺអញ្ចឹង មុនដំបូងគេត្រូវតែសំលាប់មនុស្ស បើមិនសំលាប់មនុស្ស

មិនដឹងទៅតស៊ូជាមួយស្អីទេ ។កុំនិយាយ និយាយដល់រឿងកាត់ទោសអីនេះខ្ញុំធុញណាស់ កុំនិយាយរឿងចិនអីមិនដឹង ។

ឃឹមៈ កាត់ទោសណឹង ចង់ដឹងថា អ្នកណាជាមេគំនិត ហើយហេតុអីបានធ្វើអញ្ចឹង ហេតុអបានសំលាប់ប្រជាជនឯង ធ្វើចុះបដិវត្តន៍ ធ្វើចុះសហករណ៍ តែអ្វីដែលគេមានបែរជាបំផ្លាញចោល ។ គេមិនយាត់តែធ្វើសង្គមនិយមតែធ្វើម៉េចឲ្យរីកចំរើន កុំឲ្យធ្លាក់ដល់សូន្យ ។ តុលាករគេណឹង គឺចង់ឲ្យបំភ្លឺប្រាប់ប្រជាជន ហេតុធ្វើអញ្ចឹង ហេតុអីបានសំលាប់ប្រជាជន

សនៈ ខ្ញុំចង់និយាយតែរឿងម៉ាម៉ាត់ដែលគេហៅថា បដិវត្តន៍វប្បធម៌ណឹងគេធ្វើម៉េច ។ បដិវត្តន៍វប្បធម៌ណឹងគឺអញ្ចឹងហ្នង ត្រូវតែកំទេចចោលអាណាមិនមែនគ្នាគេ គេកំទេចចោលអញ្ចឹងហ្នង ។ អាចឹងទៅសួរអ្នកចេះណាមួយក្រែងខ្ញុំយល់មិនដល់ តែបដិវត្តន៍វប្បធម៌នឹងទ ហើយ ។ បើថានិយាយពីរឿងតស៊ូ មុននឹងតស៊ូគេសំលាប់មនុស្សសិនហើយក្បួនខាតវាអញ្ចឹងហ្នង អាណឹងខ្ញុំដឹង ដល់ទៅមើលសៀវភៅបានដឹង ហើយរឿងកាបែងចែកវណ្ណៈណឹង លែងចង់ស្តាប់ហើយ ។

ឃឹមៈ កាលនៅក្នុងពេទ្យ អីមានដែលពន្យល់គេពីរឿងណឹងទេ

សនៈ អត់ដែលពន្យល់ទេ និយាយពីរឿងខ្ទាំង ។ ខ្ញុំដឹង ដឹងមាំណាស់ ។ ដល់ចុងក្រោយគេប្រកាសប្រាប់ថាបដិវត្តន៍វប្បធម៌ប្រយ័ត្នខ្លួន ទាំងអស់គ្នា ។ ខ្ញុំនិយាយខ្សឹបៗថាប្រយ័ត្នពេកហើយលោកអើយ ។ បើនិយាយពីរឿងបដិវត្តន៍វប្បធម៌ ចុងក្រោយបំផុត ប៉ុលពតប្រកាសអញ្ចឹងហើយ នៅកន្លែងផ្សេងខ្ញុំមិនដឹងទេ បើនៅកន្លែងខ្ញុំគេប្រកាស ។ កាលណឹងប្រកាសនៅឆ្នាំបញ្ចប់

ឃឹមៈ អញ្ចឹងគួរតែដឹងថា ធ្វើអញ្ចឹងជាភាពគំសោយមួយ បរាជ័យខ្លួនឯង

សនៈ អញ្ចឹងបានថា យើងដឹងថាអញ្ចឹងហើយ ពួកណឹងអន់ហើយ គេអាងតែជ័យជំនះៗ រឿងថាលុយមិនចាយ គេប្រណាំងប្រជែងគ្នាគ្រប់ស្រុក ថាកុំបាច់ចាយលុយ គឺស្រុកត្រាំកក់ណឹងប្រកាសមុនគេ ថាមិនបាច់ចាយលុយ អញ្ចឹងស្រុកដទៃទៀតគេក្តៅ គេអត់ហ៊ាន គេអត់ចាយដែរ ។ រឿងណឹងគេប្រជុំសួរ ហើយអ្នកណាហ៊ានថាចាយ ចេះតែអត់ ព្រោះគេមុននឹងលើកក្នុងអង្គប្រជុំគេធ្វើការស្ទាបស្ទង់ Indroction វែងរបស់គេថា ចាយលុយណឹង

ខូចសតិអារម្មណ៍មនុស្សឲ្យវាភ្លើត ភ្លើនអី ហើយបានសួរថាចាយ មិនចាយ អាណាហ៊ាន ថាចាយបើថាភ្លើតភ្លើនពីមុនហើយណឹង ។

ឃីមៈ ចុះ អ៊ំភូមិឃុំហៅអី?

សនៈ ភូមិព្រៃតាលី ឃុំ ត្រពាំងធំខាងជើង

ឃីមៈ អ៊ំដាក់ឈ្មោះអី

សនៈ ឈ្មោះ វៀល សន

ឃីមៈ អ៊ំធ្វើការអី

សនៈ ធ្វើប៉ូលីស តាំងពី៨៣

ឃីមៈ អាយុប៉ុន្មាន?

សនៈ ៦៥

ឃីមៈ កាល អ៊ំនិយាយដំបូង ប្រធានមន្ទីរស្រុកឈ្មោះអីដែលថានាំ អ៊ំចូលពេទ្យ?

សនៈ ឈ្មោះភី ងាប់អស់ហើយ នៅស្រុក១០៥ ឆ្នាំ ៧៦

ឃីមៈ អញ្ចឹងពេលបែក អ៊ំហើយម៉ាឆ្នាំបាន អ៊ំបានចូលធ្វើពេទ្យ

សនៈ បែកហើយ៧៦

ឃីមៈ ពេលដែល អ៊ំថាដឹកមកទាំងឡានមានប្រភេទថ្នាំអីខ្លះ?

សនៈ មានច្រើនគ្រប់មុខ ថ្នាំគ្រុចាញ់ ថ្នាំល្អណាស់ កាលណឹងឆ្នាំ ៧៥ ៧៦ នៅវត្តចំប៉ា រហូតដល់ខ្ញុំមកនេះនៅតែដឹងមក នៅកន្លែងពាណិជ្ជកម្ម

ឃីមៈ កាលពេទ្យនៅវត្តចំប៉ាណឹង អ៊ំធ្វើប្រធានពេទ្យដែរអត់?

សនៈ ធ្វើប្រធានពេទ្យដែរ កាលណឹងមានបុគ្គលិកតែ ៦នាក់ អត់មានស្រីទេ កាលណឹងមុនដំបូងគេអត់ទាន់រៀប

ឃីមៈ ចុះ អ៊ំមានដឹងថាមានពេទ្យ២២ នៅណាមុនរំដោះ?

សនៈ មាន នៅឃុំត្រពាំងធំខាងជើង

ឃីមៈ អ៊ំកាលឆ្នាំ៧១ ៧២ ៧៣ អ៊ំមានតួនាទីជាកំលាំងបង្កប់ គេឲ្យធ្វើអីខ្លះ?

សនៈ អត់មានធ្វើអីទេ គ្រាន់តែដើរកសាងកំលាំងបដិវត្តន៍ ។ កសាងបានយុវជន យុវនារីច្រើនណាស់ៗ គ្រាន់តែកងទ័ពសីងម៉ាកងពល គ្រាន់តែយុវជននិង យុវនារី ។ ដូចបាក់ទៅហ្នឹង ។ ឃុំជាងទងណឹង អូ មិនបាច់ទេ

ឃីមៈ ចុះគេខ្លាចភូមិភាគនិរតីម៉េស ខ្លាំង?

សនៈ មិនមែនខ្លាំងទេ ភូមិភាគនិរតីគឺជាទីតាំងរបស់ បដិវត្តន៍ ទីតាំងរបស់ខែរក្រហមនិយាយរួមកាលនឹងមានខៀវសំផន ហ៊ូ យន់ ហ៊ូនឹម មកនេះមុនគេ មានតាម៉ុកមុនគេ តាម៉ុកណឹងចំរើនក្រហមដោយសារគាត់បួសនៅភ្នំពេញ ហើយបានដោយៗមក ។បួនឯងទៅដល់ឃុំជាងទងមានទៅដល់តាព្រំ តាព្រំណឹងបងប្អូនយាយបឿនណឹង តាព្រំ ណឹងនិរសាខៀវ សំផន យាយបឿនណឹង ក៏និរសាខៀវសំផន ។ តាព្រំនៅភូមិក្បាលអូ

ឃីមៈ អូ តាព្រំណឹង ទៅដល់ហើយ ស៊ូព្រំណឹង ខ្ញុំជួបគាត់ដែរ ប៉ុនគាត់និយាយអត់ច្បាស់ គាត់អ្នកនាំខៀវសំផន ចេញ គាត់ចាស់ពេក រាងវង្វេង ។

ឃីមៈ ចុះថាតាម៉ុកគាត់ឲ្យដឹកថ្នាំពេទ្យមកពីណា ឆ្នាំណា?

សនៈ ថ្នាំមកពីភ្នំពេញ មិនដឹងមកពីណា

ឃីមៈ ចុះតាៗដែលចូលបក្សជនឈ្មោះ?

សនៈ តា ប៉ូ តាជូ

ឃីមៈ ម៉េចបានចូលបក្សជន?

សនៈ គេអត់មានពាក់ព័ន្ធអី គេល្អ តាគិតណឹងកាលណឹងលេខាស្រុកត្រាំកក់នេះ ហើយបានទៅគណៈតំបន់១៣ ហើយបានទៅគណៈតំបន់២៥ទៀត នេះផ្ទះនៅត្រពាំងធំខាងត្បូង

ឃីមៈ គាត់រស់ឬស្លាប់តាគិតណឹង?

សនៈ យួនបាញ់នៅភ្នំកក់ខេត្តកំពង់ស្ពឺ

ឃីមៈ តើគេធ្វើរបៀបម៉េចបានចូលបក្សជន អត់ពាក់ព័ន្ធម៉េចខ្លះ?

សនៈ អត់ពាក់ព័ន្ធបងប្អូនអត់មាននៅក្នុង សតិអារម្មណ៍ល អត់មានប្រឆាំងបដិវត្តន៍ អត់មានពាក់ព័ន្ធបងដែលគេយកទៅវៃចោល

ឃីមៈ ហើយគស៊ូប៉ុន្មានឆ្នាំបានចូលបក្សជន?

សនៈ មិនទៀង គេមើលឃើញល្អ

ឃីមៈ ចុះ អ៊ំចូលទេ?

សនៈ ខ្ញុំអត់ បានត្រឹមក្រុមស្នូល

ឃីមៈ ក្រុមស្នូលនឹងម៉េច?

សនៈ ក្រុមស្នូលគ្រាន់តែត្រៀមមុនចូលបក្សជនណឹង

ឃីមៈ ចុះយុវកកណឹងអាណាធំជាង?

សនៈ អាណឹងយុវជនត្រៀមដូចគ្នា

ឃីមៈ គាដូណឹងធ្វើពេទ្យអី?

សនៈ ធ្វើពេទ្យជាមួយខ្ញុំ ប៉ុនគាត់អត់ចេះដែរ ចេះតែចាក់ថ្នាំតិច ប៉ុនអត់បានទៅរៀនទៅសូត្រអី នឹងគេទេ គេអត់ឲ្យទៅ ។

ឃីមៈ ចុះដែលចាក់ Reaction អីទេ ?

សនៈ ដែល ខ្ញុំដែលណឹង ចាក់យាយណឹង ចាក់ត្រកៀក មកពីថ្នាំពេទ្យទេ កាលណឹង ចាក់ប្រូគាអ៊ីនអាណឹង៩លានចាក់ ៥ដង តែខ្ញុំចាក់តែបីដង គាត់ថាជា ប៉ុននៅ តិចស្ដាយ ខ្ញុំចាក់ បានម៉ាតិច ប្រតិកម្ម គាំងបេះដូង ប៉ុនបានជាងនៅ ជាន់អន្ដរកុំអីងាប់ ។

ឃីមៈ ចុះ អ៊ំទៅរៀនពេទ្យលើកទីពីរគេរៀនពីអី?

សនៈ រៀនពីព្យាបាល រៀនពីជំងឺទូទៅទាំងអស់ប៉ុនកំរិតខ្ពស់ កាយវិភាគ រៀនច្រើន ។ ពេទ្យសី អ្នកបង្រៀន ។

ឃីមៈ បែលគេចាប់យាយបូណឹង គេអត់ចាប់ពេទ្យសិណឹងទេ?

សនៈ គាត់ទៅរៀនភ្នំពេញ ពេលត្រលប់មកវិញគេដាក់គាត់នៅមន្ទីរបំប៉ន ដាក់ឲ្យនៅស្ងៀម អត់ឲ្យធ្វើអី ដឹងខ្លួនហើយ ដឹងខ្លួនជាប់គុក អត់មានធ្វើការអីរហូតដល់រត់ ។ មិនដឹងគេយក វៃចោលថ្ងៃណា ។ គាត់មកនិយាយនៅណឹង ពីរ បីដង មករកកូន ។

ឃីមៈ ចុះ អ៊ំប្រភពថ្នាំដែលថាស្វ័យខ្លួនឯងណឹងមេសុទ្ធតែយកមកពីវៀណាមទាំងអស់?

សនៈ អត់ទេ ម៉ាចំនួន ដូចខ្ញុំនិយាយជំនួយដង្ហើម ខ្ញុំធ្វើពីស្លឹកប្រេងខ្យល់អីទេ ខ្ចះទិញពីវៀតណាម ប៉ុនមិន មែនវៀតណាមអ្នកធ្វើទេ ។

ឃីមៈ គ្រាន់វាមានទីផ្សារមិនមែនវាអ្នកធ្វើទេ

សនៈ ព្រោះបេខូណឹង វាដាក់ដមមេណឹង ហើយឃើញវាដាក់ថា U S A ហើយមេកាលស្បូម ខ្ញុំទិញមកម៉ាបាវ ដាក់ U S A ប៉ុនណាណឹ ។

ឃីមៈ អ៊ំចេះធ្វើដែរ ដូចថាយកមេមកដាក់ប៉ុន្មានសេសេ ?

សនៈ គេហៅ មួយភាគពាន់នោះ គឺអាមេណឹងមួយ ហើយទឹក ម៉ាពាន់ ។ បើសិនណាមេណឹង ម៉ាគីឡូ ទឹកណឹងម៉ាពានលីតហើយ ។ យើងលាយតាមដី ហ៊ុ លី ខ្ញុំដញ្ជីងថ្ងឹងមាស សំរាប់ធ្វើថ្នាំណឹង

ឃីមៈ ចុះ អ៊ំថាបិទទឹកពីរសា បិទម្តងបានប៉ុន្មានលីត?

សនៈ បិទម៉ាថ្ងៃបាន២០ ៣០ លីត្រតាម ធ្វើ ព្រោះមានឆ្នាំច្រើនបើចាំបាច់ ព្រោះមានអ្នសុំច្រើន ។ គេមកសុំតែខ្ញុំពេទ្យតំបន់ក៏មកសុំ ពេទ្យភូមិភាគក៏មកសុំ ។

ឃីមៈ ចុះគេមកសុំយើងវិញក្រែងគេពេទ្យតំបន់?

សនៈ មិនដឹងម៉េចគេថាគេចង់បានរបស់ខ្ញុំ ខ្ញុំមិនដឹងដែរ ឃើញតែសំបុត្រ មិនមែនពេទ្យសើទេ សុទ្ធតែសំបុត្រមកពីគណៈតំបន់ គណៈភូមិភាគ ។ ខ្ញុំធ្វើហើយ ឲ្យតែត្រជាក់ស្រួលហើយ អ្នកណាចូលបន្ទប់ធ្វើ ត្រូវតែបន្តោងសេរ៉ូមអ្នកណឹង ធ្វើថ្នាំអីចាក់ថ្នាំណឹង

ឃីមៈ អូ ខ្លាច ចាក់ដើម្បីការពារ?

សនៈ ខ្លាចយកទៅដាក់អ្នកជំងឺងាប់ បើអញ្ចឹងងាប់ៗអ្នកធ្វើ ខ្ញុំធ្វើអញ្ចឹងហ្នង ។ មុនដំបូងខ្ញុំចាក់កណ្តុរអីដែរ ដល់យូរទៅបានថ្នាំ ទៅងាប់កណ្តុរអីកាលសាកថ្នាំលែងចាក់ចាក់មនុស្សម្តង

ឃីមៈ មានធ្លាប់ចាក់កណ្តុរងាប់ដែរ សាកមានទេ?

សនៈ មាន មានបងប្អូន១៧ មក យកថ្នាំណឹងមកពេទ្យឃុំខ្ញុំចាក់ ពេទ្យចាក់ដកម្ជុល អត់ ទាន់ចេញផងងាប់បាត់ នៅសល់ថ្នាំគាត់ មានបីអំពូល ខ្ញុំយកមកសាកកណ្តុរ គ្រាន់ចាក់

ម្ហូលចូលកណ្ដុរងាប់ហើយហៅពេទ្យហៅមេឃុំមកទាំងអស់ ហើយចាក់ថ្នែ ថ្នែងាប់ ក្លាម ។ ថ្នាំបេះដូង បើដាក់សេរ៉ូមម៉ាលីតត្រូបន្ដោង១២ម៉ោង មិនមែនចាក់ផ្ទាល់ អញ្ចឹង ទេ ។

ឃីមៈ ចុះងាប់គេអញ្ចឹងម៉េចទៅ?

សនៈ មានម៉េច បើគាត់យកថ្នាំណឹងមកឲ្យចាក់ខ្លួនឯង ពេទ្យវាល្ងើ ពេទ្យអត់ចេះអក្សរទៀត មីណឹងនៅពេទ្យឃុំប៉ិនចេហចាក់ថ្នាំគេឲ្យចាក់ចាក់សរសៃទៀតវាងាប់ងាប់ ។ប្រហែល ជាគាត់ចង់ស្លាប់ក៏មិនដឹង ព្រោះវាពិបាកពេកសង្គមនោះគ្មានអ្នកណាចង់រស់ទេ ។ ចង់រស់ដូចខ្ញុំអីណឹង នៅស្រួល ៗ ចេះតែចង់រស់ហើយ ។

ឃីមៈ ចុះកាលគេឲ្យអីទៅសន្និបាតណឹងឆ្នាំណា អី?

សនៈ ឆ្នាំ៧៥ គេប្រកាសសន្និបាតគេនិយាយតែបីទេបើផ្សេងបានគេនិយាយទៀត ។ គេនិយាយពីនយោបាយ យោធា សេដ្ឋកិច្ច ។

ឃីមៈ មួយ ៗ លើកឡើងម៉េចខ្លះ?

សនៈ នយោបាយ យោធា បើទាហានចាប់ពីអាត់ស៊ីដង់ត្រូវកំទេចចោលហ្មង ដាក់ចំហ្មង អញ្ចឹងបានខ្ញុំប្រហោងពោះប្អូនបងឯងធ្វើនេះ ។ និយាយពីខៀវសំផនការ បានកូនប្រុសមួយ តពូជ គេបង្ហំអញ្ចឹង អញ្ចឹងគាត់បង្ហំការជាមួយលេខាដាកទីល្ងូរបស់គាត់ អញ្ចឹងគាត់ប្រធុយប្រថាន ការទៅ គេស្គាល់ ប្រពន្ធគាត់ណឹងគេស្គាល់គ្រប់គ្នា ។ ខ្ញុំអត់ថាប្រពន្ធគាត់នៅណាទេ ។

ឃីមៈ ចុះគេការរៀបបដិវត្តន៍ ឬការមានភ្លេងខ្មែរតាមប្រពៃណី?

សនៈ គេការរៀបបដិវត្តន៍ប្ដេជ្ញា កាលណឹងប្រហែល៧២ ៧៣ កំពុងច្របូលច្របល់កាលណឹង មិនទាន់ធ្វើទំនប់ពកត្របែកទេ ។ ពេលដែលធ្វើទំនប់ពកត្របែកហើយ ចិនមកច្រើនប្រហេល ១០ ២០ឡានស៊ីប ។

ឃីមៈ ចិនមកធ្វើអី?

សនៈ ចិនមកទស្សនៈកិច្ច កាលណឹងធ្វើហើយ ឆ្នាំ៧៤

ឃីមៈ ឆ្នាំ ៧៤ មកម៉េចកើតគេមិនទាន់រំដោះផង?

សនៈ អញ្ចឹងបានថាក្នុយឯងពិចារណារឿងណឹងថា ទៅកាត់ទោសតាម៉ុកអីកើត អាណាមក ពេញដី ។ គ្រាន់សំបកបារីមិនដឹងគេជក់បារីអី ប្រហែលម៉ាឡាន ចុះបើឡាន ៤ ១០ ២០ឡាន មកយប់មិនមែនមកថ្ងៃទេ គ្មានអាណាដឹងទេ ម៉េចបានខ្ញុំដឹងព្រោះមុនខ្ញុំមក ធ្វើពេទ្យណឹង ខ្ញុំធ្វើប្រធានដាំងនៅណឹង ។ ស្រាប់តែខ្ញុំឡើងលើទំនប់ណឹង ខ្លាច អ្នក ណាកាប់ទំបន់ណឹងស្រាប់តែឃើញភ្លើងបារីច្រើនម៉េះរត់ទៅហៅគ្នា២ ៣នាក់ស្រាប់ តែ ឃើញឡានមួយមកបញ្ចេះម៉ាស៊ីន ខ្ញុំថាមិនកើតទេ កាលណឹងខ្ញុំមិនដែលឃើញឡានអី ។ ខ្ញុំទៅមើលណឹងព្រោះខ្លាចតាម៉ុកថាគេមកហើយអត់ដឹង ខ្ញុំគ្គាប់រួមជាផណឹងខ្ញុំស្ពាយកាំភ្លើង ម៉ាដើមទៅ ស្រាប់តែនិរសាគាត់មកសួរ ខ្ញុំថាមកក៏មិនប្រាប់ព្រោះខ្ញុំនៅការពារណឹង ។ អានោះរត់ទៅប្រាប់តាម៉ុកថា មិនអីទេ ហើយខ្ញុំដើរទៅ ។ ដល់ទៅឃើញចិននិយាយញ៉ៅវ ញ៉ាវ សុទ្ធតែចិន ។

ឃីមៈ អ៊ំនៅស្រុកណឹងមានផ្លាស់ប្តូរគណៈស្រុកច្រើនទេ?

សនៈ ច្រើន មុនដំបូងបំផុតលេខ តាញ៉ៅវមិនទាន់រំដោះទេ៧០-៧១ ដល់៧២-៧៣តាជឹម ៧៤-៧៥តាចាយដល់ចុងក្រោយ តាគិត តែបានលេខាស្រុកបានតែកន្លះខែទៅ ធ្វើ គណៈតំបន់១៣ ។

ឃីមៈ គណៈភូមិភាគតាម៉ុក ចុះគណៈតំបន់អ្នកណាគេ?

សនៈ តាសោម តាម៉ុត តាម៉ុតនៅណឹង

ឃីមៈ តាសោមណឹង អ្នកណាមុនអ្នកណាក្រោយ?

សនៈ ជាមួយគ្នា មួយប្រធាន មួយអនុ គាត់ធ្វើរហូតអត់កែទេ ហីយាយខ្ញុំកូនតាម៉ុកណឹង នារី តំបន់សមាជិកតំបន់ឆ្នូតឡេឡឺណឹង ។អញ្ចឹងបានថានៅជុំវិញខ្ញុំណឹងអត់ទេ អត់មាន សល់ យុវជន យុវនារី នៅតែចាស់ ចេញធ្វើបដិវត្តន៍អស់អាលឹងកាលនោះ គ្មាននៅមួយ ទេ

ឃីមៈ ចាប់តាំងពីក្មេងអាយុ១២ឡើងទៅធ្វើបដិវត្តន៍ហ្នឹង ទៅសមរភូមិមុខ?

សនៈ ឲ្យតែចេះដើរតាមគេ

ឃីមៈ ម៉ែឪ អត់មានឃាត់ទេ?

សនៈ អត់ទេ យាត់ក៏វាមិននៅដែរ វាចង់តាមគ្នាហ្នឹងជ្រើមហ្នឹង ដូចត្រីកំឡូងអញ្ចឹង ។ ហើយយើង ម៉ែឪណឹង កាលណាអត់ឲ្យកូនទៅ តែកូនមួយអីណឹង គេថាអញ្ចេះ ថាអញ្ចោះ មិនបាច់ទេ ទៅឲ្យហើយហ្នឹង ។

យឹមៈ ទៅដោយគេបង្ខំ ឬដោយចិត្តឯង?

សនៈ គេបង្ខំ ដល់ពេល ដល់បង្ខំអញ្ចឹងទៅក្មេងនៅមិនបាន

យឹមៈ ទៅណឹងទៅធ្វើស្អីម្នាក់ៗណឹង?

សនៈ ទៅធ្វើទ័ពទាំងអស់ណឹង ធ្វើពេទ្យ ។ មុនដំបូងចូលទ័ពទាំងអស់ហ្នឹង ទ័ពស្រុកអីណឹង ហើយ បានគេបញ្ចេញពីទ័ពស្រុកណឹង ខ្លះទៅទ័ពតំបន់ខ្លះមជ្ឈឹម ខ្លះទៅធ្វើពេទ្យតំបន់ ទៅពេទ្យ ណាៗ ។កូនខ្ញុំអាមួយទៅនៅភ្នំពេញរហូតដល់បែកភ្នំពេញរត់ទៅដល់ណា ត្រលប់មកវិញ មានតែកូនឆ្នាំងមួយ ។

យឹមៈ តើស្រីៗប្រុសៗទៅជុំគ្នានៅណា ពេលទៅពីភូមិឃុំ?

សនៈ ជុំគ្នាសាលាឃុំ ហើយគេបញ្ជូនទៅស្រុក ហើយបានស្រុកគេបញ្ជូនទៅណាទៅណីស្រេចតែ គេចាត់ចែង ។ហើយអញ្ចេះទៀតស្រុក១០៥នេះខុសគេណាស់ឧទាហរណ៍ថានៅតំបន់ផ្សេង ៗ ណាណឹង ឆ្ងាយ ដូចតំបន់២៥ នៅចំការកៅស៊ូគេសុំមក ។ គេយកពីស្រុកត្រាំកក់ នេះទៅចំការកៅស៊ូ អញ្ចឹងបានទៅនៅពេញដីម៉ាណាស់គ្រប់កន្លែងអស់អាលីង ។ ទៅបូព៌ា ឲ្យតែកម្មាភិបាលបញ្ជូនទៅបូព៌ា ហើយប្រជាជនបញ្ជូនទៅម៉ាចំនួនទៀត ប្រជាជនភូមិខ្ញុំ ណឹងទៅបូព៌ាច្រើនណាស់ ។ ធ្វើប្រធានស្រុកអីណឹងម៉ាគំនរណឹង ។ ខ្ញុំចង់ទៅនឹងដែរ មិនគេ អត់ឲ្យទៅ ។

យឹមៈ ចា៎ អរគុណច្រើន

D24969
3

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណីពេទ្យ រៀល សន ភូមិព្រៃតាឡៃ ឃុំត្រពាំងធំខាងជើង
## នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០១
## សម្ភាសន៍ដោយៈ អែម សុខឃីម

សនៈ ខ្ញុំតាំងពីចូលមកគឺរហូតចប់ហ្នឹង

ឃីមៈ ៧៥ ហ្នឹងអ៊ុំចូលមករហូតចប់ហ្នឹង

ឃីមៈ តែនាងហ្នឹងមុន៧៥ តាព្រួន?

សនៈ បាទ

សនៈ អត់ទេ មុន៧៥ មានពេទ្យស្រុក

ឃីមៈ អញ្ចឹងអត់មានពេទ្យស្រុកអីទេ?

សនៈ បាទ

ឃីមៈ ទើបតែ៧៥បង្កើត

សនៈ ទើបតែ៧៥បង្កើត!

ឃីមៈ ចុះពេទ្យដែលថា ពេទ្យអីគេត្រពាំងព្រួលអីណា?

សនៈ អើអាហ្នឹងហើយ ខ្ញុំហើយហ្នឹងអ្នកមកបង្កើត

ឃីមៈ បង្កើត៧៥ហ្នឹងហ្នឹងរី?

សនៈ បាទ

ឃីមៈ ចុះបុគ្គលិកយកមកពីណាដែលបាន ៩៦ នាក់ហ្នឹង?

សនៈ បុគ្គលិកគេអោយមកតាមភូមិ

ឃីមៈ មកពីណា

សនៈ តាមភូមិ តាមឃុំខ្លះ អោយតែតាមឃុំមក

ឃីមៈ ចុះដែលថាបុគ្គលិកចាស់នៅតាមពេទ្យស្អីគេមុន៧៥ហ្នឹងណា?

សនៈ មានតែយ៉ាហ្នឹងមួយ

ឃីមៈ អញ្ចឹងអ៎! អញ្ចឹងក្រៅពីហ្នឹងសុទ្ធតែបង្កើតថ្មី?

សនៈ បាទ

ឃីមៈ ហើយអ៊ុំខ្ញុំចង់អោយអ៊ុំគូរទីតាំងពេទ្យបន្តិចណា? មន្ទីរពេទ្យហ្នឹងមានប៉ុន្មាន ទីតាំងពេទ្យមានអាគារសំរាប់ដាក់អ្នកជំងឺប៉ុន្មាននាក់អ៊ុំ? ប៉ុន្មានអាគារអ៊ុំ?

សនៈ បីអាគារ

ឃីមៈ ចុះបុគ្គលិកបុរសៗអ្នកឈឺ អ្នកណាគេមើល ប្រុសមើល រឺ ក៏ស្រីមើល?

សនៈ អត់ទេ បើស្រី ដូចកន្លែងណាឆ្លបអីបើណាកូនដែតមិនបានអី អាហ្នឹងបានគេជួយ ។

ឃីមៈ អញ្ចឹងហើយមួយអាគារមានប៉ុន្មានគ្រែទៅ?

សនៈ មួយអាគារមាន ដាក់បន្ទប់ៗក្នុយ

ឃីមៈ អញ្ចឹង មួយបន្ទប់មានប៉ុន្មាន?

សនៈ មួយបន្ទប់ជាង ១០ គ្រែ

ឃីមៈ ហើយមួយគ្រែមានប៉ុន្មាន ដាក់អ្នកជំងឺប៉ុន្មាននាក់?

សនៈ ដាក់មួយៗ គ្រែតូចៗ

ឃីមៈ អញ្ចឹងអេ អ៉ឺ

សនៈ បាទ

ឃីមៈ មួយបន្ទប់ប៉ុន្មានគ្រែ?

សនៈ មួយបន្ទប់ជាង ដប់បួន ដប់ប្រាំ មួយខាងប្រាំពីរៗ

ឃីមៈ ដាក់កណ្តាល ចន្លោះកណ្តាលដែរ

សនៈ ទុកចំហកណ្តាល

ឃីមៈ បាទ

សនៈ មិនមែនមួយហូតវែងអញ្ចឹងទេ

ឃីមៈ មួយបន្ទប់ខ័ណ្ឌៗ ខ្ញុំធ្វើមួយបន្ទប់ៗ

សនៈ ធ្វើអំពីអីគេ ឈើ ប្រក់ក្បឿង

ឃីមៈ ឈើ មិនមែនសាលារៀនទេវី

សនៈ សាលារៀនមួយខ្នងដែរ ធ្វើអំពីថ្ម

ឃីមៈ នៅសល់មួយខ្នង

សនៈ បាទ

ឃីមៈ ចាំ

សនៈ សាលារៀនហ្នឹងកន្លែងប្រុសៗ កន្លែងយុវជន

ឃីមៈ អញ្ចឹងខ្ញុំសុំអោយអ៊ុំ ជួយគូរទីតាំង អាគារហ្នឹង ខ្ញុំយកទៅដាក់នៅក្នុងកុំព្យូទ័រ អ៊ុំគូរទៅខ្ញុំយកទៅគូរនៅក្នុងកុំព្យូទ័រ អាគារអ្នកជំងឺនៅណា ហើយកន្លែងដាំបាយ កន្លែងអី គ្រាន់តែបានមើល ខ្ញុំយល់ហើយ ខ្ញុំយកទៅដល់គូរនៅក្នុងកុំព្យូទ័រទីតាំងពេទ្យហ្នឹងអ៊ុំម៉េចខ្លះ

ឃីមៈ គេដាក់ផ្ទាកខ្លោងទ្វារដែររឺ

សនៈ អត់ទេ

ឃីមៈ អត់មានដាកទេខ្ញុំ

សនៈ អាគារនេះ

ឃីមៈ ចាំ

សនៈ ខ្ញុំអត់ដឹងថាប៉ុន្មានទេ

ឃីមៈ ចាំ

សនៈ ប្រហែល ៣០ ម៉ែត្រដាង

ឃីមៈ ធ្វើពីក្បឿង អាគារហ្នឹងប្រក់ក្បឿងរឺ?

សនៈ ថ្ម

ឃីមៈ នៅសល់ពីសាលារៀនអេ៎អ៊ុំ?

សនៈ នៅសល់ពីសាលារៀន

ឃីមៈ សាលារៀនសង្គមចាស់

ឃីមៈ ចាំ

សនៈ មានប៉ុន្មានបន្ទប់?

ឃីមៈ អក្សរអ៊ុំស្អាត

សនៈ អី អក្សរខ្ញុំអាក្រក់ណាស់

ឃីមៈ អក្សរធំៗ ច្បាស់ស្អាត

សនៈ ដល់ដុតពីអាគារហ្នឹងហ្នង កាលហ្នឹងវាមានរបង តែខ្ញុំមិនបាច់គូររបងទេណា

ឃីមៈ ចាំ មិនបាច់គូររបងទេ

សនៈ ខ្ញុំភ្លេចហើយក្មួយ ខ្ញុំភ្លេចប្រវែងវា

យឹមៈ ចា៎ អត់អីទេដាក់តែគួរអញ្ចឹងបានហើយ អាណាអាគារអ្នកជំងឺស្រីរ៍

សនៈ បាទ

យឹមៈ ដាក់ជំងឺស្រីទៅបានហើយអ៊ុំ ខ្ញុំចាំហើយ

សនៈ ជំងឺស្រីអាក្អួយ

យឹមៈ ចា៎

យឹមៈ ជាប់គ្នាហ្នឹងហ្មងអត់ទល់មុខគ្នាទេ

សនៈ អានេះខ្ញុំធ្វើវាស្របផ្លូវពេកណា តាមពិតវាមិនស្រប ផ្លូវទេ

យឹមៈ វាវៀងឈៀងបន្តិច

សនៈ បា៎ ព្រោះផ្លូវហ្នឹងវាបត់អា

យឹមៈ ចា៎

សនៈ ផ្លូវហ្នឹងវាកាច់អញ្ចឹងទៅ អាគេធ្វើផ្លូវជាប់របងវត្តអា៎

យឹមៈ ចា៎

សនៈ អញ្ចឹងមានអាគារត្រង់នេះមួយទៀត

យឹមៈ អាគារជាប់ហ្នឹងរឺ

សនៈ បា៎ អាហ្នឹងមួយទៀតអាហ្នឹង

យឹមៈ អ្នកជំងឺ?

សនៈ ស្រីដែរ

យឹមៈ ចា៎ តែបីទេអញ្ចឹងអ៊ុំ

សនៈ បា៎ អត់ទេនៅមានទៀត ដល់ហើយនៅមានត្រង់នេះ

យឹមៈ ចា៎ អញ្ចឹងអាគារមានបួនហើយអញ្ចឹង អាគារអ្នកជំងឺមានបួនហើយអញ្ចឹង

សនៈ អាគារអ្នកសំរាលកូន

យឹមៈ អ៎

យឹមៈ ចុះកន្លែងអ៊ុំធ្វើថ្នាំ កន្លែងណា ខាងក្រោយ?

សនៈ កន្លែងសំរាលកូន ហើយបត់មកហ្នឹងទៀត នេះចង្រ្កានបាយ

យឹមៈ អ៎អញ្ចឹងជិតគ្នា ប្រហែលប៉ុន្មានម៉ែត្រពីគ្នា?

សនៈ ប្រហែលបួនប្រាំម៉ែត្រ

ឃឹមៈ  អ៎ ចា៎ មានគុកប៉ុន្មាន ចង្ក្រានហ្នឹងមានគុកប៉ុន្មាន វែងរឺទេ ចង្ក្រានច្រើនរឺទេ?

សនៈ  ចង្ក្រានបាយខ្ញុំតូចៗទេណា

ឃឹមៈ  ចា៎ អត់អីទេ

សនៈ  មានចង្ក្រាននេះ៦ ចង្ក្រានគប់ៗ

ឃឹមៈ  ចា៎ ស្គាល់ហើយ ធ្វើពីដីហ្នឹង ចាស់ៗ

សនៈ  អត់ទេខ្ញុំធ្វើពីស៊ីម៉ង់ណោះ

ឃឹមៈ  អ៎ ម៉ាំមែនទែនអញ្ចឹង

សនៈ  ធ្វើពីស៊ីម៉ង់ទាំងអស់ តែប៉ុនហ្នឹងមានតែប៉ុនហ្នឹង

ឃឹមៈ  ហើយកន្លែងនេះ កន្លែងហូបបាយនៅណា អ្នកជំងឺអី តុអី មានតុអីរឺអត់?

សនៈ  អ្នកន្លែងហូបបាយ

ឃឹមៈ  ចា៎

ឃឹមៈ  កន្លែងរោងហូបបាយអា៎ អ្នកជំងឺទាំងរោងបុគ្គលិកពេទ្យអី?

ឃឹមៈ  អូវែងអញ្ចឹងខិតមកមុខពេទ្យនេះវិញ

សនៈ  បា៎

ឃឹមៈ  ទៅជិតអ្នកជំងឺវិញ

ឃឹម ៈ គេដាក់តុ រឺ ក៏គេអោយយើងអង្គុយ?

សនៈ  តុ

ឃឹមៈ  តុវែងៗដូចសាលាអញ្ចឹងអេ?

សនៈ  តុវែងតែស្អាត ដូចកន្លែងអ្នកទោស

ឃឹមៈ  ចា៎ ចុះបុគ្គលិកពេទ្យពិសារនៅហ្នឹងដែរ ហូបបាយនៅហ្នឹងដែរ?

សនៈ  ហ្នឹងក្រោយអ្នកនេះ ហើយបែកជួរទាំងអស់

ឃឹមៈ  ចា៎

សនៈ  នេះកន្លែងធ្វើថ្នាំ

ឃឹមៈ  នៅក្រៅរបង នៅក្រៅរបងវិញ

សនៈ  ខាងត្បូងផ្លូវ

ឃឹមៈ  អ៎ ខាងត្បូងផ្លូវ

សនៈ ត្បូងផ្លូវ សាលាឃុំស្រុក

ឃីមៈ ឃើញហើយកន្លែងហ្នឹង

សនៈ ប៉ា៎

ឃីមៈ ណោះថ្នាំសម័យ ថ្នាំស្ងួរ ចុះថ្នាំអា៎បូរាណ?

សនៈ ថ្នាំបូរាណហ្នឹងមានផ្ទះហូរហែរហ្នឹង ពីរ បី

ឃីមៈ អញ្ចឹង ប៉ុន្មានផ្ទះទៅ?

សនៈ បី

ឃីមៈ ធ្វើអីច្រើនម៉េះ

សនៈ អានេះកន្លែងធ្វើថ្នាំសម័យអា៎

ឃីមៈ ចា៎

សនៈ ថ្នាំសម័យអានេះថ្នាំបូរាណ

ឃីមៈ ចា៎ ថ្នាំបូរាណអត់មានប្រដាប់ប្រដារអីដូចថ្នាំបូរាណទេអុំ?

សនៈ អត់ កំពុងតែរៀបចំ

ឃីមៈ អញ្ចឹង ប៉ុន្មានផ្ទះ ថ្នាំបូរាណ?

សនៈ ថ្នាំបូរាណពីរផ្ទះ

ឃីមៈ អញ្ចឹង សំរាប់ដាក់គ្រឿងគ្រាហ្នឹង

សនៈ ដាក់មួយកន្លែង កន្លែងធ្វើមួយ

ឃីមៈ ចា៎

សនៈ ហើយកន្លែង មានកន្លែងនារីដេកមួយទៀត

ឃីមៈ អញ្ចឹង មានជិតហ្នឹងទៀត ជាប់ហ្នឹងដែរ?

សនៈ មានកន្លែងនារីដេកនៅជាប់គ្នាដែរ

ឃីមៈ អត់មានដេកជាមួយក្រុមពួកពេទ្យទេ?

សនៈ ប៉ា៎ នែ អានៅក្នុងសម័យនេះក៏មកដេកនៅហ្នឹង

ឃីមៈ អ៎ ចុះមានបុគ្គលិកពេទ្យអុំមកសំរាន្តដែរ?

សនៈ បុគ្គលិកពេទ្យខ្ញុំអេ៎

ឃីមៈ ចា៎

សនៈ  កន្លែងនារីគេសំរាន្តខាងនារី

ឃីមៈ  កន្លែងណា? អុំគូរមកៗ

សនៈ  មានកុដិលោកមួយនៅចំកណ្តាល

ឃីមៈ  អ៎សំរាន្តនៅកុដិហ្នឹង

សនៈ  បា៎ មានកុដិលោកមួយ

ឃីមៈ  ចា៎

ឃីមៈ  អញ្ចឹងធំអុំ ស្រីៗសំរាន្តនៅហ្នឹងច្រើននាក់ នៅក្នុងកុដិលោកហ្នឹង?

សនៈ  ទេ វាមិនមែនបានដេកទាំងអស់គ្នាទេក្មួយ

ឃីមៈ  ម៉េច?

សនៈ  ទាំងអស់គ្នារកអីដេកបាន

ឃីមៈ  អញ្ចឹងធ្វើម៉េចវិញទៅ?

សនៈ  ចុះអ្នកជំងឺនេះ អានេះ បន្ទប់នេះ មួយបន្ទប់នេះ មួយបន្ទប់បួននាក់ៗ មួយបន្ទប់ហ្នឹងតែអញ្ចឹងអស់បួនហើយ ហើយអានេះក៏អញ្ចឹងដែរ ។

ឃីមៈ  អ៎ មួយបន្ទប់បួនៗ

សនៈ  បា៎ ហើយអ្នកដាំបាយវានៅចង្ក្រានបាយនេះ

ឃីមៈ  ធ្វើយាមទៅ ហើយដាំបាយសំរាន្តនៅឯណា?

សនៈ  បា៎ នៅកន្លែងបាយ នៅចង្ក្រាន

ឃីមៈ  នៅកន្លែងបាយ មានកន្លែងសំរាន្ត

សនៈ  មានកន្លែងចង្ក្រាននៅហ្នឹងទៀត

ឃីមៈ  អ៎

សនៈ  ហើយអញ្ចឹងនៅសល់ដែលអាត្រូវយាមចុងក្រោយវាផ្លាស់ប្តូរគ្នា បេះតែមកដេក

ឃីមៈ  ចុះថាគ្រែហ្នឹងសំរាន្តបានច្រើនគ្នា ប្តូរផ្លាស់ៗ

សនៈ  បា៎ ផ្លាស់ប្តូរៗ

ឃីមៈ  ចុះកន្លែងដាំដំណាំអីអុំ ដាំនៅក្រោយ ដាំឯណា?

សនៈ  អត់មានអេ៎

ឃីមៈ  ដាំបន្លែបន្ថែមផលអីអុំ

សនៈ   ប៉ា៎ មានតែស្ទូង

ឃីមៈ   អញ្ចឹងអេ

សនៈ   ស្ទូងធ្វើស្រែជុំវិញហ្នឹង ហើយពិសេសខ្ញុំអត់ទាំងធ្វើផងហ្នឹង ដូចឧទាហរណ៍ថាថ្ងៃហ្នឹង រៀបដូចថាត្រូវថ្ងៃធ្វើពលកម្មអីអញ្ចឹង ទៅអី នោះ បបួលគ្នាអ្នកសល់ពីអ្នកធ្វើការចាត់ចែង នេះហើយហ្នឹង សល់ប៉ុន្មានប្រហែល២០ ទៅ ៣០នាក់ទៅជួយស្ទូងអ្នកសហករនេះ ទៅជួយស្ទូងអ្នកសហករនោះ

ឃីមៈ   អញ្ចឹង មិនមែននេះអេ៎ មិនមែនស្ទូងរបស់យើងនៅក្នុងពេទ្យហ្នឹងទេ?

សនៈ   អត់ទេ

ឃីមៈ   អត់មានដីពេទ្យសំរាប់មួយពេទ្យហ្នឹងទេ?

សនៈ   អត់ទេ

ឃីមៈ   អង្គការនេះគេចែកអោយ ដូចយើង

សនៈ   បើចែកអោយក៏គ្មានពេលធ្វើដែរ

ឃីមៈ   ចុះអេថាចែកវេន ក្រុម រិលអា៎

សនៈ   នៅមានចែកអញ្ចឹងតែនេះទេ តែធ្វើស្មៅអីទេ

ឃីមៈ   អញ្ចឹងទេ

ឃីមៈ   អញ្ចឹងអត់មានចិញ្ចឹមសត្វចិញ្ចឹមអីទេ?

សនៈ   អត់

ឃីមៈ   ចុះក្នុងពេទ្យហ្នឹងអត់

សនៈ   អត់

ឃីមៈ   អ៎

សនៈ   សុំគេមួយ ថ្ងៃមួយហូប ហូបមួយឃុំ មួយថ្ងៃសុំមួយឃុំនេះ មួយថ្ងៃសុំមួយឃុំនោះ

ឃីមៈ   ចា៎ អត់មានថាដាំដំណាំដូចថាស្ពៃអីអត់?

សនៈ   អត់ទេ អា៎កន្លែងធ្វើថ្នាំនេះវាដាំអីតិចតួចអី តែដាំមិនបានវាអត់មានពេល គ្នាវាតិចតួច

ឃីមៈ   ៩៦នាក់ មិនតិចទេ

សនៈ   អេ មិនច្រើនទេ ៩៦នាក់ បើពេទ្យ អាធ្វើថ្នាំខ្លួនឯងនេះ មាននាក់លាងដបហ្នឹងបីបួនប្រាំនាក់ទៅ លាងអំពូល មានអាអ្នកដេញនែបិតទឹកហ្នឹងបីបួនប្រាំនាក់ទៅ ហើយអាអ្នកចូលធ្វើថ្នាំ

គ្នាបីនាក់ទៅ ។

ឃីមៈ  អញ្ចឹងចំណាយអស់គ្នាច្រើននាក់

សនៈ  ច្រើន ហើយជាពិសេសអាចូលធ្វើថ្នាំបូរាណអេ ជាងម្ភៃនាក់ទៅ

ឃីមៈ  អូច្រើននាក់ដែរ

សនៈ  ថ្នាំបូរាណ ដប់នាក់ទៅឡើងភ្នំ ទៅគិរីរម្យ ទៅណាទៅ កាលហ្នឹងមានឡានខ្ញុំ វុលវើរហ្គេន មួយ ។

ឃីមៈ  ចាំ មិនមែនដឹកអាទេះអេំអញ្ចឹង?

សនៈ  បាំ អាទេះ ក៏ដឹកដែរ ឡានក៏ដឹកដែរ ទៅទឹកឈូរអី យកឡានទៅ

ឃីមៈ  ចាំ ហើយទៅប៉ុន្មានថ្ងៃទើបមកវិញ?

សនៈ  ជួនទៅ ទៅ បី ថ្ងៃ ទៅ បួនប្រាំថ្ងៃ ខ្ញុំដោយសារមានសគ្គមកិច្ចមួយស្ថាប់នៅក្នុងភូមិ

ឃីមៈ  ចាំ ហើយមានដែលមានអ្នកជំងឺនៅក្នុងកងស្រុកមកនេះអុំអេ ពេលដែលវៀតណាមវៃ

សនៈ  អត់មាន ឃើញមានតែខ្មោច

ឃីមៈ  ហ្នឹងហើយ

សនៈ  ដល់តែចុងក្រោយបំផុតក្អួយអើយ ខ្ញុំរៀបចំឥវ៉ាន់ហើយអស់ហើយៗ មានសំបុត្រតាម៉ុក មួយមកពីកំពុងក្រសាំង ដល់ពេលកប់ខ្មោច អឹម សេ

ឃីមៈ  អូ

សនៈ  ដាក់ក្នុងម្ជប់ កាប់ដី ហើយរៀបចំឥវ៉ាន់ទៅ

ឃីមៈ  ហើយទៅណាអស់ ហើយរត់ទៅណាទៅ ៧៩ ហ្នឹង រត់ទៅណាវិញ?

សនៈ  រត់ទៅលិច រត់ទៅកើត ទៅណា ពេញដីទាំងអស់

ឃីមៈ  អូ

សនៈ  អ្នកណាគេដឹង មនុស្សសុទ្ធតែគេដឹងតាក្អួយ

ឃីមៈ  ចាំ

សនៈ  គេដឹងថាទៅគេកើតៗ

ឃីមៈ  ចាំ

សនៈ  ដូចខ្ញុំដឹងថាទៅកើត ខ្ញុំទៅកើតទៅ កុំអោយយួនវាយងាប់ ព្រោះវាឃ្លានពេក

ឃីមៈ  ចាំ

សនៈ ទុកអោយវាដកឃ្លាសិន ខ្ញុំថាមិនឃោឃៅអីប៉ុន្មានទេ តែវាធាតុពិត គេមិនមែនស្រឡាញ់ទាំងអស់ទេ

ឃីមៈ ត្រូវហើយ

សនៈ គេស្អប់យើង

ឃីមៈ ត្រូវហើយអ៊ុំ

សនៈ អញ្ចឹងខ្ញុំចង់បង្ហាញអោយឃើញ

ឃីមៈ ទៅប៉ុន្មានថៃទើបអ៊ុំត្រឡប់មកវិកកាលហ្នឹង

សនៈ មិន ដល់ អេយូរដែរហ្នឹង ចូលមកវិញអត់ទេ គ្រាន់តែថាទៅដលខ្ញុំមានដឹកអង្ករ មាន ទេះសេះ មានគោជល់ មានអីទៀតហ្នឹងអា ទៅដល់វាចង់អស់ខ្ញុំរត់មកវិញ មកដល់នេះគេធ្វើ ស្រែ យូរដែរហ្នឹង

ឃីមៈ ខែធ្វើស្រែអញ្ចឹង? ខែ ៥ ខែ ៦ អញ្ចឹង

សនៈ ផល្គុន ចែត្រ ពិសាខ

ឃីមៈ ចាំ ព្រោះអី ខែ មួយ គេវាយបែក ខែ ៥ ខែ ៦ ត្រូវហើយ ។ ហើយអ៊ុំលួចមករឺ ក៏ មកតាមក្រោយ?

សនៈ លួចចោលអីអស់ រែកមកចោលគោ គេអាណិតខ្ញុំ គេដឹកគោយកមកអោយមួយដល់ ផ្ទះអស់

ឃីមៈ អូ បើសិនជាមកតាមត្រង់អត់បានទេអញ្ចឹង លួចអញ្ចឹង?

សនៈ អត់បានទេ

ឃីមៈ អញ្ចឹងលួច អ្នកដែលមកសុទ្ធតែលួច ។ ហើយចុះគេនារី។ពេទ្យ

សនៈ នារីពេទ្យហ្នឹងនៅជាមួយខ្ញុំ អត់ទេនៅហើយមកវិញហ្នង មកដល់ខ្ញុំចែកអង្ករអោយគ្រប់គ្នា ទៅផ្ទះវិញទៅ

ឃីមៈ ត្រឡប់មកផ្ទះវិញដែរអញ្ចឹង

សនៈ បាទ

ឃីមៈ ទៅគ្នាច្រើនរឺទេទៅដល់ស្រុកត្រាំកក់ហ្នឹង

សនៈ ទៅកាលហ្នឹងជាងដប់នាក់

ឃីមៈ ចុះក្រៅពីហ្នឹងគេទៅណាអស់ទៅ ៩០នាក់ទៀត

សនៈ ទៅតាមជួបម៉ែគេអោយ បងប្អូនគេអោយទៅ

ឃីមៈ ជួបកណ្តាលផ្លូវ?

សនៈ បាទ

ឃីមៈ អត់មានហាមឃាត់អីទេ?

សនៈ អត់ទេ

ឃីមៈ អ៊ុំកាលចេះផលិតថ្នាំសម័យហ្នឹង អ៊ុំចេះមកពីអ្នកណាគេ?

សនៈ ថ្នាំសម័យចេះមកពីឫស្សីហ្នឹង

ឃីមៈ ឫស្សីហ្នឹងចេះមកពីអ្នកណាគេ

សនៈ ឫស្សីពេទ្យពីសង្គម គាត់រត់ចូលមកជាមួយ ខៀវសំផនអីហ្នឹង អាសីហ្នឹង

ឃីមៈ ឆ្នាំ៧០

សនៈ ពេលគេបែក

ឃីមៈ គាត់មិនមែនរត់មកឆ្នាំ៧០ទេ

សនៈ មុនឆ្នាំ៧០

ឃីមៈ អញ្ចឹង

សនៈ បាទ

ឃីមៈ អញ្ចឹងគាត់ចេះ មកពីនេះ ចេះយូរហើយអញ្ចឹង

សនៈ គាត់ពេទ្យមាលាហ្នឹង អាំ តែមិនដឹងជាគាត់ពេទ្យខាងអី ខ្ញុំអត់បានសួរ

ឃីមៈ ចាំ ចុះអ៊ុំកាលឆ្នាំអុមថាចិនជំនួយមកកាលសម័យខ្មែរក្រហមហ្នឹង ជំនួយម្តងប៉ុន្មានទៅ?

សនៈ ច្រើនដែរហ្នឹង ម្តងហ្នឹងកាលយកទៅបើកអាឡានឡង់រ៉ូវែរ អាហ្នឹងបើដឹកទៅសំរាប់អ្នកស្រុក អើយជូនកាលហ្នឹងថ្នាំអាស្ពីរីន មួយឃុំអី បានតែមួយកំប៉ុងអីរ៉ុនទេ

ឃីមៈ អូ បានបន្តិចតែមួយ ៗ ហើយបានប៉ុន្មានដង កាលអ៊ុំនៅធ្វើការ ៧៩

សនៈ ចែករាល់តែខែ

ឃីមៈ មួយខែគឺមួយឡាន

សនៈ មកសំរាប់ស្រុករឺ?

ឃីមៈ ចាំសំរាប់ស្រុក

សនៈ  អោយតែមកដល់ស្រុកគេហៅយើងអោយទៅចែកហ្នឹង អត់ដឹកដល់ស្រុកនេះទេ ទៅចែកក្នុងទីស្រុក

យីមៈ  អូ ហៅពេទ្យឃុំមកដែរ

សនៈ  ពេទ្យតាមឃុំមកយក

សនៈ  អូ យើងចែកអាណាចាំបាច់ ថ្នាំផ្សំផ្គុំ ផ្សំអីហ្នឹង យើងឈប់ប្រើប្រាស់អោយពេទ្យស្រុកទៅ

យីមៈ  ចាំ

សនៈ  ហើយថ្នាំអាស្តីរីនអី អាហ្នឹងចែកគ្នាទៅ បានប្អូនដប់បន្ទះមួយឃុំហ្នឹង

យីមៈ  អូអញ្ចឹងមួយខែម្តងៗ

សនៈ  មួយខែម្តង

យីមៈ  មិនមែនតិចទេណា

សនៈ  គ្រាន់ស៊ីក្អួយ មួយឃុំបើថាគេគ្រាទំពារ បាន១០ បន្ទះ អីហ្នឹង

យីមៈ  អូ

សនៈ  ហើយធ្មើអីទៅ

យីមៈ  មកមួយឡានៗ មែនតែវាតិច

សនៈ  មួយឡានសំរាប់ មួយស្រុកមួយភូមិ

យីមៈ  ឡានតូចរឺ?

ផ្សេងៈ ឡានឡង់រ៉ូវែរ

សនៈ  ឡង់រ៉ូវែរប៉ុនឡានស៊ីប ធំជាងស៊ីប

យីមៈ  អូ មួយខែម្តង ខ្វះខាតអី ធ្វើយ៉ាងម៉េចទៅអ៊ុំ?

សនៈ  បើខ្វះខាតចាំបាច់យើងបញ្ជូនអ្នកជំងឺ

យីមៈ  ចុះអ៊ុំបានវត្ថុធាតុដើមផលិតថ្នាំមកពីណា?

សនៈ  ទិញ

យីមៈ  ទិញពីគេ

សនៈ  ទិញពីគេ

យីមៈ  អង្គការអត់មានបញ្ជូនមកទេ?

សនៈ ទិញ ដូនកាលទៅ ចិន ចិនមានអោយតែ បេខូទេ ក្រៅពីហ្នឹងខ្ញុំទិញ

ឃីមៈ អ៊ុំទៅទិញនៅឯណា?

សនៈ ទៅទិញនៅស្រុកយួន

ឃីមៈ ទិញឆ្នាំណាខ្លះអ៊ុំ?

សនៈ ទិញប្រហែលបីឆ្នាំតាមមើល ៧៣-៧៤-៧៥

ឃីមៈ ចុះអេថាអ៊ុំបង្កើតពេទ្យ កាល៧៥ ពេលបង្កើតពេទ្យ ពេទ្យ ៧៥

សនៈ ប៉ុនខ្ញុំអញ្ចឹង គេប្រើអញ្ចឹង

ឃីមៈ អូគេប្រើអញ្ចឹងហ្នឹង

សនៈ គេដឹងយើងអញ្ចឹងហ្នឹង ទើបគេអោយយើងប្រើ

ឃីមៈ អូ គេដឹងយើងគ្រលាក់គុង

សនៈ ខ្ញុំវាចូលចិត្តខ្លួនឯងដែរហ្នឹង គេចូលចិត្តប្រើ

ឃីមៈ អេមានអីអ៊ុំ គេវាទុកចិត្តយើងៗ

សនៈ គេទុកចិត្ត

ឃីមៈ ចុះមានដឹងហេតុអីបានជាគេអោយយើងធ្វើថ្នាំហ្នឹងទេ បានជាអង្គការគេអោយយើង ផលិតថ្នាំបូរាណហ្នឹងទេ?

សនៈ គេអោយឯករាជ្យម្ចាស់ការអញ្ចឹងហ្នឹង

ឃីមៈ ចង់អញ្ចឹងហ្នឹងរឺ?

សនៈ ប៉ុនអ៊ុំគិតអញ្ចេះក្មួយ បើសិនណាជារបបហ្នឹងវានៅរហូតទៀតណា អ៊ុំមិនមែនមិនចេះធ្វើវត្ថុ ធាតុដើមខ្លួនឯងទេ ធ្វើខ្លួនឯងហ្នឹង ដូចជាពេនីសេលីនជាដើម ដូចជាវាមានក្បួនវា

ឃីមៈ អញ្ចឹងវាមានក្បួនវា

សនៈ អើ វាមានផ្ទាមម៉ាស៊ី

ឃីមៈ ចា៎

សនៈ ខាងផ្ទាមម៉ាស៊ី គេបង្រៀនទាំងអស់ហ្នឹង ហើយមានធ្វើយ៉ាងម៉េចៗអី ធ្វើខ្ញុំភ្លេចអស់ ហើយ ទើបតែបានតិចទេ

ឃីមៈ អូ រៀនបានៗ ឆ្ងល់ថាហេតុអ៊ីបានជាថ្នាំគេដាក់ដបធំៗម៉្លេះ សម័យហ្នឹង ពេទ្យហ្នឹង អ្នកណាក៏ធ្វើដាក់ដបៗទឹកត្រីដែរ

សនៈ អូ កាលហ្នឹងវាអញ្ចេះ អាថ្នាំវាចាំបាច់ហ្នឹង គេត្រូវដាក់អំពូល

ឃីមៈ ចា៎

សនៈ ហើយកាលហ្នឹងអត់ទាន់ផលិតអំពូលទេ ហើយចុងក្រោយមកផលិតអំពូល ផលិតអំពូលបានខ្លួនឯងទេតើ

ឃីមៈ ឆ្នាំណាអាចផលិតអំពូលបាន

សនៈ ឆ្នាំ៧៥-៧៦ ហ្នឹងហើយបានចេះធ្វើអំពូលបាន ហើយកាលណាចេះធ្វើអំពូលហ្នឹងហើយក៏ មិនគ្រប់ទៀត ទាល់តែដាក់អាដបធំហ្នឹងហ្នង ព្រោះមួយថ្ងៃៗឧទាហរណ៍ថា បេអង ហើយពេទ្យត្រូវការព្យាបាលជំងឺវែងមិនដឹង កាលហ្នឹងអ្នកជំងឺហើបច្រើនជាងគេ ផ្លូវមិនដឹង បេអងបេខ្ទូហ្នឹងច្រើន បើអញ្ចឹងបើដាក់អំពូលចាក់មិនឈ្នះទេ វាហើមច្រើន អញ្ចឹងដាក់ដបធំតែម្តងទៅ

ឃីមៈ ចា៎

សនៈ ហើយចាក់អាដប ២០០ សេ។

ផៀងៈ អានោះ វាបានច្រើនត្រូវហើយ

សនៈ ចុងក្រោយមក នៅរហូតដល់ផ្លូវហ្នឹង អាអំពូលអាក្លាសេខ្ញុំចេះធ្វើមកហ្នឹង

ឃីមៈ លឺ ក្នុងឯកសារអុំ ឯកសារអាពត ថាគេអោយយកដបធំហ្នឹងវិញ ហេតុអីដែរ? ព្រោះអីថាបើខ្វះដប គេអោយលាងដបអាដបសល់អី

សនៈ ដបទឹកក្រូច

ឃីមៈ ហ្នឹងហើយ ដបទឹកក្រូចសល់យកមកដាក់ដូចអុំនិយាយអញ្ចឹង

សនៈ បាទ

ឃីមៈ អត់មានថែមការនេះអី ធ្វើ អត់ទាន់ទេ

សនៈ អត់ចេះ

ឃីមៈ ចា៎

សនៈ និយាយរួមតែក្រោយ តែពួកខ្ញុំចេញហូត ពូល មួយថ្ងៃហូតបានច្រើនដែរ

ឃីមៈ ចា៎ ខ្ញុំចង់សួរកន្លែងពេទ្យតំបន់ ថាតើពេល ឬស្សីហ្នឹងពេលគេចាប់ទៅអ្នកណាឡើងជំនួសវិញ?

សនៈ ថៃស៊ឺន

ឃីមៈ អ្នកណាគេត្រូវឡើងជំនួស បៃស៊ិនហ្នឹងត្រូវប្អូនតាម៉ុកហ្នឹងមែនទេ?

សនៈ បៃស៊ីន ប្អូនតាម៉ុក

ឃីមៈ ហើយគាត់ចេះដែររឺទេ?

សនៈ គាត់មិនសូវរៀនបានច្រើនផង

ឃីមៈ គាត់រៀនពេទ្យហ្នឹងដែររឺ?

សនៈ អត់ទេ តែដល់ចុងក្រោយរៀន គេអោយក្តាប់តែខ្លះទេ អ្នកបច្ចេកទេស

ឃីមៈ អ៎ គ្រាន់តែគាត់ក្តាប់រួម

សនៈ ក្តាប់រួម បាទ ផ្នែកនយោបាយនិយាយរួម កាលហ្នឹងគេគិតរឿងនយោបាយច្រើន

ឃីមៈ ខ្លាំងអាកាលហ្នឹងផ្នែកនយោបាយ ។ កាលអុំបង្រៀនគេពេទ្យនៅតាមស្រុកហ្នឹងមាន អុំបង្រៀនគេ មានកៅអី អង្គុយដែររឺអត់?

សនៈ មាន

ឃីមៈ គេធ្វើបន្ទប់បង្រៀនដែររឺ ?

សនៈ មានសាលាគេ

ឃីមៈ សាលានៅឯណា គេធ្វើនៅក្នុងមន្ទីរពេទ្យអុំ

សនៈ អូដែរពេទ្យខ្ញុំ?

ឃីមៈ ចា៎ ពេទ្យអុំ

សនៈ ខ្ញុំបង្រៀននៅឯកន្លែងវិហារ

ឃីមៈ អញ្ចឹងអេ៎ នៅឯកន្លែងវិហារ កន្លែងនេះហ្មង

សនៈ បាទ

ឃីមៈ មានកៅអីមានក្តារខៀនអី កៅអីគ្រប់គ្រាន់?

សនៈ អូ កៅអី អីមានសំបូរគ្រប់គ្រាន់មុំាអា មានប៉ុន្មានរយកៅអី កៅអីឈើ

ឃីមៈ កាលពីអុំនៅបង្រៀនមាននិយាយពីពេទ្យកាលពីសង្គមខុសគ្នាពីពេទ្យអភិវឌ្ឍយ៉ាងម៉េចខ្លះ?

សនៈ អត់ទេៗ ពេទ្យអត់មានខុសពីពេទ្យណាៗទេ

ឃីមៈ ចង់និយាយថាអញ្ចេះ លក្ខណៈនៃការបំរើ លក្ខណៈនយោបាយរបស់ខ្មែរក្រហម មាននិយាយពេទ្យពីសង្គម គាត់ដេកថាពីពេទ្យសម័យលុន ណុល សីហនុអីរឺទេ ហើយនេះអេ៎ កាលសម័យហ្នឹង?

សនៈ អត់ទេពេទ្យគេនិយាយអញ្ចេះ គេនិយាយថាពេទ្យ ទាំងគ្រប់ផ្នែកគឺដូចគ្នាទាំងអស់ហ្នឹង បាទ អត់មានថាតឹង របៀបរបបព្យាបាល របៀបធ្វើថ្នាំធ្វើអី គ្រូដូចគ្នាទាំងអស់

ឃីមៈ ដូចពីសង្គមដែរ?

សនៈ បាទ ដូចគ្នា

ឃីមៈ លក្ខណៈខុសគ្នាត្រង់ណា?

សនៈ ខុសគ្នាត្រង់អានេះអត់ អត់មានអី ខុសគ្នាត្រង់អានេះវាឯករាជ្យម្ចាស់ការ

ឃីមៈ ចុះអ៊ុំមានដែលទៅភ្នំពេញទេ?

សនៈ ទៅ

ឃីមៈ យកថ្នាំអីពីក្រសួងសង្គមកិច្ចនៅ

សនៈ អត់ដែលទេ ដែលតែយកអ្នកជំងឺទៅ ហើយដូចថាទៅម្តងទៅគ្នាវាទល់ច្រកពេកទៅ ទៅយន្តធំ អញ្ចឹងសួរគេថាផ្ទះដុកទ័រនៅឯណា ទៅផ្ទះដុកទ័រហ្នឹង

ឃីមៈ ដុកទ័រកំពុងធ្វើអី?

សនៈ កំពុងធ្វើថ្នាំ កំពុងព្យាបាល កំពុងរៀបចំធ្វើថ្នាំ

ឃីមៈ ហើយកាលហ្នឹងអ្នកណាគេដុកទ័រ?

សនៈ អូភ្លេចហើយ បំភ្លេចចោល បើសិនកាលណាខ្ញុំយកសៀវភៅហ្នឹងបានវិញ ខ្ញុំដេកលក់កាលហ្នឹងច្រើនអា គិតមើល អាឌីសសីណៃ អាឌីសសីណៃឡារ៉ូស អាផ្កាមាំកូពី ហ្នឹង ខ្ញុំដឹងប៉ុន្មានអាហ្នឹង ៤-៥-៦-៧ ៨ ក្បាល អាហ្នឹងធំៗ អញ្ចេះៗ

ឃីមៈ អាហ្នឹងឆ្នាំណា?

សនៈ ឆ្នាំ ៧៥-៧៦

ឃីមៈ នៅម្តុំណាទៅពេទ្យណា?

សនៈ ផ្ទះដុកទ័រហ្នឹងនៅ ខាងកើតវត្តមហាមន្ត្រី

ឃីមៈ ផ្ទះហ្នឹងអេ?

សនៈ ផ្ទះ នៅផ្ទះគាត់

ឃីមៈ តែគាត់ធ្វើនៅ ពេទ្យអីគេ?

សនៈ ដុកទ័រ អត់ដឹង

ឃីមៈ ឈ្មោះ ឌី ផុន រី ក៏ សុខ ធុប ពេទ្យថ្នាំបូរាណ

សនៈ មិនមែនទេ មិនមែនថ្នាំបូរាណទេ សម័យទេតើ

ឃីមៈ អញ្ចឹងអេ

សនៈ បាទ

សនៈ ដុកទ័រហ្នឹង?

ឃីមៈ ចាំ

សនៈ ខ្ញុំភ្លេចឈ្មោះគាត់សរសេរក្នុងសៀវភៅហ្នឹងទាំងអស់ ឈ្មោះគាត់ ហើយខ្ញុំទៅហ្នឹង យកទាំងប៊ិច យកទាំងស្លឹ ប្រដាប់ប្រដាពេទ្យគាត់ហ្នឹងនៅក្នុងផ្ទះគាត់ហ្នឹងខ្ញុំដឹកយកមកទាំងអស់ ហ្នឹង ពេលនោះខ្ញុំឃើញកូនមួយ ប្រហែលប៉ុនហ្នឹងស្លាប់ គាត់ដាក់ក្នុងក្រោម ប្រឡោះក្រែអញ្ចោះ ក្រែ តូចៗ

ឃីមៈ អញ្ចឹង អត់យកទៅកប់

សនៈ ដាក់នៅក្នុងឡាំង

ឃីមៈ អត់យកទៅកប់

សនៈ វាដល់ពេលកុនយើងចេញអាំ

ឃីមៈ រៀបចេញហ្នឹងដល់ឆ្នាំណា?

សនៈ ឆ្នាំ៧៩ កាលបែកគេត្រូវជំលាសចេញ

ឃីមៈ ត្រូវហើយៗ អញ្ចឹងអុំយកពីហ្នឹងហ្នឹង

សនៈ កាលហ្នឹងយកបានសៀវភៅច្រើន ហើយប្រដាប់ប្រដារប្រើប្រាស់

ឃីមៈ ៧៩ កាលបែកហ្នឹង ហើយគាត់ទៅណា ដុកទ័រហ្នឹង?

សនៈ អត់ដឹង

ឃីមៈ អញ្ចឹងបានន័យថាគាត់ខ្មែរ ខ្មែរធំ

សនៈ មិនដឹងទេ ខ្ញុំដើរទៅយកហ្នឹង

ឃីមៈ ចាំ ចុះអុំមានដឹងកូន អៀង ធារីទ្ធដឹងនៅពេទ្យអីខ្លះ?

សនៈ ខ្ញុំអត់ដឹង

ឃីមៈ ចុះទំនាក់ទំនងទៅពេទ្យលើយ៉ាងម៉េចដែរ?

សនៈ ទំនាក់ទំនងពេទ្យស្រុក ខ្ញុំទំនាក់ទំនងតែពេទ្យតំបន់

ឃីមៈ ចាំ

សនៈ ក្រដាសនេះដូចគ្នាទេតើ ក្រដាសប្រក្រតិទិន

យីមៈ ប៉ុន្តែចាស់ៗច្រើនតែដក់ស្ទីកកែ

យីមៈ អត់អីទេ ហូបទៅអ៊ុំ ធ្លាប់ហើយបើខ្ញុំនៅស្រុកស្រែដែរ

សនៈ នែ ទំនាក់ទំនងតែពេទ្យស្រុកហើយពេទ្យតំបន់ តែខ្ញុំអញ្ចេះបើកុនថ្នាំអីពេក ហើយបើដឹងគេមានដូចជា គេវាមានចំការកៅស៊ូអីវ៉ាន់ ទៅចំការកៅស៊ូ

យីមៈ ទៅអីបានឆ្ងាយម៉្លេះ

សនៈ ចុះបើតាជីមលែងធ្វើកាណៈស្រុកនៅនេះ គាត់ទៅធ្វើច្បាប់រួមនៅចំការកៅស៊ូ

យីមៈ ចុះគេថានៅតំបន់ហេត្រាត

សនៈ តាជីម

យីមៈ អ៊ំ តាជីម អញ្ចឹងគាត់ឈប់ពីខណៈស្រុកនេះទៅនេះវិញ ពេញ ជីមហ្នឹង មែនរឺទេ

សនៈ ព្រាប

យីមៈ ព្រាប គិត ទេ

សនៈ តាជីម ហ្នឹងប្អូនតាគិតហ្នឹងបង្កើត

យីមៈ អញ្ចឹង ប្អូនតាជីមទេ

សនៈ តែមិនដឹងដាក់ស្អីទៀតមិនដឹងដែរ ប្អូនបង្កើត

យីមៈ អញ្ចឹងគាត់ទៅក្តាប់ហ្នឹងឆ្នាំណាកាលហ្នឹង នៅចំការកៅស៊ូហ្នឹង?

សនៈ តាំងពី៧៥រហូត មក ដល់បែកមក

យីមៈ អ៊ំ

សនៈ ហើយអាជនហ្នឹងក៏អញ្ចឹងដែរ នៅជាមួយគាត់ហ្នឹង អូទៅដល់នោះទៅតាជីមហ្នឹងទៅដល់ អន្ទង់វែង ទៅដល់នោះទៅហ្នឹងទៅនៅអណ្តូង

យីមៈ កាលឆ្នាំកាលសម័យខ្មែរក្រហមហ្នឹងអ៊ុំ ពួកទៅក្តាប់ខាងនិរតីហ្នឹងហេតុអីបានជាគេអោយ?

សនៈ ជាពិសេសស្រុកតាប្រក់

យីមៈ ហ្នឹងហើយហេតុអីបានជានារីពេទ្យ បានទៅបាត់ដំបង ឃើញទៅបាត់ដំបង កំពង់ចាម?

សនៈ ក្អួយឯងនិយាយពីអត់មាន ទីមួយអស់រលីង

យីមៈ ហ្នឹងហើយ

សនៈ តូចៗមិនទាន់ទាំងអាយុដប់ពីរដង យាត់វាអត់បាន

ឃីមៈ ចាំ

សនៈ អាហ្នឹងយំហើយ បើកាលណាវាត្រូវអាំ

ឃីមៈ ចាំ

សនៈ វាកំពុងតែអញ្ចឹងវាលង់ ម៉ែឪឃាត់យ៉ាងម៉េចក៍មិនស្តាប់ដែរ

ឃីមៈ ចាំ

សនៈ គេថាឃាត់ប្រាប់ បើវាចង់

ឃីមៈ ប្រាប់ត្រង់ចងមិនដាប់មែនៗ ហើយកាលហ្នឹងហេតុអីបានជាគេអោយពួកស្រុកត្រាំកក់អាំ ប្រជាជនត្រាំកក់ទៅត្រួតត្រា នៅតំបន់ផ្សេងៗអញ្ចឹង

សនៈ មកពីពួកហ្នឹងបានអប់រំមុនគេ

ឃីមៈ អ៊ំ

សនៈ គេមកនៅហ្នឹងមុន អប់រំបានមុន

ឃីមៈ ហ្នឹងហើយទៅ

សនៈ ក្នុយឯងគិតមើលកសាងកម្មាភិបាល ក្នុងមួយឃុំមានប៉ុន្មាននាក់អញ្ចឹងទៅ ដល់កសាងកម្មាភិបាលគេមិនយកទៅដាក់នៅកន្លែងផ្សេងៗទៅណា

ឃីមៈ ចាំ

សនៈ ធ្វើប្រធានៗគេទៅណា

ឃីមៈ នៅប្រធានៗគេ មិនសូវទាំងចេះអីផង

សនៈ មានចេះអី អោយតែចេះប្តេជ្ញាថាស្មោះត្រង់

ឃីមៈ អញ្ចឹងគេត្រូវការភាពស្មោះត្រង់អញ្ចឹងអេំ?

សនៈ បាំ ដាច់ខាត

ឃីមៈ អ៊ំ ដាច់ខាតស្មោះត្រង់

ឃីមៈ ចេះមិនចេះគេអត់គិតទេអ៊ុំរឺ?

សនៈ គេមិនចេះគិត គាចាយអត់ចេះអក្សរមួយតួផង

ឃីមៈ ហើយទៅខណៈស្រុកដែរ

សនៈ ខណៈស្រុក

ឃីមៈ អ៊ំ ហើយដល់ពេលគាត់ឈប់ពីខណៈស្រុកគាត់ទៅណាវិញគាចាយ?

សនៈ  អត់ទេដល់ហើយរត់ ទៅគាត់ទៅនៅជាមួយតាម៉ុកនៅហ្នុង ទៅនៅអន្លង់វែងហ្នឹងហ្នុង

ឃីមៈ ចា៎ អញ្ចឹងគាត់ខណៈស្រុករហូតរឹតាថែម?

សនៈ  ខណៈតំបន់ណាទៀត ដល់ក្រោយបានខ្ញុំដឹង

ឃីមៈ  ឡើងតំបន់ទៀត

សនៈ  ឡើងតំបន់ទៀត

ឃីមៈ  ខ្លាំងមែនទែនតាចាយ

សនៈ  ទៅនែ ខាងបាត់ដំបងខាងអី

ឃីមៈ  ចា៎ អ៎ ហើយអ៊ុំខ្ញុំភ្លេចសួរកន្លែងថាពេលគេរកផ្លាស់បុគ្គលិកអា៎ បើខ្លះផ្លាស់បុគ្គលិកពេទ្យអត់ទៀតទាត់ អ៊ុំនិយាយកាលពីមុន ទៅស្រុកតិចៗដកអី អញ្ចឹងមិនបុគ្គលិកអ៊ុំខ្វះ ពិបាកមករៀនម្តងទៀតរឺអ៊ុំ បច្ចេកទេសពេទ្យអី?

សនៈ  អត់ទេ បើខ្វះហៅសុំគេ

ឃីមៈ  សុំមកពីណាវិញ?

សនៈ  សុំស្រុកអា៎ ស្រុកគេអោយយកមក យកពីឃុំមកវិញ

ឃីមៈ  អញ្ចឹងអ្នកចេះស្រាប់ រឺក៏អត់ចេះ?

សនៈ  ជួនកាល អ្នកចេះស្រាប់ ជួនកាលអ្នកក៏អត់ចេះ

ឃីមៈ  អ្នកអត់ចេះធ្វើយ៉ាងម៉េច ពិបាកបង្រៀនទៀត?

សនៈ  យើងយកមកបង្ហាត់បង្រៀន

ឃីមៈ  ខាតពេលណាអ៊ុំ

សនៈ  ខាតវាមិនច្រើនទេណា ម្នាក់ពីរនាក់ កាលណាយើងយកមកអញ្ចឹង  មុនដំបូងដូចក្មួយនោះយកមកដំបូងអញ្ចឹងអោយមករៀន អោយជួយលាងបង្ហែ លាងអាយអញ្ចឹងទៅសិនទៅណាហើយចេះតែបង្រៀនៗ

ឃីមៈ  ចា៎ ហើយបច្ចេកទេសចេះរឺទេ ពួកអ្នករៀនក្រោយហ្នឹង?

សនៈ  ចេះ ដល់តែយូរទៅ ចេះដូចតែគ្នា

ឃីមៈ  អ៎ ចុះកន្លែងពេទ្យអ៊ុំមានអគ្គការគេចាប់ទៅប៉ុន្មាននាក់ទៅ? មានដែលចាប់យកទៅដូចជានអី?

សនៈ  ចាប់អៅ មានអាជានមួយ ក្មួយឯងដែរទៅជួបអេ?

យីមៈ នៅកំពុងថា ទៅស្អែកហ្នឹងអាំ ចាំមើលទៅជួបគាត់ ឈ្មោះសារ៉ុនអាំ រ៉ុណាមួយទៀតគេចាប់ដែរ

សនៈ រ៉ុណាអេំ?

យីមៈ ហ្នឹងហើយគេចាប់ដែរ នៅពេទ្យណា? ចុះបងថានហ្នឹង ចាំមើលខ្ញុំទៅខាងប្រច័ណ្ឌ ចាំមើលខ្ញុំទៅជួបពូអីជាប់គុកខាងគុកខាងប្រច័ណ្ឌហ្នឹងកាលជុំហាយហ្នឹង គាត់ថាបងថានហ្នឹងមិនមែនជាប់គុកព្រោះខុសសីលធម៌ទេ មកពីប្ដីគាត់ហ្នឹង ហើយខ្ញុំអត់មាត់ទេ ព្រោះអីអ៊ុំនិយាយប្រាប់ថាប្រធានបងថានហ្នឹង ដឹងរឿងបងថានហ្នឹងហើយណា ថាស្រលាញ់នរណាគេហ្នឹងខុសសីលធម៌ ខុសអី គេឃើញអា ហើយគេយកទៅ បងថានហ្នឹងទៅប្រាប់គេថាប្ដីទាក់ទងគេនៅហាណូយអីរ៉ុន បងថានហ្នឹងខ្ញុំមិនទាន់ទៅបានជួបបងថានហ្នឹងដែរ រវល់តែអត់មានពេល

សនៈ អត់ជួបខ្ញុំអាណិតវាដែរ

យីមៈ តែគេអោយដាំបាយហ្នឹង អត់មានធ្វើបាបអីផង

សនៈ ខ្ញុំទៅមើលវារាល់តែដង

យីមៈ ហើយទៅដល់គេថាអ្នកគុកហ្នឹងនិយាយយ៉ាងម៉េច?

សនៈ ខ្ញុំមិនដឹង

យីមៈ ចាំ អ្នកគុកហ្នឹងនិយាយអាំ អ្នកជាប់គុក

សនៈ ដឹងទេឈ្មោះអាច័ន្ទ

យីមៈ នៅហ្នឹងរាល់ថ្ងៃហើយរស់ដែរហ្នឹង?

សនៈ វាអត់ដែលមកផង ខ្ញុំអត់ដឹងផង

យីមៈ ត្រូវហើយយើង ចុះគេចាប់តែបងថានហ្នឹងមួយទេ អត់ចាប់អ្នកណាទៀតទេ?

សនៈ ចាប់តែមួយទេ សារ៉ុនហ្នឹងចាប់ម៉េចទៅ ក្មួយឯងនិយាយមើល?

យីមៈ គេថាឈ្មោះសារ៉ុន រាល់ថ្ងៃមិនដឹងនៅឯណា នៅអីណាទេ

សនៈ ឈ្មោះសារ៉ុនហ្នឹងប្អូនយែប៉ុន

យីមៈ ហ្នឹងហើយគេថាអញ្ចោះ នៅរស់សារ៉ុនហ្នឹង?

សនៈ មិនដឹងយ៉ាងម៉េចសារ៉ុនហ្នឹង តែមិនស្រួលដូចនៅទេ

យីមៈ លឺថាដូចរស់ នៅឯណាអេ នៅអន្តរបូរី កោះអណ្តែតអីមិនដឹងទេ អ្នកនេះហ្នឹងអត់ច្បាស់ដែរ បងថានហ្នឹងដឹងតែនៅកន្លែងអុំប្រាប់ដូចគ្នា

សនៈ  បា៎

ឃីមៈ  កាលគេរៀន កាលអុំរៀនច្បាប់ពេទ្យកាលហ្នឹង មានប៉ុន្មានវគ្គ ដូចថាច្បាប់បឋម វគ្គមធ្យម អីដូចគេមានចែកខុសគ្នារឺទេ?

សនៈ  បើមករៀននេះអត់មានវគ្គអេក្លួយ

ឃីមៈ  បង្រៀនម៉េចទៅអញ្ចឹង?

សនៈ  បង្រៀនពួកខ្ញុំនេះអត់មានវគ្គទេណា បង្រៀនធម្មតា

ឃីមៈ  អោយតែចេះ

សនៈ  វគ្គ បើយើងនិយាយវគ្គបឋមនេះណា អាដំបូងហ្នឹងអា៎ គឺបង្រៀនតែប៉ុណ្ណឹងហ្នង

ឃីមៈ  ចា៎

សនៈ  ព្រោះថាព្យាបាលជំងឺខ្ញុំនេះបានទៅរៀន នោះតែម្នាក់ឯង អាញ្ចឹងណា

ឃីមៈ  ចា៎

សនៈ  ហើយដល់មកនេះ ពួកនេះគ្រាន់តែព្យាបាលតាម ឧទាហរណ៍ថាគេយកអ្នកជំងឺមកដល់ត្រូវមានខ្ញុំ ហើយក៏ត្រូវមាននារីម្នាក់ អ្នកចេះ អញ្ចឹងហើយបើសិនណាអ្នកហ្នឹងគាត់ព្យាបាលមិនកើត មើលមិនដឹងអី អោយខ្ញុំជួយមើល

ឃីមៈ  អ៎

សនៈ  ហើយបើថាជួយមើលហើយមិនកើតទៀតអាហ្នឹង យើងជូត

ឃីមៈ  អ៎ ចា៎

សនៈ  ហើយបើវាថាទំនងថាជិតងាប់ហើយ យើងស្រួលយើងបណ្តោយអោយងាប់ទៅ

ឃីមៈ  ត្រូវហើយ អញ្ចឹងបានន័យថាយើងអត់មានចែកវគ្គតាមអីទេ ទៅដល់រៀនតាមយុំអីហ្នង

**កាសែតទី៣**

ឃីមៈ  ចា៎ ធ្វើហ្នឹងល្អហើយ បើសិនជាស្ពាររបស់អាពត ប៉ុលពតធ្វើហ្នឹងដើរតាមប្រពន្ធ័ហ្នឹងល្អហ្នង ប្រជាជនមានទឹកមានអីធ្វើ

សនៈ  ធ្វើអោយបានគ្រប់ជន

ឃីមៈ  បានតែអាហ្នឹងអាចាស់ៗហ្នឹង ស្ពារអាចាស់ៗហ្នឹងខ្ញុំថាល្អហ្នង

សនៈ  គេមានចោទដែរទេតើថាប៉ុលពតធ្វើខុស ក៏ប៉ុន្តែអត់ទេ ប៉ុលពតធ្វើអត់ខុសទេ

ឃីមៈ  អត់ខុសទេ

សនៈ ប៊ុនគ្រាន់តែថា

ឃីមៈ គុណភាពវាអន់អីម៉េចមិនដឹងទេ ឆាប់បាក់

សនៈ អត់ទេគុណភាពក៏មិនអត់ដែរក្លួយអើយ អញ្ចោះ គឺអត់ដឹងថាគោលការ ដល់តែយើងពិនិត្យមើលធ្វើប៊ុនហ្នឹងតែអត់មានធ្វើស្រែមិនព្រមផង អត់មានទេណា ប៊ុនតែគោលគំនិតគេធ្វើទំនប់ត្រង់ហ្នឹងគេពីក្រោមហ្នឹងអត់មាន ប៊ុនអត់មានទេមិនដឹងគេចង់ធ្វើនៅឯណា

ឃីមៈ ចា៎

សនៈ ប៉ុលពត ណា ប៉ុលពតមិនឆាយទេ

ឃីមៈ អត់ទេសុទ្ធតែគេអ្នកសេដ្ឋកិច្ចដែររៀងប្រឡាយហ្នឹងអា

សនៈ អូ បើរឿងប្រឡាយល្អ គ្រួសារយាយហ្នឹងប្ដីស័ក្ដិប្អូនដូចគ្នាដែរ ប៊ុនដំបូងគេស្លាប់ដល់ក្រោយមកនៃដឹកប្រឡាយហើយជាប្រធានក៏ខ្លះធ្វើជាអំណោយពីដើម ជាទីបញ្ចប់

ឃីមៈ គេសុទ្ធតែអ្នកវិស្វករអី

សនៈ ដល់ទីបញ្ចប់ខ្លះធ្វើអំណោយនៅស្រុកត្រាំកក់ហ្នឹង គឺវាតែម្ដង ហើយទៅស្រុកគិរីវង្ស ទៅណាទៀត ប៉ុន្មានបីបួនប្រាំប្រាំមួយ

ឃីមៈ ឆ្លងពីខេត្តមួយទៅខេត្តមួយរឺប្រឡាយ

សនៈ ចា៎ អញ្ចឹងប៊ុនថារឿងធ្វើអីមិនដឹងទេ ប៊ុនធ្វើប្រលាយ

ឃីមៈ ព្រោះអីខៀវ សំផន គូ យុទ្ធហ្នឹងសុទ្ធតែអ្នកសេដ្ឋកិច្ចអុំ គាត់ព្រមធ្វើសេដ្ឋកិច្ចនៅស្រុកខ្មែរយើងខាងកសិកម្ម តែមិនដឹងយ៉ាងម៉េចគេផ្លាស់ គេលែងជឿតាមគាត់ ក្រោយមកគេលែងជឿលើ គូ យុទ្ធ ខៀវ សំផន អីទៅណា

សនៈ គ្រាន់តែគេប្រឆាំងគ្នា ប៉ុលពត ហើយក៏ធ្វើតាម

ឃីមៈ ចា៎

សនៈ យើងឥលូវហ្នឹងល្អជាងវៀតណាម និយាយរឿងចាយលុយក្បត់បណ្ដោយទៅហ្នឹង

ឃីមៈ ហ្នឹងហើយគ្រាន់តែចាយលុយ

សនៈ គាត់ថាត្រូវអោយចាយ រឿងចាយលុយវាពាក់ព័ន្ធអញ្ចោះមួយអញ្ចោះមួយ វាស្លាប់មនុស្សច្រើន មិនមែន

ឃីមៈ ចុះអ៊ុំថាការ រួមក្រុមៗ គេអោយធ្វើអីគេការរួមក្រុមហ្នឹង

សនៈ រួមក្រុមហ្នឹងកាលយើងធ្វើស្រែហើយ យើងមានដីធ្វើចំការ យើងធ្វើចំការ ដាំដំឡូងមីដាំ

អីហើយចែកគ្នា

ឃីមៈ អូ អាហ្នឹងក្រុមសាមគ្គីហ្នឹងមែនអេ៎?

សនៈ មិនទាន់ដល់ក្រុមសាមគ្គីទេ គេថារួមក្រុមអា៎ ធ្វើអាហ្នឹងហើយក្រុមសាមគ្គីអាហ្នឹងហើយ

ឃីមៈ ដី ដីរបស់អ្នកណាគេ?

សនៈ ដី ដីគេទាំងអស់ហ្នឹង ដីមួយក្រុមហ្នឹង

ឃីមៈ ចែករួមគ្នាដាក់ប្រមូលរួម

សនៈ ដាក់រួមគ្នាទាំងអស់លែងមានដីអ្នកណាហើយ

ឃីមៈ អ៎

សនៈ តែបើភូមិនៅធម្មតាដែរ

ឃីមៈ ចា៎ អាហ្នឹងចុងឆ្នាំរឺក៏កណ្តាលឆ្នាំ ៧៣?

សនៈ ៧៣ ហ្នឹងមួយឆ្នាំតែម្តង

ឃីមៈ អា៎ រួមក្រុមហ្នឹងអេអុំ?

សនៈ បា៎

ឃីមៈ អញ្ចឹងគេប្រមូលដីរបស់យើងដាក់មួយដុំ?

សនៈ ដាក់មួយដុំ

ឃីមៈ ហើយចែកគ្នាមួយក្រុមៗ

សនៈ ក្រោយហ្នឹងមកបានគេធ្វើសហករ ដល់គេធ្វើសហករ

ឃីមៈ ដល់ពេលហើយគេសហករ ប៉ុនគេប្រមូលដីទាំងអស់ ដូចថាទ្រព្យសម្បត្តិហ្នឹង

សនៈ ប្រមូលៗ ប្រមូលលើសដែនការ

ឃីមៈ ចា៎

សនៈ ប្រមូល ឧទាហរណ៍ថាចុះមាសអីវ៉ាន់ក៏គេដើរប្រមូលដែរ

ឃីមៈ ចុះយើងមិនព្រមលាក់អោយជិត?

សនៈ លាក់ម៉េចបើគេដឹង

ឃីមៈ អ៎

សនៈ គេដឹងថាផ្ទះហ្នឹងវាមានខ្សែមាសជុំប្រវែងប៉ុន្មាន ប៉ុន្មានៗសុទ្ធតែដឹងអញ្ចឹង

ឃីមៈ ហ្នឹងហើយ បានទឹកចិត្តប្រជាជននេះអា៎ ខ្ញុំចង់ដឹងអា៎រឿងក្រុមសាមគ្គីប្រវះដៃវាខុសគ្នា

យ៉ាងម៉េច? ដែលអ៊ុំថារួមក្រុម ក្រុមសាមគ្គីហ្នឹង ថាគេដាក់ដីរួម ហើយយើងចែកផលគ្នាវិញ

សនៈ ចាំ

ឃីមៈ តែហូប ហូបឯកជនទេរឺ?

សនៈ ហូបឯកជន

ឃីមៈ រួមក្រុមហ្នឹង?

សនៈ ចាំ ឯកជន

ឃីមៈ ចាំ

សនៈ ពួកខ្ញុំហ្នឹងមានធ្វើសាកល្បងហូបមួយក្រុមទាំងអស់គ្នាបានប៉ុន្មានថ្ងៃដែរ

ឃីមៈ ចាំ

សនៈ ប៉ុនខ្ញុំអត់នៅទេណា

ឃីមៈ ហូបរួមហ្នឹងអេ៎?

សនៈ ចាំ ហូបរួម

ឃីមៈ ហើយអញ្ចឹងធ្វើយ៉ាងម៉េចទៅ?

សនៈ ជួនកាលធ្វើបានប្រាំថ្ងៃ

ឃីមៈ ហើយមើលទៅហូបបានប្រាំថ្ងៃហ្នឹង?

សនៈ ធ្វើមិនកើតរកអីហូបមិនបាន

ឃីមៈ ត្រឹមប្រាំថ្ងៃសោះ គិតមើលៗ ទំរាំរាប់ឆ្នាំ

សនៈ មិនដឹងបានប៉ុន្មានថ្ងៃខ្ញុំភ្លេចហើយ

ឃីមៈ អ៊ុំខ្ញុំចង់សួរអ៊ុំទៀត កន្លែងគណៈស្រុកហ្នឹងខ្ញុំចង់ដឹងពីឆ្នាំ ហត្ថលេខាពីឆ្នាំណា យកជាធំនៅឆ្នាំណា ឆ្នាំណាត្រឹមណាៗអីអ៊ុំ ផ្លាស់ប្តូរ?

សនៈ ខ្ញុំវាភ្លេចហើយវាច្របូកច្របល់

ឃីមៈ ចាំ ខ្ញុំមកសម្ភាសន៍អ៊ុំមុន អ៊ុំមុនថាតាញ៉េវឆ្នាំ៧០ ដល់៧២ តាញ៉េវ ហើយ តាដឹម តែអត់មាននិយាយថាឈ្មោះយាយខុមទេ

សនៈ យាយខុម

ឃីមៈ បន្ទាប់ពីតាញ៉េវអេ?

សនៈ វាអញ្ចេះតែ តាដឹម យាយខុមធ្វើលេខាណា ហើយតាដឹមហ្នឹងអនុអាំ ដល់ពេលយាយ

ខុមប្រហែលចេញបានតាជឹមឡើង

យឹមៈ តាជឹម

សនៈ តាជឹមឡើង

យឹមៈ អ៎ ហើយយាយខុមទៅណាវិញ?

សនៈ យាយខុមកាលហ្នឹងគាត់ឆ្លូត

យឹមៈ ហើយគាត់ស្លាប់នៅសម័យប៉ុល ពតដែរយាយខុមអេ?

សនៈ ស្លាប់នៅភូមិស្រុកខ្ញុំអត់ដឹងដែរ

យឹមៈ ៧៩ អេឆ្នាំណា បែកហើយរឺក៏?

សនៈ មិនមែនអេ តាំងមុនបែក

យឹមៈ ចុះអេថាតាជឹមហើយគាត់គិតនែ បងប្អូនបង្កើត គាត់គិតថាបងប្អូនតាម៉ុកដែររឺ សាច់ឈាមតាម៉ុកដែររឺ?

សនៈ នៅភូមជិតគ្នាជាប់គ្នាហ្នឹងតែមិនដឹងថាគេបងប្អូនគ្នារឹអត់?

យឹមៈ អ៎ ចុះតាចាយអត់មានបងប្អូនអីទេ?

សនៈ អត់ទេតាចាយ គាត់មានតែបាតដៃទទេ ទេ តាចាយ គាត់នៅជិតខ្ញុំ

យឹមៈ ចា៎ គាត់បានឡើងដំណាក់តំបន់អេ អុំនិយាយអំបាញ់មិញ

សនៈ បា៎

យឹមៈ ចុះតាសានៗអា៎ តាសានហ្នឹងកូនប្រសារតាម៉ុកអេ?

សនៈ ប្អូនថ្លៃ

យឹមៈ ប្អូនថ្លៃអេ ប្ដីណាគេ

សនៈ ប្ដីយាយគឹន

យឹមៈ ចុះយាយគឹនធ្វើអីគេ យាយគឹនកាលមុនធ្វើពេទ្យអា៎?

សនៈ មិនដឹងនៅណាខ្ញុំអត់ដឹងដែរ

យឹមៈ ចា៎ ចុះអេថាយាយគឹន ទៅយាយបើន យាយគឹននិងយាយបើនអា៎ទៅផ្ទះតាគិតទៅជួបប៉ុលពតជាមួយអុំអ៎?

សនៈ អាហ្នឹងខ្ញុំទៅនៅក្រោយទេ យួនរៀបចូលហើយហ្នឹង ទៅសួរតាគិតហ្នឹង តាគិតរកទៅដែរ

យឹមៈ ប្រុងទៅសួរអញ្ចឹង?

សនៈ ទៅសួរអញ្ចឹងមែន តាគិត ហើយខ្ញុំអូជិតណាស់ដេកតែអោបគ្នា

ឃីមៈ ហើយចុះហេតុអីបានជាគាត់ទៅដែរ? .

សនៈ ទៅ យាយតាគិតស្អប់យាយគើនហ្នឹង ចេះតែបន្ទោសខ្ញុំថាហៅយាយគើនហ្នឹងទៅធ្វើអី?

ឃីមៈ ចាំ

សនៈ ស្អប់នារីៗអាំ

ឃីមៈ គាត់នេះអែ ខ្វាចទៅយកការណ៍ពីគាត់អេំ?

សនៈ ទេមិនសំថា ចេះតាគិត គាត់រត់ទៅប៉ិនថាគាត់មានជំងឺស្ងួត គាត់រត់ទៅព្យាបាលនៅស្រុកថៃជា ដល់ហើយយួនវា ចូលមកៗ ខ្ញុំវាមិនដឹងថាចូលមកយូរអេឆាប់អីទេ នៃមកដល់ភ្នំកក់នៃ ខ្ញុំដឹកតាមនាវាសាស្រ្ត មកដល់ភ្នំកក់នៃ ជិតខ្ញុំមកក៏អន្តុយសរសេរប្រហែលជាគាត់ចង់មកប្រាប់ខ្ញុំ ខ្ញុំម៉េចដឹង ។

ឃីមៈ ចាំ

សនៈ អន្តុយសរសេរអីម្នាក់អញ្ចឹង ហើយអ្នកបំរើគាត់នៅឆ្ងាយពីគាត់ដាំទឹកឆ្ងាយ ហើយអញ្ចឹងយួនវាឡើងមកវៃ

ឃីមៈ អូ ឆ្នាំណាអុំ?

សនៈ ឆ្នាំប្រហែលជា ៨៣ ៨៤ ហ្នឹងហើយ

ឃីមៈ អរ យូរដែរហើយ

សនៈ យូរដែរហើយ

ឃីមៈ អត់រត់ទៅអន្លង់វែងហ្នឹងគេទេ

សនៈ មកវិញហើយ គេចាត់តាំងអាំ

ឃីមៈ អរ គេអោយមក

សនៈ មកមូលដ្ឋានវិញអាំ ពេលយួនមកគាត់កំពុងសរសេរលើជុំថ្មអញ្ចឹងអាំ

ឃីមៈ ចាំ

សនៈ ហើយយួនឡើងទៅបាញ់តែមួយគ្រាប់

ឃីមៈ ឆាប់បណ្តោយ

សនៈ ឆាប់

ឃីមៈ អត់ដឹង

សនៈ  គាត់មិនមែនស្លាប់ហ្នឹងទេ គាត់រត់ទៅស្លាប់នៅកន្លែងដាំប្រហែលជា៤០-៥០ម៉ែត្រពីកន្លែងយួនបាញ់អាំ ហើយយួនវាយកបាន៥៤ដើម ហើយឯកាសារ កាលគាត់កំពុងសរសេរហ្នឹងអាំ អត់អេកាលហ្នឹងយួនបាញ់ខ្មែរ អោយស្លាប់មួយអោយទៅស្រុក

ឃីមៈ  អុំ

សនៈ  ដល់អញ្ចឹងលែងធ្វើទាហានហ្នឹង

ឃីមៈ  អុំ គេប្រើងដែរ

សនៈ  ចាំ ហើយគាត់ស្លាប់ទៅគេថា អញ្ចឹងមកជួបតាមផ្លូវទៅ គេថាឯងចុះទៅនិរសាស្រ្តហ្នឹងរឺអត់?

ឃីមៈ  ឈ្មោះអីអុំនិរសាស្រ្តហ្នឹង?

សនៈ  ភ្លេចបាត់នៅឃុំ នៅឃុំភូមិ

ឃីមៈ  គាត់នៅរស់អេសព្វថ្ងៃហ្នឹង

សនៈ  នៅរស់រាល់ថ្ងៃតែមិនដឹងគេទៅឯណាទៅឯណាខ្ញុំមិនដឹង ខានជួបប្រហែលដប់ឆ្នាំជាង

ឃីមៈ  អរ

សនៈ  វាធំៗហើយ ឃើញវាពាក់នាឡិកាគាត់ខ្ញុំថាអី ពាក់និឡាការអញហ្នឹង នាឡិការខ្ញុំ អូមេហ្គាថ្មីបែស អូមេហ្គាអត់ទាន់ដាក់ខ្សែ

ឃីមៈ  អត់ដឹងថានិឡិកាតាគិតទេ

សនៈ  ចាំ អេថាតាស្លាប់ហើយបើមិនអោយខ្ញុំពាក់ អោយអ្នកណាពាក់ ខ្ញុំសួរគាត់ថាឯងបាញ់គាត់អេ?អត់ទេយួនឡើងបាញ់កុំតែខ្ញុំនៅដាំតែ កុំអីបាញ់ខ្ញុំស្លាប់ដែរហើយ ហើយក៏ដឹងរឿងតាគិតស្លាប់ដោយសារអញ្ចឹង ដោយសារអាហ្នឹងៗ វាថាគាត់ហ្នឹងនៅម្តុំភូមិ ភ្លេចឈ្មោះអស់ ក្មួយវានៅតូចអាំ កាលដែលស្គាល់វាហ្នឹងអាំ

ឃីមៈ  ចាំ

សនៈ  ដល់តែពេលវាមកវិញធំមើលលែងចង់ស្គាល់ហើយ

ឃីមៈ  ចុះតាសាននៅរស់អេ តាសាន?

សនៈ  តាសាននៅ ប៉ុន្មានខែមុនមកតាំ

ឃីមៈ  ហើយគាត់ធ្វើអីគេឥលូវ? តាំងពីយួនឈប់យក

សនៈ  តាំងពីយួនឈប់យក

ឃីមៈ  អត់មានកូនមានចៅអីទេ?

សនៈ  យាយគើនឈប់យក

ឃីមៈ  ចិត្តដាច់ស្រីអីខ្លាំងម៉េះ

សនៈ  យាយគើនមានកូនតា៎

ឃីមៈ  អូយាយគើនខ្លាំងអេ?

សនៈ  គ្មានអេ  យាយគើន

ឃីមៈ  អ៎

សនៈ  គាត់នៅមានប្រពន្ធមួយទៀត

ឃីមៈ  គាត់មានប្រពន្ធអញ្ចឹងបានជាអត់យក

សនៈ  ប្រពន្ធហ្នឹងមាន

ឃីមៈ  អ៎  កាលហ្នឹងអុំធ្លាប់ប្រាប់ថាធ្លាប់ទៅគុកក្រាំងតាចាន់អេ៎  បានអុំទៅគុកក្រាំងតាចាន់បានទៅមើលនារីពេទ្យ

សនៈ  ចុះបើប្រធានគុកនៅហ្នឹងសុទ្ធតែមិត្តភ័ក្តិ

ឃីមៈ  ឈ្មោះអីដែរប្រធានគុក?

សនៈ  មានអាមួយនៅត្រាំកក់រាល់ថ្ងៃ  អាហ្នឹងគេដល់អញ្ចឹងភ្លេចឈ្មោះ  ប្រធានគុកហ្នឹងនេះ  ប្អូនយាយបើនអេបងយាយបើនអេ  យាយបើនហ្នឹងអាហ្នឹងប្រធានអា៎

ឃីមៈ  ចា៎

សនៈ  អាហ្នឹងស្លាប់បាត់ហើយ  បែបស្លាប់បាត់ហើយ  បើអានោះនៅធ្វើការអីណា  ស៊ើបការអីណា

ឃីមៈ  នៅរស់អេ៎រាល់ថ្ងៃហ្នឹង?

សនៈ  រស់

ឃីមៈ  អ៎

សនៈ  ខ្ញុំអេទៅណាក៏បានដែរ

ឃីមៈ  អុំសុំគេ  គេអោយទៅអេ?  គេអត់មានឃាត់អីទេ

សនៈ  គេអោយចូល  គេចង់អោយតែចូល

ឃីមៈ  តែចូលឃើញម៉េចខ្លះកាលហ្នឹង?

សនៈ  កាលហ្នឹងបើទៅជួបអាណា  នៅណាហ្នឹងដាំបាយ

យឹមៈ ហើយមានគួរសមអីទេ?

សនៈ ធម្មតា នៅហូបបាយហ្នឹង

យឹមៈ មានឃើញអ្នកទោសឃើញអីអេ?

សនៈ ឃើញ គេនៅនោះគេអត់មានបញ្ចេញមុខអីទេ

យឹមៈ អញ្ចឹង ហើយឈើគេប្រវែងរោងគេវែង១ដាក់ទោស

សនៈ ចាំ ឃើញគេយកមកអោយនៅក្រៅ

យឹមៈ ហ្នឹងហើយគេអោយមកក្រៅ ចុះពូអីមួយ

សនៈ តាហាណូយហ្នឹងនៅហ្នឹងដែរ

យឹមៈ ហាណូយ ខ្ញុំរកតែសួរដែរម៉េចទៅ តាហាណូយនែដាប់គុកដែរ?

សនៈ នៅជាមួយតាហានហ្នឹងមកពីហាណូយអាំ មិនមែនតាហានហ្នឹងទេ

យឹមៈ ហ្នឹងហើយ

សនៈ មកពីហាណូយអាំ មកដាំបាយជាមួយតាហានហ្នឹងដែរ

យឹមៈ ហើយគាត់នៅធ្វើអីគេតានេះហ្នឹង? .

សនៈ មិនដឹង

យឹមៈ តែឥលូវថាគាត់នៅភូមិឃុំអុំ?

សនៈ មិនដឹងច្បាស់

យឹមៈ ហើយគាត់នៅរស់អេ ថានៅរស់មានគេប្រាប់? តាហាណូយនៅត្រពាំង

សនៈ អាហ្នឹងមកពីគាត់មកពីហាណូយអាំ

យឹមៈ ហ្នឹងហើយខ្ញុំមិនដឹងថាគាត់ស្អីហាណូយបានដាក់ហាណូយហ្នឹងគេទៅ ។

ហើយអរគុណអុំច្រើនហើយនែ រំខានអុំច្រើនណាអុំ បើថ្ងៃណាខ្ញុំចាំសរសេរទៀត សរសេរ១

បានដឹងថាខ្ញុំ តែប្រហែលចាំមើលអានេះសរសេរពេទ្យនេះអាំ ខ្ញុំអត់ដឹងទីតាំងសួរអុំអាំ ។

សនៈ អូនឯងទៅឥលូវឃើញហើយ

យឹមៈ ចាំ

សនៈ ពិតមែនតែវាបាត់បង់អាដែងអាគាររបស់នារីហ្នឹង តែរបស់បុរសនៅទេ

យឹមៈ ចាំ

សនៈ អាគារថ្មីខាងនេះ ទទឹងក្រោយផ្នែកកើតឈើ មកខាងកើតនេះមិនបាច់និយាយ និយាយ

អាជិតខ្មោនញុ អាហ្នឹងដែលដាក់ត្រង់សេរ

ឃីមៈ   អូដាក់ត្រង់សេរ

សនៈ   ហើយត្រង់វិហារហ្នឹងវាមានសាលានយោបាយ

ឃីមៈ   ចាំ

សនៈ   ហើយអាកុដមួយកណ្ដាលហ្នឹង អាហ្នឹងកន្លែងដាក់ថ្នាំសម័យដាក់អោយនារីអីគេហ្នឹង

ឃីមៈ   ចាំ មានសាលានយោបាយទៀត?

សនៈ   បង្រៀន

ឃីមៈ   បង្រៀនអីខ្លះអុំនយោបាយ?

សនៈ   អត់ទេ អាសាលាហ្នឹងគេហៅសាលានយោបាយ

ឃីមៈ   សំលាប់ទុកបង្រៀន

សនៈ   បច្ចេកទេស

ឃីមៈ   ពេទ្យហ្នឹងអេ? អ៊ំ ចាំ អញ្ចឹងខ្ញុំអរគុណអុំហើយខ្ញុំចង់ទៅផ្ទះយាយពូនណា ទៅតាមណា
វិញ?

សនៈ   ទៅតាមវត្តហ្នឹង ទៅបន្លួសរហូត ផ្ទះហ្នឹងស្អាតណាស់

ឃីមៈ   ផ្ទះធំនៅត្បូងអេ ទៅសួរប្រធានភូមិៗ ខ្ញុំស្គាល់ផ្ទះអុំ ខ្ញុំអត់បានចូលទៅប្រធានភូមិ
រាល់ដងខ្ញុំធ្លាប់ចូលអាំ

**Side B**

សនៈ   ឥលូវជាពិសេសប្រធានពេទ្យខាងនារីហ្នឹងច្រើនតែជាមនុស្សល្ងង់អាំ

ឃីមៈ   ចាំ ឈ្មោះអីគេប្រធាននារី?

សនៈ   តាយ៉ា

ឃីមៈ   តាយ៉ាដដែលហ្នឹង

សនៈ   ប៉ាំ

ឃីមៈ   អ៊ំ

សនៈ   តាយ៉ាហ្នឹងមិនសូវអីទេ តែនាងនោះអើយអត់ចេះអក្សរមួយតួទេ

ឃីមៈ   អញ្ចឹង! ធ្វើពេទ្យដែរ?

សនៈ   ប្រធានក្ដាប់រួម

ឃីមៈ ហើយប្រធានក្តាប់រួមទៀត

សនៈ ចាំ បក្សជន

ឃីមៈ អូ ហើយម៉េចទៅចារិកគាត់?

សនៈ ក្លួយគាជីម ក្លួយគាគិតហ្នឹងបង្កើត

ឃីមៈ ចាំ ចុះគាជីម គាគិតហ្នឹងបងប្អូនគ្នាបង្កើតទេ?

សនៈ បងប្អូនគ្នាបង្កើត មួយសម្លួយខ្មៅ

ឃីមៈ អូ ហើយម៉េចយាយពៅគាត់ក្តាប់រួមគាត់ចិត្តអាក្រក់រឺទេ?

សនៈ គាត់ត្បិតត្បៀតរឿងនារីហ្នឹងបន្តិច ដូចថាបិទសិទ្ធអាំ

ឃីមៈ ចាំ

សនៈ បិទសិទ្ធវាច្រើនពេក ប៉ុនវាបានខ្ញុំ

ឃីមៈ ចាំ

សនៈ ខ្ញុំទស្សនាហ៍ទាមទារ

ឃីមៈ អូ

សនៈ បើវា វាអត់ដែលទេ បើទៅប្រជុំអីវ៉ិន

ឃីមៈ អត់ចេះនិយាយ

សនៈ មិនដែលទាមទារថាៗ នែអោយនារីនៅទីនេះប៉ុន្មាន ត្រូវអោយមានខោខ្ចីប៉ុន្មាន ខោទ្រនាប់ប៉ុន្មាន ពួកវាមិនដែលហ៊ាននិយាយទេ

ឃីមៈ អូ ខ្លាចគេដែរអ៊ុំ

សនៈ ខ្ញុំមិនទៅខ្លាចទេ

ឃីមៈ ឃើញម៉េចថាអញ្ចឹង

សនៈ អត់ចេះខ្លាច យើងមិនមែនថាសិទ្ធថាអីទេណា

ឃីមៈ ចាំ

សនៈ យើងថាដល់អញ្ចឹងវាអាក្រក់មើលណាស់ កូនយើងកូនគេយើងនិយាយតាមមនោសញ្ចេតនាចាស់ទុំណា

ឃីមៈ ចុះអ៊ុំដល់ពេលអ៊ុំថានារីៗអញ្ចឹងកសាងចរិកពេទ្យចារិកពេទ្យយ៉ាងម៉េចខ្លះ ភាគច្រើនកាចអេស្រីៗ

សនៈ អត់អីទេ

ឃីមៈ ទៅលើអ្នកជំងឺអត់អីទេអេ៎?

សនៈ អត់អីទេ ប៉ុនវាមានខ្លះអញ្ចឹងដែរជួនកាលអី វាទៅថាអោយអ្នកជំងឺអីអញ្ចឹងទៅណា តែអ្នកជំងឺគ្នាឈឺទៅហើយ ជួនកាលអីថាមិនអោយនោមក្នុងហ្នឹង ទៅនោមក្នុងហ្នឹងវាឈឺ ក្មេងវាមិនដូចយើងចាស់

ឃីមៈ ត្រូវហើយ

សនៈ យើង អញ្ចឹងប៉ុនធ្វើការជាមួយចាស់ៗអា៎ ធ្វើការជាមួយក្មេងពិបាកណា

ឃីមៈ ចុះនៅក្នុងពេទ្យហ្នឹងអ្នកជំងឺមានបងប្អូនអីចង់មកមើលអោយមករឺទេ?

សនៈ អោយមក អូអោយមកស៊ីបាយហ្នឹងទៀត វាគុណត្រង់ស៊ីម្ចាស់អ្នកជំងឺមកស៊ីបាយ

ឃីមៈ អញ្ចឹង

សនៈ ដល់សហករគេបាតុភាព

ឃីមៈ ចា៎

សនៈ ប្តឹងស្រុកដល់ព្រះកុរណាហ្នឹង

ឃីមៈ អូ ដល់គេអត់អោយមក

សនៈ វាអត់ស៊ីបាយនៅកោះ មកពេទ្យមានបាយស៊ី

ឃីមៈ ចា៎

សនៈ ដល់អញ្ចឹងបាន ដល់ក្មួយឯងថាពេទ្យណានៅជាមួយខ្ញុំថាហ្នឹងធ្វើការខ្លាំង គឺគ្មានទេ

ឃីមៈ ចា៎

សនៈ មិនដឹងធ្វើការអីទេ ធ្វើតែនាយអាយៗបើយកទៅប្រៀបជាមួយប្រជាជន អូមិនបានមួយកូនចំណិតប្រជាជនទេ ប្រជាជនគេធ្វើខ្លាំងណាស់

ឃីមៈ ចា៎ ចុះខាងបន្កបន្កើនផល ស្រីៗហ្នឹងចូលចិត្តជាងខាងព្យាបាលអេអុំ?

សនៈ ចូលចិត្តជាង អើវា យូរៗវាអញ្ចឹងអេ តែបើអោយទៅរាល់ថ្ងៃ មិនរត់មកពេទ្យវិញឥលូវ

ឃីមៈ មែន

សនៈ វា ក្មួយឯងកុំនេះ

ឃីមៈ ចា៎ វាអត់មានអារម្មណ៍

សនៈ និយាយថារឿងអាភារកិច្ច ហើយអាកាតព្វកិច្ចហ្នឹងវាខុសគ្នាបន្តិចដែរ

ឃឹមៈ ចាំ

សនៈ ការកិច្ចហ្នឹងបើកាលណាដល់ក្រោយ ធ្វើពេទ្យហ្នឹងហើយដល់អោយ ទៅធ្វើស្រែយូរៗម្តង វាអញ្ចឹងហើយ ប៉ុនទៅអោយ ធ្វើរាល់ថ្ងៃមើលអ្នកកំពុងតែស្ទូងហ្នឹងរឺនារីកំពុងតែស្ទូងហ្នឹងអោយ ទៅពេទ្យមើលនឹងរត់មកឥលូវ ហើយ

ឃឹមៈ ត្រូវ ហើយ

សនៈ វាអញ្ចឹង

ឃឹមៈ យូរៗ ទៅម្តងអេអញ្ចឹងៗ បន្តបន្ទើនផលតែម្តងរឺ

សនៈ មិនដែលជនហ្នឹង ដល់ជិតនេះ ទៅប្រូតទាំងអស់គ្នា

ឃឹមៈ គេអោយ

សនៈ ខ្ញុំគ្រាន់តែដឹងខ្លួនថាយួនចូលហើយ ខ្ញុំក៏បញ្ចេញអ្នកជំងឺ លែងទទួលអ្នកជំងឺ

ឃឹមៈ លែងទទួលអ្នកជំងឺ

សនៈ ចុង៧៨ហ្នឹងខ្ញុំលែងទទួល ហើយ នៅទទួលចង់លែង

ឃឹមៈ អូ

សនៈ ហើយបណ្តើរៗ កាន់ថាយួនវៃលុកជ្រៅហើយអាណាដើរមិនរួចអោយ ទៅផ្ទះទាំងអស់

ឃឹមៈ ប្រាប់អោយ ហើយ

សនៈ អត់ទេអោយ ទៅហ្នុង ចេញសំបុត្រអោយ ទៅៗ ទៅអោយអស់

ឃឹមៈ ចាំ

សនៈ អត់អោយសល់អ្នកជំងឺមួយទេ នៅសល់អ្នកជំងឺមួយអត់ចេះនិយាយ

ឃឹមៈ ដែលថាអុំនិយាយហ្នឹង

សនៈ ចាំ! ខ្ញុំរៀបចេញទៅ លើកដាក់នៅថ្នល់ហ្នុង ទៅឃើញៗ សអាវដូចអីហ្នឹងអ្នកជំងឺ អត់ចេះនិយាយ

ឃឹមៈ ចាំ

សនៈ មិនមែនគ មិនដឹងឈឺស្អី

ឃឹមៈ អ្នកជំងឺក្នុងពេទ្យហ្នឹងគេមានអោយ ដើរ ទៅណាអី ក្រៅពីការជាអេ?

សនៈ អត់ទេ ជាអោយ ចេញហ្នុង

ឃឹមៈ អត់ទេ ចង់និយាយថាមានកំលាំងដើរអីឆ្ងាយ ចេញក្រៅពេទ្យអីបានទេ?

សនៈ ចេញ តែក្នុងពេទ្យហ្នឹង
ឃីមៈ ដើរក្នុងពេទ្យ
សនៈ អត់អោយទៅក្រៅ
ឃីមៈ អូ
សនៈ ជាពិសេសគេខ្លាចមានការ វរៗ និយាយរួមកាលជិតាន់ប៉ុល ពតគេខ្លាចតែខ្លាំង
ឃីមៈ ខ្លាចតែខ្លាំង
សនៈ ទៅទំនាក់ទំនងប្រាប់ខ្លាំង
ឃីមៈ ចាំ
សនៈ តែរឿងបងប្អូនអីខ្ញុំអត់មានឃាត់ឃាំងអីទេ អ្នកណាចូលមើលអីចូលទៅ
ឃីមៈ ហើយចុះមានឆ្លុះមានអីយាយដែរនៅមន្ទីរអុំ
សនៈ អត់ទេ អត់សោះហ្នឹង
ឃីមៈ ហើយលឺសួរថាអ្នកជំងឺសតិអារម្មណ៍ៗ
សនៈ អ្នកជំងឺសតិអារម្មណ៍មាន
ឃីមៈ ឈឺម៉េចទៅអ្នកជំងឺហ្នឹង?
សនៈ អត់ឈឺអីផង ឈឺសតិអារម្មណ៍អត់មានឈឺផងច្រើនអាំ អូយឈឺមែនទែនហ្នឹង
ឃីមៈ អ្នកឈឺសតិអារម្មណ៍ច្រើនអេ?
សនៈ ច្រើនណាស់អូនអើយ បើអោយប្រើពេទ្យតូចមួយទៅចាក់ថ្នាំអត់អោយចាក់ទៀតណា
ឃីមៈ ខ្លាចអេ?
សនៈ បើពេទ្យធំអីស្រួលបបួលបានអោយចាក់
ឃីមៈ ខ្លាចអេអុំ
សនៈ មិនខ្លាចអេ វាមនុស្សហ្នឹងខូចអញ្ចឹងហ្នង ខូចសតិអារម្មណ៍ហ្នឹងអញ្ចឹងហ្នង
ឃីមៈ អញ្ចឹងគេថាអត់ខុសមែន
សនៈ ឈឺ អ្នកជំងឺមួយមកដល់យើងមើលទៅថាក៍ឈឺបេះដូងអី បើឈឺអីក៍វាមិនមែនមើល ក៍វាអត់មានទៀត មើលទឹកនោមទឹកអីទៅក៍វាអត់ នៅតែឈឺដដែល ឈឺត្រង់នេះ ឈឺត្រង់នោះ
ឃីមៈ ហើយអន្តការគេហ្នឹងគេផ្ញើម៉េចទៅវិធានការ?

សនៈ  មិនដែលមានអោយអគ្គការអីដឹងទេ ខ្ញុំបើសិនណាមានអញ្ចឹងខ្ញុំសរសេរសំបុត្រអោយទៅវិញថាខ្ញុំអត់បេះមើល បើឯងទៅពេទ្យតំបន់ខ្ញុំអោយទៅ

ឃីមៈ  អូ សរសេរប្រាប់អញ្ចឹងហ្នង

សនៈ  មានខ្លះថាទៅ មានបងប្អូនគេផ្ញើពេទ្យនៅតាកែវនៅអី ថាទៅ ជូនទៅ

ឃីមៈ  អូ ចុះនៅកន្លែងបច្ចេកទេសអុំហ្នឹងមានប្រដាប់អីពិនិត្យឈាមអីដូចយើងតាលូវទេរឺក៏អត់ទេ?

សនៈ  អត់ទេ មានតែប្រដាប់មើលឈាម មានតែអាស្ទេកូរសំរាប់មើលស្គូត មើលបេះដូងអីណា

ឃីមៈ  អញ្ចឹង អត់មានអី ហើយចុះម៉េចដឹងគេឈឺអីទៅអុំ? ខប្បមារគេឈឺអីនៅក្នុងខ្លួនទៅ

សនៈ  វាមានរោគសញ្ញាវា

ឃីមៈ  អញ្ចឹង អូ រោគសញ្ញាម៉េចទៅ?

សនៈ  អាឈឺល្មមៗ ដូចជាគ្រុនចាញ់ ដូចជាគ្រុនពោះវៀនអី យើងដឹង យើងធ្លាប់រៀនអា៎

ឃីមៈ  ហ្នឹងហើយវាចេញមកអញ្ចោះៗ

សនៈ  បា៎ ហើយយើងនៅក្នុងសរីរាង្គយើង រាងកាយវិភាគអស់រលីង ដឹង បើឧទាហរណ៍ដូចថាក្តារខៀនអីគូរផ្ទួចអាណានៅអាណាយើងដឹង

ឃីមៈ  ចា៎ ចា៎

សនៈ  បើគេចង្អុលប្រាប់កន្លែងឈឺ ហើយអោយវាដឹងច្បាស់ពេទ្យ

ឃីមៈ  ហើយអាចស្មានដឹងអេអុំ?

សនៈ  បា៎

ឃីមៈ  អ៎

សនៈ  គេវិនិច្ឆ័យ គេមិនមែនស្មានទេ

ឃីមៈ  គេវិនិច្ឆ័យអុំអេ? គេថាវិនិច្ឆ័យអាហ្នឹងអេ

សនៈ  បា៎

ឃីមៈ  ចុះពេលគេមានអ្នកជំងឺស្លាប់អា រាយការទៅលើអគ្គការថាម៉េចទៅ?

សនៈ  អត់មានថាម៉េចទេ

ឃីមៈ  គេមានទទួលខុសត្រូវ មានវិធានការថាម៉េចទេ?

សនៈ  អត់ គេមានដូចថាយើងប្រាប់គេថាមានតែជំងឺតែមួយមុខទេជំងឺហើយ ហើយរាកណា

ហើយថាស្លាប់ច្រើនអាហ្នឹង អញ្ចឹងគឺថាយើងមិនគិតគូរពីរឿងថ្នាំរាក ថ្នាំហើម អញ្ចឹងយើងប្រាប់គេថាអារាកនេះបណ្តាលមកពីហើម ថាមកពីអត់បាយ និយាយថាខ្ញុំខ្វះជីវជាតិអ៊ំ ។ ហើយអញ្ចឹងគេថាខ្ញុំវៃសហករគេគ៉ំ

ឃីមៈ អញ្ចឹង

សនៈ បានសន្និបាតមួយគេថា ខ្ញុំវៃសហករគេអ៊ំ ចោទហ្នឹងធ្ងន់អាណា

ឃីមៈ ហើយអុំរាយការណ៍ទៅមួយខែប៉ុន្មានដង?

សនៈ ពីរដង

ឃីមៈ អញ្ចឹងមួយខែពីរដង

សនៈ ប៉ំ

ឃីមៈ គេផ្ញើអោយយើងឡើងទៅប្រជុំហ្នឹងរឺ?

សនៈ អត់ទេផ្ញើហើយ ប្រជុំក៏ពីរដង

ឃីមៈ សរសេរក្រដាស

សនៈ ពេលប្រជុំខ្ញុំសរសេររបាយការណ៍អោយតាមនាយកទៅ

ឃីមៈ អ៊ំ ចុះអុំមិនគិតប្រាប់អោយគេមើលទៅ អ្នកជំងឺរាយប្រហារយ៉ាងម៉េច

សនៈ មិនគេ គេ បើអាអស់ហ្នឹងវាល្ងង់ដែរ ថាឯងមើលមិនជាវៃ

ឃីមៈ អ៊ំ

សនៈ វៃសហករគេ ដូចថាឥលូវថា ខ្ញុំកើតអេដស៍ឆាប់ពេទ្យហ្នឹងមើលមិនជាថា ខ្ញុំពេទ្យហ្នឹងមើលមិនជាថាខ្ញុំកើតអេដស៍

ឃីមៈ អូចោទទៅចោទមក ចោទដាក់

សនៈ ហ្នឹងហើយ

ឃីមៈ យើងចោទថាអត់អាហារ ខ្វះជីវជាតិហើយគេចោទពេទ្យអន្តការចោទថាយើង

សនៈ អត់ផ្ញើថ្នាំ មើលគេមិនជា

ឃីមៈ មើលគេមិនជា អត់ចេះចោទ ។ ហើយចុះដល់ពេលស្លាប់ច្រើនអន្តការគេអត់មានថាយ៉ាងម៉េចទេ ថ្នាក់លើគេ?

សនៈ គេមានវិធានការដែរទេតើ កាលនេះ ។ កន្លែងមានស៊ីបបរវាវច្រើនពេកគេដំឡើង បន្ថែមបន្ទីអញ្ចឹងទៅ

ឃីមៈ  ចាំ

សនៈ  ធ្វើម៉េចក៏ទប់មិនបានដែរ មុខតែគេបណ្តោយអោយស្លាប់អញ្ចឹងហើយ ក៏បដិវត្តវប្បធម៌

ឃីមៈ  ត្រូវហើយ កាលមុនកើតពេទ្យស្រុកហ្នឹងគេមិនបង្កើតថ្នាំ ថ្នាំបូរាណអាំ ថ្នាំស្អី គេមានប្រាប់យើងអោយធ្វើរក៏យើងធ្វើខ្លួនយើង គេណែនាំ

សនៈ  គេណែនាំយើង

ឃីមៈ  អញ្ចឹង

សនៈ  រួច អោយទំនាក់ទំនងជាមួយគ្រូថ្នាំបូរាណហ្នឹងពីណាខ្លះ រួចគេអោយសិទ្ធ

ឃីមៈ  អ៊ំ

សនៈ  ទៅឯណាទៅក៏បាន ហើយទៅរកថ្នាំហ្នឹងទៅរកឯណាក៏បាន

ឃីមៈ  អ៊ំ ហើយពេលអ្នកជំងឺស្លាប់យើងមានសរសេរសំបុត្រទៅផ្ទះរឺក៏បងប្អូន?

សនៈ  ទៅប្រធានកង

ឃីមៈ  អត់មកផ្ទះទេ?

សនៈ  អត់ទេ យើងអត់ ជួនកាលយើងអត់ដឹងផ្ទះគេនៅឯណា គ្រាន់តែដឹងកងនៅអាណាៗ គ្រាន់តែយើងសរសេរទៅ ប្រធានកងសរសេរទៅ

ឃីមៈ  អ៊ំ ហើយសំបុត្រពណ៌អី ទឹកប៊ិចពណ៌អី?

សនៈ  អត់ទេ ធម្មតា

ឃីមៈ  អញ្ចឹង លឺសួរថាប៊ិចពណ៌ក្រហមពេលដែលស្លាប់កងទ័ពអី

សនៈ  មាន ប៉ុនខ្ញុំមិនដែល ក្រែងលគេខ្ញុំមិនដឹងដែរ ប៉ុនកងទ័ពមានដែលស្លាប់នៅកន្លែងហ្នឹងណា

ឃីមៈ  មានមកមើលដែរទេតើ មានមកដែលសំរាន្តនៅហ្នឹងដែរទេតើ?

សនៈ  កាលហ្នឹងខ្ញុំទើបតែធ្វើពេទ្យបានពាក់កណ្តាល តាម៉ុកគាត់ចង់ធ្វើនៅ កន្លែងមន្ទីរនៅភ្នំនៅជ្រោកន្លែងចាញ់អា ដើរទៅពីព្រឹកអញ្ចឹង បញ្ជូនមកដល់វិញងាប់

ឃីមៈ  អ៊ំ ចាញ់លឿនអាណោះ

សនៈ  ចាញ់លឿនអាំ

ឃីមៈ  សាហាវមែនទែន ពីព្រឹក មកដល់ មិនទាន់បានមួយអាទិត្យពីអាទិត្យផង

សនៈ  និយាយពីឡើងប៉ុន្មានគ្រាន់

ឃីមៈ  អ៊ំ ហើយអុំមានថាពេទ្យមានធ្វើអីខ្លះតាំងពីព្រឹកទល់ល្ងាច?

សនៈ  គ្មានធ្វើអីទេ ធ្វើតែតាមភារកិច្ច អ្នកព្យាបាលលាងសារ៉ាំងលាងហើយចាក់ថ្នាំ

ឃីមៈ  ចាក់ថ្នាំហើយធ្វើអីទៀត

សនៈ  ចាក់ថ្នាំហើយសំរាក ដល់ពេលបាយហើយ

ឃីមៈ  អញ្ចឹងច្រើនដែរអ្នកជំងឺគ្រាន់តែចាក់ថ្នាំ

សនៈ  ច្រើនដែរ

ឃីមៈ  អត់មានធ្វើអីក្រៅពីចាក់ថ្នាំហ្នឹងណា?

សនៈ  បា៊ំ អ្នកណាត្រូវធ្វើពលកម្មអីនាយអាយ ត្រូវធ្វើខ្លះដែរហ្នឹង អ្នកដាំបាយអីត្រូវដាំបាយ

ឃីមៈ  ចា៊ំ ហើយអ្នកជំងឺ១៧មេសាហ្នឹងហើយពេទ្យមូលដ្ឋានសំរាកពេទ្យជាមួយគ្នារឺក៏បែក?

សនៈ  ជាមួយគ្នា ខ្ញុំអត់មានបែកអីទេ

ឃីមៈ  លឺសួរគេបែកៗ អូនៅពេទ្យតំបន់អីទេមិនដឹង

សនៈ  ខ្ញុំអត់មានបែកអីទេចូលគ្នាទាំងអស់ ខ្ញុំដេញចេះបែកអ្នកជំងឺ កាលឪពុកខ្ញុំគាត់មកព្យាបាល
គាត់ឈឺ ខ្ញុំអោយគាត់សំរាន្តតែម្នាក់ឯង

ឃីមៈ  អ៊ំ ចង់និយាយថាទូទៅអា៊ំ

សនៈ  អ៊ំ ទូទៅអត់ទេដាក់ចូលគ្នាទាំងអស់ហ្នឹង

ឃីមៈ  អ៊ំ ចុះស្រីៗដិតប្រុសៗដែរអេសំរាន្ត?

សនៈ  មិនមែនទេ មានរបងខណ្ឌ មានរបងមួយខណ្ឌពាក់កណ្តាលវត្តហ្នឹង

ឃីមៈ  ចុះកន្លែងមន្ទីរឃុំរាល់ថ្ងៃហ្នឹងកន្លែងវត្តអេអញ្ចឹង

សនៈ  មិនមែនទេ វត្តខាងជើងផ្លូវ

ឃីមៈ  ចុះមន្ទីរពេទ្យអុំ?

សនៈ  អាមន្ទីរពេទ្យថ្នាំ មន្ទីរពេទ្យធំ

ឃីមៈ  ហើយចុះវត្តហ្នឹងទៅណា?

សនៈ  វត្តនៅ

ឃីមៈ  មានវៃចោលសំអាតផ្លាអី?

សនៈ  អេ កាលហ្នឹងវិហារវាអត់ទាន់បានធ្វើ

ឃីមៈ  អ៊ំ

សនៈ  មានតែអញ្ចឹង ចាក់សរសរអីហើយខ្ញុំ គេចាក់អាសរសរខ្ពស់ៗ កំពស់ប្អូនម៉ែត្រហ្នឹងហើយ

ដល់អញ្ចឹងខ្ញុំសុំឈើគេយកមកប្រក់ដំបូលធ្វើកន្លែងជុំ នៅលើវិហារហ្នឹង អត់មានព្រះមានអីទេ ក្នុងហ្នឹង ។

ឃីមៈ មិនទាន់មានទេអុំរឺ? ហើយកាលហ្នឹងហេតុអីបានជាគេកំចាត់វិហារចោល?

សនៈ គេថាមិនអោយជឿសាសនា កុំអោយខ្សោយអាណា បុណ្យបាប

ឃីមៈ ហើយកាលហ្នឹងអុំជឿគេដែរ មានចិត្តមានជឿសាសនាដែររឺអត់ទេកាលហ្នឹង?

សនៈ ជឿ តែធ្វើ

ឃីមៈ ធ្វើតាមគេទៅ

សនៈ ធ្វើតាមគេតែយើងមិនធ្វើច្រើន

ឃីមៈ កាលមុនមានថាមានបុគ្គលិកចាស់នៅវត្តចំប៉ាហ្នឹង

សនៈ វត្តចំប៉ា

ឃីមៈ បុគ្គលិកហ្នឹងអ្នកណាគេអ្នកគ្រប់គ្រងកាលអុំមិនទាន់បង្កើត អ៎ថាមានពេទ្យមួយអេ

សនៈ អត់ទេខ្ញុំហ្នឹងទៅនៅមុនគេហ្នឹង

ឃីមៈ ហើយចុះអត់មានបុគ្គលិកពេទ្យចាស់ពេទ្យថ្មីអីទេ?

សនៈ មាន មានចាស់ៗដូចខ្ញុំគ្នាបីនាក់

ឃីមៈ ថាតាអីសង្គមកិច្ចហ្នឹងអ៎?

សនៈ តាឈឿន តាឈឿនហ្នឹងនៅបាត់ដំបងអោះ

ឃីមៈ ចា៎ គាត់បេះអេ?

សនៈ គាត់គ្មានទេ កាលហ្នឹងគាត់មកផ្តាំ

ឃីមៈ ចា៎

សនៈ តាឈឿនហ្នឹង ប៉ុនមានគ្នាតែបីនាក់ហ្នឹង

ឃីមៈ អ៎

សនៈ ចាស់ តាភរ

ឃីមៈ ហ្នឹងហើយតាភរហ្នឹង

សនៈ ដល់ហើយតាពោធិ៍មួយទៀតបួននាក់

ឃីមៈ ចា៎ សុទ្ធតែអ្នកធ្លាប់ធ្វើពេទ្យអេ អត់ទេ? .

សនៈ អត់ គេទៅ កាលហ្នឹងម៉េចទេ ដល់ហើយក្រោយហ្នឹងបានប៉ុន្មានខែគេទៅធ្វើខណៈភូមិខណៈ

អីទៅ

យឹមៈ អ៊ំ អញ្ចឹងគេហៅថាពេទ្យត្រពាំងគោ តែនៅក្នុងវត្តចំបារហ្នឹងអុំ?

សនៈ មិនមែនទេ ពេទ្យត្រពាំងគោនៅវត្តត្រពាំងគោណោះវិញ គ្រាន់តែជិះម៉ូតូទៅឃើញហើយ

ជិះឡានទៅឃើញហើយ

យឹមៈ នៅវត្តត្រពាំងគោហឹងហ្នងអ៊ំ ។ ហើយចុះមានពេទ្យវត្តចំបារមួយទៀតទេ?

សនៈ វត្តចំបារដាក់គ្រាន់តែបណ្ដោះអាសន្នមួយភ្លែតហ្នឹង

យឹមៈ អុំអ្នកបង្កើតដែរ?

សនៈ ខ្ញុំអ្នកមុនគេជុតលេខ ដែលថាទៅគេអោយថ្នាំអោយសារ៉ាំងមក ខ្ញុំទុកហ្នឹងទេតើ

យឹមៈ ហ្នឹងហើយ អុំនិយាយហ្នឹងខ្ញុំស្មានតែពេទ្យមួយផ្សេងទៀត ពេទ្យមួយផ្សេងទៀតអាំ

សនៈ អត់ទេៗ

យឹមៈ ដល់ហើយទើបផ្លាស់មកកន្លែងវត្ត?

សនៈ បានហើយបញ្ជូនមកនេះ មកទៅនោះ

យឹមៈ អ៊ំ ចាំ ចាំ

សនៈ អានោះអត់មានធ្វើអីទេគ្រាន់តែទៅនៅហ្នឹង

យឹមៈ បុគ្គលិកពេទ្យអុំបានទៅរៀននៅភ្នំពេញប៉ុន្មាននាក់?

សនៈ បានតែមួយនាក់ តែអាហេងមួយហ្នឹង

យឹមៈ បានតែមួយហ្នឹងទេ?

សនៈ ប៉ាំ

យឹមៈ អូ បានតិចមែនទែន ស្មានតែបានច្រើន

សនៈ ពេទ្យគ្រុនចាញ់

យឹមៈ ចុះស្រីៗអត់មានបានទៅអីទេ?

សនៈ អត់

យឹមៈ ទៅតែពេទ្យតំបន់បានទៅច្រើន

សនៈ ពេទ្យតំបន់គេអោយទៅនេះទៀតអោះទៅភ្នំ

យឹមៈ អូ បានតែម្នាក់អេអញ្ចឹងខ្ញុំស្មានតែបានច្រើននាក់

សនៈ វាឆាប់ពេកអាមួយ បើសិនណាវាយូរឆ្នាំទៅ អាហ្នឹងចេះតែបានទៅហើយ បើនេះឆាប់អាំ

បីឆ្នាំវាឆាប់អាំ

ឃីមៈ ត្រូវហើយ បានពូហេងមួយ គាត់និយាយដែរទេតើ គេជូនទៅច្រើនអុំ ក្រោយពេល ៧៩ អុំមិនថាឃើញពូហេងរត់មក ហើយពូហេងប្រាប់ខ្ញុំថាគេអោយគាត់ឡើងរទេះភ្លើងហើយ តាំពេទ្យ ហើយ ចិនៗ គ្រូពេទ្យចិនៗហ្នឹងយំណា ហើយគាត់ទៅដល់កំពង់ឆ្នាំងនៅកន្លែងវ៉ារម៉ាស អីគេនោះ គាត់លោត ទំលាក់ខ្លួនមកហើយរត់មកស្រុកមក កុំអីគាត់ថាទៅដល់អន្លង់វែង

សនៈ ជួបយើងនៅកណ្តាលផ្លូវអាវាអញ្ចេះ

ឃីមៈ ហើយគាត់ថាអាខ្លះរត់ទំលាក់ខ្លួនទំលាក់អី បើកយឺតៗដែររទេះភ្លើង

សនៈ វាបើកអោយលោតហ្នឹង

ឃីមៈ ហ្នឹងហើយ អើយ ។ ចុះអុំមានដឹងថានារីពេទ្យអុំដូចថាធ្លាប់ធ្វើពេទ្យជាមួយអុំហ្នឹងមាន ជីវភាពយ៉ាងម៉េចដែររាល់ថ្ងៃ?

សនៈ ពេទ្យស្ងួថ្នាំនៅសួងណោះវិុនគ្នាក្រណាស់

ឃីមៈ ភាគច្រើនស្លាប់ហើយអុំរឺ?

សនៈ បាំ ហើយច្រើនតែនៅស្រុក១០៦ ស្រុកនគរជ័យនោះ គេសុទ្ធតែអ្នកគ្រាន់បើ

ឃីមៈ ចាំ

សនៈ ប៉ុនតែយ៉ាប់អ្នកមួយចំនួនមួយចំនួនធំ តែមួយចំនួនតូចទេ មួយចំនួនធំទៅរលាយ តែនៅ ស្រុក១០៦អីវិុនគេសុទ្ធតែអ្នកមាន កូនគេអ្នកមានអាំ

ឃីមៈ ចាំ គេអ្នកក្រនៅតែក្រអញ្ចឹង

សនៈ នៅក្ររហាម ក្រនៅសង្គមនេះ ក្រជាងមុនឆ្ងាយណាស់

ឃីមៈ យ៉ាប់ហ្មងអេំ ហើយចុះកាលពេល៧៩ បែកហើយហ្នឹងអាំអ្នកធ្លាប់នៅពេទ្យនៅអី អ្នក រដ្ឋអំណាចគេនៅ?

សនៈ អត់ទេខ្ញុំមក គេអត់មានរករឿងអីផង

ឃីមៈ អត់អីទេរឺ កាល៧៩ហ្នឹង

សនៈ អត់

ឃីមៈ អុំ ហើយភាគច្រើនរត់ទៅជាមួយអុំតែបន្តិចតែប៉ុន្មាននាក់អុំនិយាយហ្នឹងអេ ភាគច្រើនគេ មកជាមួយឪពុកម្តាយគេវិញរឺ?

សនៈ បាំ គេទៅមែឪគេអោយគេ អោយគេទៅហ្មង ហ្នឹងតាអញ្ចឹងហ្មងអាណាចង់ទៅនៅជាមួយ

ម៉ែជាមួយឪទៅតែម្តងទៅដំណាក់កាលនេះហើយមិនដឹងយ៉ាងម៉េចទេ?

ឃីមៈ ចា៎ ប្រាប់អញ្ចឹងហ្មង

សនៈ បា៎ ហើយអញ្ចឹងទៅអស់ហ្មង

ឃីមៈ ក្រុមបង្កបង្កើនផលគេធ្វើអីខ្លះកាលនៅកន្លែងអ៊ុំអា៎?

សនៈ ដាំខ្លះ

ឃីមៈ ចុះអ៊ុំថាអត់ដាំទេ

សនៈ បន្តិចបន្តួចហ្នឹងអា៎ ។

ឃីមៈ ធ្វើបន្តិចបន្តួចថាវិលជាជុំហ្នឹងប៉ុន្មានទៅ ម្នាក់ដូរគ្នាម្តងព្យាបាល ម្តងបង្កបង្កើនផល?

សនៈ ភ្លេចហើយកាលហ្នឹង មួយខែអេប៉ុន្មានទេ នារីគេអ្នកធ្វើ

ឃីមៈ លឺថាមួយខែដែរអ៊ុំអ្នកនិយាយ

សនៈ បា៎

ឃីមៈ អត់ទេអ៊ុំមិនមែនអ្នកនេះទេ អ៊ុំមិនមែនខាងហ្នឹងណាអេ៎?

សនៈ នារីទេ គេ តែនារីគេធ្វើអា៎

ឃីមៈ ចា៎

សនៈ ខ្ញុំអត់ទេ

ឃីមៈ ហើយក្រុមដាំបាយ ក្រុមអីសុទ្ធតែដូរគ្នាអញ្ចឹងអ៊ុំអេ៎?

សនៈ ដូរ

ឃីមៈ អញ្ចឹងមិនភ្លេចពេទ្យហើយ មួយខែយូរអាណា

សនៈ អត់ទេ អត់ភ្លេចពេទ្យទេ ដូរអញ្ចោះទេ មានអ្នកដាំបាយហ្នឹងដោយឡែកហ្មង ដូរតែអ្នកជំនួយទេ អ្នកដាំបាយនោះប្រជាជនហ្មង ។

ឃីមៈ ចា៎ កាលសម័យខ្មែរក្រហមអា៎ថាគេស្អប់វៀតណាមមែនអេ៎អ៊ុំ?

សនៈ ស្អប់

ឃីមៈ ហេតុអីបានស្អប់ដូចតាម៉ុកអីវ៉ិន ហើយពួកមកពីហាណូយផ្សេងទៀតៗ មកពី ជួយ កាលហ្នឹងឆ្នាំ៧០អេ

សនៈ ហាណូយមកជួយ

ឃីមៈ ហើយពួកហ្នឹងទៅណាអស់ទៅ?

សនៈ ពួកហ្នឹងយកសំលាប់ចោល

ឃីមៈ ហើយហេតុអីបានយកសំលាប់ចោល?

សនៈ ថាក្បត់

ឃីមៈ ហើយក្បត់មែនរឺអត់?

សនៈ ហើយអ្នកណាដឹង

ឃីមៈ ថាតាម៉ុកហ្នឹងស្អប់ណា បានប្រជាជនខ្មែរសម័យហ្នឹងគេច្រើននិយាយអញ្ចឹង

ឃីមៈ ហើយកាលហ្នឹងច្រើនគេថា ដូចថាបងប្អូនអុមត្រូវគេយកទៅសំលាប់អញ្ចឹងយើងជួយអត់រួចទេ ក្បាលអាណាសក់អាហ្នឹងមែនអេអុំ?

សនៈ ចា៎ គ្មានអាណាជួយអាណាទេ

ឃីមៈ ចុះយើងអត់មានទៅតវ៉ាជំនួសអី ថាខុសអញ្ចេះៗ

សនៈ បើគេអនុគ្រោះអី ប៉ុនដូចថាអូនឯងអញ្ចឹងបងប្អូនត្រូវសំលាប់អីអញ្ចឹងកម្មាភិបាលអីត្រូវដកចោល បើអញ្ចឹង មិនសំលាប់ ល្អជាង ដូចកូនខ្ញុំវាអត់សំលាប់ មកពីគេយល់

ឃីមៈ គេយល់អុំ ហើយច្រើនតែអញ្ចឹងក្បាលយួនខ្លួនខ្មែរអីម៉េចសម័យហ្នឹង ហើយបងប្អូនអីវ៉ិនខ្វាចសតិអារម្មណ៍អីវ៉ិន លឺតែគេនិយាយអញ្ចឹងៗ

សនៈ ចា៎ យួនឥលូវហ្នឹងគេស្អប់ដូចតែពីមុនអញ្ចឹង

ឃីមៈ ចា៎

សនៈ វាចេះ ប្អូនឯងវាអត់ដែលនៅស្រុកយួន បើខ្ញុំដែលទៅដែរប៉ុនតែទៅត្រឹមពីគីឡូបីគីឡូពីព្រំប្រទល់យើងទៅអា៎ ខ្ញុំឃើញខ្មែរអោយទៅធ្វើអាញេរអាញៃ ហើយដល់ខ្មែរយើងអញ្ចឹងដែរ

ឃីមៈ ធ្វើអីអុំ?

សនៈ អោយទៅស៊ីឈ្នួលឡើងត្នោត ធ្វើកាត់ស្មៅ ធ្វើទៅស៊ីឈ្នួលកាប់ពុះអូសអោយយួន

ឃីមៈ ធ្វើអត់មានមុខរបររឺទេ?

សនៈ អញ្ចឹងបានថាដល់ទៅមើលនៅព្រំប្រទល់ប៉ុនដឹងកន្លែងច្រកទ្វារអា៎ តែព្រលឹមឡើងឃើញអោយពួនទៅហើយទៅស្រុកយួនទៅយកសំបុត្រនៅកន្លែងប៉ូលីសអា៎ ហើយទៅហើយល្ងាចមកវិញយួនក៏អញ្ចឹងៗ

ឃីមៈ រាល់ថ្ងៃហ្នឹង?

សនៈ បាទ អញ្ចឹងតា៎

ឃីមៈ  អញ្ចឹងគេអោយសំបុត្រប៉ុន្មានទៅ?

សនៈ  អោយសំបុត្រសំរាប់មួយថ្ងៃហ្នឹង

ឃីមៈ  រកទៅសាកមើល រកប៉ុន្មានថ្ងៃ

សនៈ  ប៉ុន្មានថ្ងៃខ្ញុំទៅក្រលែង ដល់ថៃហ្នឹងឃើញ

ឃីមៈ  ចាំ

សនៈ  ហើយជិះម៉ូតូទៅឆ្ងាយជាមួយអាប៉ូលីសយួនហ្នឹង អញ្ចឹងប៉ិនយួនមកនេះក្នុងន័យ ហើយគ្មានអាណាធ្វើអី កាលពីឆ្នាំ៧៩មកម៉្លេះ អាណានេះជ្រុលចូលទៅដល់វៃចោលបាន

ឃីមៈ  នៅតែស្អប់យួនថ្ងៃហ្នឹង

សនៈ  អេមិនបានទេ អេវាចៃដន្យអីកាលហ្នឹងរដ្ឋកម្ពុជាហ្នឹង ហ៊ុន សែនបានទៅពឹងយួនហ្នឹងបាន រួចរបបប៉ុលពតហ្នឹង

ឃីមៈ  ត្រូវហើយ

សនៈ  បើមិនអញ្ចឹងកុំអី មិនអេ

ឃីមៈ  មែនតាំបានគ្រាន់បើដែរបានមានកន្លែងតែអុំអើយស្រុកខ្មែរយើង យើងធ្វើអីក៏វៀតណាម ដឹង យើងខ្ជិលនិយាយរឿងនយោបាយគេ

សនៈ  ដឹង

ឃីមៈ  ហ្នឹងហើយ ពិបាកណាស់ ហើយកាលហ្នឹងគេនិយាយថាអន្តការក្អែកម្ចាស់ៗ

សនៈ  អន្តការក្អែកម្ចាស់ដូចថាមនុស្សដូចអូនឯងអីវិបត្តិដូចថាមនុស្សនៅជិតវិញអូនឯង អ្នករាយការណ៍ពីអូនឯងបានទាំងអស់

ឃីមៈ  អ៊ំ

សនៈ  មិនជាដៃជាជើងរបស់អង្គការទេណា

ឃីមៈ  អូ ថាអញ្ចឹងអង្គការកន្លែងជាអង្គការ

សនៈ  ហ្នឹងហើយ អ្នកដែលស្មោះត្រង់ជាមួយហ្នឹងអង្គការហ្នឹងគឺអង្គការហ្នឹងហើយ

ឃីមៈ  ចាំ ហើយពេលអុំ ទៅសន្និបាតៗអាំភាគច្រើនគេនិយាយអីខ្លះ?

សនៈ  សន្និបាតវាមានបែបផែនវាអាំបាទ ដែលគេនិយាយថារដ្ឋាភិបាលអញ្ចឹងទៅណា ហើយនាំទៅព្យាបាលដើម្បីទៅធ្វើពលកម្មកសិករអីអញ្ចឹងទៅណា អាហ្នឹងតែផ្នែកហ្នឹងទេ និយាយរួមគឺគេនយោបាយហ្នឹងគឺគេគាំទ្រប្រជាជនយើងដែរហ្នឹងអាំ ធ្វើម៉េចអោយយើងស្មោះចំពោះអង្គការ

អញ្ចឹងអា៎ ហើយយើងចេះតែធ្វើ ធ្វើទៅ

ឃីមៈ ដូចជាពាក្យកសាងបាតដៃទទេ អុំមានដែលជួបអេ៎ពេលចូលប្រជុំអា៎ ពាក្យសង្គមថ្មីសាង ដោយបាតដៃទទេអា៎ មានដែលលឺនិយាយទេ?

សនៈ មាន

ឃីមៈ ពាក្យហ្នឹងបានន័យថាម៉េចកសាងដោយបាតដៃទទេ?

សនៈ អត់មានអីហ្នឹងបាតដៃទទេ ពុំមានអីអញ្ចឹងទៅណា

ឃីមៈ ចា៎ ហើយចុះរបស់របរសល់ពីសម័យមុនអ៎

សនៈ ខ្ទិចអស់ហើយ ខ្ទិចអស់ហ្មង អូនឯងបើមកឃើញផ្សារអន្លុក្រសោម ផ្សារអន្លុក្រសោមគឺ ស្អាតបែស ស្អាត ល្អស្អាតណាស់

ឃីមៈ អូ អញ្ចឹងគឺសាងដោយបាតដៃទទេរបស់គេមែន

សនៈ ចុះផ្សារអង់រការនេះមាននៅផ្ទះគេមែន ផ្សារអន្លុក្រសោមគឺស្អាតរបស់គេហ្មង

ឃីមៈ គ្រាប់ផ្លោងអេអុំ?

សនៈ គ្រាប់ផ្លោងគ្រាប់នេះហ្នឹងគឺរាបនៅដី មានតែដី

ឃីមៈ អូ

សនៈ អត់ដឹងមានផ្ទះថ្មផង ជិះកង់តាមហ្នឹងខ្លាចតែម្នាក់ឯងអត់ហ៊ានជិះកង់

ឃីមៈ អូ

សនៈ រាបទាំងអស់គិតទៅ

ឃីមៈ អូគិតទៅសាហាវអាណោះ ។ ហើយភាគច្រើននិយាយពាក្យមហាលោតផ្លោះ មហាអស្ចារ្យ អុំមានដែលលឺពាក្យហ្នឹងទេ

សនៈ ដែលមហាលោតផ្លោះ មហាអស្ចារ្យហ្នឹងគឺថាវាជនឡើងលើនអា៎ ហ៊ុន សែនក៏មិនហ៊ានថា ដែរ លើនអាហ្នឹងគេថាឈាមវាលើនអ៎ មិនលើនយ៉ាងម៉េចដូចថាកាលណារៀបចាយលុយ បោះ បានហើយហ្នឹងមានបានចាយណា ខ្ញុំរ៉ុនអីបានយកមកអោយយាយនេះមកមើលដល់ផ្ទះគ្រាន់តែ ស្អែកឡើង ថាអត់ចាយវិញទេឈប់

ឃីមៈ ចា៎ អញ្ចឹងកាលហ្នឹងគេរកចាយលុយវិញអេ៎?

សនៈ អីបោះហើយ ហើយ

ឃីមៈ អញ្ចឹង អូ ឆ្នាំណាអុំ?

សនៈ  ៧៦ ហើយពួកនេះនៅក្នុងហ្នឹងស្លាប់

ឃីមៈ  ស្លាប់រឿងអី?

សនៈ  ស្លាប់រឿងចាយលុយ

ឃីមៈ  ហេតុអី?

សនៈ  ចុះបើអត់ចាយលុយវាមិនល្អជាង

ឃីមៈ  ហេតុអីបានល្អជាង ចុះហេតុអីបើគិតថាអត់ល្អជាងហេតុអីក៏រុកបុកអត់អោយចាយលុយ

សនៈ  កាលហ្នឹងប្រុងធ្វើយូរអង្វែង ប្រុងធ្វើអារណាសិវិល្យហ្នឹងអោយវាយូរទៀតត្រូវគេចាយលុយបន្តិចបន្តួច ដូចថាអូនឯងមកទិញជួយ ដូរ ទិញដូបន្លែអូនឯង ៗ ដល់ហើយទៅគេថាត្រៀមធ្វើសហករអាំ ហើយនៅតែមួយកន្លែងបង្ហើយ នែ

ឃីមៈ  អូ ប្រុងអត់ធ្វើសហករដែរអញ្ចឹងអុំ ចុះអាំពេលគេប្រមូលដីប្រមូលធ្លីអីអាំ ប្រជាជនអីផ្ទះអីរួមគ្នា?

សនៈ  អូ មិនបាច់ទេ

ឃីមៈ  ឆ្នាំប៉ុន្មានឆ្នាំ៧៥ អេំហ្នឹងប្រមូលសហករធំអេ

សនៈ  បាទ ផ្ទះអីទេខ្ញុំទ្រុងដឹកយកអោយគេ

ឃីមៈ  លះបង់ កុំអោយគេថា

សនៈ  ដាក់យកអោយយាយខុម អោយផ្ទះតាម៉ុកហ្នឹងយូរហើយ

ឃីមៈ  នៅណាឥលូវ ផ្ទះយាយខុមហ្នឹង?

សនៈ  ផ្ទះនៅតាមទីតាំងបង្គោលនេះទៅ ប្រហែលដីពីរគីឡូដល់ហើយ

ឃីមៈ  ខ្ញុំរកទៅហើយ ទៅហើយទៅតាមហ្នឹងអាំ

សនៈ  បាទ គ្រាន់តែទៅភូមិនោះដល់ហើយ ៗ គ្រាន់តែវាបែកកញ្ចក់មួយជ្រុង

ឃីមៈ  ចាំ

សនៈ  ហើយឥវ៉ាន់អីនៅហ្នឹង

ឃីមៈ  ចុះមាសពេជ្យអីគេអត់ដកចេញរឺទេ?

សនៈ  នែ មាសពេជ្យនៅក្នុងភូមិនេះគឺបងប្អូនយើងចាយចង់អស់គ្រប់គ្នា ចាយគ្រាន់នៅសល់នៅសល់តិចតួច

ឃីមៈ  ចាំ

សនៈ   មានច្រើនតែខ្ញុំចាយចង់អស់រលីង

ឃីមៈ   បានចាយដែរមិនអីទេ

សនៈ   ចាយគេផ្ញើរខ្ញុំ

ឃីមៈ   ចា៎

សនៈ   អ្នកមាន

ឃីមៈ   ចា៎

សនៈ   គេផ្ញើរខ្ញុំ ខ្ញុំទៅទិញថ្នាំទៅទិញអីអញ្ចឹងទៅ គេផ្ញើរទិញអីៗអញ្ចឹងទៅ ទិញប្រដាប់ប្រើប្រាស់អញ្ចឹងទៅ ចាយគ្រប់គ្នាតែម្តង ផ្ទះខ្ញុំ ខ្ញុំទិញនាឡិការអីអោយកូន

ឃីមៈ   ដឹងតែថាវាអស់តំលៃហើយ នៅស្រុកខ្មែរ

សនៈ   ចា៎ ប៉ុនតែថាគេចាយមិនអោយអស់ទេ ខ្ញុំនេះប៉ុនអត់មាន

ឃីមៈ   ចាយអស់ បាតដៃទទេ ហើយពេលនារីៗពេទ្យអា៎ គេមានដែលចាត់ទុកថាជាកូន អង្គការអីអេ៎អុំ?

សនៈ   គេចាត់ទុកជាកូនអង្គការទាំងអស់ហ្នឹងអោយតែនារីៗនៅមន្ទីរ

ឃីមៈ   គេចេញច្បាប់មកអញ្ចឹងហ្នងអេ?

សនៈ   ចា៎ ជាកូនរបស់អង្គការ

ឃីមៈ   ហើយដល់ពេលជីវភាពជីវអីលើអង្គការទាំងអស់ជាអ្នកគ្រប់គ្រង?

សនៈ   ហ្នឹងហើយអង្គការអ្នកចិញ្ចឹម

ឃីមៈ   ហើយចុះកុមារតូចៗ កុមារតូចៗ?

សនៈ   កុមារក៏មាន

ឃីមៈ   ហេតុអីបានជាចាត់ទុកជាកូនអង្គការអញ្ចឹង?

សនៈ   ចុះបើអាហ្នឹងគេថា យុវវ័យហើយកុមារហ្នឹងជាសរសរទ្រូងរបស់ជាតិហ្នឹងអា៎

ឃីមៈ   អ៎

សនៈ   ហើយអញ្ចឹងកាលបណ្តុះបណ្តាលមុនដំបូងគឺអង្គការជាអ្នកបណ្តុះបណ្តាលអោយទៅជាសរសរទ្រូង

ឃីមៈ   ចា៎

សនៈ   ទាំងអស់គ្នាហ្នឹងហ្នង ប៉ុនដល់ហើយគឺអញ្ចេះគេចែកវណ្ណៈកុមារវាចេះតែរត់

ឃឹមៈ អញ្ចឹង

សនៈ ដំបូងហ្នឹង

ឃឹមៈ ហើយកាលហ្នឹងថាចែកវិភាគប្រជាជនដែរអុំ?

សនៈ មិនចែក

ឃឹមៈ ថា១៧ មេសា

សនៈ ចែកទាំងអស់ចែកទាំងក្មេងក៏ចែក នារីក៏ចែកយុវជនក៏ចែក ចែកទាំងអស់ហ្នុង

ឃឹមៈ អញ្ចឹងនៅតែបែងចែកវណ្ណៈអញ្ចឹង

សនៈ បែងចែកវណ្ណៈ

ឃឹមៈ អ្នកណាគេវណ្ណៈក្រ អ្នកណាគេវណ្ណៈមានអីនៅតែយ៉ាប់

សនៈ អញ្ចឹងប៉ិនគេរៀបការគេរៀបចំហ្នឹង

ឃឹមៈ ហើយថាស្រុក ១០៥ ហ្នឹង គេដាក់ឈ្មោះថាស្រុកត្រាំកក់ហ្នឹងថាស្រុក១០៥អេ?

សនៈ អាហ្នឹងគឺអគ្គការហ្នុង

ឃឹមៈ អគ្គការថ្នាក់លើអេ?

សនៈ បាទ ដាក់ទូទាំងប្រទេសអាំ ស្រុកប៉ុន្មានៗ កាលមុនខ្ញុំម៉េចចាំអស់ ស្រុកទូទាំងប្រទេសអាំ

ឃឹមៈ ហើយកាលអុំលឺនៅឆ្នាំណាស្រុក១០៥ហ្នឹង ឆ្នាំណា?

សនៈ តាំងពីមុនឆ្នាំ៧៥

ឃឹមៈ អុំ អញ្ចឹងគេចែកយូរហើយ?

សនៈ ចែកយូរហើយ គេធ្វើយូរហើយ មិនដឹងឆ្នាំណា ដូចអាឡាដិនវាវៃអាមេរិកតាំងមិនដឹងជាវាគិតតាំងពីកាលណា

ឃឹមៈ កាលណា បើយើងប្រើតាមគេ

សនៈ បាទ ហើយប៉ិនបក្សជន បក្សជនខ្ញុំមិននិយាយទេកាលហ្នឹង កាលសម័យគស្ទូនៅភ្នំពេញនៃ វានេះអាំ បក្សជននៅនេះមានឆ្នាំ ៦០ ៦៥មក ៦០ជាងមក

ឃឹមៈ ចាំ

សនៈ បក្សជនអាំ ពីរនាក់គ្នាជាមួយតាម៉ុកហ្នឹងមានអ្នកណាខ្លះនៅម៉ុំៗ ខ្ញុំកាលហ្នឹង ខ្ញុំ តែឥលូវហ្នឹងគាត់ស្លាប់អស់ហើយ នៅត្រាំកក់ ហើយក្រោយហ្នឹងមកបានដល់ក្រោយៗមកទៀតមកដល់ឆ្នាំ ដល់ឆ្នាំ៧៣-៧៤ហ្នឹង ៧៣-៧៤ហ្នឹងអាហ្នឹងបានមាន ដល់ខ្ញុំហើយ អាហ្នឹងជាបក្សជនអាំ

ឃីមៈ ចា៎

សនៈ បើតាំងពីមុនមកហ្នឹងតាំងពីឆ្នាំ៧០ដាង គេសោយរាជ្យដល់ពេញដីហើយ មើលទៅ

ឃីមៈ ហើយបាត់ហើយ

សនៈ គ្រាន់តែឆ្នាំ៧០ភ្លាមហ្នឹងអា៎មីអូន មេឃុំ មេភូមិ ប៉ូលីស ទាហ៊ាន នៅចេញចូលបាន ហ្នឹងអា៎ ដើរមក ខ្សឹបខ្សៀវគ្នាហើយ មេឃុំនេះ អានេះមេឃុំនោះ ដឹងហើយអស់រលីង អូដើរធ្វើការប៉ូលីស ទាហ៊ាននៅចេញចូលបាន នៅតែចេញចូលបានអញ្ចឹង

ឃីមៈ ចា៎

សនៈ គេរៀបចំអាហ្នឹងតាំងពីឆ្នាំណាមកទេ

ឃីមៈ ចា៎ ហើយកាលហ្នឹងមិនទាន់មានសហករអា៧២-៧៣ហ្នឹង

សនៈ នៅ

ឃីមៈ ថានៅទំនប់គោកត្របែកអា៎?

សនៈ បា៎

ឃីមៈ តាំងឆ្នាំណាមក?

សនៈ តាំងឆ្នាំ ៧០ប៉ុន្មានទេ កាលហ្នឹងដូចលែងអោយមានយន្តហោះ ទំលាក់

ឃីមៈ ៧៣ហើយអញ្ចឹង លែងមានយន្តហោះ ទំលាក់

សនៈ បា៎ ៧៣

ឃីមៈ អញ្ចឹងមិនទាន់ហួសណាអុំ? ម៉េចមិនទាន់ធ្វើបានខាងម៉ារីអី

សនៈ ខ្លាំងអា៎ កាលហ្នឹងនៅធ្វើរួមក្រុម ខ្ញុំទៅជិនួសមុខក្រោយឃុំដាងទរ

ឃីមៈ ឆ្នាំ៧៣ហ្នឹង?

សនៈ បា៎ វែកមួយបន្ទីរមុនគេទ្រនប់គោត្របែកគឺខ្ញុំហ្នឹង

ឃីមៈ អ៎

សនៈ អេនៅ ធ្វើអាហ្នឹងក៍យន្តហោះវៃដែរ

ឃីមៈ ចា៎

សនៈ ធ្វើយន្តហោះវៃ

ឃីមៈ ហើយវៃធ្វើម៉េចទៅគេមិនឃើញ?

សនៈ អត់ រត់ពួន

ឃីមៈ  ចុះ ហើយឆ្នាំ៧៨ ពួកចិនមកសម្ភោធន៍ អុំថាពេលយប់អោះ

សនៈ  នៅយន្តហោះមកនៅក៏មានមួយថ្ងៃនោះកុន ខ្ញុំនៅឈរកណ្ដាលវាលហ្វូង

ឃីមៈ  ចាំ

សនៈ  កំទុយរ៉ុយពីរបាញ់ៗ